ក្រសួងអប់រំ យុវជន និងកីឡា
សម្រាប់ថ្នាក់
ភាសាខ្មែរ
១
គ្រឹះស្ថានបោះពុម្ពនិងចែកចាយ

ក្រសួងអប់រំ យុវជន និងកីឡា

ភាសាខ្មែរ

ថ្នាក់ទី ៤

បោះពុម្ពផ្សាយដោយ

គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

អគារ ១៤៨ មហាវិថី ព្រះនរោត្តម ភ្នំពេញ

គណៈកម្មការនិពន្ធ លោក យិន ធី លោក ព្រៃ សំបូរ
លោកស្រី ម៉ៅ តាន់ណារី លោកស្រី ប៊ី គីមសែន
លោក យ៉ង់ កំសាន

អ្នកវាយអត្ថបទ លោក សេង តុងបុត្តា

វិចិត្រករ លោក ឃុន សុវណ្ណរិទ្ធី

អ្នករៀបរៀង លោកជំទាវ ទន់ សាអ៊ីម

អ្នករចនាគំរប លោក គង់ ចិត្រា

គណៈកម្មការពិនិត្យ លោកបណ្ឌិត នៅ ស៊ុន លោកស្រី ភោគ សុធា

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី ក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ ៦៦២ អយក.ប្រក. ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១១ ដើម្បីប្រើប្រាស់នៅតាមសាលារៀន។

ហាមចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©

ក្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

បោះពុម្ពឆ្នាំ ២០១៦

ISBN 9-789-995-001-360

អារម្ភកថា

សៀវភៅភាសាខ្មែរថ្នាក់ទី ៩ នេះ បាននិពន្ធឡើងតាមកម្មវិធីសិក្សាថ្មី របស់ក្រសួងអប់រំ យុវជន និងកីឡា។ សៀវភៅនេះបន្តពង្រឹងនិងពង្រីកសមត្ថភាពអាន និយាយ ស្តាប់ និងសរសេរ ឱ្យកាន់តែប្រសើរឡើងថែមទៀត។

សៀវភៅនេះបង្ហាញអំពីប្រធានបទសំខាន់ៗដូចជា មោទនភាពជាតិ អត្តសញ្ញាណជាតិ ការគោរពបូជា ការទទួលស្គាល់ការពិត ភាពជាពលរដ្ឋ។ល។ ដើម្បីបណ្តុះនិងអភិវឌ្ឍគំនិតប្រាជ្ញាស្មារតី និងការទទួលខុសត្រូវរបស់កុលបុត្រ កុលធីតាខ្មែរចំពោះជាតិមាតុភូមិ។ មេរៀននៅក្នុងសៀវភៅនេះនឹងជួយអ្នកសិក្សាឱ្យទទួលបានចំណេះដឹង និងបំណិនកាន់តែស៊ីជម្រៅនិងច្បាស់លាស់តាមរយៈការសិក្សាអត្ថបទអក្សរសិល្ប៍ប្រជាប្រិយ អក្សរសិល្ប៍បុរាណ អក្សរសិល្ប៍ទំនើប អត្ថបទអត្ថាធិប្បាយ ល្ខោន ចម្រៀង របាំ វេយ្យាករណ៍ និងសំណេរជាច្រើនទម្រង់ដូចជា ការបំពេញទម្រង់បែបបទផ្សេងៗ ការតាក់តែងរឿង សំណេរតែងសេចក្តី សំណេរអត្ថបទព័ត៌មានជាដើម។

តាមរយៈខ្លឹមសារ បំណិន សំណួរ លំហាត់ ការសិក្សាពាក្យគន្លឹះ ដែលមាននៅក្នុងសៀវភៅនេះ អ្នកនឹងមានការអភិវឌ្ឍចំណេះដឹងកាន់តែស៊ីជម្រៅនិងទទួលបានបំណិនថែមទៀតលើផ្នែកភាសាខ្មែរ ដើម្បីបន្តការសិក្សានៅថ្នាក់ខ្ពស់ទៀត។

គណៈកម្មការនិពន្ធសង្ឃឹមថា សៀវភៅភាសាខ្មែរថ្នាក់ទី ៩ ថ្មីនេះនឹងក្លាយជាមិត្តដ៏ល្អរបស់អ្នកជាពុំខាន។

សូមឱ្យការសិក្សារបស់ប្អូនៗទទួលបានជោគជ័យដ៏ត្រចះត្រចង់។

គណៈកម្មការនិពន្ធ

បញ្ជីអត្ថបទ

ទំព័រ

១. តម្លៃសោភ័ណ..... ១

២. មោទនភាពជាតិ..... ២៣

៣. ការទទួលស្គាល់ការពិត..... ៤៧

៤. សាមគ្គីភាព..... ៧៥

៥. ការកំណត់គោលដៅ..... ៩៩

៦. ស្មារតីទទួលខុសត្រូវ..... ១២៥

៧. ការជឿជាក់..... ១៥៧

៨. សេចក្តីព្យាយាម..... ១៧៩

៩. ជោគជ័យនៃជីវិត..... ១៩៧

១០. ពលរដ្ឋល្អ..... ២២៣

មេរៀនទី

តម្លៃសោភ័ណ

មនុស្សទូទៅទទួលស្គាល់អ្វីៗដែលល្អប្រសើរថ្លៃថ្លា ខ្ពង់ខ្ពស់ ឧត្តុង្គឧត្តម ... និងមានប្រយោជន៍សុទ្ធតែថាមានតម្លៃសោភ័ណ។ គ្រប់កាលៈទេសៈ សង្គមជាតិនីមួយៗរមែងតែងតែយកចិត្តទុកដាក់លើសោភណភាពជានិច្ច។ តម្លៃសោភ័ណបានចាប់ផ្តើមពីការធ្វើឱ្យខ្លួនឯងជាមនុស្សមានតម្លៃសម្រាប់គ្រួសារនិងសង្គមរស់នៅក្នុងភាពថ្លៃថ្នូរនិងបានចូលរួមលើកកម្ពស់តម្លៃសីលធម៌ តម្លៃស្នាដៃសង្គមជាតិឱ្យមានវឌ្ឍនភាពនិងកិត្តិយសឧត្តុង្គឧត្តមទៀតផង។

ក្នុងមេរៀននេះ អ្នកនឹងបានសិក្សាស្វែងយល់ពីតម្លៃសោភ័ណនៃជីវិតរបស់បុគ្គលមួយចំនួនតាមរយៈជីវប្រវត្តិផ្ទាល់ខ្លួន។ លើសពីនេះអ្នកនឹងបានសិក្សាអំពីការសម្គាល់ពាក្យបាលីសំស្ក្រឹត របៀបប្រើសញ្ញារចាទ នាមជីវចល នាមអជីវចល និងការនិយាយអំពីប្រវត្តិផ្ទាល់ខ្លួន និងការសរសេរជីវប្រវត្តិផ្ទាល់ខ្លួន។

នាមជីវចលនិងនាមអជីវចល

អ្នកធ្លាប់សិក្សាអំពីនាម រួចមកហើយ។ នាមមានច្រើនប្រភេទដូចជា នាមសាធារណៈ នាមអសាធារណៈ។ល។ ឥឡូវអ្នកនឹងសិក្សាអំពីនាមជីវចល និងនាមអជីវចល។

ក. នាមជីវចល

នាមជីវចលអាចបង្ហាញភាវៈមនុស្ស ភាវៈសត្វ និងជីវចលណាមួយ។ ចូរពិនិត្យឧទាហរណ៍ខាងក្រោម ៖

- តើឯងឃើញនរណា ?
  - ខ្ញុំឃើញកសិករភូមិយើង។
  - ខ្ញុំឃើញនារីម្នាក់។

ពាក្យកសិករ នារី ជានាមជីវចលព្រោះជាពាក្យបង្ហាញពីភាវៈមានជីវិត មានវិញ្ញាណ(មនុស្ស)។

នាមជីវចល គឺជានាមទាំងឡាយណាដែលបង្ហាញពីភាវៈមានជីវិតនិងមានសកម្មភាពក្នុងជីវិតរស់នៅប្រចាំថ្ងៃ។

ខ. នាមអជីវចល

នាមអជីវចលប្រើចំពោះវត្ថុ ទីកន្លែង រុក្ខជាតិ ... ។

ចូរពិនិត្យឧទាហរណ៍ខាងក្រោម ៖

- តើឯងឃើញអ្វី ?
  - ខ្ញុំឃើញរទេះគោ (នង្គ័ល ផ្កា)។
  - ខ្ញុំឃើញផ្លែចេក។

ពាក្យរទេះគោ ផ្លែចេក ជានាមអជីវចល ព្រោះជាពាក្យបង្ហាញពីភាវៈគ្មានញាណដូចមនុស្សទេ។

នាមអជីវចល គឺជានាមទាំងឡាយណាដែលបង្ហាញពីភាវៈគ្មានជីវិត ឬមានជីវិតដែរតែពុំមានសកម្មភាពក្នុងជីវិតរស់នៅប្រចាំថ្ងៃទេ។

លំហាត់

១. ពាក្យមីងសំ តាសុខ ពាណិជ្ជករ មេឃ ដី ស្ទឹង បងប្រុស តើពាក្យណាខ្លះជានាមជីវចល ? ណាខ្លះជានាមអជីវចល ?

២. ចូរស្រង់នាមជីវចលដែលមាននៅក្នុងអត្ថបទខាងក្រោម ៖

ឧកញ៉ាសុត្តន្តប្រីជាឥន្ទ កើតនៅថ្ងៃចន្ទទី ២២ ខែកក្កដា ឆ្នាំ ១៨៥៩ នៅភូមិរកាកោង ស្រុកមុខកំពូល ខេត្តកណ្តាល។ មាតាឈ្មោះ មុំ បិតាឈ្មោះ បញ្ចង់កែ។ កាលអាយុ ១០ឆ្នាំលោកបានសិក្សាអត្ថបទខ្មែរនៅវត្ត ដល់អាយុ ១៥ឆ្នាំ លោកចេញរៀនប្រែធម៌ បួសជាសាមណេរនៅវត្តព្រែកពោធិ៍។ បួសបាន ១វស្សា លោកសឹកចាកសិក្ខាបទជាសាមណេររួចទៅរៀននឹងលោកព្រះអាចារ្យពេជ្រ ស្រុកព្រះត្រពាំង។ អាយុ ១៨ឆ្នាំ លោកទៅរៀននឹងលោកគ្រូព្រះពុទ្ធឃោសាចារ្យប្រាក់ វត្តឧណ្ណាលោម ក្រុងភ្នំពេញ។ អាយុ ១៩ឆ្នាំ លោករៀនក្នុងសំណាក់លោកគ្រូព្រះអាចារ្យសុក នាវត្តកែវខេត្តបាត់ដំបង។ លុះអាយុ ២០ឆ្នាំ លោកបានបួសជាភិក្ខុនៅវត្តកែវបាន១វស្សាទើបលាព្រះឧបជ្ឈាយាចារ្យទៅរៀននៅក្រុងបាងកកប្រទេសថៃ។ សិក្សាបានប្រាំពីរវស្សា លោកក៏វិលមកស្រុកខ្មែរវិញក្នុងអំណាចលោកព្រះយ៉ាកថាថនញ្ជុញ្ញនៅវត្តកណ្តាល ខេត្តបាត់ដំបង។ ការបួសនេះបាន ១០វស្សា លោកក៏លាចាកសិក្ខាបទ រួចមានភរិយា មានបុត្រនៅភូមិជ្វាធំ។ លោកបានទទួលមរណភាពថ្ងៃអាទិត្យ១២កើត ខែកត្តិក ឆ្នាំជូតឆស័ក ត្រូវនឹងថ្ងៃទី ៨ ខែវិច្ឆិកា ឆ្នាំ ១៩២៤ វេលាម៉ោង ៨ព្រឹកក្នុងជន្មាយុ៦៥ឆ្នាំ ដោយរោគាពាធ (រោគក្អក)។

(ដកស្រង់ និងកែសម្រួលពីសៀវភៅអក្សរសិល្ប៍ខ្មែរសតវត្សរ៍ទី ២០ របស់បណ្ឌិត ឃឹង ហុកឌី ទំព័រ ៦៧-៦៨)

៣. ចូរស្រង់នាមអជីវចលដែលមាននៅក្នុងអត្ថបទខាងក្រោម ៖

ឧកញ៉ាសុត្តន្តប្រីជាឥន្ទ បានបន្សល់ទុកស្នាដៃអក្សរសិល្ប៍ជាច្រើនដែលមានដូចតទៅ :

- គតិលោក (ពាក្យរាយ) និរាសនគរវត្ត (កំណាព្យបទពាក្យ ៨) សុភាសិតច្បាប់ស្រី (កំណាព្យ) រឿងអំបែងបែក លោកនីតិប្បករណ៍ (កំណាព្យជាភាសាបាលីអធិប្បាយជាភាសាខ្មែរ) ព្រះរាជពង្សាវតារខ្មែរ ច្បាប់ចម្លងដៃរក្សាទុកនៅបណ្ណាល័យ សង្គមបេសកកម្មបរទេសនៅក្រុងប៉ារីស បកប្រែជាភាសាបារាំងដោយម៉ាទីនព្យ៉ាត។
- នៅភាគទី ១នៃគតិលោកមានប្រស្នាចោទនិងដោះស្រាយដែលអ្នកនិពន្ធហៅថា បុច្ឆាវីស្សជ្ជនា (សំណួរនិងចម្លើយ)នៅក្នុងរចនាបថដែលព្រះសង្ឃយើងសម្តែងធម៌ទេសនាត្រែ ២ គឺមានមហាថេរនិងអនុថេរចោទឆ្លើយឆ្លងគ្នា។ លោកបានពន្យល់ដោយយោងទៅលើរឿងនិទានចំនួនមួយរយដប់ប្រាំពីររឿង។ រឿងនិទានសីលធម៌ទាំងនេះ លោកទាញចេញពីរឿងព្រេងខ្មែរ រឿងពិតក្នុងសង្គមខ្មែរ រឿងដែលមានប្រភពមកពីឥណ្ឌា (តាមរយៈប្រទេសថៃ) គឺមាន ជាតក បញ្ចតន្ត្រៈ ស្រីហិតោបទេសជាដើម។

គតិលោក គឺជាតំណាងចំណេះដឹងចម្រុះរបស់ឧកញ៉ាសុត្តន្តប្រីជាឥន្ទដែលបានផ្សំរវប្បធម៌ខ្មែរនិងវប្បធម៌បរទេស។

(ដកស្រង់ និងកែសម្រួលពីសៀវភៅអក្សរសិល្ប៍ខ្មែរសតវត្សរ៍ទី ២០របស់បណ្ឌិត ឃឹង ហុកឌី ទំព័រ ៦៨-៦៩)

ជីវប្រវត្តិអ្នកព្រះតិរម្យភាសាអ្វ

ក. សិក្សាពាក្យគន្លឹះ

- គោរម្យ៌ងារ (ន) : របៀបពាក្យដ៏ឧត្តម បន្ថែមតពីងារទៅទៀត ជាពាក្យសរសើរងារ សម្រាប់ប្រើសរសេរចំពោះតែការចេញសំបុត្រជីកាធំៗ ។
- សាមណេរ (ន) : បព្វជិតពុទ្ធសាសនិកអ្នកកាន់សីល ១០ (លោកនេន) ។
- ឧបសម្បទា (ន) : ការដល់នូវភាពជាភិក្ខុ ឬការបានជាភិក្ខុភាព គឺការបួសជាភិក្ខុ ឬការបំបួសសាមណេរឱ្យបានជាភិក្ខុ ។
- ភិក្ខុ (ន) : សមណៈអ្នកខ្លាចភ័យក្នុងវដ្តសង្សារ អ្នកខ្លាចបាបជានិច្ច អ្នកបានព្យាយាមជុតបំផ្លាញអំពើអាក្រក់ ...(ព្រះសង្ឃ) ។
- ត្រៃបិដក (ន) : ប្រជុំនៃព្រះធម្មវិន័យពុទ្ធសាសនា ៣គឺ សុត្តន្តបិដក វិន័យបិដក និងអភិធម្មបិដក ។
- វិបស្សនា (ន) : ការពិចារណាឃើញច្បាស់ដោយប្រាជ្ញា ពិចារណាឱ្យឃើញច្បាស់នូវដំណើរសង្ខារធម៌តាមការណ៍ពិត ។
- គ្រហស្ថ (ន) : អ្នកមានផ្ទះ អ្នកគ្រប់គ្រងផ្ទះ គឺអ្នកមានគ្រួសារ ។

- សំនួន (ន) : ជំណើរឬទំនងពាក្យ លំនាំសេចក្តី វោហារ ពាក្យពោលសង្កត់
- វោហារ (ន) : ពាក្យ ពាក្យពេចន៍ សំនួនសំដី ។
- ពន្ធដារ (ន) : សួយអាករគ្រប់មុខដែលប្រជានិករត្រូវបង់តាមកំណត់ជូនរាជការតាមចំនួនដែលមានកម្រិតទុកជាស្រេចក្នុងបញ្ជី ។

ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទ អ្នកគប្បីអានដោយយកចិត្តទុកដាក់ ដើម្បីឆ្លើយនឹងសំណួរទាក់ទង ទៅនឹងការសង្ខេបចំណុចសំខាន់ៗនៃព័ត៌មានពន្យល់ន័យពាក្យពហុព្យាង្គ ។

គ. អត្ថបទ

"អ្នកព្រះភិរម្យភាសាអ៊ូ" នាមដើម "អ៊ុក-អ៊ូ" ហៅក្រៅថា "ង៉ុយ" កើតនៅឆ្នាំ ១៨៦៥ នៅឃុំកំបូល ស្រុកភ្នំពេញ(សព្វថ្ងៃគឺស្រុកអង្គស្នួល) ក្នុងខេត្តកណ្តាល ។ ឪពុកឈ្មោះ អ៊ុក ធ្វើជាមេឃុំកំបូល ស្រុកភ្នំពេញ ខេត្តកណ្តាល មានគោរម្យងារថា "ចៅពញាធម្មធារា" ។ ម្តាយលោកជាកូនរបស់ "ចៅពញាម៉ុក" មេឃុំស្តានថ្ម នៅស្រុកខេត្តជាមួយគ្នា ។ ឪពុកម្តាយរបស់លោកជាបងប្អូនជីដូនមួយនឹងគ្នា ។

កាលពីកុមារបានសំណាក់រៀននឹងលោកចៅអធិការវត្តអង្គបឹងចក នៅស្រុកកំណើតរបស់លោក ។ កុមារង៉ុយ ជាក្មេងឧស្សាហ៍រៀនសូត្រ ហើយបានបួសជាសាមណេរចេះធម៌អាចិជ្រៅជ្រះ ។ លុះដល់ព្រះជន្ម ២១ឆ្នាំ លោកបានបំពេញឧបសម្បទាជាភិក្ខុ ។ ភិក្ខុអង្គនេះបានសិក្សាសូរស្វែងរៀនប្រែព្រះត្រៃបិដកដំបូងក្នុងសំណាក់លោកគ្រូអាចារ្យទិត្យ គង់នៅវត្តអង្គបឹងចក ភូមិបែកស្តរ ឃុំបែកចាន ស្រុកភ្នំពេញ(អង្គស្នួល) ខេត្តកណ្តាល ។ បន្ទាប់ពីប្រែព្រះត្រៃបិដក ភិក្ខុង៉ុយសិក្សាស្វែងរៀនវិបស្សនាកម្មដ្ឋានក្នុងសំណាក់ព្រះអាចារ្យជាច្រើនកន្លែងទៀត ។

ក្រោយពីបានចាកសិក្ខាបទមកជាគ្រហស្ថ លោកបានរៀបអាពាហ៍ពិពាហ៍នៅឃុំបែកចាន ស្រុកភ្នំពេញ(អង្គស្នួល) ហើយប្រកបរបរជាអ្នកស្រែធម្មតាក្នុងឃុំនោះនិងមានកូន ៦ នាក់ ដែលក្នុងនោះមានកូនប្រុសម្នាក់ឈ្មោះអ៊ូ-ចុង ក៏ជាកវីមានឈ្មោះល្បីខាងសំនួនវោហារដែរ ។ ក្នុងមុខរបរជាកសិករ លោកអ៊ុក-អ៊ូ មានប្រជាប្រិយភាពខ្លាំងខាងវោហារនិងល្បិចលើកកំណាព្យភ្លាមៗច្រៀងឡើងព្រមជាមួយនឹងសំនៀងសាដៀវយ៉ាងពីរោះ ព្រមទាំងចំណេះខាងធម៌អាចិយ៉ាងខ្ពង់ខ្ពស់ដែលធ្វើឱ្យកសិករឯទៀតរាប់អានស្រលាញ់ទុកជាអ្នកប្រាជ្ញក្នុងភូមិស្រុក ហើយពួកគេហៅគាត់ថា "ភិរម្យង៉ុយ" ។ បន្ទាប់មករដ្ឋអំណាចបានតាំងលោកថា "ក្រម" (ក្រមង៉ុយ) គឺជាភារជនដែលធ្វើទំនាក់ទំនងរវាងរាជរដ្ឋាភិបាលនិងប្រជាជនក្នុងឃុំ ។

ពេលរដូវរំហើយ ក្រោយពីកិច្ចការច្រូតកាត់ ក្រមង៉ុយតែងទេសនាប្រៀនប្រដៅ ច្រៀង សូត្រ កំណាព្យ បន្ទរដោយសំនៀងសាដៀវដ៏គ្រលួចពីភូមិមួយទៅភូមិមួយ សម្តែងទឹកចិត្តស្រណោះអាណិត ខ្មែរគ្នាឯង ដែលរស់នៅភាពខ្សត់ខ្សោយ ក្រីក្រ លង់ខ្លៅ ឈ្លោះគ្នាឯង បែកបាក់សាមគ្គី ។ល។ ព្រោះតែទម្ងន់ពន្ធដារនៃរដ្ឋអំណាចបារាំង ភាពរហ័សរហួនឆ្លាតក្នុងការកេងបន្លំរបស់ជនបរទេស។ កេរ្តិ៍ឈ្មោះល្បីល្បាញនៃកវី សិល្បករក្រមង៉ុយបានលេចឮទៅដល់ទីក្រុង ហើយសម្តេចចក្រីបានហៅលោកទៅច្រៀងថ្វាយព្រះករុណាព្រះស៊ីសុវត្ថិ។ ព្រះករុណាពេញព្រះរាជហឫទ័យបានប្រទានរង្វាន់ជាប្រាក់កាសនិងគោរម្យងារថា "ព្រះភិរម្យភាសាអ៊ូ"។ បន្ទាប់មកលោកសីដេសសមាជិកសាលាបារាំងចុងបូព៌ាប្រទេសបាននាំព្រះភិរម្យភាសាអ៊ូ ទៅជួបអ្នកស្រី ស៊ូសានកាពេលេស នាយកវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ។ នៅឆ្នាំ ១៩៣០ អ្នកស្រីស៊ូសានបានឱ្យអ្នកប្រាជ្ញនៅវិទ្យាស្ថានកត់ត្រាសំដីចម្រៀងកំណាព្យព្រះភិរម្យភាសាអ៊ូទាំងអស់នៅពេលដែលលោកច្រៀងរងើលៗ។ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យបានបោះពុម្ពកំណាព្យនោះជាសៀវភៅតូចៗចំនួនបួនចប់។ អ្នកស្រីកាពេលេស បានឱ្យកម្រៃជាប្រាក់ ១រៀលជំនាន់នោះជូនចំពោះគាត់។

លោកតាក្រមង៉ុយទទួលអនិច្ចកម្មក្នុងឆ្នាំ ១៩៣៦ ក្នុងជន្មាយុ ៧១ឆ្នាំដោយបន្សល់ទុកនូវស្នាដៃចម្រៀង ពាក្យកាព្យជាច្រើន ប៉ុន្តែគេបានរកឃើញស្នាដៃមួយចំនួនប៉ុណ្ណោះដូចជា សេចក្តីរំឭកជាស្តៀន ច្បាប់កេរកាលថ្មី ច្បាប់ល្បើកថ្មី ច្បាប់ប្រដៅទូន្មានជនប្រុសស្រី និងបណ្តាំក្រមង៉ុយជាដើម។

(ដកស្រង់ និងកែសម្រួលពីសៀវភៅអក្សរសិល្ប៍ខ្មែរសតវត្សរ៍ទី ២០ របស់លោកបណ្ឌិត ឃឹង ហុកឌី ទំព័រ ៧៦-៧៩)

សំណួរ

១. តើលោក អ៊ុក-អ៊ូកើត នៅឆ្នាំណា ? ទីកន្លែងកំណើតនៅឯណា ? ឪពុកម្តាយលោកឈ្មោះអ្វី ?

២. ក្រោយសឹកពីផ្ទួសតើលោក អ៊ុក-អ៊ូ បានធ្វើអ្វីខ្លះ ? បានទទួលងារជាអ្វី ? នរណាជាអ្នកផ្តល់ជូនគាត់ ?

៣. ចូរស្រង់ពាក្យពហុព្យាង្គពីអត្ថបទឱ្យបាន ៥ ពាក្យ រួចធ្វើការញែកព្យាង្គ ដើម្បីពន្យល់ន័យពាក្យទាំងនោះ។

៤. ចូរបង្ហាញទឹកចិត្តអ្នកស្រី ស៊ូសានកាពេលេស ចំពោះលោក អ៊ុក-អ៊ូ។

៥. ចូរសង្ខេបជីវប្រវត្តិលោក អ៊ុក-អ៊ូ។

"... លោកអ៊ុក-អ៊ូ មានវោហារខ្លាំងនិងល្បិចលើកកំណាព្យភ្លាមៗច្រៀងឡើង ព្រមជាមួយនិងសំនៀងសាដៀវយ៉ាងពីរោះ។ គាត់ចេះដឹងខាងធម៌អាថ៌យ៉ាងខ្ពង់ខ្ពស់ដែលធ្វើឱ្យអ្នកស្រុកថាត់ទុកជាអ្នកប្រាជ្ញក្នុងភូមិស្រុក ហើយពួកគេហៅគាត់ថា"ភិរម្យង៉ុយ"។ បន្ទាប់មករដ្ឋអំណាចបានតាំងលោកថា "ក្រម" (ក្រមង៉ុយ) គឺជាភារជនដែលធ្វើទំនាក់ទំនងរវាងរាជរដ្ឋាភិបាលនិងប្រជាជនក្នុងឃុំ ..."។

ការសម្គាល់សំណេរពាក្យបាលីសំស្ក្រឹត

ប្រទេសយើងទទួលឥទ្ធិពលសាសនាធំៗ គឺព្រហ្មញ្ញសាសនានិងព្រះពុទ្ធសាសនាតាំងពីយូរលង់ណាស់មកហើយ។ តាមរយៈឥទ្ធិពលនេះ ពាក្យខ្មែរយើងមួយចំនួនក៏មានប្រភពពីបាលីសំស្ក្រឹតដែរ ហើយបានធ្វើខ្មែរនីយកម្មដើម្បីបំពេញតម្រូវការចាំបាច់ក្នុងការប្រើប្រាស់ភាសាប្រចាំថ្ងៃ។

តើគេអាចសម្គាល់ពាក្យខ្មែរដែលមានប្រភពមកពីបាលី សំស្ក្រឹតដូចម្តេចខ្លះ ?

គេអាចសម្គាល់ពាក្យខ្ចីពីបាលីសំស្ក្រឹតដោយសង្កេតលក្ខណៈសំណេរដូចតទៅ ៖

- មិនប្រើបន្តក់ " ◌់ " *ឧទាហរណ៍ :* កល ជន កុហក ផល មង្គល។
- មិនប្រើលេខទោ " ◌ៗ " *ឧទាហរណ៍ :* នានា។
- ប្រើទណ្ឌឃាត " ◌៍ " *ឧទាហរណ៍ :* ប្រយោជន៍ ទូរទស្សន៍ ទេសចរណ៍ ប្រសាសន៍ ... ។
- ប្រើសំយោគសញ្ញា (ជាត់លើ) " ◌្ " *ឧទាហរណ៍ :* អត្ថន័យ វិស័យ ការិយាល័យ សម្ព័ន្ធ ជ័យ ... ។
- ប្រើវបាទ " ◌ិ " *ឧទាហរណ៍ :* ពណ៌ កាណ៌ ធម៌ ទុជ៌ន សួគ៌ បូរ៌... ។
- ប្រើព្យញ្ជនៈប្រកប " គ ជ ទ ព ភ" *ឧទាហរណ៍ :* មុជ ភោគផល ប្រមាទ លាភ ប្រភព ... ។
- ប្រើព្យញ្ជនៈប្រកប "ក ខ ថ ធ" *ឧទាហរណ៍ :* នាយក សមាជិក ពិសាខ សុនខ ប្រមាថ សម្បថ សម្ពាធ ពិសោធ ... ។
- ប្រើព្យញ្ជនៈប្រកប "ដ ឌ" *ឧទាហរណ៍ :* ប្រាកដ ទណ្ឌឃាដ គ្រុឌ ទ្រុឌ ... ។
- ប្រើព្យញ្ជនៈប្រកប " ណ" *ឧទាហរណ៍ :* ប្រាណ កល្យាណ គុណ ទក្សិណ បវេណី ... ។
- ប្រើស្រៈ " ◌ិ " នៅខាងលើព្យញ្ជនៈប្រកប *ឧទាហរណ៍ :* ភូមិ ជាតិ វិបត្តិ វណ្ណយុត្តិ កោដិ សក្តិ កុដិ ... ។
- ប្រើជើងព្យញ្ជនៈពីក្រោមតួប្រកប *ឧទាហរណ៍ :* បិណ្ឌ បុណ្យ ខេត្ត ចិត្ត មនុស្ស កោសល្យ ក្រឹត្យ ឃុទ្ធ សង្ឃ មុជ្ជ ... ។
- ប្រើឃុគលពិន្ទុ " ◌ៈ " នៅខាងចុងព្យញ្ជនៈប្រកប *ឧទាហរណ៍ :* អវយវៈ សិល្បៈ ស្រៈ វីរៈ សច្ចៈ តថៈ ... ។
- សំណូរខុសពីសំណេរ

  ឧទាហរណ៍ :

  - ស្រៈ "◌ិ" អានថាស្រៈ " ◌ី " *ឧទាហរណ៍ :* បិតា [បីដា]
  - ស្រៈ "◌ិ" អានថាស្រៈ "◌េ" *ឧទាហរណ៍ :* មិគសិរ [មិ-គ-សៃ] ... ។
  - ស្រៈ "◌េ" អានថាស្រៈ "◌ែ" *ឧទាហរណ៍ :* ខេត្ត [ខែត] កេណ្ឌ [កែន] ... ។

លំហាត់

១. ចូរអ្នកពិនិត្យមើលជីវប្រវត្តិអ្នកស្រី សិទ្ធិ រួចជ្រើសរើសពាក្យបាលីសំស្ក្រឹត ដែលមានសំណួរខុសពីសំណេរនិងពាក្យដែលមានប្រើសញ្ញា " ិ " ។

ជីវប្រវត្តិអ្នកស្រី សិទ្ធិ

អ្នកស្រី **សិទ្ធិ** កើតនៅថ្ងៃពុធ ខែ មិគសិរ ឆ្នាំ មមី ព.ស. ២៤២៤ ត្រូវនឹង គ.ស. ១៨៨១ នៅសង្កាត់លេខ ៤ ក្រុងភ្នំពេញ ជាធីតាពៅនៃអ្នកស្រី ភ្លង និងលោក **ពិពិធសិរី** ចាងហ្វាងតួរ្យតន្ត្រីក្នុងរាជវាំង ។

កុមារីសួ **សិទ្ធិ** បានរៀនអក្សរខ្មែរក្នុងសំណាក់បិតា លុះត្រាបានចេះដឹងច្បាស់លាស់ ។ តមកទៀតកុមារី **សួ សិទ្ធិ** បានរៀនអក្សរនិងភាសាសៀមពីសំណាក់មាតានិងអ្នកជិតខាងខ្លះទៀត រហូតចេះអាននិងនិយាយបានដូចអ្នកដែលបានទៅរៀននៅឯស្រុកសៀមដែរ ។ លុះពេញវ័យ កញ្ញាសួ **សិទ្ធិ** បានរៀបអាពាហ៍ពិពាហ៍ជាមួយលោក **ផាក់ អាំ** ជាមន្ត្រីក្រសួងយុត្តិធម៌ ហើយបានរស់នៅជាមួយគ្នារហូតបានកូនស្រីមួយ ឈ្មោះនាង **ឃុន សារ៉ខុន** ។ ដោយមិនអាចរស់នៅជាមួយគ្នាតទៅទៀតបាន អ្នកស្រី **សិទ្ធិ** ក៏បានធ្វើពាក្យសុំលែងគ្នាតាមច្បាប់ ខណៈដែលបុត្រីអ្នកស្រីមានអាយុ ៣ឆ្នាំ ។ ក្រោយមក អ្នកស្រី **សិទ្ធិ** បានចូលមកបម្រើក្នុងរាជវាំងក្នុងជំនាន់ហ្លួងព្រះស៊ីសុវត្ថិ ។

អាស្រ័យដោយបានទទួលការអប់រំពីមាតាបិតានូវចំណេះដឹងនានា អ្នកស្រី **សិទ្ធិ** បានរៀនច្រៀងជាមួយគ្រូចម្រៀងនិងរបាំបានចេះចាំយ៉ាងឆាប់រហ័ស ។ អ្នកស្រី **សិទ្ធិ** មានសំឡេងពីរោះ ហ្លួងស៊ីសុវត្ថិ បានតែងតាំងអ្នកស្រីជាចាងហ្វាងល្ខោនហ្លួងនិងជារាជលេខាធិការទទួលការខុសត្រូវលើក្រុមរបាំ ហើយតែងកំណាព្យបែបបទសកវាទី៍ ច្រៀងនៅពេលបុណ្យនានា ។ ក្រៅពីតួនាទីនេះ អ្នកស្រី **សិទ្ធិ** ឆ្លៀតសរសេរកំណាព្យ កាព្យឃ្លោង និងពាក្យរាយ ជាសៀវភៅរឿង ដែលបោះពុម្ពហើយខ្លះនិងសល់ខ្លះពុំទាន់បោះពុម្ពនៅឡើយ ដោយសារសំណៅរាត់រាយពេក ។

អ្នកស្រី **សិទ្ធិ** និយមតាក់តែងកាយតាមទំនៀមទម្លាប់ខ្មែរសុទ្ធសាធ គឺសក់ផ្កាថ្នូរ ពាក់ខ្សែកមាសមួយខ្សែ ពាក់ទុំហូទងត្រង់ ស្លៀកជាមួងឬខៀនចងក្បិន ជួនស្លៀកសំឡុយដែរ គឺសំពត់ហូល ពាក់អាវកមូលដៃខ្លី បង់ក្រមាពណ៌ ឬពានាជាហ៊ីមស ។ ដំណើរមួយៗក្បាលរាងឈ្លោកដីបន្តិច បើនិយាយស្តីច្រើនប្រើពាក្យសុភាពមួយៗ តែហួរហែមិនអាក់ សម្តីផ្អែមល្ហែមគួរជាទីគោរពរាប់អានពេកណាស់ ។

ទម្រង់មុខវែងបន្តិច តែផ្ចាមធំ ថ្ងាសទូលាយ ច្រមុះធំចុង ឯត្រង់ប្រជុំចិញ្ចើមទូលាយ ត្រចៀកធំលើ ឯទងក្រោមជិតរួមគ្នាធ្លាក់ចុង រោមចិញ្ចើមក្រាស់គ្របលើត្របកភ្នែករាងលីបបន្តិច ដែលជាជម្រកកែវភ្នែកថ្លាយង់។ ដោយសារឫកពាសុភាពរាបសាដូច្នេះហើយ បានជាមានញាតិមិត្តរាប់អានច្រើនគ្នាសូម្បីទៅធ្វើសីល ១០ នៅឯវត្តទៅហើយក៏គង់មានអ្នករាប់អានចេញចូលសួរសុខទុក្ខញឹកញាប់ដែរ។

នៅបច្ឆិមវ័យអ្នកស្រី **សិទ្ធិ** ទៅរស់នៅវត្តកាន់សីលទានជានិច្ចកាល។ ដល់ជរាភាពមែនទែន បុត្រីគាត់ **ឃុន សារឌុន** ជាស្នំហ្លួង **មុនីវង្ស** បានយកម្តាយមកឧបត្ថម្ភ ហើយអ្នកស្រី **សិទ្ធិ** បានទទួលអនិច្ចកម្មនៅថ្ងៃ ៥ ខែ កញ្ញា ឆ្នាំ ១៩៦៣ ក្នុងជន្មាយុ ៨២ឆ្នាំ។

(ដកស្រង់ និងកែសម្រួលពីសៀវភៅអក្សរសិល្ប៍ខ្មែរសតវត្សរ៍ទី ២០ របស់លោក ឃឹង ហុកឌី ទំព័រ ១០៧-១០៩)

២. ចូររកពាក្យបាលីសំស្ក្រឹតដែលមានប្រើ ៖

- សញ្ញាទណ្ឌឃាត " ្ "
- សញ្ញារបាទ " ិ "
- ព្យញ្ជនៈប្រកប " ក ខ ថ ធ ណ"
- ព្យញ្ជនៈប្រកបមានស្រៈ " ិ " នៅខាងចុងដែលក្នុងសញ្ញានីមួយៗឱ្យបាន ៣ពាក្យ។

៣. ចូរអានព្រះរាជជីវប្រវត្តិសម្តេចព្រះមហាសុមេធាធិបតី ជួន ណាត ហើយស្រង់ពាក្យកម្ចីបាលីសំស្ក្រឹតទាំងអស់ដែលមានក្នុងអត្ថបទខាងក្រោម :

ព្រះរាជជីវប្រវត្តិនៃសម្តេចព្រះមហាសុមេធាធិបតីព្រះសង្ឃរាជថ្នាក់ទី ១ ជួនណាត

សម្តេចបានទ្រង់ប្រសូតនៅថ្ងៃ អង្គារ ១១រោច ខែផល្គុណ ព.ស. ២៤២៧ គឺថ្ងៃទី ១១ មីនា ១៨៨៣ នៅភូមិកំរៀង សង្កាត់រកាកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។ ព្រះបិតានាម ជួន ព្រះមាតានាម **ឃក់**។ គ្រួសារនេះ មានបុត្រតែពីរនាក់ទេ គឺសម្តេចនិងឧកញ៉ាសោភណមន្ត្រី ជួន នុត។

កាលនៅជាកុមារ បានសិក្សាអក្សរនិងលេខ ដរាបដល់ជន្មាយុ ១៤ឆ្នាំ បានបួសជាសាមណេរ ក្នុងថ្ងៃ ១៥កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៤៤១(ឧសភា ១៨៩៧) នៅវត្តពោធិព្រឹក្ស (ហៅវត្តពោលុំ) សង្កាត់រលាំងកែន ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។ បួសជាសាមណេរបានពីរឆ្នាំ ក្នុងព.ស. ២៤៤៣ គ.ស. ១៨៩៩ សម្តេចបានចូលសិក្សាព្រះបរិយត្តិធម៌នៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ។

លុះបានជន្មាយុគម្រប់ ២១ឆ្នាំ សម្តេចបានទៅសូមបំពេញឧបសម្បទាជាភិក្ខុនៅថ្ងៃ ១៤កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៤៤៨(មិថុនា ១៩០៤) នៅវត្តពោធិព្រឹក្ស ដែលជាវត្តដើម ដោយបាននិមន្តព្រះតេជព្រះគុណ ព្រះពុទ្ធឃោសាចារ្យ ម៉ា តេត សុវណ្ណប្បញ្ញោ កាលនៅជាចៅអធិការវត្តពោធិព្រឹក្សជាឧបជ្ឈាយ៍ ព្រះតេជព្រះគុណ កែ ម៉ម មិស្សនិគោ ជាគ្រូសូត្រធម្មវាចាចារ្យ និងព្រះតេជព្រះគុណ អ៊ិន ខឹម តិក្ខប្បញ្ញោ ជាគ្រូសូត្រអនុស្សាវនាចារ្យ។ សម្តេចបានទ្រង់ទទួលនាមប្បញ្ញត្តិថា ជោតញ្ញាណោ បានទ្រង់បំពេញជាភិក្ខុហើយ សម្តេច និមន្តត្រឡប់មកគង់នៅវត្តឧណ្ណាលោមវិញ។

ស្នាព្រះហស្តសំខាន់ៗរបស់សម្តេចសង្ឃរាជ ជួន ណាត មាន :

- នាគោបមាទិកថា ព.ស. ២៤៧៥ គ.ស. ១៩៣៣
- សុភមង្គលកថា បប្បាវត្ត ៧គាថា ជាភាសាបាលីក្នុងព.ស. ២៤៨៤ គ.ស. ១៩៤១ និងប្រែសម្រាប់សូត្រថ្វាយសុភមង្គលសួស្តី ចំពោះព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន
- អត្ថបទផ្សេងៗក្នុងទស្សនាវដ្តី កម្ពុជសុរិយា របស់ពុទ្ធសាសនបណ្ឌិត្យ តាំងពីក្នុងឆ្នាំ ១៩៦២
- អត្ថបទផ្សេងៗក្នុងទស្សនាវដ្តី ពន្លឺពុទ្ធចក្រ របស់ពុទ្ធិកសមាគម មជ្ឈមណ្ឌលកម្ពុជរដ្ឋ។

ជាពិសេស ស្នាព្រះហស្តដែលរំឭកឃើញរាល់ថ្ងៃ គឺព្រះរាជនិពន្ធបទនគររាជ សម្រាប់ភ្លេងជាតិខ្មែរ ព្រះរាជនិពន្ធពីថ្ងៃទី ២០ កក្កដា ១៩៤១ និងបទសរភញ្ញ ដែលទ្រង់បាននិពន្ធក្នុងឱកាសបុណ្យពាក់កណ្តាលព្រះពុទ្ធសាសនាក្នុងពុទ្ធសករាជ ២៥០០។

(ដកស្រង់ចេញពីសៀវភៅ "ស្នាព្រះហស្តក្រោយបង្អស់"

នៃសម្តេចព្រះមហាសុមេធាធិបតី ជួនណាត ឆ្នាំ ១៩៧០ ទំព័រទី ៨៨និងទី ៩៩)

សញ្ញារបាទ (ិ)

អ្នកធ្លាប់បានសិក្សាវណ្ណយុត្តិមួយចំនួនរួចមកហើយ ។ វណ្ណយុត្តិនីមួយៗសុទ្ធតែមានតួនាទីខុសៗគ្នាដែលអាចបំពេញសេចក្តីត្រូវការក្នុងសំណេរភាសាខ្មែរបានគ្រប់គ្រាន់ ។

ឥឡូវអ្នកនឹងសិក្សាស្វែងយល់អំពីវណ្ណយុត្តិមួយបែបទៀត គឺសញ្ញារបាទ " ិ " ។

១ . ចូរអ្នកពិនិត្យឧទាហរណ៍ខាងក្រោម :

ឧទាហរណ៍	សំណូរ	ព្យញ្ជនៈ " ិ "
ទុគ៌ត	[ទុរៈគត់]	រ> ិ
បពិត	[បរិៈពត់]	រ> ិ
មតិក	[មរៈដក់]	រ> ិ

តាមរយៈឧទាហរណ៍ខាងលើយើងឃើញថា ព្យញ្ជនៈ "រ" ត្រូវបានជំនួសដោយសញ្ញារបាទ "ិ" ។

សញ្ញារបាទ "ិ" ប្រើជំនួសព្យញ្ជនៈ "រ" ។

២ . វិធីប្រើ

ក. ទីកន្លែង

- សញ្ញារបាទ " ិ " ដែលប្រើលើតួព្យញ្ជនៈខាងចុង ពុំបញ្ចេញសូរព្យញ្ជនៈ " រ "ទេ
  ឧទាហរណ៍ : ធម៌ ពណ៌ បូព៌ មាគ៌ា បរិបូណ៌ ...
- សញ្ញារបាទ " ិ " ដែលប្រើលើតួព្យញ្ជនៈកណ្តាលនៃពាក្យ មានសូរព្យញ្ជនៈ " រ "
  ឧទាហរណ៍ : ទុគ៌ត មតិក បពិត ទុគ៌ម ...

ខ. ព្យញ្ជនៈ " រ "

- របាទជាព្យញ្ជនៈ [រ] សុទ្ធ គ្មានស្រៈនៅជាមួយទេ ។
  ឧទាហរណ៍ : ធម៌ [ធ័រ] គតិ [គ័រ] ពណ៌ [ព័រ] ...
- [រ] បន្លឺឡើងមុនព្យញ្ជនៈដែលខ្លួននៅលើ ។
  ឧទាហរណ៍ : ទុជ៌ន [ទុរៈជន់] ពណ៌នា [ព័រណៈនា]

៣ . សង្ខេប

- សញ្ញារបាទ " ិ " ប្រើចំពោះតែពាក្យខ្ចីអំពីសំស្ក្រឹត
- ពាក្យខ្លះអាចសរសេរជាតួ " រ " ក៏បាន ឬជាសញ្ញារបាទក៏បាន ។

ឧទាហរណ៍ :

- មត៌ិក = មរតក
- ទុយ៌ិស = ទុរយស
- អជ៌ិន = អរជុន
- បពិត = បរពត

កំណត់សម្គាល់ : ពាក្យសំស្ក្រឹតក្លាយ ដែលព្យញ្ជនៈចុងព្យាង្គមានសញ្ញារបាទនៅខាងលើច្រើនគួនឹងពាក្យបាលីក្លាយដែលព្យញ្ជនៈចុងព្យាង្គសរសេរតម្រួតជើង ។

ឧទាហរណ៍ :

ពាក្យសំស្ក្រឹតក្លាយ	ពាក្យបាលីក្លាយ
វណ៌ (ព័ណ៌)	វណ្ណ
ធម៌	ធម្ម
គភ៌	គព្ភ
បរិបូណ៌	បរិបុណ្ណ
សួគ៌	សគ្គ
អឃ៌	អគ្ឃ

សំណួរ

១. តើសញ្ញារបាទមានទ្រង់ទ្រាយដូចម្តេច ?

២. គេប្រើសញ្ញារបាទយ៉ាងដូចម្តេច ?

លំហាត់

១. ចូររកពាក្យដែលប្រើសញ្ញារបាទ" ិ "ឱ្យបានប្រាំពាក្យដោយប្រាប់សូររបស់ពាក្យនីមួយៗ ។

២. ចូរតែងល្បះដែលប្រើសញ្ញារបាទ " ិ " ឱ្យបាន ៥ ល្បះ ។

ពុទ្ធប្រវត្តិសង្ខេប



ក. សិក្សាពាក្យគន្លឹះ

- បដិសន្ធិ (ន) : កំណកំណើត ការចាប់កំណើត ។
- ព្រាហ្មណ៍ (ន) : វណ្ណៈមួយក្នុងសង្គមឥណ្ឌានិងសង្គមខ្មែរបុរាណ ។ ពីព្រេងនាយ គេជឿថា ពួកព្រាហ្មណ៍កើតចេញអំពីព្រះឱស្ឋព្រហ្ម ។
- ឃរាវាស (ន) : ការនៅគ្រប់គ្រងផ្ទះ អ្នកនៅគ្រប់គ្រងផ្ទះ ។
- គម្ពីរត្រៃវេទ (ន) : ឈ្មោះគម្ពីរក្នុងសាសនាព្រាហ្មណ៍មានបីគឺ ឬគ្វេទ យជុរ្វេទ សាមវេទ
- ភាវនា (ន) : ការចម្រើន ការនឹកចំពោះត្រង់អារម្មណ៍ដ៏ល្អតែមួយដដែលៗឱ្យច្រើនៗ គឺ នឹកហើយនឹកទៀតរឿយៗជាអនេក ការរំពឹងស្មឹងស្មាធ៍ ។
- ហេមន្តរដូវ (ន) : ឈ្មោះរដូវមានទឹកសន្សើម រដូវរងា ។
- វស្សានរដូវ (ន) : រដូវភ្លៀង ។

- គិម្ហៈរដូវ (ន) : រដូវក្តៅ ។
- ទុក្ករកិរិយា (ន) : អំពើយ៉ាងកម្រ ដំណើរធ្វើកិច្ចដែលអ្នកទាំងពួងធ្វើបានដោយកម្រ បានឯខាងការបំពេញសេចក្តីព្យាយាមដើម្បីឱ្យបានសម្រេចពោធិញ្ញាណ ។
- រាជាភិសេក (ន) : ពិធីស្រោចទឹកក្លស់ ទឹកសង្ឃតាំងព្រះរាជាឱ្យឡើងពេញជាក្សត្រទ្រង់រាជ ។
- សច្ចធម៌ (ន) : ធម៌ពិត សេចក្តីពិត ។
- មេសបាល (ន) : អ្នកឃ្វាលពពែ ឬគង្វាលចៀម ។
- មធុបាយាស (ន) : បាយចម្អិនលាយនឹងទឹកដោះគោ ព្រមទាំងគ្រឿងផ្សំមានតម្លៃផ្សេងៗមានទឹកឃ្មុំជាដើម ។
- កាឡនាគ (ន) : នាគខ្មៅ ។
- ភទ្ទកប្ប (ន) : កប្ប ឬកល្បដ៏ចម្រើន ឈ្មោះកប្ប ឬកល្បដែលមានព្រះពុទ្ធត្រាស់ ៥ ព្រះអង្គ ដូចយ៉ាងកប្បយើងសព្វថ្ងៃនេះមានព្រះសព្វញ្ញូពុទ្ធ ៥ព្រះអង្គ គឺ ព្រះពុទ្ធកកុសន្ធៈ កោនាគមនៈ កស្សបៈ គោតមៈ អរិយមេត្តេយ្យ ។
- ផ្សង (កិ) : ធ្វើសត្យាធិដ្ឋាន សំបួងសង្រួង សុំឱ្យឃើញបុព្វនិមិ្មតជាក់ស្តែង ឬសុំឱ្យបានសម្រេចដូចបំណង ។
- បាបធម៌ (ន) : ធម៌លាមក អាក្រក់ គឺសភាវៈដែលជាជំនួយចិត្តនាំចិត្តឱ្យហ៊ានធ្វើអំពើអាក្រក់ ដូចយ៉ាងសេចក្តីច្រណែនឈ្នានីស ឥតអៀនខ្មាស ឥតរាងរអាទៅរកអំពើអាក្រក់ជាដើម ។
- ភាជន៍ (ន) : ប្រដាប់សម្រាប់ដាក់ភោជនាហារមានបាយជាដើម ។
- បញ្ចវគ្គី (ន) : ក្រុមភិក្ខុប្រាំអង្គ ។
- ប្រោស (កិ) : ស្រោចស្រង់ អនុគ្រោះ រាប់អានដោយមេត្តាប្រណី ។
- បរិនិព្វាន (ន) : ចូលទិវង្គត ស្លាប់ ។
- វណ្ណៈ (ន) : ពណ៌សម្បុរ ពន្លឺ រស្មី ... ។

ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទ អ្នកត្រូវអានដោយយកចិត្តទុកដាក់ដើម្បីត្រៀមឆ្លើយនឹងសំណួរដែលទាក់ទងនឹងកម្មវត្ថុនិងសង្ខេបចំណុចសំខាន់ៗនៃអត្ថបទ ការប្រើប្រាស់ពាក្យខ្ចីពីបាលីសំស្ក្រឹត វណ្ណយុត្តិ របាទ ជាដើម ។

គ. អត្ថបទ

ព្រះពុទ្ធចាប់បដិសន្ធិក្នុងផ្ទៃព្រះនាងសិរិមហាមាយារាជទេវី អគ្គមហេសីនៃព្រះបាទសិរីសុទ្ធោទនៈព្រះចៅក្រុងកបិលព័ស្តុសក្កៈត្រកូលសាក្យវង្សនៅថ្ងៃព្រហស្បតិ៍ ពេញបូណ៌មី ខែអាសាឍ ឆ្នាំរកាវេលាទៀបភ្លឺ។

ព្រះអង្គទ្រង់ប្រសូតនៅព្រំប្រទល់នគរពីរ គឺកបិលព័ស្តុនិងទេវទហៈនៃព្រៃលុម្ពិនី ក្រោមដើមសាលព្រឹក្សមួយដើម នាថ្ងៃសុក្រពេញបូណ៌មី ខែពិសាខ ឆ្នាំច វេលាថ្ងៃជិតត្រង់នា ៦២៣ឆ្នាំមុនគ្រិស្តសករាជ។ ព្រះបាទសិរីសុទ្ធោទនៈបានដាក់ព្រះនាមព្រះរាជបុត្រថា "ព្រះសិទ្ធត្ថ" វង្សគោតម។

ក្នុងព្រះជន្ម ៥ថ្ងៃ ព្រះបិតាបានអញ្ជើញព្រាហ្មណ៍ ៨នាក់ឈ្មោះ រាម លក្ខណៈ សញ្ជៈ ធជៈ សុទត្តៈ សុយាមៈ និងកោណ្ឌញ្ញៈ មកទស្សន៍ទាយថ្វាយអំពីលក្ខណៈរបស់ព្រះសិទ្ធត្ថ។ ព្រាហ្មណ៍ហោរាទី ១ដល់ទី ៧ បានទស្សន៍ទាយថា "ព្រះមហាបុរសបើនៅជាឃរាវាសនឹងបានឡើងសោយរាជ្យសម្បត្តិជាស្តេចចក្រពត្តិ បើចេញទៅបួសនឹងបានត្រាស់ជាព្រះពុទ្ធ"។ ចំណែកឯកោណ្ឌញ្ញព្រាហ្មណ៍ដែលក្មេងជាងគេលើកម្រាមដៃតែមួយទស្សន៍ទាយថា "ព្រះមហាបុរសនឹងបានត្រាស់ជាព្រះពុទ្ធពិតប្រាកដ"។

ព្រះសិទ្ធត្ថមានព្រះជន្ម ៧ថ្ងៃ ព្រះមាតាសិរិមហាមាយាសោយទិវង្គត។ ព្រះបាទសិរីសុទ្ធោទនៈបានជ្រើសរើសព្រះនាងគោតមី ឱ្យមើលបីបាច់ថែរក្សាព្រះរាជឱរស តរៀងមក។ លុះដល់ព្រះជន្ម ៧វស្សាព្រះអង្គបានសិក្សាវិជ្ជាផ្សេងៗដូចជាគម្ពីរត្រៃវេទតាមលទ្ធិព្រាហ្មណ៍ក្នុងសំណាក់ឥសីពិស្វាមិត្រ។ ក្នុងជីវិតនៃការរៀនសូត្រ ព្រះអង្គមានសេចក្តីរីករាយនិងមានក្តីមេត្តាធម៌ជានិច្ច។ ព្រះអង្គបានជួបទុក្ខកង្វល់ជាខ្លាំងនៅពេលដែលឃើញសត្វក្លានមានរបួស គឺពេលនោះហើយដែលទ្រង់ដឹងថា នេះជាសេចក្តីឈឺចាប់បំផុតនៃជីវិត។ ចាប់ពីពេលនោះមក ព្រះអង្គទ្រង់គង់ភាវនាយ៉ាងស្ងៀមស្ងាត់។ ព្រះបាទសិរីសុទ្ធោទនៈ បានចាត់ឱ្យគេសង់ប្រាសាទ ៣គឺ ប្រាសាទចន្ទសម្រាប់គង់នៅហេមន្តរដូវ កោញ្ចប្រាសាទសម្រាប់គង់នៅវស្សានរដូវ កោទនប្រាសាទសម្រាប់គង់នៅគិម្ហៈរដូវដោយរារាំងការចេញទៅបួសនៃព្រះសិទ្ធត្ថ។

ថ្ងៃសៅរ៍ ពេញបូណ៌មី ខែអាសាឍ ឆ្នាំឆ្លូវ ៦០៧ឆ្នាំ មុនគ្រិស្តសករាជ ព្រះសិទ្ធត្ថទ្រង់រាជាភិសេកជាមួយព្រះនាងពិម្ពាយសោធរា បុត្រីព្រះសុប្បពុទ្ធហើយស្នងរាជ្យពីព្រះបិតាក្នុងព្រះជន្ម ១៦វស្សា។ វេលានេះ ព្រះបាទសិរីសុទ្ធោទនៈ បានកសាងព្រះរាជវាំងថ្មីមួយទៀតដែលមានសោភណភាពល្អត្រកាល មានអ្នករបាំ អ្នកបម្រើក្មេងៗហើយស្អាត មានវុក្ខជាតិស្រស់បំព្រងក្នុងបរិវេណរាជវាំង ជាពិសេស គឺមានទ្វារវាំងធ្វើអំពីសិទ្ធមាំនិងមិនងាយនឹងបើក ឬបិទឡើយ។ ព្រះបិតាព្រះអង្គធ្វើបែបនេះក្នុងបំណងរារាំងព្រះសិទ្ធត្ថកុំឱ្យចេញទៅសាងផ្នួសតាមទំនាយព្រាហ្មណ៍ហោរា។

ក្នុងព្រះជន្ម ២៩ ព្រះវស្សា ព្រះសិទ្ធត្ថមានព្រះរាជបុត្រាមួយអង្គទ្រង់ដាក់ព្រះនាមថា រាហុល កុមារ។ ព្រះរាជកុមារប្រសូតក្នុងថ្ងៃព្រហស្បតិ៍ ពេញបូណ៌មី ខែអាសាឍ ឆ្នាំថោះ ហើយក៏ជាថ្ងៃដែល ព្រះសិទ្ធត្ត ទ្រង់យាងចេញសាងផ្នួសដើម្បីស្វែងរកសច្ចធម៌ក្នុងសំណាក់ ឧទកតាបសនិងអាឡារតាបស នៅនគររាជគ្រឹះតែមិនបានសម្រេចឡើយ។ ព្រះសិទ្ធត្ត បានធ្វើទុក្ករកិរិយាក្នុងរូងថ្មមួយនាភ្នំដុរង្គស្វារី នៅឧរុវេលសេនានិគម។ គ្រានោះ ព្រះអង្គមានព្រះកាយទ្រុឌទ្រោមទ្រង់ដួលសន្លប់លើផ្ទាំងថ្ម។ ព្រះឥន្ទ្រាធិរាជបានយកឧបករណ៍ស្លេងពិណមកលេងថ្វាយទ្រង់សណ្តាប់ដោយដាក់ជាប្រស្នាតាមសំឡេង ខ្សែពិណ លើកទី ១ តឹងពេកដាច់ខ្សែ លើកទី ២ ធូរពេកស្តាប់មិនពីរោះ ហើយចុងក្រោយល្មមសំឡេង ស្មើ ពីរោះជាទីគាប់ចិត្ត។ ព្រះអង្គពិចារណារកផ្លូវកណ្តាលដើម្បីរកឃើញនូវហេតុផលនៃសេចក្តីទុក្ខ។ ក្រោយពីបានសោយទឹកដោះពពែដែលមេសបាលថ្វាយរួចមក ព្រះសិទ្ធត្ត បានយាងទៅគង់ក្រោមដើមជ្រៃមួយដើម បែរព្រះភក្ត្រទៅទិសបូព៌។ វេលាព្រឹកនោះ នាងសុជាតាបានយកចង្ហាន់មធុបាយាសមកថ្វាយ។ ព្រះអង្គក៏បានយកចង្ហាន់មធុបាយាសនោះទៅឆាន់នាមាត់ស្ទឹងនេរញ្ជរា រួចបានយកភាជន៍មាសដែលដាក់ចង្ហាន់មធុបាយាសនោះទៅផ្សងថា "បើប្រាកដជាបានត្រាស់ដឹងមែន សូមឱ្យភាជន៍នេះអណ្តែតបញ្ច្រាសទឹកមុននឹងលិចចុះ"។ ភាជន៍មាសអណ្តែតបញ្ច្រាសទឹកប្រហែល ៨០ ហាត្ថ ហើយលិចទៅដល់ពិភពកាឡនាគទៅទង្គិចនឹងថាសនៃព្រះពុទ្ធ ៣ អង្គពីមុនភទ្ទកប្បនេះ ហើយសៀតស៊កពីក្រោមថាសទាំង ៣ នោះ។

ក្រោយពីបានចម្លើយនៃការផ្សងភាជន៍មាសរួចមក ព្រះសិទ្ធត្ត បានយាងទៅកាន់ពោធិព្រឹក្ស មួយដើម ដោយយកស្មៅស្តា ៨ ក្តាប់ដែលបានពីព្រាហ្មណ៍ឈ្មោះសោត្ថិយថ្វាយព្រះអង្គ មកក្រាលគង់ភ្នែនពីលើបែរព្រះភក្ត្រទៅគល់ពោធិព្រឹក្ស។ មួយរំពេច នោះរតនៈបល្ល័ង្កក៏ផុសឡើងមានកម្ពស់ ១៤ ហាត្ថ ទ្រព្រះអង្គនៅក្រោមដើមពោធិ៍នោះ។ ជាបន្តមកទៀត ព្រះអង្គបែរព្រះភ័ក្ត្រទៅទិសបូព៌វិញ ហើយទ្រង់គង់ភាវនាដោយស្ងៀមស្ងាត់។ វេលានោះ មានស្តេចមារជាច្រើនបានកៀរគរប្រមូលសេនាបាបធម៌អកុសលមកផ្តាច់ព្រះអង្គដោយស្រែកសំឡុតសន្ធាប់ឱ្យព្រះសិទ្ធត្តចាកចេញពីព្រះរាជបល្ល័ង្ក ដោយថា រាជបល្ល័ង្កនេះជារបស់ពួកគេ។ ចំណែកព្រះអង្គបានយកព្រះធរណីជាសាក្សី ថាបល្ល័ង្កនោះជារបស់ទ្រង់។ ភ្លាមនោះព្រះធរណីក៏កម្រើកឡើងហាក់ដូចជាទទួលធ្វើជាសាក្សីពិតមែន។

ព្រះសិទ្ធត្ថបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ នាថ្ងៃពុធ ពេញបូណ៌មី ខែពិសាខ ឆ្នាំរកា ៥៨៨ឆ្នាំមុនគ្រិស្តសករាជនៅក្រោមដើមពោធិព្រឹក្សលើរតនបល្ល័ង្កកែ្បរស្ទឹងនេរញ្ជនាវេលាទៀបភ្លឺ។ បន្ទាប់ពីបានត្រាស់ដឹង ព្រះអង្គបានប្រោសបញ្ចវគ្គីភិក្ខុដែលជាសហការីចាស់នៅក្នុងព្រៃឥសីបតនមិគទាយវ័នកែ្បរក្រុងពារាណសីនិងទ្រង់បានប្រកាសរំលាយវណ្ណៈផង។

ថ្ងៃអាទិត្យ ពេញបូណ៌មី ខែមាឃ ឆ្នាំម្សាញ់ ព្រះពុទ្ធទ្រង់ដាក់អាយុសង្ខារដោយប្រាប់មារថាព្រះអង្គនឹងចូលបរិនិព្វានរវាងបីខែទៀត។

ថ្ងៃអង្គារ ពេញបូណ៌មី ខែពិសាខ ឆ្នាំម្សាញ់៥៤៣ឆ្នាំមុនគ្រិស្តសករាជព្រះពុទ្ធទ្រង់ចូលបរិនិព្វានក្នុងព្រះជន្មាយុ ៨០វស្សានៅកុសិនរា ហើយព្រះពុទ្ធសាសនាក៏ចាប់ផ្តើមប្រកាសជាផ្លូវការតាំងពីពេលនោះមក។

(ដកស្រង់ និងកែសម្រួលពីសៀវភៅប្រស្នាពុទ្ធប្រវត្តិ)

សំណួរ

១. តើព្រះពុទ្ធប្រសូតនៅឯណា ? ព្រះមាតាបិតាព្រះអង្គព្រះនាមអ្វី ?

២. ចូរស្រង់កាលបរិច្ឆេទប្រវត្តិព្រះពុទ្ធសំខាន់ៗដាក់តាមលំដាប់។

៣. តើព្រាហ្មណ៍ហោរា ៨នាក់បានទស្សន៍ទាយលក្ខណសម្បត្តិរបស់ព្រះសិទ្ធត្ថយ៉ាងដូចម្តេចខ្លះ ?

៤. ចូររកពាក្យដែលប្រើសញ្ញារបាទ " ិ " នៅក្នុងអត្ថបទខាងលើ។

៥. ចូរស្រង់ពាក្យសម្គាល់បាលីសំស្កឹតក្នុងវគ្គខាងក្រោមនេះចំនួន ៣ពាក្យ រួចប្រាប់ពីលក្ខណៈសម្គាល់ផង ៖

" ... ព្រះសិទ្ធត្ថមានព្រះជន្ម ៧ថ្ងៃ ព្រះមាតាសិរិមហាមាយាសោយទិវង្គត។ ព្រះបាទសិរីសុទ្ធោទនៈបានជ្រើសរើសព្រះនាងគោតមីមើលបីបាច់ថែរក្សាព្រះរាជឱរស តរៀងមក ..."។

៦. ហេតុអ្វីបានជាព្រះពុទ្ធជាម្ចាស់ជ្រើសរើសព្រះធរណីធ្វើជាសាក្សី នៅពេលដែលពួកស្តេចមារផ្តាញ់ព្រះអង្គ ?

៧. តើគំនិតសំខាន់នៃអត្ថបទនេះនិយាយពីអ្វីខ្លះ ?

១ រឿង ព្រះនាងឥន្ទ្រទេវី



នៅសម័យមហានគរ ប្រទេសកម្ពុជាមានកេរ្តិ៍ឈ្មោះល្បីល្បាញលើពិភពលោក មានទឹកដីធំទូលាយ ប្រាង្គប្រាសាទល្អប្រណីត ធនធានមនុស្សខ្លាំងពូកែ ទាំងយុទ្ធសាស្ត្រនិងអក្សរសាស្ត្រដូចជាព្រះនាងឥន្ទ្រទេវីជាដើម។

ឥឡូវចូរអ្នកស្តាប់អត្ថបទដែលតំណាលពីប្រវត្តិព្រះនាងឥន្ទ្រទេវី រួចត្រៀមឆ្លើយនឹងសំណួរមួយចំនួនដែលទាក់ទងនឹងប្រភេទពាក្យបាលីសំស្ក្រឹត សង្ខេប អត្ថបទ តម្លៃអប់រំនៃអត្ថបទ ... ។

សំណួរ

១. ព្រះនាងឥន្ទ្រទេវីទ្រង់ប្រសូតឡើងក្នុងត្រកូលណា ? ស្ថានភាពគ្រួសារយ៉ាងដូចម្តេច ?

២. តើព្រះនាងបំពេញបេសកកម្មអ្វីខ្លះ ជាប្រយោជន៍គ្រួសារនិងប្រទេសជាតិ ?

៣. ចូរស្រង់ពាក្យបាលីសំស្ក្រឹតឱ្យបាន ៥ ពាក្យ។

៤. តើព្រះនាងឥន្ទ្រទេវីបានលើកកម្ពស់សិទ្ធិនារីដូចម្តេចខ្លះ ?

៥. ចូរបង្ហាញតម្លៃអប់រំនៃអត្ថបទនេះ។

៦. ចូរសង្ខេបអត្ថបទឡើងវិញ។

ជីវប្រវត្តិផ្ទាល់ខ្លួន

អ្នកធ្លាប់បានសិក្សារួចមកហើយអំពីការនិយាយ ដើម្បីណែនាំនិងផ្តល់ព័ត៌មានអំពីខ្លួនឯង។ ឥឡូវអ្នកត្រូវសិក្សាបន្តទៀតអំពីការនិយាយពីជីវប្រវត្តិផ្ទាល់ខ្លួន ដើម្បីឱ្យសិស្សក្នុងថ្នាក់ទាំងអស់គ្នាស្គាស់។

នៅថ្នាក់ទី ៩ "ក" មានសិស្សថ្មីម្នាក់ផ្ទេរការសិក្សាមកពីសាលាផ្សេង។ លោកគ្រូបានណែនាំសិស្សថ្មីឱ្យសិស្សក្នុងថ្នាក់ទាំងអស់ស្គាល់។ បន្ទាប់មក លោកគ្រូណែនាំឱ្យសិស្សថ្មីនិយាយពីប្រវត្តិផ្ទាល់ខ្លួនប្រាប់ទៅសិស្សទាំងអស់នោះវិញម្តង។ សិស្សថ្មីឡើងនិយាយ ៖

ជម្រាបសួរលោកគ្រូ ! សួស្តីមិត្តរួមថ្នាក់ទាំងអស់ ! នាងខ្ញុំឈ្មោះ មុត សុភក្ត្រ អាយុ ១៤ឆ្នាំ មកពីអនុវិទ្យាល័យ "គ" ខេត្តកោះកុង។ ឪពុកខ្ញុំឈ្មោះ មុត សុខុម អាយុ ៤០ឆ្នាំ មានមុខរបរជាកម្មករនេសាទ។ ម្តាយខ្ញុំឈ្មោះ គីម ស៊ីម អាយុ ៣៦ឆ្នាំ មានមុខរបរជាមេផ្ទះ។ គ្រួសារខ្ញុំមានជីវភាពមធ្យម។ និយាយមកដល់ត្រីមនេះសុភក្ត្រមានទឹកមុខស្រពាប់ស្រពោន។ ប្រធានថ្នាក់ទី ៩ "ក"ឃើញដូច្នេះក៏សួរថា ហេតុអ្វីបានជាមិត្តមានទឹកមុខស្រពាប់ស្រពោនម្ល៉េះ។ សិស្សថ្មីឆ្លើយយ៉ាងស្រងូតថា ឪពុកខ្ញុំនឿយហត់ណាស់ គាត់ត្រូវចេញទៅធ្វើការពេលរសៀលតាមទូកនេសាទ ឆ្លងកាត់រលកសមុទ្រធំៗដែលពេលខ្លះជួបព្យុះភ្លៀងស្ទើរផុតរបូតជីវិតម្តងៗទៅហើយ។ ខ្ញុំធ្លាប់ឃើញគាត់ចាកចេញទៅធ្វើការទាំងខ្លួនមានជំងឺផងក៏មាន។ ព្រឹត្តិការណ៍ទាំងអស់នេះបានជិតជាប់ក្នុងអារម្មណ៍ខ្ញុំ ហើយក៏ជាកម្លាំងជំរុញចិត្តខ្ញុំឱ្យខិតខំធ្វើជាកូនល្អ ប្រឹងប្រែងរៀនសូត្រឱ្យទៅជាសិស្សពូកែ។ ទីបំផុតនៅចុងឆ្នាំកន្លងមកនេះ ខ្ញុំបានប្រឡងជាប់លេខ ១ ប្រចាំឆ្នាំសិក្សា ដែលជាលេខល្អបំផុត ធ្វើឱ្យឪពុកម្តាយនិងបងប្អូនៗខ្ញុំសប្បាយរីករាយ។ ពួកគាត់បានលើកទឹកចិត្តខ្ញុំដោយនិយាយថា "គាត់មានកម្លាំងចិត្តខិតខំធ្វើការគ្រប់បែបយ៉ាងដើម្បីកូនៗទាំងអស់គ្នារៀនសូត្រហូតបានជោគជ័យក្នុងជីវិត"។

សំណួរ

១. តើសិស្សថ្មីផ្ទេរការសិក្សាចូលថ្នាក់ទី ៩ "ក" ឈ្មោះអ្វី ? មកពីសាលាណា ?

២. ឪពុកម្តាយនាងឈ្មោះអ្វី ? ប្រកបរបរអ្វីអ្វី ?

៣. តើជីវភាពគ្រួសារនាងស្ថិតក្នុងស្ថានភាពណា ?

៤. តើកត្តាអ្វីជំរុញឱ្យនាងខិតខំរៀន ?

៥. តើឪពុកម្តាយនាងបានបែជ្ញាចិត្តដូចម្តេច ? ហេតុអ្វី ?

៦. តើអ្នកយល់ដូចម្តេចចំពោះជីវប្រវត្តិសិស្សថ្មី ?

លំហាត់

ចូរអ្នកនិយាយពីជីវប្រវត្តិរបស់ខ្លួន(ទាក់ទងនឹងព្រឹត្តិការណ៍ណាមួយ)ឱ្យមិត្តរួមថ្នាក់បានស្តាប់អំពី ៖

- ជីវិតសិក្សារបស់អ្នកនៅឆ្នាំសិក្សាដំបូងនៃមធ្យមសិក្សាបឋមភូមិ ។
- ចំណង់ចំណូលចិត្តរបស់ខ្លួន ។
- ជំនាញពិតប្រាកដមួយ ។
- ទម្លាប់បងប្អូនរបស់អ្នកក្នុងការរស់នៅក្នុងផ្ទះ ។ នៅពេលអ្នកនិយាយពីព្រឹត្តិការណ៍ដែលទាក់ទងនឹងជីវិតរបស់អ្នក ចូរអ្នក ៖
  - បង្ហាញនូវឥរិយាបថរបស់ខ្លួនឱ្យបានសមរម្យ
  - លើកដៃជម្រាបសួរគ្រូជាមុន មុននឹងជម្រាបសួរមិត្តរួមថ្នាក់
  - ប្រើសម្តីរាបសាច្បាស់លាស់ សមរម្យ ទន់ភ្លន់
  - បង្ហាញពីអារម្មណ៍របស់ខ្លួនដែលទាក់ទងនឹងព្រឹត្តិការណ៍ទាំងនោះ ។

ជីវប្រវត្តិ

អ្នកធ្លាប់សរសេរបំពេញសលាកបត្រនិងពាក្យសុំចូលរៀនរួចមកហើយ។ ពេលនេះអ្នកនឹងសិក្សាអំពីការសរសេរជីវប្រវត្តិ។

ចូរពិនិត្យគំរូខាងក្រោម ៖

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
ជីវប្រវត្តិសង្ខេប

- គោត្តនាម និងនាម : មុត សុភក្ត្រ អាយុ ១៤ ឆ្នាំ ភេទស្រី សញ្ជាតិ ខ្មែរ
- អាសយដ្ឋានបច្ចុប្បន្ន : ផ្ទះលេខ ៤២ E_0 ភូមិ ១៨ ឃុំ/សង្កាត់ជ័យជំនះ ស្រុក/ខណ្ឌ ដូនពេញ ខេត្ត/ក្រុង ភ្នំពេញ
- ឪពុកឈ្មោះ : មុត សុខុម មុខរបរ កម្មករនេសាទ
- ម្តាយឈ្មោះ : គីម ស៊ីម មុខរបរ មេផ្ទះ
- ទីកន្លែងកំណើត : ភូមិ២ ឃុំ/សង្កាត់ដងទង់ ស្រុក/ខណ្ឌ ស្ទាច់មានជ័យ ខេត្តកោះកុង
- ថ្ងៃខែឆ្នាំកំណើត : ១០ កុម្ភៈ ១៩៩៦
- បងប្អូនបង្កើត : ២ នាក់
  - ឈ្មោះ មុត សុភា អាយុ ១២ឆ្នាំ ភេទប្រុស ត្រូវជាប្អូន
  - ឈ្មោះ មុត វាសនា អាយុ ១០ឆ្នាំ ភេទប្រុស ត្រូវជាប្អូន
- ការសិក្សាអប់រំ : ឆ្នាំ ២០០៩ -២០១០ ថ្នាក់ទី ៩ សាលា ក
  ឆ្នាំ ២០០៨ -២០០៩ ថ្នាក់ទី ៨ សាលា គ
  ឆ្នាំ ២០០៧ -២០០៨ ថ្នាក់ទី ៧ សាលា គ
- ចំណង់ចំណូលចិត្ត : គំនូរ
- ជំនាញពិសេស : សូត្រកំណាព្យ

ខ្ញុំសូមធានាអះអាងថា ជីវប្រវត្តិនេះពិតជាត្រឹមត្រូវឥតក្លែងបន្លំ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១០

ហត្ថលេខានិងឈ្មោះ

Sophak

មុត សុភក្ត្រ

សំណួរ

១. តើសំណេរជីវប្រវត្តិខាងលើនេះប្រាប់ពីព័ត៌មានអ្វីខ្លះ ?

២. តើការសរសេរជីវប្រវត្តិផ្ទាល់ខ្លួនមានអត្ថប្រយោជន៍ដូចម្តេច ?

៣. តើការក្លែងបន្លំជីវប្រវត្តិមានទោសឬទេ ? ព្រោះអ្វី ?

លំហាត់

ចូរអ្នកសរសេរប្រវត្តិរូបផ្ទាល់ខ្លួនរបស់អ្នកដោយអនុវត្តតាមលំនាំគំរូខាងលើ ។ នៅពេលសរសេរ អ្នកគប្បីយកចិត្តទុកដាក់លើ ៖

- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានច្បាស់លាស់ ។
- ការរៀបចំឃ្លាល្បះឱ្យសមរម្យច្បាស់លាស់និងបំពេញគ្រប់ចំណុចឱ្យបានត្រឹមត្រូវ ។
- ភាពច្បាស់លាស់នៃសំណេរតាមលំដាប់លំដោយនៃគំរូខាងលើ ។
- ការប្រើនាមជីវចលនិងនាមអជីវចល ។
- ភាពត្រឹមត្រូវនៃប្រវត្តិរូបជាក់ស្តែងរបស់ប្អូន ។
- ការបំពេញកាលបរិច្ឆេទនិងចុះហត្ថលេខាជាក់ឈ្មោះឱ្យបានត្រឹមត្រូវ ។

មេរៀនទី

មោទនភាពជាតិ

បុព្វបុរសខ្មែរ បានបង្កើតនិងបន្សល់ទុកនូវទឹកដីដ៏ធំទូលាយ សម្បត្តិវប្បធម៌ដ៏ល្បីល្បាញ ដូចជាប្រាង្គប្រាសាទសិលាតូចធំ សម្បត្តិធម្មជាតិដ៏ស្រស់បំព្រង ព្រមទាំងអត្តសញ្ញាណជាតិដ៏ច្រើនលើសលប់មិនអាចគណនាបានសម្រាប់កូនខ្មែរជំនាន់ក្រោយ។ យើងជាកូនខ្មែរ មានមោទនភាពចំពោះជាតិឥតឧបមា។ យើងប្តេជ្ញាថែរក្សាការពារកេរដំណែលវប្បធម៌ទាំងនោះ ឱ្យបានស្ថិតស្ថេរគង់វង្ស ដើម្បីជាតិមាតុភូមិជាទីស្នេហារបស់យើង។

ក្នុងមេរៀននេះ អ្នកនឹងសិក្សាខ្លឹមសារអត្ថបទមួយចំនួនទាក់ទងនឹងមោទនភាពជាតិ។ ទន្ទឹមនេះ អ្នកក៏សិក្សាផងដែរអំពី តម្លៃអប់រំ ពាក្យចួន ផ្ទួន រណ្តំ និងកាព្យមាត្រ មេតាផរ ន័យចំ ន័យធៀប សុភាសិត នាមអរូបី នាមអរូបី និងសំណេរអត្ថបទកំណាព្យ។

នាមរូបី នាមអរូបី

ប្អូនបានសិក្សារួចមកហើយអំពីនាមសាធារណៈ នាមអសាធារណៈ នាមករណៈ នាមការក៍ ។ល។ ក្នុងមេរៀននេះប្អូននឹងសិក្សាអំពីនាមរូបី និងនាមអរូបីបន្តទៀត ។

ចូរប្អូនពិនិត្យឧទាហរណ៍ខាងក្រោម ៖

ឧទាហរណ៍ទី ១ :

- <u>វិចិត្រករ</u>កំពុងគូរគំនូរប្រាសាទអង្គរវត្តដ៏ស្រស់ប្រិមប្រិយរបស់ខ្មែរយើង ។
- <u>សិល្បករ</u>សម្តែងរបាំជូនពរក្នុងពិធីដ៏ឱឡារិកនេះ ។
- <u>ប្រាសាទ</u>សម្បូរព្រៃគុហ៍ស្ថិតក្នុងខេត្តកំពង់ធំ ។
- <u>ប្រជាកសិករ</u>កំពុងភ្ជួររាស់ ដកស្ទូង យ៉ាងញាប់ដៃញាប់ជើង ។
- <u>កុមារ</u>ជាទំពាំងស្នងឫស្សី ។

ពាក្យជានាមរូបី : កុមារ កសិករ វិចិត្រករ សិល្បករ... គោ ក្របី ស្រែ ចម្ការ តុ ទូ ប្រាសាទ ព្រះអាទិត្យ ព្រះចន្ទ ។ល។

ឧទាហរណ៍ទី ២ :

- <u>សេចក្តីសុខសន្តិភាព</u>ជាបំណងប្រាថ្នារបស់មនុស្សទូទៅ ។
- <u>កូនល្អ</u>ជាសេចក្តីសង្ឃឹមរបស់ឪពុកម្តាយ ។
- <u>ភាពទំនេរ</u>នាំឱ្យមានជំងឺ ។
- <u>សុភមង្គល</u>ជាបំណងប្រាថ្នារបស់ខ្ញុំ ។

ពាក្យជានាមអរូបី : ការស្ទូង ការភ្ជួរ សេចក្តីសុខ សន្តិភាព សេចក្តីសង្ឃឹម ភាពទំនេរ ភាពចំណាស់ ។ល។

តាមឧទាហរណ៍ខាងលើនេះ យើងឃើញថាក្នុងឧទាហរណ៍ទី ១ ពាក្យដែលគូសបន្ទាត់ពីក្រោម គឺជាពាក្យដែលបង្ហាញពីនាមរូបី ព្រោះជាពាក្យដែលយើងអាចដឹងដោយញាណ ។ ក្នុងឧទាហរណ៍ទី ២ ពាក្យដែលគូសបន្ទាត់ពីក្រោម គឺជាពាក្យដែលបង្ហាញពីនាមអរូបី ព្រោះជាពាក្យបង្ហាញនូវសភាពលក្ខណៈ ... ។

នាមរូបី គឺជានាមបង្ហាញពីមនុស្ស សត្វ វត្ថុ ឬរុក្ខជាតិដែលយើងដឹងបានដោយវិញ្ញាណ ។
នាមអរូបី គឺជានាមដែលបង្ហាញពីអំពើ គុណភាព ភាព ឬ លក្ខណៈរបស់មនុស្ស សត្វ ឬ វត្ថុ ... ។

ចូរអ្នករកនាមរូបី និងនាមអរូបីក្នុងល្បះនិងកថាខណ្ឌខាងក្រោម ៖

១. ក្រដាស ប្រាសាទ អ្នកលក់ដូរ ស្ថាបត្យករ ការអនុវត្ត ទីក្រុងកេបិក ប្រទេសកាណាដា បេតិក ភណ្ឌ ប្រជាជន សិល្បករ អ្នកដកស្នូង

២. សម្តីមាស តម្លៃ សៀវភៅ បញ្ជី ខេមរបុត្រ វត្តអារាម នាយកសាលា ភាពក្លាហាន មោទន ភាព

៣. សត្វកណ្តៀរពាំនាំជញ្ជួនដីបន្តិចម្តងៗក៏គង់កើតជាដំបូកធំៗសម្រាប់ស្នាក់អាស្រ័យនៅ ។ រីង មនុស្សដែលប្រកាន់សេចក្តីព្យាយាម រមែងសម្រេចតាមបំណងប្រាថ្នា ។

៤. លោកអធិបតីចូលមក "សូជាត បន្ទប់នេះគឺបន្ទប់ឯង ការរចនាឱ្យបានរុងរឿងស្រេចលើចិត្ត បាស្រាប់ អញរៀបចំប្រជាប់ឱ្យឯងស្រួលបួលនេះ គឺអញមានសេចក្តីសង្ឃឹមថា ឯងគង់តែនឹង បានរៀនសូត្រកើនទៅមុខពុំខាន" ។

មោទនភាពជាតិខ្មែរ



ក. សិក្សាពាក្យគន្លឹះ

- បេតិកភណ្ឌ (ន) : ទ្រព្យសម្បត្តិឬកេរមរតកមានតជាប់ពីខាងឪពុក ។
- មោទនភាព (ន) : សេចក្តីអំណួត ។
- រមណីយដ្ឋាន (ន) : ទីកន្លែងគួរឱ្យរីករាយ គួរឱ្យសប្បាយ ។
- ស្ថាបត្យកម្ម (ន) : ការសាងសង់ សំណង់ ។
- កាតព្វកិច្ច (ន) : កិច្ចដែលគួរធ្វើ ការងារដែលត្រូវតែធ្វើខានពុំបាន ។
- សហប្រតិបត្តិការ (ន) : ការងារដែលបានអនុវត្តរួមគ្នាយ៉ាងជិតស្និទ្ធ ។
- កេរមរតក (ន) : ទ្រព្យរបស់ជាកេរដំណែលពីដូនតា ។
- លក្ខន្តិក: (ន) : ការកំណត់ឬសេចក្តីកំណត់ដែលជាច់ស្រេច ។
- អរូបី (គុ) : ដែលគ្មានរូប ។
- លទ្ធផល (ន) : ផលនៃការងារដែលបានសម្រេចផល ផលដែលបានសម្រេចហើយ ។
- ប្រតិភូ (ន) : អ្នកទទួលអំណាចធ្វើការជំនួស ។

- សាលក្រម (ន) : សំបុត្រសម្រេចសេចក្តីដែលចៅក្រមប្រគល់ឱ្យគូក្តីអ្នកឈ្នះកាន់រក្សាទុកជាសម្គាល់ ។
- អធិបតេយ្យភាព (ន) : ភាពជាធំ ជាម្ចាស់ប្រទេស ភាពជាម្ចាស់ប្រទេស ។
- បេសកកម្ម (ន) : កិច្ចការរបស់ជនដែលចាត់បញ្ជូនឱ្យទៅបំពេញការកិច្ចអ្វីមួយ ។
- ទីសក្ការៈ (ន) : កន្លែងសម្រាប់គោរពឬកន្លែងសម្រាប់ធ្វើបជិសណ្ឋារៈដោយគោរព ។
- សុឆន្ទៈ (ន) : បំណងដ៏ល្អប្រពៃ បំណងដែលត្រឹមត្រង់តាមគតិធម៌និងគតិច្បាប់ដែលញុំាងឱ្យសេចក្តីសុខកើតមាន ។
- ខណ្ឌសីមា (ន) : ទីមានព្រំកំណត់ ព្រំដែន ព្រំប្រទល់ ។
- បរិវេណ (ន) : ទីជិតខាងដែលព័ទ្ធជុំវិញ ។
- បរិសុទ្ធ (គុ) : ដែលស្អាត ដែលល្អឥតសៅហ្មង ។

ខ អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទ "មោទនភាពជាតិខ្មែរ"ខាងក្រោមនេះ អ្នកគប្បីអានដោយយកចិត្តទុកដាក់ ដើម្បីត្រៀមឆ្លើយសំណួរមួយចំនួនទាក់ទងនឹងអត្ថន័យនៃអត្ថបទ គំនិតសំខាន់និងតម្លៃអប់រំនៃអត្ថបទឱ្យបានត្រឹមត្រូវ ។

ក អត្ថបទ

[...] នៅថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ ២០០៨ នាសម័យប្រជុំលើកទី ៣២របស់ខ្លួន ដែលប្រព្រឹត្តទៅនៅទីក្រុងកេបិក ប្រទេសកាណាដា គណៈកម្មាធិការបេតិកភណ្ឌពិភពលោកនៃអង្គការដើម្បីវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំរបស់អង្គការសហប្រជាជាតិ(យូណេស្កូ-UNESCO) បានសម្រេចចុះប្រាសាទព្រះវិហាររបស់ខ្មែរក្នុងបញ្ជីបេតិកភណ្ឌពិភពលោកតាមសំណើរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

នេះគឺជាមោទនភាពថ្មីមួយទៀត សម្រាប់ប្រជាពលរដ្ឋ និងព្រះរាជាណាចក្រកម្ពុជាយើង ក៏ដូចជាសម្រាប់ប្រជាពលរដ្ឋនានានៅក្នុងតំបន់និងពិភពលោក ដែលប្រាសាទព្រះវិហារត្រូវបានក្រុមប្រឹក្សាអន្តរជាតិស្តីពីប្រាង្គប្រាសាទ និងរមណីយដ្ឋាន (ICOMOS) ទទួលស្គាល់ថាជាកំពូលស្នាដៃដ៏អស្ចារ្យនៃស្ថាបត្យកម្មខ្មែរ និងមានតម្លៃជាសាកលនោះ ត្រូវបានបញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ។

ការចុះបញ្ជីនេះនឹងតម្រូវឱ្យសហគមន៍អន្តរជាតិទាំងមូលមានកាតព្វកិច្ចសហប្រតិបត្តិការ ការពារនូវបេតិកភណ្ឌសាកលនេះនិងថែរក្សាជាសម្បត្តិវប្បធម៌កេរមរតកសម្រាប់មនុស្សជំនាន់ក្រោយ។ នេះជាបេតិកភណ្ឌខ្មែរទី៤ ហើយដែលត្រូវបានទទួលលក្ខន្តិក:ដ៏ខ្ពង់ខ្ពស់ ថ្លៃថ្នូរ បន្ទាប់ពីប្រាសាទអង្គរវត្តត្រូវបានបញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។ ដូចគ្នាដែរនៅឆ្នាំ ១៩៩២ របាំក្បាច់បុរាណខ្មែរ (របាំព្រះរាជទ្រព្យ) និងល្ខោនស្បែកធំ ត្រូវបានបញ្ចូលជាបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិនៅឆ្នាំ ២០០៣ និងនៅឆ្នាំ ២០០៥កន្លងមក។

ការដាក់ប្រាសាទព្រះវិហារចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ជាលទ្ធផលនៃដំណើរការងារនិងការចរចាដ៏យូរ និងស្មុគស្មាញមួយ។ សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានលើកសំណើជូនទៅឯកឧត្តមអគ្គនាយកយូណេស្កូ កាលពីថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០០១។

បន្ទាប់មកក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដោយមានទីប្រឹក្សាបច្ចេកទេសនិងជំនួយដ៏សំខាន់ពីសំណាក់អង្គការយូណេស្កូ បានរៀបចំសំណុំឯកសារពេញលេញមួយស្របតាមទិសដៅណែនាំការអនុវត្តអនុសញ្ញាស្តីពីការការពារបេតិកភណ្ឌពិភពលោក វប្បធម៌និងធម្មជាតិដែលកម្ពុជាជារដ្ឋសមាជិក នោះដាក់ជូនមជ្ឈមណ្ឌលបេតិកភណ្ឌពិភពលោកនាទីក្រុងប៉ារីស នាថ្ងៃទី ៣០ ខែមករា ឆ្នាំ ២០០៦។ បន្ទាប់ពីបេសកកម្មបច្ចេកទេសមួយនៅរមណីយដ្ឋានប្រាសាទព្រះវិហារ ដោយតំណាងរបស់ក្រុមប្រឹក្សាអន្តរជាតិស្តីពីប្រាង្គប្រាសាទនិងរមណីយដ្ឋាន ពីថ្ងៃទី ២៣ ដល់ថ្ងៃទី ២៩ ខែតុលា ឆ្នាំ ២០០៦ និងបន្ទាប់ពីបានទទួលព័ត៌មានបន្ថែមដែលកម្ពុជាបានផ្ញើជូននៅថ្ងៃទី ០៣ ខែមករា ឆ្នាំ ២០០៧ រួចមកក្រុមប្រឹក្សាអន្តរជាតិស្តីពីប្រាង្គប្រាសាទនិងរមណីយដ្ឋាន បានទទួលស្គាល់តម្លៃសាកលដ៏អស្ចារ្យនៃរមណីយដ្ឋាន ហើយផ្តល់អនុសាសន៍ឱ្យដាក់រមណីយដ្ឋានជាទីសក្ការៈនៃប្រាសាទព្រះវិហារចូលក្នុងបញ្ជីនៃបេតិកភណ្ឌពិភពលោក។ នៅសម័យប្រជុំសាមញ្ញលើកទី ៣១ របស់ខ្លួននៅទីក្រុងក្រៃស្ចិចប្រទេសនូវែលសេឡង់ ពីថ្ងៃទី ២៣ ខែមិថុនា ដល់ថ្ងៃទី ០២ ខែកក្កដា ឆ្នាំ ២០០៧ គណៈកម្មាធិការបេតិកភណ្ឌពិភពលោកបានពិនិត្យសំណុំឯកសារទាំងអស់ពាក់ព័ន្ធនឹងសំណើនេះ រួចទទួលស្គាល់ថា រមណីយដ្ឋានជាទីសក្ការៈនៃប្រាសាទព្រះវិហារមានសារៈសំខាន់អន្តរជាតិដ៏ធំ ហើយមានតម្លៃសាកលអស្ចារ្យ ព្រមទាំងសម្តែងនូវ "សេចក្តីយល់ព្រមជាគោលការណ៍ចំពោះប្រការដែលថា រមណីយដ្ឋានត្រូវតែដាក់បញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក"។

[...] "សេចក្តីសម្រេចនេះមានន័យថា គណៈកម្មាធិការបានយល់ព្រមថា រមណីយដ្ឋានជាទីសក្ការៈនេះស័ក្តិសមនឹងបានបញ្ចូលក្នុងបញ្ជីមរតកពិភពលោក ហើយការបញ្ចូលជាផ្លូវការនឹងត្រូវធ្វើឡើងនៅសម័យប្រជុំលើកក្រោយរបស់ខ្លួននាឆ្នាំ ២០០៨"។

ពិតណាស់ គឺ ៤៦ឆ្នាំមុននេះ ឆ្លើយតបនឹងសំណើរបស់រាជរដ្ឋាភិបាលកម្ពុជា កាលពីថ្ងៃទី ៦ ខែតុលា ឆ្នាំ ១៩៥៩ តុលាការអន្តរជាតិទីក្រុងឡាអេ ទទួលស្គាល់ក្នុងសាលក្រមរបស់ខ្លួន នាថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៦២នោះថា ប្រាសាទព្រះវិហារស្ថិតក្នុងដែនដីដែលនៅក្រោមអធិបតេយ្យភាពរបស់កម្ពុជា ហើយតម្រូវឱ្យប្រទេសថៃដកចេញរាល់កម្លាំងប្រដាប់អាវុធ ប៉ូលិស ឬឆ្មាំទាំងអស់ដែលខ្លួនបានដាក់នៅក្នុងប្រាសាទ ឬក្នុងបរិវេណប្រាសាទដែលស្ថិតក្នុងដែនដីរបស់កម្ពុជា ។

[...]សាលក្រមរបស់តុលាការអន្តរជាតិទីក្រុងឡាអេ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៦២ បានសម្រេចថា ប្រាសាទព្រះវិហារស្ថិតនៅលើទឹកដីដែលនៅក្រោមអធិបតេយ្យភាពកម្ពុជា ។ ផ្អែកលើសាលក្រមនេះនិងផ្អែកទៅស្ថានភាពជាក់ស្តែងនៃប្រាង្គប្រាសាទនោះ ក្នុងឋានៈជាប្រទេសម្ចាស់ប្រាសាទ ព្រះរាជាណាចក្រកម្ពុជាបានធ្វើសំណើសុំដាក់ប្រាសាទព្រះវិហារចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ក្នុងគោលបំណងការពារបេតិកភណ្ឌសាកលនេះ ដែលជាស្នាដៃដ៏អស្ចារ្យរបស់បុព្វបុរសខ្មែរសម័យអង្គរ ដើម្បីទុកជាកេរមរតកនិងសម្បត្តិវប្បធម៌ជូនមនុស្សជំនាន់ក្រោយៗទៀត ។

ប្រជាជនកម្ពុជាទាំងមូល ពិតជាកោតស្ញប់ស្ញែងនូវព្រះរាជបញ្ញាញាណនិងសូមថ្លែងអំណរព្រះគុណដ៏ជ្រាលជ្រៅ និងស្មោះស្ម័គ្របំផុតថ្វាយសម្តេចព្រះមហាវីរៈក្សត្រ ព្រះបាទសម្តេចព្រះ**នរោត្តមសីហនុ** ដែលបានប្រទាននូវព្រះរាជកិច្ចដ៏ខ្ពង់ខ្ពស់បំផុតប្រកបដោយស្នារតីស្នេហាជាតិដ៏ជ្រាលជ្រៅក្នុងការតស៊ូទាមទារមកវិញ និងការពារបាននូវអធិបតេយ្យភាព បូរណភាពទឹកដីស្របច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាលើប្រាង្គប្រាសាទព្រះវិហារដែលជាស្តាបត្យកម្មខ្មែរដ៏អស្ចារ្យ ។

សំណួរ

១. តើប្រាសាទព្រះវិហារបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក នៅថ្ងៃណា ? ខែណា ? ឆ្នាំណា ? នៅប្រទេសណា ?

២. តើប្រាសាទអង្គរវត្ត បានដាក់បញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកពីឆ្នាំណាដែរ ?

៣. តើអ្នកយល់ដូចម្តេច ចំពោះការដាក់បញ្ចូលឬចុះបញ្ជីប្រាសាទទាំងនេះជាបេតិកភណ្ឌពិភពលោក ?

៤. តើអត្ថបទខាងលើបង្កប់តម្លៃអប់រំដូចម្តេច ?

៥. តើអ្នកគួរធ្វើ ឬត្រូវធ្វើអ្វីខ្លះដើម្បីសម្តែងនូវឆន្ទៈនិងមោទនភាពចំពោះជាតិ ?

៦. សម្រាប់ប្រទេសកម្ពុជាការដាក់បញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកសំខាន់ៗទាំង ៤ លើកមានអ្វីខ្លះ ? ចូរវៀបរាប់ ។

៧. ចូរស្រង់នាមរូបី ក្នុងអត្ថបទខាងលើឱ្យបានចំនួន ៣ និងនាមអរូបីឱ្យបានចំនួន ៣ ។

3

រំឭកបញ្ញត្តិ

នាម គឺថ្នាក់ពាក្យមួយប្រភេទសម្រាប់សម្គាល់មនុស្ស សត្វ វត្ថុ ទីកន្លែង សកម្មភាព និង បញ្ជាក់ពីឈ្មោះមនុស្ស សត្វ ទីកន្លែងណាមួយ ... ។

- សាធារណនាម ឬនាមសាធារណ៍ គឺជានាមសម្តែងមិនចំពោះ ទូទៅ ។
- អសាធារណនាម ឬនាមអសាធារណ៍ គឺជានាមសម្តែងឈ្មោះប្រាកដ ចំពោះ មិនទូទៅ ។
- នាមករណ៍ ឬករណនាម គឺជានាមសម្តែងសភាព ឬសកម្មភាព ។
- នាមការក៍ឬការកនាម គឺជានាមសម្តែងអ្នកធ្វើអំពើឬអ្នកមានសភាពលក្ខណៈបែបណាមួយ ។

• នាមករណ៍ ឬករណនាមចេញមកពី :

កិរិយាសព្ទ :

- ធ្វើ	>	ទង្វើ	ប្រព្រឹត្ត	>	ការប្រព្រឹត្ត
- សង្កេត	>	ការសង្កេត	ជោរ	>	ជំនោរ

គុណនាម :

- សុខ	>	សេចក្តីសុខ	វែង	>	ប្រវែង
- កាច	>	កំណាច	ក្រាស់	>	កម្រាស់

• នាមការក៍ឬការកនាមចេញមកពី :

កិរិយាសព្ទ :

- យាម	>	អ្នកយាម	ដើរ	>	ថ្មើរ
- កាន់	>	ខ្នាន់	ពោល	>	អ្នកពោល

គុណនាម :

- កណ្តាល	>	អ្នកកណ្តាល	ខ្សត់	>	អ្នកខ្សត់
- ល្អ	>	អ្នកល្អ	ក្លាហាន	>	អ្នកក្លាហាន

នាម :

- ក្រុង	>	អ្នកក្រុង	ភូមិ	>	អ្នកភូមិ
- ចម្ការ	>	អ្នកចម្ការ	ស្រែ	>	អ្នកស្រែ

បំរៀបន័យ ឬមេតាផរ

មេតាផរ គឺជាបដិរូបមួយបែបនៃភាសាដែលកើតឡើងដោយសារការប្រៀបធៀបអង្គទំហៀបពីរ ឬច្រើនដោយមិនប្រើចំណងធៀប។ ទំហៀបនេះគេមិនប្រើពាក្យ ជាសំនួនប្រៀបធៀបដូចជា ហាក់ដូច ឬហាក់ដូចជា ...នោះទេ។ បំរៀបន័យមានច្រើនយ៉ាងដូចជា បំរៀបន័យផ្តួច(ដូច) បំរៀបន័យផ្តប់(បង្កប់) ... ។

ឧទាហរណ៍ :

- មេឃស្រកានាគ គឺមានន័យថា មេឃមានដុំពពកនិងមានរូបរាងដូចស្រកាធំៗដែលប្រៀបបាននឹងស្រកានាគ។ ប៉ុន្តែកវីនិពន្ធមិនប្រើ ដូច ដូចជាស្រកានាគនោះទេ គឺគេប្រើ "មេឃស្រកានាគ" តែម្តង។
- ជើងភ្នំ គឺមានន័យថា ជាផ្នែកខាងក្រោមនៃភ្នំដូចជាអវយវៈខាងក្រោមរបស់មនុស្សដែលហៅថា "ជើង" ដែរ។
- ភ្នំឆ្ពឹង គឺមានន័យថា ឆ្ពឹងច្រើនគរជាគំនរខ្ពស់ដូចភ្នំ។
- មនុស្សធម៌បង់បាត់ ខ្លួនមនុស្សចិត្តសត្វ លែងស្គាល់ប្អូនបង
  ជាតិជាមួយគ្នា ប្រហារចាប់ចង ចិត្តពាលយង់ឃ្នង
  មោហ៍បាំងជុំជិត។ (មើលផែនដីខ្មែរ)

កវីប្រើ "ខ្លួនមនុស្សចិត្តសត្វ"តែម្តង ដែលមានន័យថា "ខ្លួនមនុស្សចិត្តដូចសត្វ"តែកវីមិនប្រើចំណងធៀបទេ។

បំរៀបន័យ ឬមេតាផរ គឺជាទំហៀបដោយគ្មានប្រើសំនួនប្រៀបធៀប ដូច ដូចជា។ល។

លំហាត់

១. ចូរអានអត្ថបទដកស្រង់ខាងក្រោមហើយគូសបន្ទាត់ពីក្រោមពាក្យដែលបញ្ជាក់ពី "មេតាផរ"
រថភ្លើងបោលលឿនដូចព្យុះកាត់ព្រៃផ្តួង និងព្រៃព្រេច រត់ឆ្លងអូរហើយពុះជ្រែកជើងភ្នំដោយបញ្ចេញសន្ធឹកខ្ទំរំពងធ្វើឱ្យរញ្ជួយផែនពសុធា។.បើគេសម្លឹងតាមបង្ហួចនៃទូរថភ្លើងណាមួយគេនឹងបានឃើញ កម្រាលព្រំបៃតងលាតសន្ធឹងដាច់កន្ទុយភ្នែកនារដូវវស្សា។

២. ចូរអ្នកជ្រើសរើសពាក្យឬឃ្លាខាងក្រោមដែលបញ្ជាក់ពី មេតាផរ
ក្អែកខ្មៅរលោង សដូចសំឡី ក្បាលជ្រោយ សមុទ្រមេឃា ម្រាមដូចបន្លាក្រូច ចិត្តស្រាលដូចសំឡី ចង្កេះភ្នំ មាត់កំភ្លាញ ស្ទឹងឈាម ជើងជណ្តើរ សមុទ្រទុក្ខ។

៣. ចូរអ្នកតែងកថាខណ្ឌមួយដែលរៀបរាប់ពីសម្រស់ធម្មជាតិ ដោយប្រើប្រាស់មេតាផរ ឬបំរៀបន័យឱ្យបាន ៥ទៅ ៧បន្ទាត់។

វាក្យបញ្ញត្តិ : ចួន ផ្ចួន រណ្តំ

ក្នុងមេរៀននេះអ្នកនឹងសិក្សាឡើងវិញអំពីពាក្យចួន ផ្ចួន រណ្តំដែលកវីប្រើនៅក្នុងកំណាព្យ ។

ពាក្យចួន គឺជាពាក្យទាំងឡាយដែលមានព្យាង្គកើតឡើងដោយកវីប្រើសូរស្រៈនិងព្យញ្ជនៈប្រកបដូចគ្នាទៅតាមបទនីមួយៗ ។

ឧទាហរណ៍ :

មើលដងទំនងព្រៃស្រងាត់ ដូចបងព្រាត់បាត់ពៅពិសី
សុក្រមក្រំចិត្តប្រពន្ធប្តី ឆ្នូនស្រីដូចស្រីស្រស់ឆោមឆាយ ។

- ព្យាង្គទី ៧ នៃឃ្លាទី ១ ចួននឹងព្យាង្គទី ៤ នៃឃ្លាទី ២ ។
- ព្យាង្គទី ៧ នៃឃ្លាទី ២ ចួននឹងព្យាង្គទី ៧ នៃឃ្លាទី ៣ ហើយព្យាង្គទី ៧ នៃឃ្លាទី ៣ ចួននឹងព្យាង្គទី ២ ឬទី ៤ នៃឃ្លាទី ៤ ។

ចួនក្នុងវគ្គ គឺការចួននៃព្យាង្គពីរដែលចួនគ្នានៅក្នុងវគ្គតែមួយឬដែលចួនគ្នាពីឃ្លាមួយទៅឃ្លាមួយទៀតនៃវគ្គតែមួយ ។

ចួនឆ្លងវគ្គ គឺការចួននៃព្យាង្គពីរដែលចួនគ្នា ឆ្លងពីវគ្គមួយទៅវគ្គមួយទៀត ។

ឧទាហរណ៍ :

មើលមានជ្រៃជ្រែសង្កែថ្ងាន់ ត្រៀលត្រសក់ក្រវាន់គុយស្រគំ
ស្រឡីស្រឡៅក្របៅក្ងួត ទ្រនំអារអូដ្ឋចង្ហរត្នាត ។
ដង្កោទ្រយីងខ្ទីងក្រសាំង អំពិលភ្លងភ្លាំងទាំងភ្លូបាត
គូលេនទុរេនមៀនលាំងសាត មាក់បាតបង្គៅព្នៅចាន់ចារ ។

ផ្ចួន ជាការដែលកវីជ្រើសរើសពាក្យ ឃ្លាកាព្យមកប្រើច្រើនដង ។ ការផ្ចួននេះជាវិធីដែលកវី ប្រើដើម្បីសង្កត់ន័យ លើគំនិតណាមួយឬបង្កើតសញ្ចេតនាអ្វីមួយ ។

ឧទាហរណ៍ :

ត្រីក្រាញ់រលេញដេញត្រីក្រុស ត្រីក្រឹមក្រាបចុះឈប់បង្ហង់
ត្រីក្រាយហែលក្រោយបណ្តោយត្រង់ ត្រីក្រឹមវិលវល់ក្រោមត្រីក្រាយ ។

រណ្តឹ គឺកវីអាចប្រើព្យញ្ជនៈតែមួយឬស្រៈតែមួយច្រើនដងក្នុងឃ្លាឬវគ្គ ។
រណ្តឹមាន រណ្តឹព្យញ្ជនៈនិងរណ្តឹស្រៈ គឺជាការប្រើព្យញ្ជនៈដដែលៗឬស្រៈដដែលៗក្នុងឃ្លាឬវគ្គ ។

- រណ្តឹព្យញ្ជនៈ "ក" ក្នុងវគ្គខាងលើមានពាក្យ ក្រាញ ក្រុស ក្រឹម ក្រាប ក្រាយ ក្រោយ ។
- រណ្តឹស្រៈមានពាក្យ លេញ ដេញ ។

លំហាត់

១. ចូររកព្យាង្គចួនក្នុងវគ្គខាងក្រោម ៖
ឧបករណ៍ភ្លេងខ្មែរមានច្រើនមុខ រៀបចំដាក់ទុកប្រមូលផ្តុំ
ច្រៀងរាំដេញដំគោះកូតផ្តុំ គឺយើងចេះផ្សុំទើបពីរោះ ។

២. ចូររកព្យាង្គផ្ញនក្នុងវគ្គខាងក្រោម ៖
កំពីសតោងឫសកំពឹងពួយ កំពតស្មុះស្មួយស្មាក់ពីឆ្ងាយ
ពើបពះពានលើកំពូលបាយ កំពុងវាត់វាយកំពីសពង ។

៣. ចូររកព្យាង្គរណ្តឹក្នុងវគ្គខាងក្រោម ៖
កញ្ជុះស្មុះចឹកកញ្ជាក់ស្លា ត្រីឆ្លាំងហែលឆ្លារវត់ឆ្ងាយ
អណ្តែងអណ្តើកអណ្តែតកាយ ក្លាំងហាយហែលលាយនឹងក្លាំងហាត ។

វិឫកបញ្ញត្តិ : កាព្យមាត្រ

អ្នកធ្លាប់បានសិក្សារួចមកហើយអំពីកំណាព្យខ្មែរ។ ធាតុសំខាន់ៗនៃកំណាព្យ គឺរង្វាស់កាព្យឬកាព្យមាត្រ ចំណាប់ចួន ផ្ទួន រណ្តំ និងបរិយាកាស។

តើកាព្យមាត្រជាអ្វី ? កាព្យមាត្រគឺជាការរាប់ចំនួនព្យាង្គនៅក្នុងឃ្លានិងការរាប់ចំនួនឃ្លានៅក្នុងវគ្គ ទៅតាមបទនីមួយៗ។

ឧទាហរណ៍ :

មួយភ្លេងពិណពាទ្យមានឧបករណ៍	ឈឹងនិងសំគោរនាតប៊ី
គងរង់តូចធំនិងស្គរជ័យ	ហើយថែមស្រឡៃអ្នកនាំមុខ។

ឧទាហរណ៍ខាងលើនេះជាបទពាក្យ ៧ដែលមាន :

- ក្នុង ១វគ្គមាន ៤ឃ្លា។
- ក្នុង ១ឃ្លាមាន ៧ព្យាង្គជាទៀងទាត់គ្រប់វគ្គ។

លំហាត់

ចូររាប់ចំនួនព្យាង្គនៅក្នុងឃ្លា និងចំនួនឃ្លានៅក្នុងវគ្គនៃអត្ថបទកាព្យដកស្រង់ខាងក្រោម :

បទពាក្យ ៧

១. ទ្រខ្មែរខ្សែបីនិងសាដៀវ	សម្រើបស្រើបស្រៀវបទបំពេរ
ពីរោះស្រណោះអ្វីម្ល៉េះទេ	នៅដោយស្រុកគេនឹកស្រុកឯង។
បួនគ្រឿងឧបករណ៍ភ្លេងខ្ពុយប៊ី	របាំស្រីៗដែលសម្តែង
ថ្វាយព្រះរាជានៅនាល្ងែង	ប្រាសាទកន្លែងព្រះអង្គគង់។

(ឧបករណ៍ភ្លេងខ្មែរ លោក សួនប្រង់)

បទបន្ទោលកាក

២. ថ្លែងដោយទំនង	ដំណើរត្រីផងយាត្រា
ពើបនឹងជុចណា	ត្រីស្រែកថារើយចៀសចេញ។
ជុចថាអះអើ	បុណ្យអ្នកនេះតើម្តេចមិញ
ក៏មកប្រើអញ	ចៀសចេញឱ្យអ្នកជាល្បែង។
ត្រីថាបើទ្មោះ	អញនឹងទំលុះចៅឯង

ឱ្យយល់ជាក់ស្តែង ត្បិតឯងមកនៅរាំងផ្លូវ ។
ជុចថាអើហោង បើខឹងចង់លងឥឡូវ
នេះហើយសមត្រូវ នឹងម្ហូរប្រហើរសាអាំង ។

(សាស្ត្រា ល្បើកជុចនិងត្រី របស់លោក វិសេស ដួង)

បទភុជង្គលីលា

៣. ហៃកូនស្រីស្ងួនមាសម្តាយ ក្រណាស់នាងអាយ តាមដោយច្បាប់ស្រី ។
ក្រមួយមិនបានសម្តី ពាក្យទន់តិចនៃ ឱ្យញាតិចូលចិត្ត ។
ក្រមួយមិនចេះរិះគិត ឃើញញាតិឆ្ងាយជិត ហៅឡើងឆីស្លា ។
ទោះមានមិនមានក្តីណា ពាក្យផ្អែមចរចា ទើបគេស្រលាញ់ ។
កុំជួចិត្តស្ទូរកំណាញ់ មិនមានអស់អញ នឹងញាតិសន្តាន ។
កើតយសរបស់ផងបាន កើតសុខក្សេមក្សាន្ត ពីព្រោះកូនស្រី ។

(ច្បាប់ស្រីរបស់ បណ្ឌិត ម៉ឺន មៃ)

បទព្រហ្មគីតិ

៤. រៀនបទរៀនបាទថាស កុំក្រឡាសលើរៀមច្បង
ស្រដីនឹងអ្នកផង ពាក្យឱ្យគួរកុំឯងវី ។
អឺអើអញដាច់សាច់ ឆ្គងពាក្យពេចន៍គេស្រដី
ដើមដៀលឱ្យអប្រិយ ស្រដីថាកូនអត់ពូជ ។
ចាស់ទុំមិនប្រដៅ ជេរកូនចៅទើបវាខូច
គេថាកូនអត់ពូជ មិនដឹងច្បាប់នឹងចាស់ទុំ ។
គេដៀលដល់ម៉ែឪ កេរ្តិ៍អាស្រូវស្ទួយរហ៊ឹម
គេស្តីដើមដៀវដុំ ដំនៀលនោះមកដល់ចាស់ ។

(ច្បាប់ប្រុសរបស់បណ្ឌិតម៉ឺន មៃ)

បទកាកគតិ

៥. បើចង់ស្រាលខ្លួន រៀនសូត្រឱ្យមួន ឱ្យមាំឱ្យស្ទាត់
កុំចេះស្ងាក់ស្ទើរ ល្ងីល្ងើឥតបទ បើចេះប្រាកដ
ប្រាក់រត់តាមហៅ ។

(ច្បាប់ល្បើកថ្មី របស់ក្រមង៉ុយ)

ឧត្តមភាពជាតិខ្មុំ



ក. សិក្សាពាក្យគន្លឹះ

- វរ្ម័ន (ន) : ព្រះបរមនាម ឬគោរមនៃព្រះបរមព្រះមហាក្សត្រសម័យកម្ពុជរដ្ឋ សម័យមហានគរ ។
- សីមា (ន) : ទីមានព្រំកំណត់ ព្រំដែន ព្រំប្រទល់ ។
- បុត្រភ្លា (ន) : បុត្រដ៏ល្អប្រសើរ ថ្លៃថ្លា ជាទីស្រឡាញ់ ។
- សោភា (គុ) : ដែលល្អ ហ្មត់ហ្មង ភ្លឺត្រចះត្រចង់ ។
- ទិវង្គត (កិ) : លាចាកលោក (ស្លាប់) ។
- រាស្ត្រ (ន) : ប្រជាជន ។
- រាជវង្ស (ន) : វង្សត្រកូលព្រះរាជា ។
- បេតិកភណ្ឌ (ន) : ទ្រព្យសម្បត្តិឬកេរមរតកមានជាប់ជាតំណតាំងពីដូនតា ។
- ភ័ន្ត (ន) : ការយល់ច្រឡំ ។
- សុគត (កិ) : ស្លាប់ មរណៈទៅកើតឋានដែលល្អហើយ ទៅហើយដោយស្រួល ។
- សតវត្សរ៍ (ន) : មួយរយឆ្នាំ ។
- គម្ពីរ (ន) : សាស្ត្រា ច្បាប់វិន័យ ។

- ញាតិ (ន) : អ្នកដែលរួមខ្សែលោហិតនឹងគ្នាខាងមាតា ឬបិតាហៅថាញាតិសន្តាន ។
- ឯករាជ្យ (ន) : ភាពជាម្ចាស់លើប្រទេសខ្លួន ។
- ប្រវ៉ាំង (ន) : ការបោកបញ្ឆោត ការបោកប្រាស់ ការឆបោក ។

ខ. អភិវឌ្ឍន៍បំណិន

នៅពេលដែលអ្នកបានអានអត្ថបទកាព្យខាងក្រោម សូមអ្នកអានដោយយកចិត្តទុកដាក់ ដើម្បីត្រៀមឆ្លើយសំណួរមួយចំនួនទាក់ទងខ្លឹមសារ អត្ថន័យនៃកំណាព្យ ពាក្យចួន ផ្ទួនរណ្តំ កាព្យមាត្រ ការប្រាប់ពីអារម្មណ៍ដែលបង្ហាញក្នុងកំណាព្យ មេតាផរ និងតម្លៃអប់រំឱ្យបានត្រឹមត្រូវ ។

គ. អត្ថបទ

កាលនោះ[(១)]ដីខ្មែរធំល្វឹងល្វើយ កូនចៅខ្មែរអើយកុំខ្ជីខ្ជា
ស្តេចខ្មែរខ្លាំងណាស់ឥតគណនា កម្រជាតិណាផ្ទឹមរាជា ។
ខាងកើតដីខ្មែរទល់ស្រុកចាម ខាងលិចហួសសៀមទល់ភូមា
ខាងជើងទល់ចិនណាបុត្រភ្លា ខាងត្បូងសោភាទល់សមុទ្រ ។
ស្តេចខ្មែរខំថែប្រមូលផ្តុំ ពង្រីកឱ្យធំគ្មានតក់ស្លុត
ទុកឱ្យកូនចៅកម្ពុជបុត្រ សាងឈ្មោះល្អផុតឱ្យគង់វង្ស ។
មុនព្រះអង្គចូលទិវង្គត បណ្តាំមួយគត់ចាំឱ្យគង់
មិនថាប្រជាឬរាជវង្ស កុំស្តេចទ្រទ្រង់បេតិកភណ្ឌ ។
សម្បត្តិបេតិកភណ្ឌខ្មែរ ច្រើនមិនតិចទេកុំភាំងភ័ន្ត
ប្រយ័ត្នខ្មាំងចូលមករកប្លន់ ការពារឱ្យទាន់កុំឱ្យស្លាត់ ។
ព្រះបណ្តាំនេះពិតជាត្រូវ ទ្រង់សុគតទៅមួយសតវត្សរ៍
ខ្មាំងសៀមវាយលុកចូលឡោមព័ទ្ធ យកនគរវត្ត អង្គរធំ ។
មួយពាន់បីរយហាសិបបី ទ័ពសៀមហាក់បីប្រមូលផ្តុំ
លុកលុយអង្គរតូចនិងធំ ដឹកគម្លឹរធំចេញទៅក្រៅ ។
សៀមត្រួតកម្ពុជាបានបួនឆ្នាំ កូនខ្មែរចងចាំអស់ញាតិជៅ
ទ័ពសៀមសាមាន្យចិត្តយោរយៅ ខ្មែរចងចាំនៅពុំភ្លេចអើ ។

---

(១) : រជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧

សៀមថៃហុតទឹកសម្លឹងកាក
តែកុំច្រឡំសៀមឬថៃ
សតវត្សរ៍ទីដប់ប្រាំបួន
សៀមចូលលូកដៃឥតរអែង
មកដល់សង្គ្រាមលោកទីពីរ
បារាំងខ្មែរខ្វល់សៀមរំអួយ
បាត់ដំបង សៀមរាប កំពង់ធំ
ដប់ប្រាំបួនសែប្រាំមួយគន់
ពេលខ្មែរកំពុងខ្វល់ខ្វាយខ្លាំង
ប្រគល់ឯករាជ្យខ្មែរឱ្យពេញ
ដូច្នេះសូមខ្មែរប្រុងប្រយ័ត្ន
នាំគ្នាសាមគ្គីកុំខ្ចីខ្ចា

ខ្មែរស្តោះខ្មែរខាកសៀមធ្វើហឺ
សម្លឹងទឹកដីខ្មែរឥតក្រែង ។
ខ្មែរយើងភ្លេចខ្លួនឈ្លោះគ្នាឯង
បាត់ខេត្តជាក់ស្តែងអស់ដប់មួយ ។
សៀមលេបវាតទីឥតមានព្រួយ
បានបីខេត្តជួយអាងជប៉ុន ។
ខ្មែរទ្រហោយំព្រួយពេកពន់
ទើបសៀមទោរទន់ឱ្យខ្មែរវិញ ។
ទាមទារបារាំងឱ្យថយចេញ
សៀមឆ្លៀតប្រវីញព្រះវិហារ ។
ប្រហែសត្រូវបាត់គួរម្ដីម្នា
ការពារប្រសើរជាងព្យាបាល ។

(ដកស្រង់ និងកែសម្រួលពីសៀវភៅ ពង្សាវតារកំណាព្យខ្មែររបស់លោក សួរអឿ)

សំណួរ

១. តើអត្ថបទកំណាព្យខាងលើនេះនិយាយពីអ្វី ? ជាបទអ្វី ?

២. ចូរបង្ហាញចំណាប់ចួនក្នុងវគ្គទី ១និងទី ២ខាងលើ ។

៣. ចូរគូសចំណាប់ចួននិងបង្ហាញពីកាព្យមាត្រក្នុងវគ្គទី ១និងទី ២ ។

៤. ចូរពន្យល់ន័យនៃពាក្យ"លូកដៃ""លេប"ក្នុងអត្ថបទកាព្យ ។

៥. ចូររកមេតាផរក្នុងអត្ថបទកំណាព្យខាងលើ ។

៦. ចូរពន្យល់ពាក្យស្លោក"ការពារប្រសើរជាងព្យាបាល"

៧. តើអ្នកមានចំណាប់អារម្មណ៍ដូចម្តេច ចំពោះអត្ថបទកំណាព្យខាងលើនេះ ?

៨. តើអត្ថបទកំណាព្យខាងលើនេះមានតម្លៃអប់រំដូចម្តេចខ្លះ ?

កម្ពុជាមាតុភូមិជាទីស្នេហា





ក. សិក្សាពាក្យគន្លឹះ

- កេរដំណែល (ន) : ដំណែល ជាសម្បាច់របស់ដូនតា ឬ មាតាបិតាជំនាន់ដើម ។
- ពិសិដ្ឋ (គុ) : ដែលល្អក្រៃលែង ដែលប្រសើរខ្ពង់ខ្ពស់ផ្លែផ្ការបំផុត ។
- អនេក (គុ) : ដែលច្រើនលើសលប់ ក្រៃលែង ឥតគណនា ។
- បុរី (ន) : ក្រុង រដ្ឋមណ្ឌល ។
- មច្ឆ (ន) : ត្រី ។
- គីរី (ន) : ភ្នំ ។
- បព្វតា (ន) : ភ្នំ ។
- ម្រឹគីម្រឹគា (ន) : ពួកសត្វចតុប្បាទព្រៃញីឈ្មោល មានសីហៈ ខ្លា ឈ្លូស ប្រើស ។ល ។
- ពុទ្ធសាសនិក (ន) : អ្នកកាន់ព្រះពុទ្ធសាសនា ។
- រចនា (កិ) : លម្អ តុបតែងលម្អឱ្យល្អ ។

- ស្ថាបត្យករ (ន) : អ្នកស្ថាបនា អ្នកកសាង អ្នកបង្កើត ។
- ពុទ្ធរូប (ន) : រូបសំណាករបស់ព្រះពុទ្ធ ។
- មរតក (ន) : ទ្រព្យដំណែលរបស់បុគ្គលស្លាប់ ។
- មោទនភាព (ន) : សេចក្តីអំណួត ។
- ស្ងប់ស្ងែង (គុ) : ដែលគួរឱ្យកោតសរសើរ ក្រៃលែង ។
- បុព្វបុរស (ន) : បុរសសម័យដើម ។

ខ. អភិវឌ្ឍន៍បំណិន

ពេលអ្នកអានអត្ថបទខាងក្រោម សូមអ្នកយកចិត្តទុកដាក់ ត្រៀមឆ្លើយសំណួរមួយចំនួនទាក់ទងនិងសេចក្តីលម្អិត គំនិតសំខាន់នៃអត្ថបទ គំនិតសំខាន់បង្កប់ តម្លៃអប់រំ ពាក្យន័យដូច ពាក្យផ្ទុយឱ្យបានត្រឹមត្រូវ ។

ក អត្ថបទ

កម្ពុជាជាប្រទេសកំណើតរបស់យើង គឺជាទឹកដីកេរដំណែលដ៏ពិសិដ្ឋនៃដូនតា ដែលជាមហាបុរសជាតិយើងបានខិតខំការពារនិងថែរក្សាទុកឱ្យកូនខ្មែរគ្រប់ៗរូប ។

ទីនេះយើងធ្លាប់បានរស់នៅជារៀងដរាបមក ។ កម្ពុជាមាតុភូមិយើង ជាទឹកដីសម្បូរបែប ។ ប្រាសាទបុរាណដ៏ច្រើនអនេក បានក្លាយជាស្ថានីយប្រវត្តិសាស្ត្រ និងជាបុរីទេសចរណ៍ដ៏ល្បីល្បាញ ហើយត្រូវបានប្រសិទ្ធិនាមថា "កម្ពុជាព្រះរាជាណាចក្រអច្ឆរិយៈ" ។ ក្រៅពីសម្បត្តិវប្បធម៌ដ៏ល្អឆ្នើម កម្ពុជាមានធម្មជាតិស្រស់បំព្រងដូចជា ត្រពាំង បឹងបួ ស្ទឹង ព្រៃក ទន្លេ សមុទ្រ សម្បូរមច្ឆជាតិគ្រប់ប្រភេទ ។

បឹងទន្លេសាបដ៏ធំល្វឹងល្វើយ មានត្រីច្រើនជាងគេបំផុត ក្នុងចំណោមបឹងក្នុងទូទ្បលោកទាំងប្រាំ ។ វាលស្រែធំធេង ដែលមានសម្រស់ស្រស់បំព្រង ពណ៌ខៀវស្រងាត់លាតសន្ធឹងល្វឹងល្វើយដាច់កន្ទុយភ្នែក ។ ស្រូវអង្ករអាចចិញ្ចឹមជីវិតប្រជាជនកម្ពុជាបានយ៉ាងគ្រប់គ្រាន់ ។ ព្រៃព្រឹក្សាលតាវល្លិគីរីបព្វតាជាជម្រកដ៏សុកស្តម្ភនៃបក្សាបក្សី និងម្រិគីម្រិគា ។ ធ្នែធនធានដ៏មានតម្លៃកប់ក្នុងជម្រៅស្រទាប់ធរណី ។

វត្តអារាមដែលជាដួងព្រលឹងនៃពុទ្ធសាសនិកជនខ្មែរគ្រប់រូប មានស្ទើរគ្រប់ភូមិស្ថាន ។ វត្តអារាមនីមួយៗតែងមានព្រះវិហារដ៏ល្អនិងធំស្កឹមស្កៃ ដែលមានរូបចម្លាក់ក្បាច់រចនាតាមសសរ មាត់ទ្វារ មាត់បង្អួច និងតាមជញ្ជាំងគួរឱ្យគយគន់ ។ បើមើលពីចម្ងាយ គេនឹងឃើញដំបូលព្រះវិហារក្រហមឆ្អិនឆ្អៅ លម្អដោយក្បាច់រចនាដែលជាស្នាដៃស្ថាបត្យករខ្មែរយើងសុទ្ធសាធ ។ ក្នុងព្រះវិហារ

មានព្រះពុទ្ធរូបធំមានពណ៌លឿងទុំដូចមាស ដែលមានតុបតែងដោយពន្លឺភ្លើងចែងចាំងភ្លឺផ្លេក។ វត្ត អារាមនេះហើយដែលជាកន្លែងប្រជាជនខ្មែរគោរពបូជាគ្រប់ៗគ្នា។

យើងជាកូនខ្មែរមានភ័ព្វសំណាងណាស់ដោយមាតុភូមិយើងមានសម្បត្តិធនធានសម្បូរបែបនិង កេរដំណែលវប្បធម៌ដ៏រុងរឿងអស្ចារ្យមិនអាចកាត់ថ្លៃបាន។ ទឹកចិត្តយើងរំភើបប្រកបដោយភាពក្លៀវ ក្លានិងមោទនភាពក្រៃលែង។ យើងគោតស្ងប់ស្ងែងណាស់នូវបញ្ញាញាណគតិបណ្ឌិតនិងពលកម្មប្រកប ដោយគំនិតច្នៃប្រឌិតខ្ពស់ ទើបលោកអាចបង្កើតឡើងនូវស្នាដៃមហាស្ចារ្យ ហើយថែរក្សាបានគង់វង្ស ទុកឱ្យយើងឃើញរហូតមក។ យើងសូមទទួលមរតកដ៏ឧត្តុង្គឧត្តមនេះ ដោយទឹកចិត្តស្ងើចសរសើរ និង គោរពដោយស្មោះ ហើយសូមប្តេជ្ញាដើរតាមគំរូវីរភាពរបស់លោក និងបន្តរក្សាកសាងស្នាដៃថ្មីៗ សម្រាប់ជាកេរមរតកដល់អ្នកជំនាន់ក្រោយយើងផងដែរ។ ទឹកចិត្តស្នេហារបស់យើងចំពោះមាតុភូមិ ពុំអាចមានឥទ្ធិពលអ្វីមកធ្វើឱ្យរង្គោះរង្គើបានឡើយ។

សំណួរ

១. ពាក្យ "យើង" ក្នុងអត្ថបទសំដៅលើនរណា ?

២. ចូរចែកអត្ថបទជាផ្នែកៗទៅតាមគោលគំនិត ហើយរកគំនិតសំខាន់នៃផ្នែកនីមួយៗ។

៣. ចូររកល្បះដែលបង្ហាញពីឆន្ទៈនិងការប្តេជ្ញាចិត្តយ៉ាងមោះមុត។ តើអ្នកមានគំនិតស្របជាមួយ អ្នកនិពន្ធលើចំណុចសំខាន់ណាខ្លះ ? ហេតុអ្វី ?

៤. ក្នុងនាមជាសិស្ស តើសកម្មភាពអ្វីដែលកំណត់បានថាស្រឡាញ់ជាតិមាតុភូមិ ? ហេតុអ្វី ?

៥. ចូរកំណត់ន័យដូចនឹងពាក្យ : ល្បីល្បាញ ពិសិដ្ឋ ស្នេហា ផ្តល់ ថ្លៃថ្នូរ។

៦. ចូររកពាក្យផ្ទុយនឹងពាក្យ : រស់ ល្អ បុរាណ ច្រើន ស្តើមស្តែ រុងរឿង។

๑ ចម្រៀងប្រជាប្រិយ



ចម្រៀងប្រជាប្រិយ គឺជាចម្រៀងមួយប្រភេទដែលមានកំណើតតាំងពីសម័យដើមមកម្ល៉េះ។ ចម្រៀងប្រជាប្រិយ គឺជាព្រលឹងរបស់ប្រជាជាតិមួយ ហើយក៏ជាកញ្ចក់មួយឆ្លុះបញ្ចាំងនូវផ្នត់គំនិតរបស់ប្រជាជន ដែលអាចឱ្យគេយល់បាននូវចំណង់ចំណូលចិត្ត សេចក្តីព្យាយាម ការតស៊ូ សេចក្តីសប្បាយរីករាយនិងការប៉ងប្រាថ្នារបស់ប្រជាជន។ ចម្រៀងប្រជាប្រិយខ្មែរបានលាតត្រដាងនូវមនោសញ្ចេតនាការគោរពបុព្វបុរសជាតិ សភាពទន់ភ្លន់នៃប្រពៃណី ទំនៀមទម្លាប់ជាតិ ជីវភាពប្រជាជន ជាពិសេសកសិករ ស្ថានភាពប្លែកៗនៃគ្រួសារ និងទឹកចិត្តជាប់ជំពាក់យ៉ាងជ្រាលជ្រៅទៅលើមាតុភូមិ បរិយាកាសរីករាយក្នុងការងារ ឬសុខទុក្ខក្នុងគ្រួសារនិងសង្គម។ ចម្រៀងប្រជាប្រិយមានច្រើនប្រភេទ ច្រើនបទដូចជា បទបេះស្លឹកមន បទនាងបុកស្រូវ បទនាងស្លកុក បទអុំទូក បទបំពេចៅ។ល។ ឥឡូវនេះចូរប្អូនស្តាប់ដោយយកចិត្តទុកដាក់ លោកគ្រូអ្នកគ្រូប្អូននឹងច្រៀងចម្រៀងបទ "អុំទូក" ឱ្យប្អូនស្តាប់។

សំណួរ

១. តើចម្រៀងនេះនិយាយពីអ្វី ?

២. តើចម្រៀងនេះមានអត្ថន័យនិងតម្លៃអប់រំដូចម្តេច ?

៣. តើនៅក្នុងបទចម្រៀងនេះមានបង្ហាញលក្ខណៈនៃកំណាព្យត្រង់ចំណុចណាខ្លះ ?

៤. តើអ្នកយល់ថាអត្ថន័យនៃបទចម្រៀងនេះស្តែងចេញនូវមោទនភាពជាតិដូចម្តេចខ្លះ ?

បកស្រាយអត្ថន័យសុភាសិត

ក្នុងមេរៀននេះ អ្នកនឹងសិក្សាពីការនិយាយបកស្រាយសុភាសិត។ សុភាសិតជាពាក្យបានមកពីបាលី "សុ" ប្រែថាល្អ ផ្សំនឹង "ភាសិត" ប្រែថាសម្តីឬពាក្យ។ មានន័យថាពាក្យដែលពោលពីរោះដែលនិយាយត្រូវ ដែលថាត្រូវ។ ដូចនេះសុភាសិត គឺជាប្រភេទអត្ថបទខ្លីតែច្រើនមានន័យពីរ គឺន័យត្រង់និងន័យបង្កប់(មានតែមួយឃ្លា ពីរឃ្លា) ច្រើនជាពាក្យចួនដែលមានខ្លឹមសារទូន្មាន ប្រៀនប្រដៅ ដើម្បីឱ្យមហាជនទូទៅស្រួលស្តាប់និងងាយចងចាំ។ សុភាសិត គឺជាពាក្យពីរោះ ពាក្យត្រូវ ឬឱវាទត្រឹមត្រូវដែលមានប្រយោជន៍គួរឲ្យ គួរស្តាប់និងយកទៅអនុវត្តតាមកាលៈទេសៈ។ ជួនកាលខ្មែរយើងសម្គាល់ដោយពាក្យ "ភាសិតឬស្លោក"។

ការនិយាយបកស្រាយ សុភាសិតគឺយើងត្រូវយល់ន័យពាក្យនីមួយៗក្នុងភាសាខ្មែរ និងបរិបទសង្គម ទើបយើងអាចយល់អត្ថន័យរបស់សុភាសិតនីមួយៗបាន។

បុព្វបុរសខ្មែរយើងបានប្រើវិធីបង្កើតសុភាសិត និងការបកស្រាយតាមវិធីពីរយ៉ាង ៖

១ . តាមន័យចំឬអត្ថានុរូប

ជាន័យបង្ហាញដោយចំត្រង់ៗមិនបញ្ឆិតបញ្ឆៀងឬជាន័យដែលមិនឃ្លាតពីន័យដើម។

ឧទាហរណ៍ :

ច្រើនមកពីតិច	ដោយចម្រើនកិច្ច	ខាងការសន្សំ
ដូចប្រឡាយតូច	ក្លាយជាស្ទឹងធំ	ហូរច្រាសច្រោះចំ
	ឃ្លរវិតធំសាយ។	

- ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ
- ចេះមកពីរៀន មានមកពីរក
- ចំណីច្រើនមុខ ច្រើនពិសា កូនច្រើនបា ច្រើនល្ហ។

២ . តាមន័យឆ្ងៀបឬអត្ថបដិរូប

ជាន័យដែលគេត្រូវនិយាយបកស្រាយ ដោយមិនចំគឺនិយាយបែបបញ្ឆិតបញ្ឆៀងពីន័យដើមឬន័យត្រង់។ ម្យ៉ាងទៀត អ្នកក៏ធ្លាប់បានស្គាល់ន័យធៀបខ្លះៗកន្លងមកហើយដែរ នៅក្នុងបំរៀបន័យឬមេតាផរ ទំហៀបន័យឬឧបមានជាដើម។

ឧទាហរណ៍ : "ឆើយស្កក ឱនដាក់គ្រាប់"

- **ន័យចំ :** សុភាសិតនេះសំដៅទៅលើស្រូវនៅពេលទុំ។ កួរស្រូវណាដែលមានដើមនិងផ្លែឈរត្រង់ទៅលើគឺគ្មានគ្រាប់ គ្មានសាច់ គេហៅថា"ស្កក"ហើយគ្មានប្រយោជន៍ថែមទៀតផង។ ចំណែកឯកួរស្រូវដែលឱនចុះក្រោមមានទម្ងន់គឺមានសាច់ មានគ្រាប់អង្ករពេញផ្លែ គឺជាស្រូវដែលល្អ ដែលមានប្រយោជន៍ដល់អ្នកជាំ។
- **ន័យធៀប :** សុភាសិតនេះសំដៅលើការប្រដូចទៅនឹងមនុស្ស។ មនុស្ស "ឆើយស្កក" ប្រើសម្រាប់សម្គាល់មនុស្សដែលមានឫកពា ក្រអើតក្រទម ច្រឡើសបឹស មិនចេះគួរសម មិនចេះគោរពឱនលំទោនចំពោះចាស់ទុំ ពោលគឺគ្មានសីលធម៌ មានឫកឆ្មើងឆ្មៃ... ។ "ឱនដាក់គ្រាប់" ប្រើសម្រាប់មនុស្សមានសុជីវធម៌ មានកិរិយាមារយាទល្អ សុភាពរាបសា ទន់ភ្លន់ ថ្លៃថ្លូរ ប្រកបដោយគុណតម្លៃ មានគេស្រឡាញ់រាប់អាន និងជាមនុស្សមានប្រយោជន៍ចំពោះសង្គមថែមទៀតផង។

លំហាត់

ចូរប្តូនចាប់ដៃគូក្នុងក្រុមពីរៗនាក់ រួចជ្រើសរើសប្រធានបទនៃសុភាសិតដូចខាងក្រោមណាមួយដែលក្រុមពេញចិត្ត ហើយឡើងនិយាយបកស្រាយម្តងមួយក្រុមៗបង្ហាញគ្នាទៅវិញទៅមក :

១. តក់ៗ ពេញបំពង់ ឆុងៗកន្លះគ្រែហែត។

២. ចង្កឹះមួយបាច់កាច់មិនបាក់។

៣. ចេះដប់មិនស្មើនឹងប្រសប់មួយ។

៤. អូសទូកកុំឱ្យល្ហាន ចាប់ត្រីបានកុំឱ្យល្អក់ទឹក។

៥. ធ្វើស្រែចម្ការឱ្យមើលស្មៅ ទុកដាក់កូនចៅមើលផៅសន្តាន។

៦. ធ្វើទីលំនៅ មើលភូមិស្ថាន បរិភោគប្រមាណមើលអាហារ។

៧. សន្សឹមៗកុំបំបោល ក្រែងពុំដល់ដូចប្រាថ្នា។

៨. វិជ្ជានិងវ័យមនុស្ស មិនគួរឱ្យខុសជំនាន់គ្នា
វ័យច្រើនត្រូវចម្រើនវិជ្ជា ទាំងពីរស្មើគ្នាទើបប្រពៃ។

៩. វែងផុតត្រឹមពាក្យសំដី ខ្លីផុតត្រឹមមិននិយាយ។

១០. យល់ឆ្ងាយកុំណាយគិត ទោះយល់ជិតកុំណាយខំ
មិនជាក់មើលឱ្យចំ ក្រែងច្រឡំ សជាខ្មៅ។

អត្ថបទកំណាព្យ

ប្អូនធ្លាប់សិក្សារួចមកហើយអំពី ពាក្យចួន ផ្ទួន រណ្តំ និងកាព្យមាត្រដែលមានក្នុងកំណាព្យបទផ្សេងៗដូចជា បទកាកគតិ បទភុជង្គលីលា បទព្រហ្មគីតិ បទពំនោល បទពាក្យ ៧ ។ល។

ក្នុងមេរៀននេះ ប្អូននឹងហាត់តែងកំណាព្យបទពាក្យ ៧ ។

ចូរប្អូនអាននិងសូត្រកំណាព្យខាងក្រោម ៖

- កម្ពុជាតូចពិតតែសម្បត្តិមាន　　មានគ្រប់ធនធានសម្បូរផល
  ផលរ៉ែព្រឹក្សទឹកសុទ្ធតែផ្តល់　　ផ្តល់សត្វចល់ក្នុងព្រៃឈើ ។
- ឈើធំភ្នំខ្ពស់ជ្រោះជាមេ　　មេគង្គទន្លេនាំល្បាប់លើ
  លើសលប់វាលស្រែចម្ការធ្វើ　　ធ្វើផ្តល់ផលលើលើសអស់ដី ។
- ដីក្នុងមានថ្មកំបោររ៉ែ　　រ៉ែត្បូងដែកដែរប្រេងកាតល្បី
  ល្បីទន់ឡាបស៊ើជាមេត្រី　　ត្រីទឹកសាបល្បីធម្មជាតិកេរ ។
- កេរកោះសម្បត្តិលទ្ធកម្មស្នែង　　ស្នែងស្បែកោតក្រែងចិត្តបិតថេរ
  ថេរបេតិកភណ្ឌសល់ជាសដេរ　　ដេរជាសជាកេរខ្មែរប្រុសស្រី ។
- ស្រីប្រុសឧស្សាហ៍ការកសាង　　សាងពាន់ប្រាប្រាង្គជាស្នាថ្មី
  ថ្មីសាងវាវីធានីល្បី　　ល្បីកសិកម្មដីខ្មែរស្រឡាញ់ ។

(ដកស្រង់ពី "កំណាព្យខ្មែរ" ភាគ ២ ក្រសួងអប់រំ ឆ្នាំ ១៩៨៥ ទំព័រទី ៤-៥)

- **គំនូសតាងចំណាប់ចុងចួន :**



- ចំណាប់ចុងចួន :

  ចួនក្នុងវគ្គ :

  - ព្យាង្គទី ៧ ឃ្លាទី ១ វគ្គ ១ ចួននឹងព្យាង្គទី ២ ឬទី ៤ ឃ្លាទី ២ វគ្គ ១
  - ព្យាង្គទី ៧ ឃ្លាទី ២ វគ្គ ១ ចួននឹងព្យាង្គទី ៧ ឃ្លាទី ៣ និងព្យាង្គទី ២ឬទី ៤ ឃ្លាទី ៤ គ្រប់វគ្គ ។

  ចួនឆ្លងវគ្គ :

  - ព្យាង្គទី ៧ ឃ្លាទី ៤ វគ្គទី ១ ចួននឹងព្យាង្គទី ៧ ឃ្លាទី២ វគ្គ ២ ។

លំហាត់

១. ចូរប្អូនតែងអត្ថបទកំណាព្យបទពាក្យ ៧ឱ្យបានចំនួន ៥វគ្គដែលទាក់ទងប្រធានបទ "មោទនភាពជាតិខ្មែរ"

២. មុនពេលប្អូនតែងប្អូនត្រូវធ្វើសំណៅព្រាងនិងអនុវត្តតាមលំណែនាំដូចខាងក្រោម ៖

- កំណត់ប្រធានបទ ឱ្យទាក់ទងនឹងប្រធានបទ "មោទនភាពជាតិខ្មែរ" ។
- កំណត់គំនិតសំខាន់ៗទាក់ទងឬស្របប្រធានបទយ៉ាងហោចណាស់បានចំនួន ៥វគ្គ ។
- អនុវត្តទៅតាមក្បួនតែងកាព្យបទពាក្យ ៧បានត្រឹមត្រូវ តាំងពីការចាប់ចុងចួន ផ្ទួន រណ្តំ (ការចួនក្នុងវគ្គ និងចួនឆ្លងវគ្គ) ។
- រៀបចំសំណេរទៅតាមលំដាប់គំនិត និងលំដាប់ខ្លឹមសារ តាំងពីការផ្តើមសេចក្តី តួសេចក្តី និងការបញ្ចប់ ។
- មានការប្រើប្រាស់សញ្ញាសម្ព័ន្ធវេយ្យាករណ៍ ពិសេសការប្រើប្រភេទនាមរួបី នាមអរូបីនៅក្នុងសំណេរផ្ទាល់ខ្លួនឱ្យបានត្រឹមត្រូវ ។
- កែលម្អសំណៅព្រាងឱ្យបានល្អ ផ្ចិតផ្ចង់កុំឱ្យមានកំហុសអក្ខរាវិរុទ្ធ និងសរសេរសម្រេចបានល្អដើម្បីឡើងបង្ហាញ ។

មេរៀនទី

ការទទួលស្គាល់ការពិត

ការទទួលស្គាល់ការពិត គឺជាការទទួលស្គាល់អ្វីទាំងអស់ដែលកើតមានពិត។ យើងត្រូវហ៊ានទទួលស្គាល់រាល់អំពើឬសកម្មភាពឬព្រឹត្តិការណ៍ដែលបានកើតឡើងពីអតីតកាលឬបច្ចុប្បន្នកាលទោះបីអំពើនោះល្អក្តីឬអាក្រក់ក្តី។ ការហ៊ានទទួលស្គាល់បែបនេះនឹងធ្វើឱ្យសង្គមមានការរីកចម្រើន និងមនុស្សរស់នៅប្រកបដោយភាពសុខដុម ព្រោះបើយើងទទួលស្គាល់អ្វីមួយជាអំពើល្អ នោះយើងនឹងរក្សាទុកជាបទពិសោធល្អសម្រាប់ប្រព្រឹត្តទៅទៀត។ ផ្ទុយទៅវិញ បើយើងទទួលស្គាល់អ្វីមួយជាអំពើអាក្រក់នោះយើងនឹងចៀសវាងមិនប្រព្រឹត្តឡើយ។ ការទទួលស្គាល់ការពិត គឺជាគុណធម៌មួយយ៉ាងល្អប្រពៃសម្រាប់មនុស្សគ្រប់រូប។

មេរៀននេះ អ្នកនឹងបានសិក្សាអំពីបំណិនមួយចំនួនដូចជា ធាតុសំខាន់ៗនៃរឿង(ការផ្តើមរឿង តួរឿងឬដំណើររឿង និងការបញ្ចប់រឿង) នាមករណ៍ នាមការក៍ និងសញ្ញាក្បៀសបើកបិទ ការនិយាយនិងសំណេរដោយប្រើសង្ឃសព្ទនិងរាជសព្ទ។

ទម្រង់និងធាតុសំខាន់ៗនៃរឿង

ប្រលោមលោក រឿងព្រេង រឿងបែបពុទ្ធនិយម និងរឿងបែបព្រាហ្មណ៍និយមក្តីសុទ្ធតែមានទម្រង់និងធាតុផ្សេងៗគ្នា ហើយប្រភេទរឿងនីមួយៗតែងមានលក្ខណៈពិសេសដោយឡែកៗពីគ្នាតាំងពីចំណុចផ្តើមរឿង តួរឿងរហូតដល់ចំណុចបញ្ចប់នៃរឿង ។

ក. ការផ្តើមរឿង

វិធីផ្តើមរឿងអាស្រ័យទៅតាមចលនាអក្សរសិល្ប៍ ៖

- អក្សរសិល្ប៍ព្រាហ្មណ៍និយមផ្តើមឡើងដោយការបង្ហាញឈ្មោះរបស់អាទិទេពធំៗទាំងបីដូចជា ព្រះព្រហ្ម ព្រះវិស្ណុ ព្រះឥសូរ ឬការធ្វើពិធីបូជាយញ្ញ ។ល ។
- អក្សរសិល្ប៍ពុទ្ធនិយមផ្តើមឡើងដោយបទនមស្ការ ឬផ្តើមដោយតំណាលថា ព្រះពុទ្ធគង់នៅអារាមណាមួយសម្តែងធម៌ទេសនាពីអតីតជាតិ ។ល ។
- អក្សរសិល្ប៍ខេមរនិយមផ្តើមឡើងដោយមិនមានលក្ខណៈឯកភាពគ្នាទេ ពោលគឺអាស្រ័យលើទេពកោសល្យរបស់អ្នកនិពន្ធម្នាក់ៗ ។

ខ. តួរឿងឬដំណើររឿង

- តួអង្គ
  - ក្នុងអក្សរសិល្ប៍ព្រាហ្មណ៍និយម តួអង្គសំខាន់ជាអាទិទេពឬអវតារនៃព្រះវិស្ណុយោនយកកំណើតជាមនុស្សបុរសអស្ចារ្យនិងជានារីអស្ចារ្យ ឯតួអង្គផ្សេងទៀតមាន ឥសី ទេវតា យក្ស គ្រុឌ ... ។
  - អក្សរសិល្ប៍ពុទ្ធនិយម តួអង្គសំខាន់ជាព្រះពោធិសត្វ ឯតួអង្គស្រីជាកន្សែសារពេជ្ជ ។
  - តួអង្គមានមនុស្សទេវៈ អសុរៈ ... ។
  - ក្នុងអក្សរសិល្ប៍ខេមរនិយម តួអង្គសំខាន់ជាមនុស្សធម្មតាដែលជាអ្នកស្ថិតនៅក្នុងឋានៈចាប់ពីអ្នកបម្រើរហូតដល់វណ្ណៈអភិជន ក្រៅពីនេះ ក៏មានតួអង្គដែលមានលក្ខណៈ អច្ឆរិយៈដូចជា យក្ស ខ្មោច បិសាច អ្នកតា ទេវតា និងមានតួអង្គជាសត្វដូចជា ចចក ទន្សាយ ... ប៉ុន្តែតួអង្គទាំងនោះសុទ្ធតែតំណាងឱ្យមនុស្សឬជីវភាពរបស់សង្គមមនុស្ស ។
- ទីកន្លែង
  - ក្នុងអក្សរសិល្ប៍ព្រាហ្មណ៍និយម គេច្រើនបង្ហាញទីកន្លែងនៅព្រៃហោមពាន្ត ស្ថានសួគ៌ ស្ថានបាតាល ស្ថានសិម្ពលី ស្ថានមនុស្ស ។ល ។

- ក្នុងអក្សរសិល្ប៍ពុទ្ធនិយម ទីកន្លែងនៃរឿងច្រើនប្រព្រឹត្តទៅនៅស្ថានមនុស្ស ស្ថានសួគ៌ ស្ថាន នរក ឬនគរពារាណសី តក្កសិលា ព្រៃហោមពាន្ត ។ល ។
- ក្នុងអក្សរសិល្ប៍ខេមរនិយម ទីកន្លែងនៃរឿងច្រើនប្រព្រឹត្តទៅនៅក្នុងសង្គមជាក់ស្តែង ។

• បញ្ហាចោទ

- អក្សរសិល្ប៍ព្រាហ្មណ៍និយម និយាយពីទំនាស់វិបត្តិរវាងសភាវៈល្អនិងសភាវៈអាក្រក់ ។
- អក្សរសិល្ប៍ពុទ្ធនិយម និយាយពីទំនាស់រវាងព្រះពោធិសត្វនិងសង្គមមនុស្ស ទំនៀមទម្លាប់ កម្មពៀរ ។ល ។
- អក្សរសិល្ប៍ខេមរនិយម និយាយពីទំនាស់រវាងមនុស្សនិងមនុស្សក្នុងសង្គម ។ ទោះជាសាច់ រឿងលើកយកតួអង្គសត្វ មកនិយាយក៏ដោយ ក៏បញ្ហានោះលើកយកបញ្ហាមនុស្សនៅក្នុង សង្គមមកចោទដែរ ។

• ដំណោះស្រាយ

- អក្សរសិល្ប៍ព្រាហ្មណ៍និយម ប្រើសិល្ប៍មន្តឫទ្ធិអំណាច សងសឹក ធ្វើចម្បាំងនឹងគ្នា ដោះ ស្រាយដោយសង្គ្រាមឬការប្រឡងឫទ្ធិគ្នា ។
- អក្សរសិល្ប៍ពុទ្ធនិយម បង្ហាញការព្យាយាមតស៊ូប្រឹងប្រែងប្រកបដោយវីរភាពយកសីលធម៌ ខន្តី ទៅអប់រំដោយសន្តិវិធី ប្រើធម៌អហិង្សាដោះស្រាយបញ្ហាជានិច្ច ។
- អក្សរសិល្ប៍ខេមរនិយម មិនទៀងទាត់ ឬឯកភាពគ្នាទេ ប៉ុន្តែតួអង្គតំណាងសភាវៈល្អតែង ទទួលជ័យជំនះលើតួអង្គអាក្រក់ជានិច្ច ។

• ស្នេហា

- អក្សរសិល្ប៍ព្រាហ្មណ៍និយម បង្ហាញឥទ្ធិពលរបស់អាទិទេព អ្នកឈ្នះតឹបានទទួលស្នេហា ។
- អក្សរសិល្ប៍ពុទ្ធនិយម បង្ហាញក្តីស្នេហាបរិសុទ្ធនិងការកសាងបារមីព្រះពោធិសត្វ និងកន្សៃ សារពេជ្ជ ។
- អក្សរសិល្ប៍ខេមរនិយម បង្ហាញក្តីស្នេហារវាងមនុស្ស និងមនុស្ស ។

• ឧត្តមគតិរឿង

- អក្សរសិល្ប៍ព្រាហ្មណ៍និយម អប់រំមនុស្សឱ្យជឿលើអាទិទេព អប់រំមនុស្សឱ្យមានជំនឿថា ទុក្ខសោក ល្អ អាក្រក់របស់ខ្លួនបានមកពីអាទិទេព ។ ទាំងនេះធ្វើឱ្យមនុស្សខ្វះការតស៊ូ ខ្វះ ការជឿជាក់លើខ្លួនឯង ។

- អក្សរសិល្ប៍ពុទ្ធនិយម អប់រំមនុស្សឱ្យស្គាល់បុណ្យ បាប ឱ្យធ្វើអំពើល្អខំប្រឹងតស៊ូព្យាយាម ដោយជឿជាក់លើខ្លួនឯង ជឿលើយុត្តិធម៌ ។ល។
- អក្សរសិល្ប៍ខេមរនិយម អប់រំមនុស្សឱ្យស្គាល់សង្គមរស់នៅ ចេះដោះស្រាយបញ្ហាទៅតាមកាលៈទេសៈ ដោយជឿជាក់លើខ្លួនឯងនិងយុត្តិធម៌សង្គម ។

គ. បញ្ចប់រឿង

ការបញ្ចប់រឿងអាស្រ័យទៅតាមចលនាអក្សរសិល្ប៍ ៖

- អក្សរសិល្ប៍ព្រាហ្មណ៍និយម តួអង្គតំណាងអាទិទេព(សភាវៈល្អ)មានជ័យជម្នះលើសភាវៈអាក្រក់ យក្ស គ្រុឌ អសុរៈ ។
- អក្សរសិល្ប៍ពុទ្ធនិយម ការបញ្ចប់រឿងដោយមានការសជាតិរបស់តួអង្គព្រះពោធិសត្វ និងកន្សៃសារពេជ្ជ ។
- អក្សរសិល្ប៍ខេមរនិយម ការបញ្ចប់រឿងមិនមានឯកភាពគ្នាទេ អាស្រ័យលើទេពកោសល្យរបស់អ្នកនិពន្ធម្នាក់ៗ ជាទូទៅអំពើល្អឈ្នះអំពើអាក្រក់ ។

កំណត់សម្គាល់

ការផ្តើមរឿង តួរឿងឬដំណើររឿង និងការបញ្ចប់រឿងរបស់រឿងព្រេង ឬរឿងនិទានមានលក្ខណៈសំខាន់ៗដូចខាងក្រោម ៖

ក. ការផ្តើមរឿង

អ្នកនិពន្ធផ្តើមរឿងដោយប្រើ :

- កាលពីព្រេងនាយ ...
- តាំងពីយូរលង់ណាស់មកហើយ ...
- មានតំណាលថា ...
- កាលពីរជ្ជកាលព្រះបាទ ...
- ក្នុងកំលុងឆ្នាំ ... ព.ស. ...
- សម័យថ្ងៃមួយ ...
- នៅឯ ...
- មាននិទានមួយ ...
- ..... ។

ខ. តួរឿងឬដំណើររឿង

ដំណើររឿងច្រើនរៀបរាប់ពីប្រវត្តិនៃឈ្មោះភូមិស្រុក ទីកន្លែងនានា បូជនីយដ្ឋាន បុរាណដ្ឋាន ប្រពៃណី ទំនៀមទម្លាប់ ទំនាស់វិបត្តិផ្សេងៗក្នុងសង្គម ។ល ។

គ. បញ្ចប់រឿង

អ្នកនិពន្ធច្រើនបញ្ចប់រឿងដោយបង្ហាញសមិទ្ធផល ប្រាប់មូលហេតុ អំពើល្អឈ្នះអំពើអាក្រក់ យុត្តិធម៌ឈ្នះអយុត្តិធម៌ ។ល ។

ឧទាហរណ៍ :

- ហេតុដូចនេះហើយបានយើងឃើញ ...រហូតដល់សព្វថ្ងៃ ។
- ហេតុនេះទើបគេនាំគ្នាគោរព ... រហូតសព្វថ្ងៃ ។
- ... មានឈ្មោះ ... រហូតដល់សព្វថ្ងៃ ។
- ... រស់នៅសុខសាន្តតរៀងទៅ ។
- ... ។ល ។

ឧទាហរណ៍ : ចូរអ្នកអានរឿង "ក្រុងឧដុង្គ" ដោយកត់សម្គាល់លើការផ្តើមរឿង ដំណើររឿង ឬតួរឿង និងការបញ្ចប់រឿង ៖

រឿង ក្រុងឧដុង្គ

ទីក្រុងឧដុង្គ ចាប់ផ្តើមកសាងឡើងក្នុងសតវត្សរ៍ទី ១៧ នៃគ្រិស្តសករាជក្នុងរជ្ជកាលព្រះបាទ សម្តេចព្រះជ័យជេដ្ឋាទី ២ មានរឿងនិទានមួយទាក់ទងនឹងប្រវត្តិក្រុងឧដុង្គនេះ ។

ក្នុងពុទ្ធសករាជ ២១៦៤ គ្រិស្តសករាជ ១៦២០ ព្រះបាទសម្តេចព្រះជ័យជេដ្ឋាទី ២ ជាអម្ចាស់ជីវិតលើត្បូង ស្តេចគង់នៅព្រះរាជវាំងល្វាឯម ។ ថ្ងៃមួយ ព្រះអង្គបាននាំអគ្គមហេសី ព្រះស្នំ ក្រមការ សេនាបតី និងនាហ្មឺនសព្វមុខមន្ត្រីរាជការទាំងពួង ចុះព្រះរាជទីនាំងនាវា ស្តេចយាងទៅប្រពាតនៅ តំបន់អូរក្រងលាយ ខេត្តសំរោងទង ។ ទ្រង់ប្រថាប់នៅព្រះពន្លាជាយូរថ្ងៃ ។ បន្ទាប់មក ព្រះអង្គយាង ទៅក្រសាលនៅទីតាដុង យាយជ័យ ។ នៅទីនោះ ទ្រង់ទតឃើញទីទួលមួយនៅតំបន់ស្រះកែវ ជាទី មានទេសភាពល្អ ។ ទ្រង់ចាប់ព្រះរាជហឫទ័យ ក៏មានព្រះតម្រាស់នឹងនាហ្មឺនមន្ត្រីទាំងពួងមានហោរាធិបតីជាដើម ៖ "យើងចង់សាងព្រះរាជវាំងគង់នៅទីនេះ តើអស់លោកទាំងពួងយល់ដូចម្តេច ?" ។

លោកឧកញ៉ាហោរាធិបតី មុំ គន់គួរមើលជីទីនោះតាមក្បួនហោរាសាស្ត្រ រួចទូលព្រះរាជា ៖ "ទូលបង្គំសូមក្រាបទូលព្រះអង្គ ជីទីនេះជាជ័យភូមិល្អណាស់ ព្រោះតាមក្បួនទាយថានឹងមានឫទ្ធិតប: តេជ: ឈ្នះអស់សត្រូវទាំង ៨ទិស" ។ ព្រះរាជាទ្រង់ជ្រាបដូច្នេះហើយ ក៏ចាត់ឱ្យឧកញ៉ាក្រឡាហោមកែវធ្វើជានាយកចាត់ចែង ស្ថាបនាព្រះរាជវាំងនៅតំបន់ស្រះកែវនោះ។ ទ្រង់នឿយហត់ ហើយស្តេចយាងត្រឡប់ទៅព្រះរាជវាំងនៅល្ងាចមវិញ។

លំដាប់ពីនោះ ឧកញ៉ាក្រឡាហោមកែវ បានបង្គាប់ចៅហ្វាយស្រុកឱ្យកេណ្ឌប្រជារាស្ត្រកាប់ឈើមកធ្វើព្រះរាជវាំងតាមព្រះរាជបញ្ជា។ លុះប្រមូលគ្រឿងសម្ភារៈបានសព្វគ្រប់ហើយ ឧកញ៉ាក្រឡាហោមកែវ បង្គាប់មេការឱ្យចាប់ផ្តើមចាត់ការលើកដីធ្វើជាបន្ទាយយាមល្បាតជុំវិញការដ្ឋានសំណង់ព្រះរាជវាំង។ លោកឧកញ៉ា ក្រឡាហោមកែវបានដឹកនាំការសាងសង់ព្រះរាជមន្ទីរ ព្រះរាជដំណាក់តូចធំ ព្រះរាជរោង អស់រយៈពេលប្រមាណ ១០ខែទើបរួចរាល់ ហើយលោកក៏ទៅទូលព្រះរាជា។

លុះទ្រង់ជ្រាបហើយ ព្រះបាទសម្តេចព្រះជ័យជេដ្ឋាទី ២ជាអម្ចាស់ជីវិតលើត្បូង ស្តេចចេញចាកព្រះបរមរាជវាំងល្ងាចម យាងតាមព្រះទីនាំងនាវា ធ្វើដំណើរតាមទន្លេសាបមួយអន្លើដោយព្រះអគ្គមហេសី ព្រះស្នំ ក្រមការ ព្រះរាជវង្សានុវង្ស សេនាបតី នាហ្មឺនសព្វមុខមន្ត្រី ខ្ញុំរាជការគ្រប់ក្រុមជារាជបរិពារមកដល់កំពង់តាដុង យាយជ័យ ទ្រង់ប្រថាប់ទីនោះ ៣រាត្រី។ ទ្រង់ព្រះរាជបញ្ញត្តហៅទីនោះថា "កំពង់ហ្លួង"។ ទ្រង់ព្រះរាជបញ្ជាភ្នាក់ងារមុខក្រសួងឱ្យរៀបចំធ្វើព្រះរាជពិធីឡើងព្រះវាំងថ្មី និមន្តព្រះរាជាគណៈចម្រើនព្រះបរិត្ត ៣ថ្ងៃ ចូលព្រះរាជពិធីនៅថ្ងៃ ៥កើត ខែផល្គុន ឆ្នាំវកទោស័ក ពុទ្ធសករាជ២១៦៤គ្រិស្តសករាជ ១៦២០ ហើយព្រះអគ្គមហេសី ព្រះស្នំ ក្រមការ ព្រះរាជវង្សានុវង្សសេនាបតី នាហ្មឺនសព្វមុខមន្ត្រីខ្ញុំរាជការគ្រប់ក្រុមជារាជបរិពារ ហែស្តេចពីកំពង់ហ្លួងចូលមកនៅព្រះរាជវាំងថ្មី រួចឱ្យគេរៀបធ្វើព្រះរាជពិធីសម្ពោធព្រះនគរបីថ្ងៃទៀតដោយមានល្បែងមហោស្រពគ្រប់បែបយ៉ាងឧឡារិកអធិកអធមក្រៃលែង។ ព្រះរាជាទ្រង់ដាក់ព្រះនាមព្រះនគរ (ទីក្រុង) ថ្មីនោះថា "ព្រះបរមរាជវាំងមហានគរឧដុង្គមានជ័យបុរីរម្យឧត្តមរាជនិវេសនដ្ឋាន" ដែលហៅខ្លីថា "ក្រុងឧដុង្គមានជ័យ"។

(ដកស្រង់ និងកែសម្រួលពីប្រជុំរឿងព្រេងភាគទី ៥)

រឿងនេះ គឺជាប្រភេទរឿងព្រេងបែបប្រវត្តិសាស្ត្រ ស្ថិតក្នុងអក្សរសិល្ប៍ខេមរនិយម។ រឿងខាងលើបានបង្ហាញពីធាតុសំខាន់ៗដូចជា ៖

ក. ការផ្តើមរឿង

ក្នុងអក្សរសិល្ប៍ខេមរនិយម ការផ្តើមរឿងគ្មានភាពទៀងទាត់ឬក៏គ្មានគោលការណ៍ឯកភាពណាមួយទេ គឺផ្អែកលើទេពកោសល្យរបស់អ្នកនិពន្ធម្នាក់ៗ។ ជាឧទាហរណ៍ រឿងខាងលើផ្តើមដោយបង្ហាញពីកាលបរិច្ឆេទនៃការកសាងក្រុងឧដុង្គ ៖ "ក្នុងពុទ្ធសករាជ ២១៦៤គ្រិស្តសករាជ ១៦២០ ព្រះបាទសម្តេចព្រះជ័យជេដ្ឋាទី ២ជាអម្ចាស់ជីវិតលើត្បូងស្តេចគង់នៅព្រះរាជវាំងល្ងាងម។ ថ្ងៃមួយ ព្រះអង្គបាននាំអគ្គមហេសី ..." ។

ខ. តួរឿងឬដំណើររឿង

- **តួអង្គ**

រឿងនេះ ជារឿងបែបប្រវត្តិសាស្ត្រ។ តួអង្គគឺជាមនុស្សពិតប្រាកដក្នុងសង្គមដូចជា ព្រះបាទសម្តេចព្រះជ័យជេដ្ឋាទី ២ជាព្រះរាជាខ្មែរសម័យឧដុង្គដែលជាស្តេចបានស្ថាបនាក្រុងឧដុង្គក្នុងពុទ្ធសករាជ ២១៦៤គ្រិស្តសករាជ ១៦២០ ។ លោកឧកញ៉ាហោរាធិបតី មុំ ជាហោរា លោកឧកញ៉ាក្រឡាហោម កែវ និងព្រះអគ្គមហេសី ព្រះស្នំ ក្រមការ ព្រះរាជវង្សានុវង្ស សេនាបតី នាហ្មឺនសព្វមុខមន្ត្រី ខ្ញុំ រាជការជាច្រើនទៀត ។

- **ទីកន្លែង**

រឿងនេះកើតឡើងនៅក្នុងស្រុកខ្មែរ ដែលមានទីកន្លែងពិតប្រាកដ គឺល្ងាងម កំពង់ហ្លួង ឧដុង្គ ទន្លេសាប ... ។

- **បញ្ហាចោទ**

រឿងនេះ បង្ហាញពីបញ្ហាពិតជាក់ស្តែងក្នុងសម័យកាលដែលសង្គមខ្មែរមានសត្រូវយាយី ។ ព្រះរាជាត្រូវការផ្លាស់ប្តូររាជវាំងពីល្ងាងមមកឧដុង្គដើម្បីសុវត្ថិភាពនិងធ្វើជាទីតាំងយុទ្ធសាស្ត្រតទល់នឹងសត្រូវ ។

- **ដំណោះស្រាយ**

ក្នុងពុទ្ធសករាជ ២១៦៤គ្រិស្តសករាជ ១៦២០ព្រះបាទសម្តេចព្រះជ័យជេដ្ឋាទី ២ជាអម្ចាស់ជីវិតលើត្បូងទ្រង់ចាត់ឱ្យឧកញ៉ាក្រឡាហោមកែវ ឱ្យធ្វើជានាយកចាត់ចែងស្ថាបនាព្រះរាជវាំងនៅតំបន់ស្រះកែវនោះរហូតបានសម្រេច។ ការកសាងក្រុងថ្មីនេះគឺជាយុទ្ធសាស្ត្រក្នុងការប្រយុទ្ធតស៊ូជាមួយសត្រូវដែលប៉ុនប៉ងមកយាយី។

- **ឧត្តមគតិរឿង**

ខ្លឹមសាររឿងនេះ អប់រំខ្មែរយើងឱ្យស្គាល់ប្រវត្តិសាស្ត្រខ្លួន ស្គាល់ស្នាព្រះហស្តអតីតព្រះមហាក្សត្រ ហើយមានទឹកចិត្តស្នេហាជាតិ។

គ. បញ្ចប់រឿង

រឿងនេះបញ្ចប់ដោយតួអង្គព្រះរាជាទទួលជោគជ័យ អាចសម្រេចបំណងបាន ពោលគឺនៅក្នុងពុទ្ធសករាជ ២១៦៤គ្រិស្តសករាជ ១៦២០ព្រះបាទសម្តេចព្រះជ័យជេដ្ឋាទី ២ជាអម្ចាស់ជីវិតលើត្បូងបានសាងសង់ព្រះរាជវាំងរួចជាស្ថាពរ ព្រមទាំងដាក់ព្រះនាមព្រះនគរ(ទីក្រុង) ថ្មីនោះថា "ព្រះបរមរាជវាំងមហានគរឧដុង្គមានជ័យបុរីរម្យឧត្តមរាជនិវេសនដ្ឋាន" ដែលហៅខ្លីថា "ក្រុងឧដុង្គមានជ័យ"។

លំហាត់

ចូរអ្នកអានរឿងខាងក្រោម រួចបង្ហាញពីការផ្តើមរឿង តួរឿងឬដំណើររឿង និងការបញ្ចប់រឿងរបស់រឿងនេះ។

រឿង ភ្នំសំពៅ

កាលពីព្រេងនាយ មានព្រះមហាក្សត្រមួយអង្គព្រះនាម រាជកុល សោយរាជ្យនៅប្រទេសកម្ពុជាដោយតាំងព្រះរាជវាំងនៅលើភ្នំដងរែក។ ព្រះបាទរាជកុលទ្រង់សព្វព្រះរាជហឫទ័យនឹងស្ត្រីម្នាក់ឈ្មោះនាងសុវណ្ណមសា។ នាងនេះជាកូនអ្នកក្រីក្រ ប៉ុន្តែនាងមានរូបឆោមសក្តិសមល្អឆើត។ នាងចិញ្ចឹមក្រពើមួយដ៏មានឫទ្ធិក្លាហានឈ្លាសវៃណាស់ ទោះបីប្រើឱ្យធ្វើអ្វី វាធ្វើបានទាំងអស់។ ក្រពើនេះមានខ្លួនធំលើសប្រមាណ។ នាងដាក់ឈ្មោះវាថា អាធន។ តាមតំណាលថា មុនដំបូងនាងសុវណ្ណមសារើសបានពងសត្វមួយមកទុកដោយនាងមិនស្គាល់ថាជាពងសត្វអ្វីទេ។ លុះដល់ថ្ងៃខែញាស់ស្រាប់តែញាស់ចេញមកជាកូនក្រពើ។ នាងអាណិតក៏ចិញ្ចឹមថែរក្សាដោយពេញចិត្តណាស់។ ក្រពើនោះទៀតសោត ក៏ស្លែកពីក្រពើទាំងពួង ចេះស្តាប់បង្គាប់នាងដូចមនុស្សសុទ្ធសាធ។

ឯព្រះបាទរាជកុល លុះបាននាងសុវណ្ណមសា មកជាគូស្នេហាហើយ មិនយូរប៉ុន្មានក៏បែរជាមានព្រះទ័យពុំសូវស្និទ្ធស្នាលទៅវិញ ដោយទ្រង់ព្រះតម្រិះយល់ឃើញថានឹងលើកនាងជាអគ្គមហេសីពេញទីពុំបាន ព្រោះនាងជារាស្ត្រមានឋានៈពុំស្មើ ពុំសមនឹងរៀបអភិសេកជាឯកអគ្គមហេសីឡើយ។ លុះព្រះតម្រិះដូច្នេះហើយ ក៏ទៅក្រាបបង្គំទូលព្រះវរបិតាមាតា។ ព្រះបិតាមាតា ក៏យល់តាម ហើយស៊ើបសួររកស្រីណាដែលមានពូជពង្សត្រកូលខ្ពង់ខ្ពស់ដើម្បីរៀបអភិសេកជាមួយព្រះរាជបុត្ររបស់ព្រះអង្គ។

ថ្លែងពីស្តេចមួយអង្គនៅក្រុងចន្ទបុរី មានព្រះរាជបុត្រីមួយអង្គ ព្រះនាមព្រះនាងវិសាយសក់។ ព្រះនាងមានព្រះនាមដូច្នេះ ព្រោះព្រះនាងមានសក់ទិព្វ ចង់បានអ្វីក៏បានដូចព្រះទ័យ ដោយព្រះនាងគ្រាន់តែច្បូតព្រះកេសីទៅ ទោះចង់ឱ្យទឹកសមុទ្រខះទៅជាដីគោកក៏បាន ចង់ឱ្យដីគោកក្លាយជាទឹកក៏បាន។ លុះព្រះបិតាមាតារបស់រាជកុល ទ្រង់ជ្រាបហើយក៏ត្រាស់ឱ្យសេនានាំសារទៅថ្វាយស្តេចក្រុងចន្ទបុរី ដើម្បីដណ្តឹងព្រះនាងវិសាយសក់តាមព្រះរាជប្រពៃណី។ ស្តេចក្រុងចន្ទបុរី ទ្រង់ពុំយល់ទាស់ឡើយ ទ្រង់បានតបរាជសារមកព្រះវរបិតាមាតានៃព្រះបាទរាជកុលថា "បើទ្រង់សព្វព្រះរាជហឫទ័យសូមទ្រង់លើកបណ្តាការមកចុះ"។ សេនាបានទទួលព្រះរាជឱង្ការហើយក៏ក្រាបបង្គំលាត្រឡប់មកក្រាបបង្គំទូលព្រះវររាជបិតាមាតានៃព្រះបាទរាជកុលវិញសព្វគ្រប់តាមដំណើរនោះ។ ព្រះបាទរាជកុលបានព្រះសណ្តាប់ដូច្នេះ ក៏មានព្រះទ័យសោមនស្សពន់ពេក ទើបទ្រង់ត្រាស់បង្គាប់ឱ្យរៀបចំគ្រឿងបណ្ណាការយ៉ាងឱឡារិកទុកក្នុងសំពៅដើម្បីធ្វើព្រះរាជដំណើរចេញទៅក្រុងចន្ទបុរី។

ចំណែកនាងសុវណ្ណមសា លុះបានដឹងដំណឹងនេះហើយក៏កើតចិត្តក្តៅក្រហាយខ្លាំងណាស់ ទើបប្រើក្រពើឱ្យមកកល់សំពៅនោះឱ្យលិចវិនាសអន្តរាយដើម្បីកុំឱ្យព្រះបាទរាជកុលទៅជួបនឹងព្រះនាងវិសាយសក់បាន។ ក្រពើបោះពួយលឿនដូចព្រួញសំដៅទៅកល់សំពៅព្រះរាជកុល។ លុះទៅជិតដល់ព្រះបាទរាជកុលទ្រង់ទតឃើញ "អាធន" ក៏មានព្រះបន្ទូលខ្លាំងៗ៖ "ន៎ែ! អាធនអញទេ! កុំមកធ្វើផ្តេសផ្តាស"។ អាធនតបវិញ៖ "ស៊ីបាយអ្នកណាយកអាសាអ្នកនោះ"។ ពួកពលក្រឡេកឃើញក្រពើធំសម្បើមក៏ភ័យស្រែកឡោឡោពេញទាំងសំពៅ នាំគ្នាបោះត្រឡាច ល្ពៅ មាន់ ទា ទាំងទ្រុងៗទៅឱ្យអាធនស៊ីដើម្បីឱ្យវាឈប់ឃ្លាតឆ្ងាយពីសំពៅ តែអាធនពុំទទួលស៊ីសោះ។ ព្រះបាទរាជកុលក៏បួងសួងអស់ទេវតាសូមឱ្យលោកជួយឱ្យផុតពីគ្រោះថ្នាក់។ ដោយបុណ្យបារមីព្រះអង្គសេចក្តីបួងសួងនោះក៏រំជួលដល់ឋានព្រះឥន្ទ្រាធិរាជ។ ព្រះអង្គទ្រង់ប្រើអ្នកបម្រើឱ្យទៅប្រាប់ព្រះនាងវិសាយសក់ស្លាម។ ព្រះនាងវិសាយសក់ច្បូតព្រះកេសីឱ្យទឹកសមុទ្រខះរីងទៅជាដីទាំងអស់។ ក្រពើក៏ជាប់នៅក្នុងដីនោះ តែ

មុននឹងដាច់ខ្យល់ស្លាប់ ក្រពើនោះគោះកន្ទុយផង ដកដង្ហើមធំផង រមួលខ្លួនត្រឡប់ត្រឡិន ហើយតួខ្លួនក្រពើនោះកើតទៅជាភ្នំមួយធំហៅថា "ភ្នំក្រពើ" រហូតដល់សព្វថ្ងៃ។ កន្លែងក្រពើគោះកន្ទុយនិងត្រង់ច្រមុះក្រពើក៏កើតទៅជាបឹងពីរ ដែលសព្វថ្ងៃនេះហៅថា "បឹងកន្ទុយក្រពើ" និង "បឹងច្រមុះក្រពើ"។ ឯសំពៅនោះក៏កើតទៅជាភ្នំមួយ មានរូបរាងដូចសំពៅហៅថា "ភ្នំសំពៅ" តែរាងផ្អៀងបន្តិចព្រោះរលកបោកខ្លាំងណាស់។ នៅពេលអាធនជិតទៅដល់សំពៅ ក្តោងសំពៅក៏សណ្តកធ្លាក់ទៅក្នុងទឹកកើតជាភ្នំមួយហៅថា "ភ្នំក្តោងសំពៅ"។ ទ្រុងមាន់ ទ្រុងទាដែលពួកពលបោះទៅឱ្យក្រពើកើតទៅជាភ្នំមួយឈ្មោះ "ភ្នំទ្រុងមាន់ទ្រុងទា"។ កន្លែងដែលព្រះនាងរំសាយសក់ច្បូតសក់កកើតជាភ្នំមួយនៅខាងត្បូងភ្នំសំពៅហៅថា "ភ្នំនាងរំសាយសក់"។

លុះសមុទ្រខះរីងស្ងាយជាដីហើយ ព្រះរាជកុលក៏ប្រើពួកពលឱ្យជញ្ជូនប្រដាប់ប្រដាទាំងពួងយាងទៅដល់ក្រុងចន្ទបុរី ដើម្បីរៀបអភិសេកជាមួយនាងរំសាយសក់តាមប្រពៃណី។ កាលបើរៀបអភិសេករួចហើយ ព្រះបាទរាជកុលទ្រង់នាំព្រះនាងរំសាយសក់ជាអគ្គមហេសី ព្រមទាំងពលសេនាជាច្រើនត្រឡប់ទៅកាន់រាជបុរីវិញ។ ព្រះអង្គគង់លើដីរីជាមួយព្រះជាយាដោយមានពលសេនាហែហមជាច្រើន។ មកដល់ពាក់កណ្តាលផ្លូវទ្រង់ទតឃើញភ្នំសំពៅ ភ្នំក្រពើ ទ្រង់នឹកទោមនស្សជាខ្លាំងនឹងនាងសុវណ្ណមសាថា "ព្រោះតែចិត្តអាក្រក់ បានជាធ្វើឱ្យគេស្លាប់វិនាសអស់យ៉ាងនេះ"។ ព្រះអង្គត្រាស់បង្គាប់ឱ្យសេនាទៅចាប់សុវណ្ណមសា យកទៅសម្លាប់ចោល។ សេនាធ្វើតាមព្រះរាជបញ្ជា ចាប់នាងសុវណ្ណមសា មកកាត់ក្បាលសងសឹកវិញ។ ក្បាលនោះកើតទៅជាភ្នំមួយហៅថា "ភ្នំសងក្បាល" នៅជិតស្រុកមង្គលបុរីសព្វថ្ងៃ ប៉ុន្តែអ្នកស្រុកហៅក្លាយថា "ភ្នំសងក្បាន"។ នៅជិតភ្នំនេះមានវាលមួយឈ្មោះថា "វាលចិញ្ចាំពោះ" ព្រោះពួកសេនាចិញ្ចាំពោះវៀននាងចោលនៅទីនោះ។ ឯយោនីរបស់នាង សេនាបានអារគ្រវែងចោល ក៏កើតជាភ្នំមួយទៀតឈ្មោះថា "ភ្នំក្រនាយនាង" តែសព្វថ្ងៃគេហៅក្លាយមកថា "ភ្នំបន្ទាយនាង"។

ទៅដល់នគរ ព្រះបាទរាជកុល និងព្រះនាងរំសាយសក់ជាព្រះអគ្គមហេសី យាងចូលទៅថ្វាយបង្គំព្រះវរបិតាមាតា ហើយទ្រង់គង់នៅជាសុខសាន្តតទៅ។

(ដកស្រង់ និងកែសម្រួលពីប្រជុំរឿងព្រេងភាគទី ៥)

រឿង ភ្នំសុពណ៌កាលី

ក. សិក្សាពាក្យគន្លឹះ

- ឈាបនកិច្ច (ន) : ការដុតសព ការបូជាសព ។
- ជំណែងខ្លួន (កិ) : ប្រែកាឡាខ្លួន និម្មិតខ្លួន ។
- និមន្ត (កិ) : ធ្វើដំណើរ , អញ្ជើញ ។
- និម្មិត (កិ) : ប្រែកាឡាខ្លួន និម្មិតខ្លួន ។
- បិណ្ឌបាត (ន) : អាហារដែលប្រមូលឱ្យជាដុំដាក់ក្នុងបាត្រ គឺចង្ហាន់ដាក់រាប់បាត្រ ។
- បិសាច (ន) : អមនុស្ស មានពពួកខ្មោច ព្រាយជាដើម ។
- បច្ចាមិត្រ (ន) : អមិត្ត សត្រូវ ។
- ពោរ (គុ) : ដែលជន់ឡើង ដែលឡើងកំពុង ទឹកឡើងពោរ ។
- មន្ត (ន) : អាគម វេទ ពាក្យស័ក្តិសិទ្ធិសម្រាប់សូត្រប្រសិទ្ធីឱ្យកើតសុខសួស្តី ។
- ស័ក្តិសិទ្ធិ (ន) : ការសម្រេចដោយអំណាច ។

- សព (ន) : សាកសព រូបបុគ្គលដែលស្លាប់ ខ្មោចស្រស់ ។
- សុគត (កិ) : ស្លាប់ ។
- សូធ្យាយ (កិ) : សូត្រឮតិចៗ សូត្រខ្សឹបៗ សូត្រមន្ត ។
- ឫទ្ធានុភាព (ន) : អានុភាពនៃឫទ្ធិ ។

ខ. អភិវឌ្ឍន៍បំណិន

នៅក្នុងការសិក្សាអត្ថបទរឿងនេះ ចូរអ្នកយកចិត្តទុកដាក់ដើម្បីត្រៀមឆ្លើយនឹងសំណួរទាក់ទងនឹងតួអង្គ កាលអាកាស ការផ្តើមរឿង តួរឿង បញ្ចប់រឿង បញ្ហាចោទ ដំណោះស្រាយ និងអត្ថន័យ ។

គ. អត្ថបទ

បើយើងធ្វើដំណើរពីភ្នំពេញតាមដងទន្លេមេគង្គទៅដល់ភ្នំជីច្រាល ហើយបត់ទៅដល់ផែក្រូចឆ្មារ ខេត្តកំពង់ចាម ក្រឡេកចោលភ្នែកទៅទិសឦសាន ក្នុងស្រុកព្រះប្រសព្វ ខេត្តក្រចេះ ត្រើយខាងជើងត្រង់ឃុំចំបក់ យើងនឹងឃើញភ្នំមួយខ្ពស់ទទុង នៅក្បែរមាត់ទន្លេនោះ ។ ភ្នំនោះឈ្មោះ "ភ្នំសុពណ៌កាលី" ជាភ្នំស័ក្តិសិទ្ធិ ។ ភ្នំនេះមានរឿងព្រេងតំណាលដូចតទៅ ៖

កាលពីព្រេងនាយ មានក្រពើមួយឈ្មោះ"សុពណ៌កាលី" ។ វាមានខ្លួនធំមហិមា មានឫទ្ធានុភាពពូកែណាស់ ឥតមានក្រពើណាប្រឡងឫទ្ធិឈ្នះឡើយ ។ ក្រពើសុពណ៌កាលី បានអាស្រ័យនៅក្នុងអន្លង់មួយឈ្មោះអន្លង់សាលី ដែលសព្វថ្ងៃហៅថា ភូមិអន្លង់សាលី ក្នុងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម នៅខាងក្រោយភ្នំសុពណ៌កាលី ចម្ងាយប្រហែល ២០គីឡូម៉ែត្រ ។

ក្នុងសម័យជាមួយគ្នានោះ នៅឃុំមហាលាភ ស្រុកកោះសូទិន ខេត្តកំពង់ចាម មានក្រពើមួយឈ្មោះ "នាងឱរ៉ែ" អាស្រ័យនៅក្នុងទន្លេតូច ត្រង់កំពង់វត្តមហាលាភ ជាក្រពើដែលលោកសង្ឃចិញ្ចឹម ។ ពេលលោកនិមន្តទៅបិណ្ឌបាត ក្រពើនោះតែងបញ្ជូនចម្លងលោកទៅវិញទៅមកជាធម្មតា ។ នាងឱរ៉ែ មានមាឌធំណាស់ ក្បាលប្រវែង ៧ហាត្ថ អាចដំណែងខ្លួនជាមនុស្សបាន ។

ថ្ងៃមួយ ពេលវាដំណែងខ្លួនជាមនុស្សស្រាប់តែឮមនុស្សនិយាយគ្នាថា "ក្រពើនាងឱរ៉ែធំអ្វីប៉ុណ្ណឹង ក្រពើសុពណ៌កាលី នៅអន្លង់សាលីធំជាងនេះទៅទៀត" ។ នាងឱរ៉ែបានឮមនុស្សនិយាយដូច្នេះ ក៏ប្រែកាឡាជាក្រពើហែលទៅតាមដងទន្លេតូចមានចម្ងាយច្រើនគីឡូម៉ែត្រ សំដៅទៅរកក្រពើសុពណ៌កាលីដើម្បីប្រឡងឫទ្ធិគ្នា ។ លុះចេញទៅទល់មាត់ពាមផ្កាយម្រេច វាប្រទះនឹងតាចាស់យាយចាស់កំពុង

ចែវទូកឆ្លងទន្លេធំ នាងឱរ៉ែគិតថា "បើខ្លួនអញនៅជាក្រពើនឹងសុំដោយសារតាយាយនេះពុំបានទេ ព្រោះគាត់ខ្លាច ដូច្នេះគួរអញនិម្មិតខ្លួនជាលោកនេន ទើបសុំដោយសារគាត់បាន"។ គិតហើយ ក៏និម្មិតខ្លួនជាលោកនេនសុំដោយសារជាមួយតាយាយបានដូចបំណង។ នាងឱរ៉ែបានសុំតាយាយចែវទូក ហើយប្រាប់តាយាយថា ៖ "សូមតាយាយទៅអង្គុយកាន់ជើងចែវក្បាលទូក ទប់ខ្លួនឱ្យនឹងចុះ"។ ថាដូច្នេះហើយ លោកនេនក្រពើក៏ចែវទូកលឿនបន្តិចម្តងៗ ឃួរទៅរឹតតែលឿនឡើងៗ ដោយអំណាចនាងឱរ៉ែនិម្មិត យកកន្ទុយជួយកាយទឹកផ្សំផង ចំនួនកន្លះថ្ងៃ ទើបទៅដល់ទឹកន្លែងក្រពើសុពណ៌កាលី។ នាងឱរ៉ែលោកនេនសួរតាយាយថា "តាយាយឡើងត្រើយខាងណា?"។ តាយាយឆ្លើយប្រាប់វិញថា "ឡើងត្រើយខាងស្តាំនេះបានហើយ"។ លុះចូលទូកដល់កំពង់ នាងឱរ៉ែលោកនេនជួយអូសទូកតាយាយផុតពីទឹក។ តាថា "ជាក់ទូកត្រង់ហ្នឹងហើយ"។ នាងឱរ៉ែលោកនេនថា "ពុំបានទេតា!"។ ថាហើយក៏អូសទូកនោះទៅដាក់ចិញ្ចើមច្រាំង ចងក្រៀកដោយច្រវាក់ជាប់នឹងបង្គោល ព្រោះនាងឱរ៉ែគិតថា នៅពេលប្រឡងឫទ្ធិគ្នានោះនឹងមានរលកខ្លាំងណាស់ពោរដល់ចិញ្ចើមច្រាំងបើប្រហែសមិនចងឱ្យជាប់ ទូកនេះមុខជាអណ្តែតទៅបាត់មិនខាន។ រួចកិច្ចការហើយក៏សម្តែងឫទ្ធិប្រែកាឡាជាក្រពើលោតចុះទៅក្នុងទឹក ហែលសំដៅទៅរកក្រពើសុពណ៌កាលី។ ពេលបានជួបហើយក៏ប្រទាំគ្នាដោយឫទ្ធិយ៉ាងអស្ចារ្យ បញ្ឈរខ្លួនផុតពីទឹកផ្អើលអស់មនុស្សមកមើលត្រៀបត្រា រលកទឹកបោកហួសចិញ្ចើមច្រាំង។ លុះប្រទាំគ្នាយូរទៅ ក្រពើនាងឱរ៉ែមានឫទ្ធិខ្លាំងជាងទាំត្រូវពោះក្រពើសុពណ៌កាលីធ្លាយស្លាប់មួយរំពេចទៅ។ ក្រពើសុពណ៌កាលីស្លាប់ទៅកើតជាភ្នំមួយមានឈ្មោះថា "ភ្នំសុពណ៌កាលី" តាមឈ្មោះក្រពើនោះរហូតមកដល់សព្វថ្ងៃនេះ។

ភ្នំនេះពួកែស័ក្តិសិទ្ធិណាស់ បើអ្នកណាទៅរៀនមន្តវិជ្ជានៅភ្នំនោះ នៅពេលកំពុងអង្គុយស្វាធ្យាយតែងមានពួកបិសាចមកល្បងធ្វើជាដុំមាសប៉ុនដួងទុំឬស្រីក្រមុំមកពិតអែបស្មាសងខាង បើអ្នករៀនវិជ្ជានោះភ្លាត់ចំណាប់ចង់បានរបស់នោះ មុខជាពួកនេះវាយបំបាក់កស្លាប់មិនខាន។

កាលបើមានជ័យជម្នះហើយ ក្រពើនាងឱរ៉ែក៏ត្រឡប់មកលំនៅស្ថានវិញ។ ចំណេរកាលក្រោយមក ថ្ងៃមួយពេលក្រពើនាងឱរ៉ែកំពុងចម្លងលោកនេន ស្រាប់តែប្រទះនឹងក្រពើបច្ចាមិត្រដទៃទៀតមកបៀតបៀន។ នាងឱរ៉ែគិតថា "ឥឡូវនឹងទុកលោកនេននៅកន្លែងណា?"។ រកកន្លែងដាក់គ្មាននាងឱរ៉ែ ក៏លេបលោកនេនលាក់ទុកទៅក្នុងពោះខ្លួន ហើយប្រយុទ្ធនឹងក្រពើបច្ចាមិត្រ។ ក្រពើបច្ចាមិត្រចាញ់ក្រពើនាងឱរ៉ែហើយគេចខ្លួនបាត់ទៅ។ លុះប្រយុទ្ធរួចហើយ នាងឱរ៉ែក៏ខ្ចាក់លោកនេនចេញពី

ពោះ ឃើញលោកនេនសុគតទៅហើយក៏កើតសេចក្តីសោកស្តាយពេកក្រៃ។ នៅក្នុងឱកាសដែលពួកមហាជន កំពុងធ្វើបុណ្យឈាបនកិច្ចរំលាយសពលោកនេននោះ ក្រពើនាងឱរ៉ែក៏ឡើងទៅដេកលើភ្នក់ភ្លើងដែលកំពុងឆេះពេញអំណាច។ ភ្លើងក៏ឆេះក្រពើនាងឱរ៉ែនោះបាត់បង់ជីវិតទៅជាមួយលោកនេនទៅ។

(ដកស្រង់ និងកែសម្រួលពីប្រជុំរឿងព្រេងភាគទី ៥)

សំណួរ

១. តើរឿងនេះមានតួអង្គណាខ្លះ ? តើតួអង្គទាំងនោះធ្វើសកម្មភាពអ្វីខ្លះ ?

២. ចូរបង្ហាញតួអង្គឯក និងតួអង្គរងដោយបញ្ជាក់អំណះអំណាងឱ្យបានច្បាស់លាស់។

៣. ចូរបង្ហាញពីការផ្តើមរឿង តួរឿង និងការបញ្ចប់រឿង។

៤. តើរឿងនេះមានខ្លឹមសារសំខាន់ៗដូចម្តេចខ្លះ ?

៥. ចូរធ្វើការសិក្សាអំពីកាលអាកាសនៃរឿង។

៦. ចូរបង្ហាញពីបញ្ហាចោទនិងដំណោះស្រាយរឿង។

៧. ចូរបកស្រាយពីអត្ថន័យនៃរឿងឱ្យបានក្បោះក្បាយ។

កំណើតនាមករណ៍ឬករណនាម និងនាមការក៍ឬការកនាម

- នាមករណ៍មានកំណើតមកពីកិរិយាសព្ទមានដូចខាងក្រោម ៖

កក	> កំណក	កើន	> កំណើន
ធ្វើ	> ទង្វើ	រីប	> របឹប
ជោរ	> ជំនោរ	សង្កេត	> ការសង្កេត
កត់	> កំណត់	គោរព	> ការគោរព
នឹក	> លំនឹក	ប្រព្រឹត្ត	> ការប្រព្រឹត្តឬប្រព្រឹត្តិ
នាច	> លំនាច	អធិប្បាយ	> ការអធិប្បាយ
ងាក	> លំងាក	អនុវត្ត	> ការអនុវត្តឬអនុវត្តន៍
លើក	> ល្បើក	អនុញ្ញាត	> ការអនុញ្ញាតឬអនុញ្ញាត
លះ	> ល្បះ	បញ្ញត្ត	> ការបញ្ញត្តឬបញ្ញត្តិ
ឃ្លាត	> គម្លាត	ពិសោធ	> ការពិសោធឬពិសោធន៍
ប្តូរ	> បណ្តូរ	សន្ធត	> ការសន្ធតឬសន្ធតិ
អាច	> អំណាច	បដិវត្ត	> ការបដិវត្តឬបដិវត្តន៍

- នាមករណ៍មានកំណើតមកពីគុណនាមមានដូចខាងក្រោម ៖

កាច	> កំណាច	សុខ	> សេចក្តីសុខ
ខ្ពស់	> កម្ពស់	ចម្រើន	> សេចក្តីចម្រើន
ក្រ	> កម្រ	ថ្លៃថ្នូរ	> សេចក្តីថ្លៃថ្នូរ
ខ្មៅ	> កម្មៅ	សម្បូណ៌	> ភាពសម្បូណ៌
ខ្ចៃ	> កម្ចៃ	សម្បើម	> ភាពសម្បើម
ល្ហ	> លម្ហ	ទាប	> ទំនាប
ស្តើង	> សម្តើង	ធំ	> ទំហំ
ខុស	> កំហុស	ខ្ចិល	> កម្ចិល
តូច	> តំណូច	ក្តៅ	> កម្តៅ

នាមករណ៍មានកំណើតមកពី កិរិយាសព្ទ និងគុណនាម ។

នាមករណ៍ឬករណនាម ជានាមសម្រាប់សម្តែងសភាពឬសកម្ម ។

5

- នាមការក៍មានកំណើតមកពី កិរិយាសព្ទមានដូចខាងក្រោម ៖

យាម	>	អ្នកយាម	ចាំ	>	ឆ្មាំ
ពោល	>	អ្នកពោល	ដើរ	>	ថ្មើរ
នាំ	>	អ្នកនាំ	កាន់	>	ខ្ចាន់
ស៊ី	>	អ្នកស៊ី	កើត	>	ខ្ចើត
ទិញ	>	អ្នកទិញ	ជួញ	>	ឈ្មួញ
សើច	>	អ្នកសើច	លួន	>	ឈ្លួន
ចម្លង	>	អ្នកចម្លង	ជីក	>	ប្រមឹក
ឆ្លៀត	>	អ្នកឆ្លៀត	បាញ់	>	ប្រមាញ់
ជីក	>	អ្នកជីក	បង់	>	ប្រមង់
ចាញ់	>	អ្នកចាញ់	ឈ្នះ	>	អ្នកឈ្នះ

- នាមការក៍មានកំណើតមកពី គុណនាមមានដូចខាងក្រោម ៖

ល្អ	>	អ្នកល្អ	អាក្រក់	>	អ្នកអាក្រក់
កណ្តាល	>	អ្នកកណ្តាល	តូច	>	អ្នកតូច
ក្រ	>	អ្នកក្រ	ក្លាហាន	>	អ្នកក្លាហាន
ខ្សត់	>	អ្នកខ្សត់	ខ្សោយ	>	អ្នកខ្សោយ

- នាមការក៍មានកំណើតមកពី នាមមានដូចខាងក្រោម ៖

ក្រុង	>	អ្នកក្រុង	ភូមិ	>	អ្នកភូមិ
ចម្ការ	>	អ្នកចម្ការ	ស្រែ	>	អ្នកស្រែ
ស្រុក	>	អ្នកស្រុក	ព្រៃ	>	អ្នកព្រៃ

នាមការក៍មានកំណើតមកពី កិរិយាសព្ទ គុណនាមឬនាម។ នាមការក៍ឬការកនាម ជានាមសម្រាប់សម្តែងអ្នកធ្វើអំពើឬអ្នកមានសភាពលក្ខណៈបែបណាមួយ។

លំហាត់

១. ចូរស្រង់នាមករណ៍ពីប្រអប់ខាងក្រោម ។

សម្តី ពពក កំណើត អ្នកចម្រៀង ទំនប់ ល្បឿន សេចក្តីចម្រើន ទំនុក សៀវភៅ អ្នកចម្បាំង ទន្លេ ភាពរីករាយ វាលស្រែ ដំណេក ប្រទេស ចំណុះ សាលារៀន ការការពារ ចំណែក ចងចាំ បំណែក ផ្ទះ ដំណាំ សេចក្តីថ្លៃថ្នូរ អ្នកនេសាទ ដើមឈើ ពីរោះ ជម្ងឺ សំណើម ការលំបាក ។

២. ចូរធ្វើកម្លាយពាក្យខាងក្រោមឱ្យទៅជានាមករណ៍ ។

ពាក្យឫស	នាមករណ៍
កាន់	.....
សើម	.....
បាក់	.....
ចែក	.....
កាច	.....
រុងរឿង	.....
ជាំ	.....
ខុស	.....

៣. ចូរតែងល្បះដោយប្រើនាមករណ៍ឱ្យបានប្រាំល្បះ ។

៤. ចូរស្រង់នាមការក៍ពីប្រអប់ខាងក្រោម ។

អ្នកលេង អាកាស អ្នកទេសចរ អ្នកខ្លាំង បិសាច អ្នកតា កម្រៃ ចំណូល អ្នកតស៊ូ សមុទ្រ ដក អ្នកនយោបាយ ថ្មើរជ្រៃ សួម ចំណាក អ្នកស្រុក អ្នកក្រីក្រ ការរីកដុះដាល ឆ្មាំ អ្នកការពារ ឈាមរា ការសិក្សា អ្នកភូមិ អ្នកលឿង អ្នកនិពន្ធ តំបន់ អ្នកយាម ដើមស្វាយ អ្នកទាប កម្មករ

៥. ចូរធ្វើកម្លាយពាក្យខាងក្រោមឱ្យទៅជានាមការក៍ ។

ពាក្យឫស	នាមការក៍
កាន់	.....
សើច	.....
ស្លូត	.....
ភ្ញាំ	.....
ចាញ់	.....
ខុស	.....
ទោស	.....
ខ្លាំង	.....
ខ្ចាត់	.....
ចង	.....
ធូន់	.....
ប្រែត	.....
ពោល	.....
កាច	.....
ផឹក	.....
កើត	.....

៦. ចូរតែងល្បះដោយប្រើនាមការក៍ឱ្យបានប្រាំល្បះ ។

អត្ថន្តរសញ្ញាឬសញ្ញាក្បៀសបើកបិទ ‹‹ ... ›› ឬ " ... "

ភាសាខ្មែរយើងមានសញ្ញាសម្ព័ន្ធជាច្រើនដូចជា សញ្ញាបញ្ចប់ល្បះ សញ្ញាដំពីរ និងសញ្ញាក្បៀសបើកបិទជាដើម។ ក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពីសញ្ញាក្បៀសបើកបិទឬអត្ថន្តរសញ្ញា។ ចូរស្វែងយល់អំពីការប្រើប្រាស់សញ្ញានេះនៅក្នុងឧទាហរណ៍ខាងក្រោម ៖

- ជីតាខ្ញុំមានប្រសាសន៍ ៖ "ក្មេងៗពេលជួបចាស់ទុំត្រូវគោរពនិងលើកដៃសំពះទើបប្រពៃ"។
- ក្រមង៉ុយបានលើកឡើង "ឃើញឫកគេល្អ ទោះបីមានក្រ យកគេជាញាតិ"។
- <<ថោកអីនឹងដៃថ្លៃអីនឹងមាត់>> ជាសុភាសិតខ្មែរ។
- អត្ថបទនេះដកស្រង់ចេញពីសៀវភៅ "ស្រីហិតោបទេស ភាគ ៤"។
- យើងកំពុងសិក្សាអំពី "សិល្បៈនិងវប្បធម៌ជាតិ"។

ពាក្យ ឃ្លា ល្បះក្នុងសញ្ញាក្បៀសបើកបិទនៃឧទាហរណ៍នីមួយៗខាងលើបញ្ជាក់អំពី ៖

- សម្តីផ្ទាល់របស់អ្នកនិយាយ(ក្នុងឧទាហរណ៍ទី ១)
- សេចក្តីស្រង់បណ្តាំ(ក្នុងឧទាហរណ៍ទី ២)
- ពាក្យឬសេចក្តីដែលគេចង់បញ្ជាក់(ក្នុងឧទាហរណ៍ទី ៣)
- ឈ្មោះស្នាដៃ(ក្នុងឧទាហរណ៍ទី ៤)
- ឈ្មោះវត្ថុ(ក្នុងឧទាហរណ៍ទី ៥)

សញ្ញាក្បៀសបើកបិទសម្រាប់ដាក់អមពាក្យ ឃ្លា ឬល្បះ ដើម្បីបញ្ជាក់នូវឈ្មោះ មនុស្ស សត្វ ឬវត្ថុអ្វីមួយដែលសំខាន់ឬលើកសម្តីផ្ទាល់របស់អ្នកនិយាយ។

កំណត់សម្គាល់ : កាលណាក្បៀសបើកបិទប្រើអមសម្តីផ្ទាល់របស់អ្នកនិយាយគេប្រើសញ្ញា "៖" នៅខាងមុខ(មើលឧទាហរណ៍ទី ១)។

លំហាត់

១. ចូរប្រើសញ្ញាក្បៀសបើកបិទនៅក្នុងល្បះខាងក្រោមឱ្យបានត្រឹមត្រូវតាមកន្លែង។

- អ្នកគ្រូនិយាយទៅកាន់សិស្សពេលទៅដល់ផ្ទះអ្នកត្រូវជម្រាបសួរអ្នកមានគុណ។
- អណ្តាតជាអាទិ៍កន្លងបានសុខទុក្ខផងពីព្រោះតែអណ្តាត ជាសុភាសិតខ្មែរ។
- នៅក្នុងរឿងកុលាបប៉ែលិន តាចឹមបានផ្តាំចៅចិត្រ ខ្ជួនទីពឹងខ្ជួន។
- រឿងនេះដកស្រង់ចេញពីគតិលោកភាគទី ១។
- សុភាសិតខ្មែរចែងថា ព្យាយាមគង់បានសម្រេច។

២. ចូរតែងល្បះដោយប្រើអត្ថន្តរសញ្ញាឱ្យបានប្រាំល្បះ។

ព្រៃកបញ្ញត្តិ : ការប្រើពាក្យ រាជសព្ទ និងសង្ឃសព្ទ

ពាក្យខ្មែរយើងមួយចំនួនមានន័យដូចគ្នា ប៉ុន្តែពេលខ្លះ គេមិនអាចយកពាក្យនោះមកប្រើបានជាទូទៅទេ ពីព្រោះពាក្យខ្មែរមានរាជសព្ទនិងសង្ឃសព្ទដើម្បីប្រើប្រាស់ទៅតាមប្រភេទមនុស្ស ទីកន្លែង និងពេលវេលា។ ក្រៅពីពាក្យសម្រាប់ប្រើជាមួយព្រះសង្ឃ(សង្ឃសព្ទ) ពាក្យសម្រាប់ស្តេចនិងរាជវង្សានុវង្ស(រាជសព្ទ) ក៏មានពាក្យខ្លះប្រើសម្រាប់មនុស្សដែលមានវ័យខុសគ្នា ឬឋានន្តរសក្តិទាបខ្ពស់ថែមទៀតផង។

ឥឡូវចូរអ្នកអានពាក្យជារាជសព្ទនិងសង្ឃសព្ទខ្លះៗខាងក្រោម ៖

ពាក្យសាមញ្ញ	សង្ឃសព្ទ	រាជសព្ទ
ដេក	សឹង	ផ្ទំ
ដើរ	និមន្ត	យាង
និយាយ	មានសង្ឃដីកា	មានព្រះបន្ទូលឬទ្រង់ត្រាស់
ស្លាប់	សុគត	សោយទិវង្គត
ហូប	ឆាន់	សោយ
យំ	កន្សែង	កន្សែង
ក្បាល	ព្រះសិរ	ព្រះសិរ
ប្រាប់	ទូលឬពិត	ទូលឬក្រាបបង្គំទូល
ខ្ញុំ	ខ្ញុំព្រះករុណា	ទូលបង្គំ(ប្រុស) ខ្ញុំម្ចាស់(ស្រី)
ធ្មេញ	ព្រះទន្ត	ព្រះទន្ត
យានជំនិះ	យានជំនិះ	ព្រះទីនាំង
ជូន	ប្រគេន	ថ្វាយ
ឱ្យ	ប្រទាន	ប្រទាន
ខឹង	ខ្ញាល់	ខ្ញាល់
ស្បែកជើង	ស្បែកជើង	សុពណ៌បាទ
ប្អូន	ប្អូន	ព្រះអនុជ
យាយ	យាយ	អយ្យកា
ត្រចៀក	ព្រះកាណ៌	ព្រះកាណ៌

លំហាត់

១. ចូរស្រង់រាជសព្ទពីក្នុងរឿង "ក្រុងឧដុង្គ" ។

២. ចូររកពាក្យមកបំពេញតារាងខាងក្រោម ។

ពាក្យសាមញ្ញ	សង្ឃសព្ទ	រាជសព្ទ
.....	ខមាលទោស	.....
ស្គាក់នៅ	.....	.....
.....	អាពាធ	.....
ដៃ	.....	.....
.....	ដោះទុក្ខសត្វ	.....
.....	.....	គាល់
.....	កុដិ	.....
.....	.....	ព្រះនេត្រ
ជើង	.....	.....
ឡាន	.....	.....
.....	.....	ប្រសូត
កូន	.....	.....
.....	ចង្ហាន់	.....
.....	.....	បុត្រី
.....	និមន្ត	.....
គោ	.....	.....
.....	.....	មាតា
.....	ញោមប្រុស	.....
.....	.....	ព្រះរៀម
.....	.....	ព្រះអយ្យកោ
.....	ព្រះឱស្ឋ	.....

រឿង កំណើតរាជធានីភ្នំពេញ



ក. សិក្សាពាក្យគន្លឹះ

- ចតុមុខ (ន) : មុខបួន ។
- ជយភូមិ (ន) : ទឹកដីមានជោគជ័យ ។
- ទេវរូប (ន) : រូបតំណាងទេវៈ ។
- ព្រះពុទ្ធរូប (ន) : រូបតំណាងព្រះពុទ្ធ ។
- មហិទ្ធិឫទ្ធិ (ន) : ឫទ្ធិធំឬឫទ្ធិខ្លាំងក្រៃលែង ។
- ល្អណ្តាច (គុ) : ល្អមើលទៅឃើញរាចណ្តាច ទឹកឡើងចូលវាលល្អណ្តាច ។
- សក្តិសិទ្ធិ (ន) : ការសម្រេចដោយអំណាច ។
- សន្ធគ (ន) : ប្តេជ្ញា សន្យា យល់ព្រមជាមួយ ។
- សិរីទ្ធ (ន) : ឈ្មោះលោហធាតុម្យ៉ាង ។
- ស្តុកស្តម្ភ (គុ) : បរិបូណ៌ មានច្រើន ។
- ស្ថាបនា (កិ) : កសាង សាងសង់ ។
- អាសនៈ (ន) : កន្លែងអង្គុយ ។

ខ. អភិវឌ្ឍន៍បំណិន

នៅក្នុងការសិក្សាអត្ថបទរឿងនេះ ចូរអ្នកយកចិត្តទុកដាក់ដើម្បីត្រៀមឆ្លើយសំណួរទាក់ទងនឹងតួអង្គ កាលអាកាស ការផ្តើមរឿង តួរឿង បញ្ចប់រឿង បញ្ហាចោទ ដំណោះស្រាយ និងអត្ថន័យ។

គ. អត្ថបទ

ភ្នំដែលសន្មតជានាមរាជធានីរបស់ខ្មែរគឺ "រាជធានីភ្នំពេញ" សព្វថ្ងៃ កើតមានតាំងពីមុនពេលស្ថាបនាព្រះរាជវាំងដោយមានរឿងតំណាលថា ៖

ក្នុងកាលកន្លងទៅហើយនៅ គ.ស.១៣៧២ មានដួនចាស់ម្នាក់ឈ្មោះពេញ ជាអ្នកមានភោគទ្រព្យស្តុកស្តម្ភ មានទីលំនៅក្បែរមាត់ច្រាំងទន្លេបួនមុខ។ ផ្ទះគាត់សង់នៅលើទីទួលមួយខាងកើតភ្នំតូចមួយ។ ថ្ងៃមួយមានភ្លៀងធ្លាក់យ៉ាងខ្លាំងធ្វើឱ្យទឹកទន្លេជន់លិចល្ហល្ហាច។ គ្រានោះ ដួនពេញចុះទៅកំពង់ទឹកស្រាប់តែឃើញដើមគគីរធំមួយ កំពុងអណ្តែតទឹកមកក្បែរមាត់ច្រាំង ហើយដោយអំណាចទឹកហូរចុះឡើងដើមគគីរនោះចេះតែអណ្តែតវិលវល់នៅក្បែរមាត់ច្រាំងនោះ។ លុះដួនពេញឃើញដូច្នេះក៏រត់អំពាវនាវហៅអ្នកជិតខាងឱ្យមកជួយទាញយកដើមគគីរនោះ។ អ្នកជិតខាងក៏នាំគ្នាយកពួរទៅចងហើយអូសរំកិលបន្តិចម្តងៗទាល់តែមកដល់មាត់ច្រាំង។ ពេលដែលដួនពេញ យកកំណាត់ឈើទៅកោសកៀរភក់ចេញ គាត់បានឃើញក្នុងប្រហោងឈើមានព្រះពុទ្ធរូបបួនអង្គតូចៗធ្វើពីសរីទ្ធនិងទេវរូបមួយអង្គទៀតធ្វើអំពីថ្ម។ ទេវរូបនោះទ្រង់ឈរ ព្រះហស្តម្ខាងទ្រង់ដំបង ព្រះហស្តម្ខាងទៀតទ្រង់សង្ខព្រះកេសទ្រង់ភ្នង។ ដួនពេញនិងអ្នកជិតខាងដែលទៅជួយមានសេចក្តីត្រេកអរណាស់ដោយរើសបានរបស់ជាទីគោរព ក៏នាំដង្ហែព្រះបដិមាទាំងនោះមកដល់ផ្ទះដួនពេញ ហើយដួនពេញចាត់ការសង់ខ្ទមតូចមួយតម្កល់ជាបណ្តោះអាសន្ន។ ថ្ងៃក្រោយមក ដួនពេញបានអំពាវនាវឱ្យអ្នកជិតខាងជួយលើកពូនភ្នំដែលនៅខាងលិចផ្ទះគាត់នោះឱ្យទៅជាភ្នំធំមែនទែន។ បន្ទាប់ពីនោះ គាត់ឱ្យគេអារឈើគគីរនោះធ្វើជាសសរវិហារដែលគាត់បម្រុងសង់លើភ្នំ។ ក្នុងគ.ស.១៣៧២ ដួនពេញនិងអ្នកស្រុកជាច្រើននាក់បានស្រុះស្រួលគ្នាសង់វិហារមួយខ្នងប្រក់ស្បូវភ្លាំងនៅលើកំពូលភ្នំនោះ ហើយគាត់ដង្ហែព្រះពុទ្ធរូបសរីទ្ធទាំងបួនអង្គទៅតម្កល់ទុកក្នុងវិហារនោះ។ ចំណែកទេវរូបថ្មមួយអង្គ គាត់ដង្ហែទៅតម្កល់ទុកលើអាសនៈមួយទៅជើងភ្នំខាងកើត ដោយគាត់យល់ថាទេវរូបនោះអណ្តែតទឹករសាត់មកពីស្រុកលាវ និងមានបែបភាពដូចជាលាវគាត់ក៏សន្មតថា "អ្នកតាព្រះថៅ"។ នាមនោះជាប់មកដល់សព្វថ្ងៃ។

កាលបើសាងសង់វិហាររួចហើយ ដូនពេញបានទៅនិមន្តព្រះសង្ឃមកគង់លើជើងភ្នំនោះក្នុងទិសខាងលិច ទើបកើតមានឈ្មោះថា "វត្តភ្នំដូនពេញ"ដែលសព្វថ្ងៃហៅកាត់ខ្លីថា "វត្តភ្នំ" តាំងពីពេលនោះរហូតដល់សព្វថ្ងៃ។ តាមជំនឿអ្នកស្រុកថា ព្រះពុទ្ធរូបទាំងបួនអង្គ និងអ្នកតាព្រះថៅនោះបានបញ្ចេញមហិទ្ធិឫទ្ធិឱ្យឃើញពូកែស័ក្តិសិទ្ធិណាស់។ អ្នកដែលបានបន់ស្រន់តែងបានសម្រេចដូចបំណង។

ក្រោយមក ព្រះបាទសម្តេចបរមរាជាពញាយ៉ាតទ្រង់គ្រងរាជសម្បត្តិនៅក្នុងព្រះរាជវាំង មហានគរ(នគរភ្នំ)បាន ១៦ឆ្នាំ ទើបទ្រង់បានបញ្ជាឱ្យស្ថាបនាព្រះរាជវាំងថ្មីនៅឯទួលបាសានក្នុងខេត្តស្រីសឈរគឺស្រុកស្រីសន្ធរ ខេត្តកំពង់ចាមសព្វថ្ងៃនេះ។ នៅក្នុង ព.ស.១៩៧៦ គ.ស.១៤៣២ព្រះបរមរាជាពញាយ៉ាត រួមជាមួយសេនាបតី នាហ្មឺនសព្វមុខមន្ត្រី ទ្រង់យាងមកគង់នៅរាជវាំងថ្មីឯទួលបាសាន។ ព្រះអង្គគង់នៅទីនោះបានតែជាងមួយឆ្នាំប៉ុណ្ណោះ ដោយទឹកទន្លេចេះតែជន់លិចទ្រង់ក៏បញ្ជាឱ្យសម្តេចថៅពញាកែនិងឧកញ៉ាហោរាធិបតីខៀវ ព្រមទាំងមន្ត្រីឯទៀតរកកន្លែងសាងសង់ព្រះរាជវាំងថ្មី។ តាមឧកញ៉ាហោរាធិបតីខៀវទស្សន៍ទាយទៅឃើញថា ទីកជីនាទិសអាគ្នេយ៍នៃភ្នំដូនពេញជាកន្លែងជយភូមិល្អ។ ព្រះអង្គក៏បញ្ជាឱ្យគេសាងសង់រាជវាំងនៅទីនោះ។ ក្រោយពីសាងសង់រួចរាល់នៅឆ្នាំ១៤៣៤ ព្រះអង្គប្រទាននាមក្រុងថ្មីថា "ទន្លេច្រាបឈាម" តាំងពីឃុរមកហើយនោះ ដោយទ្រង់បានប្រទានឈ្មោះជាថ្មីថាទន្លេចតុមុខបូពារិញ។ ព្រះអង្គមានព្រះរាជបញ្ជាឱ្យឧកញ៉ាតេជោស្រីថៅហ្វាយស្រុកសំរោងជាអ្នកកាន់ការលើកដីចាក់លុបបំពេញទីក្រុងថ្មី ព្រមទាំងលើកដីចាក់បន្ថែមលើភ្នំដូនពេញឱ្យកាន់តែខ្ពស់ឡើង។ ទីក្រហូងជ្រៅដែលកើតចេញមកពីការជីកយកដីនោះជាប់ឈ្មោះថា ចឹងតេជោ គឺដីត្រង់ផ្សារថ្មីសព្វថ្ងៃនេះ។ មកដល់ គ.ស. ១៨៦៥ ព្រះបាទសម្តេចព្រះនរោត្តមបានផ្លាស់ព្រះរាជវាំងពីក្រុងឧដុង្គមានជ័យមកគង់នៅក្រុងចតុមុខនេះ។ ព្រះអង្គបានកសាងក្រុងនេះជាលើកទីពីររហូតបានក្លាយជារាជធានីភ្នំពេញសព្វថ្ងៃនេះ។

(ដកស្រង់ និងកែសម្រួលពីសៀវភៅប្រជុំរឿងព្រេងខ្មែរ ភាគ ៥)

សំណួរ

១. តើរឿងនេះមានតួអង្គណាខ្លះ ? តើតួអង្គទាំងនោះធ្វើសកម្មភាពអ្វីខ្លះ ?

២. ចូរបង្ហាញតួអង្គឯកនិងតួអង្គរងដោយបញ្ជាក់អំណះអំណាងឱ្យបានច្បាស់លាស់។

៣. ចូរបង្ហាញពីការផ្តើមរឿង តួរឿង និងការបញ្ចប់រឿង។

៤. ចូរធ្វើការសិក្សាអំពីកាលអាកាសនៃរឿង។

៥. ចូរបង្ហាញពីបញ្ហាចោទនិងដំណោះស្រាយនៃរឿង។

៦. ចូរបកស្រាយពីអត្ថន័យនៃរឿងឱ្យបានក្បោះក្បាយ។

ធនញ្ជ័យជាញ់អ្នកប្រាជ្ញចិន

នៅក្នុងការស្តាប់រឿងនេះ អ្នកនឹងបានសិក្សាអំពីចំណិនមួយចំនួនដូចជា ការប្រើប្រាស់រាជសព្ទ និងសង្ឃសព្ទ តួអង្គ កាលអាកាស បញ្ហាចោទ ដំណោះស្រាយ និងអត្ថន័យនៃរឿង ។

សំណួរ

១. តើអត្ថបទនេះដកស្រង់ចេញពីប្រភពណា ?

២. តើក្នុងអត្ថបទដកស្រង់នេះមានតួអង្គប៉ុន្មាននាក់ ? តើតួអង្គនីមួយៗបានធ្វើសកម្មភាពអ្វីខ្លះ ?

៣. ចូរអ្នកសិក្សាអំពីកាលអាកាសនៃអត្ថបទ ។

៤. ចូរបង្ហាញពីបញ្ហាចោទនិងដំណោះស្រាយនៅក្នុងអត្ថបទ ។

៥. ចូរបកស្រាយពីអត្ថន័យនៃអត្ថបទដកស្រង់ឱ្យបានក្បោះក្បាយ ។

៦. តើមានរាជសព្ទនិងសង្ឃសព្ទអ្វីខ្លះនៅក្នុងអត្ថបទនេះ ?

ការប្រើរាជសព្ទ

អ្នកបានសិក្សាអំពីរាជសព្ទខ្លះៗរួចមកហើយ នៅក្នុងមេរៀននេះអ្នកបានសិក្សាអំពីការសន្ទនាដោយប្រើរាជសព្ទ។ ចូរអានការសន្ទនារវាងព្រះអង្គម្ចាស់ជាមួយវិទូ។

វិទូ : ព្រះអង្គម្ចាស់! ទូលបង្គំខានចូលគាល់សួរសុខទុក្ខព្រះមាតាបិតាទ្រង់យូរមក ហើយមិនដឹងថាទ្រង់មានព្រះរាជសុខភាពយ៉ាងណាទេ ?

ព្រះអង្គម្ចាស់ : វិទូ! យើងអរគុណឯងហើយ ដែលយកចិត្តទុកដាក់នឹងមាតាបិតាយើង។ សព្វថ្ងៃទ្រង់សុខសប្បាយជាធម្មតាទេ ហើយទ្រង់កំពុងគង់នៅឯបរទេសឯណោះ។ ឥឡូវនេះ យើងគង់នៅព្រះដំណាក់ជាមួយព្រះវៀមនិងព្រះអនុជរបស់យើង។

វិទូ : ចុះព្រះអយ្យកា ព្រះអយ្យកោរបស់ព្រះអង្គម្ចាស់គង់នៅឯណាដែរ ?

ព្រះអង្គម្ចាស់ : ទ្រង់គង់នៅឯបរទេសដែរ ព្រោះព្រះរាជសុខភាពទ្រង់ពុំសូវល្អតែងអាពាធជាញឹកញាប់។ ទ្រង់ឧស្សាហ៍រំឭកពីឈ្មោះឯងណាស់។

វិទូ : តើពេលណាទើបទ្រង់យាងត្រឡប់មកវិញ ?

ព្រះអង្គម្ចាស់ : យើងមិនដឹងច្បាស់ដែរ តែព្រះបិតាខ្ញុំឧស្សាហ៍យាងចុះឡើងជាញឹកញាប់។

វិទូ : បើដូច្នេះស្រួលហើយ! ពេលទ្រង់យាងមក ទូលបង្គំនឹងសរសេរលិខិតមួយផ្ញើទៅសួរសុខទុក្ខព្រះអយ្យកានិងព្រះអយ្យកោរបស់ទ្រង់ផង។

ព្រះអង្គម្ចាស់ : មិនអីទេ ចាំពេលទ្រង់យាងមកយើងនឹងប្រាប់ឯង។

សំណួរ

១. តើតួអង្គសន្ទនាមានដើមកំណើតក្នុងវង្សត្រកូលអ្វី ?

២. តើពួកគេសន្ទនាគ្នាអំពីអ្វី ?

៣. តើក្នុងខ្លឹមសារសន្ទនា គេប្រើសំនួនពាក្យដូចម្តេចខ្លះ ?

៤. តើគេបានប្រើរាជសព្ទអ្វីខ្លះនៅក្នុងការសន្ទនានេះ ?

លំហាត់

ចូរចាប់គូរួចធ្វើការសន្ទនាគ្នាដោយប្រើប្រាស់រាជសព្ទឱ្យបានត្រឹមត្រូវ។

ការប្រើរាជសព្ទ

អ្នកបានសិក្សាអំពីរាជសព្ទខ្លះៗរួចមកហើយ នៅក្នុងមេរៀននេះអ្នកបានសិក្សាអំពីសំណេរដោយប្រើរាជសព្ទបន្តទៀត ។ ចូរអានខ្លឹមសារក្នុងសំបុត្រខាងក្រោម ។

ប៉ារីស, ថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០១០

បុត្រសូមក្រាបថ្វាយបង្គំព្រះមាតា ព្រះបិតាជាទីនឹករឭកដ៏ជ្រាលជ្រៅ !

អស់រយៈពេលច្រើនខែមកហើយ ដែលបុត្របានមករស់នៅក្នុងទីក្រុងប៉ារីសប្រទេសបារាំងដើម្បីបន្តការសិក្សា ។ ក្នុងរយៈពេលនេះ បុត្រមានសេចក្តីសុខជាធម្មតាទេ ប៉ុន្តែបុត្រមានសេចក្តីនឹករឭកមកដល់ព្រះមាតា និងព្រះបិតាជាពន់ពេក ។ បុត្រមិនដឹងថា តើទ្រង់មានសុខទុក្ខនិងមានព្រះទ័យនឹករឭកមកដល់បុត្រដែរ ឬយ៉ាងណា ?

ចំណែកការសិក្សាវិញ បុត្រកំពុងយកព្រះទ័យទុកដាក់ព្យាយាមយ៉ាងខ្លាំង សូមព្រះមាតាព្រះបិតាកុំព្រួយព្រះទ័យឱ្យសោះ ។ កាលពីឆ្នាំមុន បុត្រទទួលបានចំណាត់ថ្នាក់លេខ ១ ។ បុត្រសន្យាថានឹងព្យាយាមយកលេខ ១នៅឆ្នាំនេះទៀត ។ បុត្រសង្ឃឹមថាទ្រង់នឹងប្រទានរង្វាន់ដល់បុត្រជាមិនខាន ។

តាមរយៈចុតហ្នាយនេះដែរ ទូលបង្គំសូមផ្ញើសេចក្តីនឹករឭកសាកសួរសុខទុក្ខចំពោះព្រះរាជវង្សានុវង្សទាំងអស់ពីចម្ងាយផង ។ បុត្រសង្ឃឹមថា ទ្រង់នឹងបានសុខ មានព្រះសុខភាពបរិបូណ៌គ្រប់ៗអង្គ ។

ដោយសារពេលវេលាមិនអនុគ្រោះ ទូលបង្គំសូមក្រាបថ្វាយបង្គំលាព្រះមាតាព្រះបិតាជាទីសក្ការៈដ៏លើសលប់ត្រឹមនេះចុះ ។ ជាទីបញ្ចប់ ទូលបង្គំសូមបួងសួងដល់ទេវតាទាំងឡាយទាំងពួងតាមជួយថែរក្សាព្រះអង្គឱ្យជួបប្រទះតែសេចក្តីសុខចម្រើនគ្រប់ប្រការមានព្រះសុខភាពបរិបូណ៌ព្រះជន្មាយុយឺនយូរ កុំបីខាន ។

ពីបុត្រ

សំណួរ

១. តើអ្នកណាជាអ្នកសរសេរសំបុត្រ ? តើសរសេរផ្ញើទៅឱ្យអ្នកណា ?

២. តើពួកគេមានពូជពង្សជាអ្វី ?

៣. តើសំបុត្រជាប្រភេទសំបុត្រអ្វី ? តើសំបុត្រនេះមានទម្រង់ដូចម្តេច ?

៤. តើក្នុងខ្លឹមសារសំបុត្រគេប្រើសំនួនពាក្យដូចម្តេចខ្លះ ?

៥. តើគេបានប្រើរាជសព្ទអ្វីខ្លះនៅក្នុងសំបុត្រនេះ ?

លំហាត់

ចូរអ្នកសរសេរសំបុត្រមួយច្បាប់ ដោយប្រើប្រាស់រាជសព្ទឱ្យបានត្រឹមត្រូវ ។

មេរៀនទី

សាមគ្គីភាព



សាមគ្គីភាព គឺជាការរួបរួមកម្លាំងគ្នាជាធ្លុងមួយ ឬការព្រមព្រៀងគ្នាដោយឯកច្ឆន្ទក្នុងការធ្វើអ្វីមួយឱ្យសម្រេចបានដោយជោគជ័យដោយមិនប្រកាន់ វណ្ណៈ ឋានៈតួនាទី ជាតិសាសន៍ ពណ៌សម្បុរឬភេទឡើយ។ សាមគ្គីភាពអាចកើតមានឡើងដោយទឹកចិត្តស្រឡាញ់ ការជឿជាក់ ស្មោះស្ម័គ្រ យោគយល់ អធ្យាស្រ័យ និងការចេះអនុគ្រោះគ្នាទៅវិញទៅមក។ សាមគ្គីភាពជាកត្តាសំខាន់នាំទៅរកជ័យជំនះគ្រប់បែបយ៉ាង។ ទឹកដី ជាតិសាសន៍ ភាសា អក្សរ វប្បធម៌ប្រពៃណី ទំនៀមទម្លាប់ ព្រមទាំងសមិទ្ធិផ្សេងៗក្នុងសង្គមអាចស្ថិតស្ថេរគង់វង្សនិងរីកចម្រើនបានអាស្រ័យដោយមានសាមគ្គីភាព។ ការពង្រឹងកិច្ចសហប្រតិបត្តិការជាដើមចមនៃសន្តិភាពនិងការអភិវឌ្ឍ។ ។

ក្នុងមេរៀននេះ អ្នកនិងសិក្សាអត្ថបទមួយចំនួន ដែលទាក់ទងនឹងសាមគ្គីភាព។ ទន្ទឹមនេះអ្នកក៏បានសិក្សាផងដែរអំពី ប្រធានបទនិងចំណងជើងនៃអត្ថបទ កំណើតនាមការក៍ឬការកនាម និងការចូលរួមពិភាក្សាវែកញែក ការបញ្ចេញមតិ និងសំណេរអត្ថបទបែបបញ្ចុះបញ្ចូល។

ការបង្ហាញប្រធានបទនិងចំណងជើងអត្ថបទ

យើងអាចកំណត់ប្រធានបទនិងដាក់ចំណងជើងសមស្របឱ្យអត្ថបទមួយ អាស្រ័យលើសេចក្តីលម្អិតនិងគំនិតសំខាន់របស់អត្ថបទនោះ។ ប្រធានបទឬចំណងជើងអត្ថបទអាចជាកន្សោមពាក្យ ឬឃ្លា។ ប្រធានបទនៃអត្ថបទក៏អាចជាចំណងជើងនៃអត្ថបទបានដែរ។ ជួនកាលចំណងជើងអាចប្លែកពីប្រធានបទ។ ចូរអានឧទាហរណ៍ខាងក្រោម រួចបង្ហាញថា ៖

តើប្រធានបទនៃអត្ថបទនេះនិយាយពីអ្វី ? តើអត្ថបទនេះមានចំណងជើងដូចម្តេច ?

ឧទាហរណ៍ ៖ មនុស្សដែលទទួលគ្រោះថ្នាក់បាត់បង់ជីវិត ដោយសារការជក់បារីមានចំនួន ៦២លាននាក់ នៅក្នុងប្រទេសអភិវឌ្ឍ។ បណ្តាអ្នកស្លាប់ទាំងនោះ មានបុរស ៥២លាននាក់ និងស្ត្រីមាន១០លាននាក់។ តាមតួលេខថ្មីៗរបស់អង្គការសុខភាពពិភពលោកបានបង្ហាញថាថ្នាំជក់បានសម្លាប់មនុស្ស ១០០លាននាក់ នៅក្នុងសតវត្សរ៍ទី ២០នេះ។ នាពេលបច្ចុប្បន្នថ្នាំជក់សម្លាប់មនុស្ស៥.៤ លាននាក់ក្នុងមួយឆ្នាំ ដោយជំងឺមហារីកចំពង់ក សួត ជំងឺបេះដូង និងជំងឺផ្សេងៗទៀត។ អង្គការសុខភាពពិភពលោកបានប៉ាន់ប្រមាណថានៅឆ្នាំ ២០៣០ថ្នាំជក់នឹងសម្លាប់មនុស្ស ៨លាននាក់ក្នុងមួយឆ្នាំ ហើយ៨០% នៃអ្នកស្លាប់គឺស្ថិតនៅក្នុងប្រទេសកំពុងអភិវឌ្ឍ។

(ដកស្រង់ និងកែសម្រួលពីកម្រងឯកសារថ្នាំជក់ឬសុខភាព រៀបចំដោយក្រសួងអប់រំយុវជននិងកីឡា)

- ប្រធានបទនៃកថាខណ្ឌខាងលើនេះគឺ "គ្រោះថ្នាក់នៃការជក់បារី"
- ចំណងជើងអត្ថបទអាចថា "ការស្លាប់មកពីបារី"។

តាមឧទាហរណ៍ខាងលើបញ្ជាក់ថា ប្រធានបទមានលក្ខណៈទូលំទូលាយជាងចំណងជើង។

- *ប្រធានបទ គឺជាពាក្យ កន្សោមពាក្យឬឃ្លា ដែលមានន័យទូលំទូលាយគ្រប់លើខ្លឹមសារអត្ថបទទាំងមូល។*
- *ចំណងជើង គឺជាពាក្យ កន្សោមពាក្យឬឃ្លា ដែលមានន័យចង្អៀត ច្បាស់លាស់ ហើយគ្រប់តែលើផ្នែកណាមួយនៃខ្លឹមសារអត្ថបទទាំងមូល។ ប្រធានបទអាចប្រើជាចំណងជើងអត្ថបទបាន។*

លំហាត់

ចូរអានអត្ថបទខាងក្រោម ហើយកំណត់ប្រធានបទនិងចំណងជើងនៃអត្ថបទ :

១. [...] ពេលដឹងការពិតហើយ ចចក គិតទ្រុស្តមិត្តនិងកុហករាជសីហ៍ជាមិត្តថា មានរាជសីហ៍មួយទៀតចង់ល្បែងប្ញទ្ធិ។ កាលណារាជសីហ៍ស្លាប់នឹងក្លាយជាចំណីរបស់វា។ គិតរួចវាក៏ដើរចេញពីគុហា សំដៅទៅជួបរាជសីហ៍ ហើយពោលពាក្យប្រាប់ដូចដែលវាបានគិត។ ក្រោយពីឮចចកប្រាប់ រាជសីហ៍ខឹងណាស់ស្រែកខ្លាំងៗ " នរណាអីក៏ថ្លើមធំម្ល៉េះ" រួចឱ្យចចកនាំទៅគុហា។ ចចកក៏នាំរាជសីហ៍ចូលព្រៃឡើងភ្នំរហូតដល់ល្ហាងថ្មឆ្ងាំ។ ចចកក្លែងធ្វើជាខ្លាច ថយមកនៅពីក្រោយរាជសីហ៍ដោយនិយាយខ្សឹបៗ "មិត្តមើលចុះនោះវា! វាគ្មានញញើតមិត្តបន្តិចសោះ វាឈរធ្វើកន្តើយ។ បើមិត្តធ្វើដូចម្តេច វាក៏ធ្វើតបវិញដែរ"។ រាជសីហ៍មិនបានដឹងការពិតក៏ស្ទុះចូល យល់ស្រមោលខ្លួនឯងស្មានថាជាសត្រូវ ទើបសម្តែងប្ញទ្ធិលុតក្រាបញាក់មុខមាត់ ហើយស្ទុះទៅទះតប់ សង្កត់ជល់នឹងថ្មជាបាក់កសួន្យសង្ខារនាពេលនោះទៅ។

(ដកស្រង់ និងកែសម្រួលពីគតិលោកភាគ ៣)

២. [...]បណ្ឌិតថាស់ទុំ និងវប្បធម៌ទូខ្មែរ សឹងគ្រប់សម័យកាលកន្លងមក បានទូន្មានថាបញ្ហាវប្បធម៌គឺជាបញ្ហារបស់ខ្មែរគ្រប់រូប ដែលខ្មែរមិនគ្រាន់តែត្រូវខិតខំស្វែងយល់រៀនសូត្រអំពីសារៈ និងកំណើតរបស់វាប៉ុណ្ណោះទេ គឺត្រូវខិតខំរក្សាការពារមរតកវប្បធម៌ជាតិ ឱ្យបានគង់វង្ស ដើម្បីបុព្វហេតុសន្តិភាព និងព្រលឹងរបស់ប្រជាជាតិខ្លួន។ តាមនិយមន័យទូទៅ វប្បធម៌គឺជាសមិទ្ធផលនៃជ័យជំនះ ដោយបញ្ញាពលកម្ម ហត្ថកម្មរបស់មនុស្សលើធម្មជាតិ លើអវិជ្ជាលើភាពអន្ធការ។ គោលដៅជាមូលដ្ឋានរបស់វប្បធម៌គឺមនុស្ស។ កាលណាស្មារដៃវប្បធម៌កាន់តែខ្ពង់ខ្ពស់ គោលដៅរបស់មនុស្សកាន់តែជ្រាលជ្រៅ និងសុក្រឹត។ វប្បធម៌មានតួនាទីចង្អុលទិសបណ្តុះបណ្តាលអប់រំចំណេះដឹងនិងបញ្ញាស្មារតី ដើម្បីរកសេចក្តីចម្រើនខាងផ្លូវចិត្តគំនិត និងឧត្តមគតិប្រសើរខ្ពង់ខ្ពស់របស់មនុស្ស។ វប្បធម៌ជួយកែច្នៃមនុស្សឱ្យមានកិរិយាមារយាទល្អប្រសើរ មានរបៀបរស់នៅថ្លៃថ្នូរ មានច្បាប់ទម្លាប់ត្រឹមត្រូវ មានកម្រិតជីវភាពរុងរឿង មានទស្សនវិស័យជឿនលឿន មានរបៀបគ្រប់គ្រងត្រឹមត្រូវ មានសច្ចៈ យុត្តិធម៌ និងមានសេចក្តីសុខសន្តិភាព។ ប្រជាជាតិខ្មែរធ្លាប់ជាជនជាតិមួយ មានអរិយធម៌រុងរឿង ថ្កុំថ្កើង ព្រមទាំងមានកិត្តិនាមល្បីល្បាញទូទាំងសកលលោកទាំងមូល ព្រោះតែតម្លៃសិល្បៈ វប្បធម៌ជាតិខ្លួន។ ជាការពិតណាស់ កាលណាគេទស្សនាសិល្បៈបុរាណខ្មែរដូចជារបាំក្បាច់បុរាណ វិមាន ប្រាសាទអង្គរ ស្ថាបត្យកម្ម គំនូរចម្លាក់ ល្ខោនតន្ត្រី គេត្រូវគិតពិចារណាទើបយល់ខ្លឹមសារពិតរបស់វា។

(ដកស្រង់និងកែសម្រួលពីទស្សនាវដ្តីគ្រូស្តីពីសិទ្ធិមនុស្សប្រជាធិបតេយ្យនិងអហិង្សា លេខ ០៧-០៨-៩៦)

ខ្ញុំត្រូវគេនិយាយបញ្ចុះបញ្ចូល

ក. សិក្សាពាក្យគន្លឹះ

- អគ្គិសនី (ន) : ភ្លើងអេឡិចត្រិក (ពាក្យសន្មតប្រើតាមសម័យនិយម) ។
- បុគ្គលិក (ន) : ភ្នាក់ងាររាជការដែលធ្វើការក្នុងក្រសួងរាជការផ្សេងៗឬនិយោជិតនៃគ្រឹះស្ថានពាណិជ្ជកម្មជាដើម ។
- ធនាគារ (ន) : ឃ្លាំងដាក់ទ្រព្យ ឃ្លាំងប្រាក់ ។
- រអា (កិរិយាគុ) : ធុញទ្រាន់ខ្លាំង រាងចាលព្រោះទ្រាន់ខ្លាំងក្រែងចិត្ត ។
- បដិសេធ (កិ) : ឃាត់ ហាម លើកចោលឬទាត់ចោលលែងយកជាការ លែងរាប់អាន ។
- រំភើប (កិ) : រញ្ជួយ ចំប្រប់ ។
- កិត្តិយស (ន) : យសស័ក្តិដែលល្បីទូទៅ កេរ្តិ៍ឈ្មោះដ៏រុងរឿង ។
- ធុរៈ (ន) : រវល់ ជំណើរជំពាក់ដោយកិច្ចនីមួយៗ ។
- ហ៊ុន(ចិន) (ន) : ប្រាក់ដើមទុនដែលព្រមព្រៀងចូលរួមជាមួយគ្នាធ្វើជំនួញ ។

ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទខាងក្រោម អ្នកគប្បីអានដោយយកចិត្តទុកដាក់ដើម្បីឆ្លើយនឹងសំណួរទាក់ទងទៅនឹងផលនៃការបញ្ចុះបញ្ចូល ខ្លឹមសារអត្ថបទ ប្រធានបទ ការប្រើប្រាស់ភាសាបញ្ចុះបញ្ចូល ។

គ. អត្ថបទ

យើងធ្លាប់និយាយបញ្ចុះបញ្ចូលគេ តែក៏មានពេលខ្លះយើងក៏ត្រូវគេនិយាយបញ្ចុះបញ្ចូលវិញផងដែរ ។ មានករណីខ្លះ យើងក៏ដឹងថាត្រូវគេបញ្ចុះបញ្ចូលដែរ ពេលខ្លះយើងបដិសេធ ប៉ុន្តែពេលខ្លះយើងក៏ទទួលយកគំនិតគេដោយមិនដឹងខ្លួនឬដោយមិនអាចប្រកែកបានដែរ ។ ហេតុអ្វីយើងត្រូវបានគេធ្វើការបញ្ចុះបញ្ចូលបែបនេះ ? មានហេតុផលច្រើន ប៉ុន្តែហេតុផលដ៏ធំចម្បងនោះគឺស្ថិតលើទេពកោសល្យនៃដៃគូដែលខិតខំប្រឹងប្រែងបញ្ចុះបញ្ចូល ។

នៅក្នុងឆ្នាំ ១៩២៧ ក្រុមហ៊ុនអគ្គិសនី MATSUSHITA បានចាប់ផ្តើមធ្វើជំនួញជាមួយនឹងធនាគារ SUMITOMO ។ ការចាប់ផ្តើមរកស៊ីជាមួយគ្នារបស់ក្រុមហ៊ុនទាំងពីរនេះកើតឡើងដោយសារបុគ្គលិកម្នាក់នៃសាខារបស់ធនាគារបានខិតខំប្រឹងប្រែងមកធ្វើការបញ្ចុះបញ្ចូល ។ នាពេលនោះ យើងបានរកស៊ីជាមួយធនាគារ YUUGO មួយភាគធំហើយ មួយភាគតូចជាមួយធនាគារ ROKUYUUGO ។ ដូច្នេះយើងមិនចាំបាច់រកស៊ីជាមួយនឹងធនាគារផ្សេងពីនេះទៀតទេ ។

ប៉ុន្តែធនាគារ SUMITOMO បានបើកដំណើរការសាខាមួយនៅជិតក្រុមហ៊ុនអគ្គិសនី MATSUSHITA ។ ចាប់តាំងពីសាខានៃធនាគារនេះបើកមក គេក៏បានមកបបួលយើងឱ្យចូលរួមរកស៊ីជាមួយគេ ហើយការបបួលនេះមិនត្រឹមធ្វើឡើងតែម្តងឬពីរដងនោះទេ គឺគេបានមកជាច្រើនលើកច្រើនសា ។ ដោយសារស្ថានភាពក្នុងពេលបច្ចុប្បន្នមានភាពគ្រប់គ្រាន់គួរជាទីពេញចិត្ត ខ្ញុំពុំមានចិត្តចង់បន្ថែមការរកស៊ីថ្មីទៀតឡើយ ។ ខ្ញុំមានការរអាចិត្ត ចំពោះអ្នកទទួលបន្ទុកខាងបុគ្គលិកធនាគារនោះណាស់ ប៉ុន្តែដោយសារខ្ញុំគិតថាការរកស៊ីនេះមិនចាំបាច់ ទើបការចាប់ផ្តើមដំណើរការរកស៊ីមិនអាចទៅមុខបានទេ ។ ក្រោយពីខ្ញុំស្តាប់ដោយមិនយកចិត្តទុកដាក់មក ខ្ញុំក៏សូមឱ្យគេត្រឡប់ទៅវិញ ។

ក៏ប៉ុន្តែ បុគ្គលិកធនាគារនោះហាក់ដូចជាមិនងាយនឹងបោះបង់ចោលការបញ្ចុះបញ្ចូលនេះសោះ ។ ទោះបីជាកន្លះឆ្នាំ ឬក៏មួយឆ្នាំកន្លងផុតទៅក៏ដោយ ក៏គាត់នៅតែព្យាយាមមកបញ្ចុះបញ្ចូលបបួលយើងឱ្យរកស៊ីជាមួយគាត់ដដែល ។

ជារៀងរាល់ពេលដែលគាត់មក យើងតែងតែបដិសេធ ក៏ប៉ុន្តែគាត់នៅតែមកទៀត។ ទោះបីជាគាត់និយាយថានឹងមកម្តងទៀត ឬមកប៉ុន្មានដងទៀតក៏ដោយ ក៏យើងគិតថាគ្មានភាពចាំបាច់នឹងរកស៊ីជាមួយគាត់សោះ។ ប៉ុន្តែយើងមានចិត្តស្ងើចសរសើរគាត់យ៉ាងខ្លាំង ចំពោះឆន្ទៈដ៏មោះមុតរបស់បុគ្គលិកធនាគារនេះ។

ដើម្បីកុំឱ្យគាត់មកបញ្ចុះបញ្ចូលហើយបញ្ចុះបញ្ចូលទៀត យើងត្រូវតែបដិសេធម្តងឱ្យបានច្បាស់លាស់។ ខ្ញុំក៏និយាយជាមួយបុគ្គលិកធនាគារនេះយ៉ាងច្បាស់លាស់ថា ៖ "ខ្ញុំមានការរអាចិត្តយ៉ាងខ្លាំងចំពោះអ្នកដែលមកម្តងហើយម្តងទៀត ខ្ញុំមានការរំភើបចិត្តយ៉ាងខ្លាំងចំពោះការខិតខំប្រឹងប្រែងរបស់អ្នក។ លើសពីនេះទៀត ខ្ញុំមានកិត្តិយសយ៉ាងខ្លាំងដែលធនាគារ SUMITOMO ដ៏ធំនេះមានបំណងរកស៊ីជាមួយក្រុមហ៊ុនខ្ញុំ។ តាមពិតទៅយើងគួរតែរកស៊ីជាមួយធនាគាររបស់លោកហើយ ប៉ុន្តែដោយសារក្រុមហ៊ុនអគ្គិសនី MATSUSHITA ខ្ញុំបានរកស៊ីជាមួយធនាគារ YUUGO ជាយូរមកហើយ បើក្រុមហ៊ុនខ្ញុំធ្វើជំនួញជាមួយធនាគារផ្សេងទៀត នោះពិតជាមានការលំបាក ហើយខ្ញុំមានអារម្មណ៍ពិបាកបន្តិច ពីព្រោះការងាររកស៊ីហ្នឹងប្រហែលជាមានការខាតបង់ផងដែរ។ ដូច្នេះខ្ញុំពិតជាអរគុណអ្នកហើយដែលអ្នកបានខិតខំប្រឹងប្រែងមកបបួលខ្ញុំរកស៊ីជាមួយ។ ប៉ុន្តែដោយសារតែខ្ញុំមានធុរៈដូចនេះសូមអ្នកអភ័យទោសឱ្យខ្ញុំផង"។ តាមការពិត ខ្ញុំមានបំណងជំទាស់ដាច់ខាត ក៏ប៉ុន្តែដៃគូរបស់ខ្ញុំនៅតែមិនយល់ព្រមនឹងការជំទាស់របស់ខ្ញុំ។ ដៃគូជាបុគ្គលិកនោះនិយាយ "សូមថ្លែងអំណរគុណចំពោះការពន្យល់ដ៏ក្បោះក្បាយ។ រឿងហ្នឹងពិតជាត្រឹមត្រូវ ខ្ញុំយល់ច្បាស់ហើយ។ ឥឡូវនេះក្រុមហ៊ុន MASUSHITA របស់លោកមានដំណើរការបែបនេះល្អហើយ ប៉ុន្តែខ្ញុំឃើញថាក្រុមហ៊ុន MATSUSHITA នឹងរីកចម្រើនទៅមុខយ៉ាងខ្លាំងនាពេលអនាគត។ តាមការសង្កេតរបស់យើងខ្ញុំ លទ្ធផលនឹងដូចអ្វីដែលខ្ញុំបាននិយាយអីចឹង។ ដូច្នេះ ប្រសិនបើក្រុមហ៊ុនរបស់លោករីកចម្រើនទៅមុខថែមទៀតនោះ ខ្ញុំគិតថាការដែលយើងជ្រើសរើសធនាគារពីរជាដៃគូដ៏សំខាន់នោះ និងមានចំណុចងាយស្រួលច្រើនជាងការជ្រើសធនាគារ YUUGO តែមួយ។ រឿងនេះមានឧទាហរណ៍ជាក់ស្តែងច្រើនដែលជាបទពិសោធ។ ហេតុដូច្នេះហើយ ដើម្បីឱ្យក្រុមហ៊ុន MATSUSHITA បានរីកចម្រើនទៅមុខថែមទៀតផងនោះ បានជាខ្ញុំជំរុញឱ្យធ្វើជំនួញជាមួយនឹងធនាគារ SUMITOMO។ រឿងនេះមិនមែនគ្រាន់តែដើម្បីធនាគារ SUMITOMO តែប៉ុណ្ណោះទេ តែខ្ញុំគិតថាជាការចំណេញដ៏ធំចំពោះក្រុមហ៊ុន MATSUSHITA ផងដែរ។

ខ្ញុំប្រាកដជាមិនគិតថាឱ្យអ្នកសម្រេចចិត្តរាប់ៗនោះទេ ខ្ញុំនឹងមកបន្តទៀត ដូច្នេះសូមអ្នកគិតរឿងនេះម្តងទៀតកុំខាន"។

ខ្ញុំគិតថា គាត់ប៉ិនប្រសប់និយាយគ្រាន់បើ។ ប៉ុន្តែ រឿងនេះមិនមែនជាមូលហេតុដែលធ្វើឱ្យខ្ញុំរំជួលចិត្តនោះទេ ទើបខ្ញុំមិនខ្វល់ខ្វាយអំពីការដែលគេមកលេងជាលក្ខណៈឯកជនឡើយ។ ខ្ញុំនៅតែស្វាគមន៍គេដដែល ពីព្រោះថាខ្ញុំមានជំនឿចិត្តទៅលើការខិតខំប្រឹងប្រែងរបស់គាត់។ ដូច្នេះ នៅពេលមានដំណើរការបានបន្តិច គាត់ក៏មកម្តងទៀត។ មួយរយៈក្រោយមក គាត់ក៏ខិតខំប្រឹងប្រែងបបួលម្តងទៀត។ ដោយលើកពីការដែលយើងរកស៊ីជាមួយធនាគារ SUMITOMO នោះនឹងមានការរីកចម្រើនទៅដល់ក្រុមហ៊ុនអគ្គិសនី MATSUSHITA ថែមទៀតបែបណា ហើយគាត់ក៏ទទូចឱ្យខ្ញុំដាក់ទុនរកស៊ី។ នៅទីបំផុត ខ្ញុំក៏ចាញ់ភាពខំប្រឹងប្រែងរបស់គាត់។ ខ្ញុំក៏ចាញ់គាត់ ដោយសារខ្ញុំក៏មានការរំភើបចិត្តយ៉ាងខ្លាំងនិងដោយសារតែលើកមុនៗយើងបានពិភាក្សាគ្នារហូតដល់កើតមានភាពស្និទ្ធស្នាលជាមួយគ្នា ហើយក៏ដោយសារតែមនោសញ្ចេតនា ទើបបណ្តាលឱ្យខ្ញុំចាញ់គាត់។ ខ្ញុំត្រូវបានគេនិយាយបញ្ចុះបញ្ចូលបាន។

ការពិតទៅទឹកចិត្តមនុស្សយើង ពិតជាមានការចម្លែកមែន។ នោះគឺជាមនោសញ្ចេតនាពីធម្មជាតិ តើមែនឬទេ ? ជាបន្តទៅទៀតនេះ យើងត្រូវតែឆ្លុះបញ្ចាំងនូវហេតុផលដែលបណ្តាលឱ្យយើងព្រមព្រៀងនោះ។ ហេតុផលទី១គឺការដែលរកស៊ីជាមួយធនាគារ SUMITOMO គឺមកពីគេមានជំនឿចិត្តយ៉ាងខ្លាំង ថានឹងមានចំណូចល្អ គឺគ្មានចំណុចអាក្រក់។

ហេតុផលមួយទៀតគឺ យើងកំពុងតែរកស៊ីជាមួយនឹងធនាគារ YUUGO មួយភាគធំ ប៉ុន្តែយើងគ្មានគោលការណ៍ពិសេសដែលចង់ថាត្រូវរកស៊ីតែជាមួយធនាគារតែមួយប៉ុណ្ណោះទេ។ យើងមានចិត្តចង់ចាប់ផ្តើមសាកល្បងរកស៊ីទៅតាមលក្ខខណ្ឌនោះលមើល។ នៅទីបំផុត ត្រូវគេបញ្ចុះបញ្ចូលខ្ញុំបានចាញ់ចំពោះការខំប្រឹងប្រែងរបស់អ្នកបញ្ចុះបញ្ចូល។ ខ្ញុំនិយាយ ៖ "ខ្ញុំព្រមចាញ់លោកហើយ យើងចាប់គិតពីការចូលហ៊ុនរកស៊ីទៅ។ ប៉ុន្តែចំពោះការរកស៊ីខ្ញុំមានសង្ឃឹមចំពោះលក្ខខណ្ឌមួយ។ បើអ្នកអាចទទួលបានយើងនឹងចាប់ផ្តើមរកស៊ីជាមួយគ្នា"។

បុគ្គលិកធនាគារនោះមានការសប្បាយរីករាយដោយបានប្រើពេលមួយឆ្នាំដើម្បីបញ្ចុះបញ្ចូលយើងឱ្យរកស៊ីជាមួយ។ គាត់មានទឹកមុខរីករាយ ហើយបានមកលេងនឹងខ្ញុំជារៀងរាល់ថ្ងៃ។ ប៉ុន្តែ នៅខាងខ្ញុំឯណោះមានដាក់លក្ខខណ្ឌមួយ។ បុគ្គលិកធនាគារបានសួរ ៖ "តើវាជាលក្ខខណ្ឌបែបណា ? សូមលោកជួយប្រាប់ផង ខ្ញុំនឹងខំធ្វើតាមលក្ខខណ្ឌទាំងនោះតាមលទ្ធភាពរបស់ខ្ញុំ"។

ខ្ញុំបានសម្លឹងមើលទឹកមុខដ៏ហ្មត់ចត់របស់ដៃគូយ៉ាងយូរ ។ ខ្ញុំបានជឿលើអនាគតរបស់ក្រុមហ៊ុន អគ្គិសនី MATSUSHITA ហើយដោយសារខ្ញុំគិតចាប់ផ្តើមរកស៊ីដើម្បីឱ្យក្រុមហ៊ុន MATSUSHITA មានការរីកចម្រើននោះ ។ យើងត្រូវតែធ្វើឱ្យគេទុកចិត្តទៅលើក្រុមហ៊ុន MATSUSHITA ។ ដូច្នេះ ហើយការចាប់ផ្តើមធ្វើជំនួញជាថ្មី ក៏មានអត្ថន័យដែរ ។ បើមិនដូច្នេះទេ ការចាប់ផ្តើមធ្វើជំនួញនោះ មានន័យតិចតួច ។

មកដល់ទីនេះ ខ្ញុំបានដាក់លក្ខខណ្ឌមួយដោយសូមឱ្យធនាគារ SUMITOMO យល់ព្រមឱ្យលុយខ្ចី ។ ចាប់ពីពេលដំបូងគេត្រូវឱ្យយើងខ្ចីរហូត ២០ ០០០យ៉េន តាមដែលយើងត្រូវការ ។ ការដាក់លក្ខខណ្ឌនៅពេលនោះពិតជាមានការយកចិត្តទុកដាក់យ៉ាងខ្លាំង ។

ដោយសារតែការចាប់ផ្តើមធ្វើជំនួញជាមួយធនាគារ SUMITOMO ទើបអាចធ្វើឱ្យក្រុមហ៊ុន អគ្គិសនី MATSUSHITA ចៀសផុតពីវិបត្តិក្នុងឆ្នាំ ១៩២៧ ។

(ដកស្រង់និងកែសម្រួលពីឯកសារ វិធីសាស្ត្រនៃការគ្រប់គ្រងនិងប្រើប្រាស់មនុស្សឱ្យអស់ពីសមត្ថភាព
របស់លោក ម៉ាស៊ីស៊ិតា កូណូស៊ីកិ ទំព័រ ៦៥-៦៩ បោះពុម្ព ខែ កុម្ភៈ ឆ្នាំ ២០០៣)

សំណួរ

១. ចូរសង្ខេបអត្ថបទខាងលើ ។

២. តើអត្ថបទនេះនិយាយអំពីអ្វី ? (ប្រធានបទ)

៣. តើអ្នកបញ្ចុះបញ្ចូលជានរណា ? គេបាននិយាយបញ្ចុះបញ្ចូលដូចម្តេចខ្លះ ?

៤. តើអ្នកណាដែលត្រូវគេបញ្ចុះបញ្ចូល ? គេបដិសេធការបញ្ចុះបញ្ចូលដោយប្រើពាក្យអ្វីខ្លះ?

៥. តើការបញ្ចុះបញ្ចូលក្នុងអត្ថបទខាងលើនេះបានសម្រេចលទ្ធផលបែបណា ? ចូរបង្ហាញ ។

៦. តើអត្ថបទខាងលើមានន័យអប់រំដូចម្តេច ?

៧. បើអ្នកជាអ្នកផ្សព្វផ្សាយផលិតផលសាប៊ូក្រអូបម៉ាក X តើអ្នកប្រើពាក្យអ្វីដើម្បីបញ្ចុះបញ្ចូលឱ្យអតិថិជនជឿជាក់លើសាប៊ូនេះ ?

នាមការក៍ ឬការកនាម

អ្នកធ្លាប់បានសិក្សាអំពីកំណើតនាមការក៍ នាមករណ៍ខ្លះៗរួចមកហើយ។ ពេលនេះអ្នកនឹងសិក្សាអំពីទម្រង់នាមការក៍ ឬការកនាម និងកំណើតរបស់នាមនោះ។

ចូរពិនិត្យឧទាហរណ៍ :

១. អ្នកភ្ជួរ អ្នករាស់ អ្នកស្រូង បំពេញភារកិច្ចរៀងៗខ្លួនយ៉ាងសកម្ម។ "ពាក្យអ្នកភ្ជួរ អ្នករាស់ អ្នកស្រូង " ជានាមការក៍។ ចូរមើលទម្រង់នៃនាមការក៍ខាងក្រោម ៖

- អ្នកភ្ជួរ < អ្នក + ភ្ជួរ (កិ)
- អ្នករាស់ < អ្នក + រាស់ (កិ)
- អ្នកស្រូង < អ្នក + ស្រូង (កិ)។

២. ពូសំជាថ្មើរព្រៃម្នាក់។ សត្វដំបូងដែលគាត់ជួបគឺល្មួន។ ពាក្យ "ថ្មើរ ល្មួន"ជានាមការក៍។ ចូរមើលទម្រង់នៃនាមការក៍ខាងក្រោម ៖

- ថ្មើរ < ជើរ + ផ្នត់ជែក [-ម-]
- ល្មួន < លួន + ផ្នត់ជែក [-ម-]។

៣. អ្នកតូចក្តី អ្នកធំក្តី ត្រូវចេះអធ្យាស្រ័យគ្នាទៅវិញទៅមកនិងរក្សាសាមគ្គីភាពឱ្យបាន ទើបមានឈ្មោះថាជាអ្នកខ្ពស់ អ្នកប្រាជ្ញ ពុំមែនជាអ្នកលួង ឬអ្នកខ្លៅ។ ពាក្យ " អ្នកតូច អ្នកធំ អ្នកខ្ពស់ អ្នកប្រាជ្ញ "ជានាមការក៍។ ចូរមើលទម្រង់នៃនាមការក៍ខាងក្រោម ៖

- អ្នកតូច < អ្នក + តូច (គុ)
- អ្នកធំ < អ្នក + ធំ (គុ)។

៤. អ្នកស្រែ អ្នកចម្ការ អ្នកក្រុង នាំគ្នាប្រយុទ្ធស្ថារសេដ្ឋកិច្ចពុំឈប់ឈរ។ ពាក្យ "អ្នកស្រែ អ្នកចម្ការ ..."ជានាមការក៍។ ចូរមើលទម្រង់នៃនាមការក៍ខាងក្រោម ៖

- អ្នកស្រែ < អ្នក + ស្រែ (ន)
- អ្នកចម្ការ < អ្នក + ចម្ការ (ន)។

ដូចនេះនាមការក៍ឬការកនាមកើតអំពី

អ្នក + កិរិយា (ឧទាហរណ៍ទី ១)		អ្នក + គុណនាម (ឧទាហរណ៍ទី ៣)	
កិរិយា + ផ្នត់កម្លាយ (ឧទាហរណ៍ទី ២)		អ្នក + នាម (ឧទាហរណ៍ទី ៤)	

នាមការក៍ឬការកនាម គឺជានាមសម្តែងអ្នកធ្វើអំពើ ឬអ្នកមានសភាពលក្ខណៈបែបណាមួយ។ នាមការក៍ឬការកនាមមានកំណើតពីកិរិយា គុណនាម និងនាម។

កំណត់សម្គាល់ : នាមការក៍ ក្នុងភាសាបាលីសំស្ក្រឹត អាចសម្គាល់បានដោយសារផ្តត់ចុងក្រោយបច្ច័យ និងមានបច្ច័យបីទៀត (ឥនី ឥ ឆ្ឆ) សម្រាប់បន្ថែមលើពាក្យឱ្យក្លាយទៅឥត្តីលិង្គ។

ឧទាហរណ៍ :

កម្មករ	(ប៉ុំ)	កម្មការិនី	(ឥ)
ទាយក	(ប៉ុំ)	ទាយិកា	(ឥ)

លំហាត់

១. ចូររកការកនាមក្នុងឃ្លះខាងក្រោម ៖

តំបន់ព្រៃនេះមិនធ្លាប់មានអ្នកស្រែ ឬអ្នកក្រុងណាមកតាំងទីលំនៅ និងប្រកបរបរនៅទីនេះទេ។ អ្នកដែលរស់នៅតំបន់នេះ ភាគច្រើនជាទ្រមាក់ដំរី និងអ្នកភ្នំនេះតែម្តង។

២. ចូររកកំណើតនាមការក៍ទាំងនេះ ៖

ល្មួច អ្នកជំងឺ ខ្មាន់ អ្នកច្រូត អ្នកទន្លេ។

រយៈពេលដ៏យូរកន្លងផុតទៅ ប្រជាជនស្ងួតត្រង់ពុំអាចរកឃើញការពិតក្នុងរឿងសុបិននេះឡើយ។ លុះដល់សម័យវិទ្យាសាស្ត្រីរកចម្រើន មានវេជ្ជវិទូ ដ៏ល្បីម្នាក់ឈ្មោះ "ប៉ាប្លូប" បានខិតខំស្រាវជ្រាវអស់មួយជីវិត ទើបគាត់បើកអាថ៌កំបាំងនេះដោយរបៀបវិទ្យាសាស្ត្រ។

លោក "ប៉ាប្លូប" បានបកស្រាយអំពីបញ្ហាសុបិនដូច្នេះ ៖ ពេលថ្ងៃមនុស្សប្រកបការងារគ្រប់ប្រភេទ។ ពេលធ្វើការខួរក្បាលយើងបានទទួលប្រតិកម្មផ្សេងៗនាំឱ្យមានចលនារស់រវើក។ លុះពេលសម្រាន្តលក់ ខួរក្បាលយើងស្ថិតនៅក្នុងសភាពស្ងៀមគ្មានទិដ្ឋភាពក្រៅណាមួយដែលនាំឱ្យមានប្រតិកម្មដល់ខួរក្បាលយើងឡើយ។ ប៉ុន្តែនៅពេលរលីវៗហៀបនឹងលក់ស៊ប់និងមុនពេលភ្ញាក់ពីដេក (តែយើងមិនទាន់ដឹងខ្លួនមែនទែន) ពេលនោះអាចឱ្យយើងយល់សុបិន។ សុបិននេះកើតមកពីការហាត់នឿយខ្លាំង។ សភាពការណ៍ដែលជួបប្រទះនាពេលថ្ងៃជះឥទ្ធិពលឬមានការជិតជាមនៅក្នុងខួរក្បាល ក៏បណ្តាលឱ្យអារម្មណ៍យើងកើតជាសុបិនផ្សេងៗ។

សំណួរ

១. តើអត្ថបទខាងលើនេះនិយាយពីអ្វី ?

២. ចូរស្រង់នាមការក៍ ឬការកនាមដែលមានក្នុងអត្ថបទខាងលើ រួចរកកំណើតរបស់នាមការក៍នីមួយៗ។

៣. ក្នុងចំណោមពាក្យខាងក្រោមតើពាក្យណាខ្លះជានាមការក៍ ឬការកនាម ?

ការសង្កេត អ្នកភូមិ ជំនួញ សេចក្តីចម្រើន អ្នកតូច ខ្មាន់កាំភ្លើង អ្នកធំ ការអត់ធ្មត់ អ្នកក្លាហាន។

សាមគ្គីធម៌

ក. សិក្សាពាក្យគន្លឹះ

- រង្កៀស (កិ) : នឹកពិភាល់ មិនទុកចិត្ត មិនអស់ចិត្ត មិនស៊ប់ចិត្ត ឈ្នើសចិត្ត នឹកស្តាយក្រោយ។
- រឱសឋាន (ន) : សេចក្តីហ្មងគ្នង ឬមោះហ្មង មោះមែដែលនាំឱ្យក្តៅក្រហាយ ស្អុះស្អាប់ បែកចិត្តគំនិតគ្នាឬបែកឃ្លាតចាកទី ចាកលំនៅ។
- ឧត្តុង្គឧត្តម (គុ) : ខ្ពង់ខ្ពស់លើសលែង ប្រសើរកន្លង។
- បច្ចាមិត្ត (ន) : អមិត្ត សត្រូវ។
- ប្រមាថ (ន) : ការបៀតបៀនគេ ការញ៉ាំញីគេ ការធ្វើទុក្ខបុកម្នេញឱ្យគេលំបាក ការមើលងាយគេ។
- ពាធា (កិ) : បៀតបៀន សម្លាប់។

- អស្មិមានៈ (ន) : សេចក្តីប្រកាន់ចិត្តរឹងត្អឹង ថាអញ ថាគេឬថាយើងថាគេ មិនព្រមទទួលជឿ ស្គាល់អ្នកណា ។ អស្មិមានៈ មានបីយ៉ាងគឺ ១.ប្រកាន់ថាស្រេចនឹងអញ គ្មាននរណាម្នាក់ដល់អញ ២.ប្រកាន់ថាគេយ៉ាងម៉េចអញយ៉ាងម៉េចដូចៗ តែគ្នា ៣.ប្រកាន់ថាខ្លួនអញថយថោកអាប់អន់ទន់ខ្សោយជាងគេ មិនដល់គេ ឬ "គេដោយគេ អញដោយអញ" ។
- ច្រណែន (កិ) : មិនសុខចិត្តដោយគេបានលើសខ្លួន ឬដោយគេបាន ខ្លួនមិនបាន ។
- ឈ្នានីស (កិ) : ច្រណែនឫស្សា កាត់លាភ កាត់ប្រយោជន៍គេ ។
  (ន) : អំពើច្រណែនឫស្សា កាត់លាភ កាត់ប្រយោជន៍គេ ។
- ឧបាយកល (ន) : ល្បិចល្បែងយ៉ាងល្អិត ។
- ទុច្ចរិត (ន) : ដំណើរប្រព្រឹត្តអាក្រក់ដោយកាយ វាចា ចិត្ត(អកុសល) ។
- សាធារណប្រយោជន៍ (គុ) : ប្រយោជន៍សម្រាប់សាធារណជន ។
- ស្រវាស្រទេញ(កិ) : ខំប្រឹងខ្លាំង សង្វាតខ្លាំង ខ្ចីឃ្មាតសង្វាតពេញកម្លាំង ។
  (កិវិ) : ធ្វើការស្រវាស្រទេញ ឈឺរ៉ាលស្រវាស្រទេញ ។
- ធ្នូង (ន) : តួសរសៃខ្នាញ់ត្រកួញឬធ្មួញ ។ ធ្នូងមួយគឺរួមគំនិតគ្នា វេញគំនិតចូលគ្នា ដូចគេវេញខ្សែចូលធ្នូង ។
- វឌ្ឍនភាព (ន) : ភាវៈ ឬដំណើរនាំឱ្យចម្រើន ។
- កេរ (ន) : ដំណែល ជាសម្បាច់របស់ជូនតាឬមាតាបិតាជាដើម ។
- ឆន្ទៈ (ន) : សេចក្តីប្រាថ្នា បំណង គំនិត ការយល់ព្រម ។
- ឃ្លាង (កិឬកិវិ) : ដើរជ្រួស ដើរជ្រួសគ្នា ។
- ប្រតិបត្តិ (ន) : ការប្រព្រឹត្ត កាន់ ការធ្វើតាម ។
- ឧបសគ្គ (ន) : ឧបទ្រព ចង្រៃ គ្រឿងទើសទាស់ គ្រឿងជំទាស់ គ្រឿងរារាំងដំណើរ ។
- ចង្អៀត (កិឬគុ) : ទីទៃពីទូលាយ ចង្អៀតចង្អល់ គឺចង្អៀតពេកទាំងទីលំនៅទាំងផ្លូវចិត្ត ។
- កាតព្វកិច្ច (ន) : កិច្ចដែលគួរធ្វើ ការងារដែលត្រូវតែធ្វើ ។
- សន្តោស (ន) : ការប្រណីសេចក្តីត្រេកអរ ពេញចិត្តចំពោះវត្ថុជារបស់ខ្លួនគឺបានប៉ុន្មានក៏ល្មមចិត្តត្រឹមប៉ុណ្ណោះ មិនរវះរវាម មិនវាទទីហួសហេតុឬហួសទំនង ។
- និន្ទា (ន) : ដំណើរតិះដៀល ការរិះគន់ ដំណៀល ។ និន្ទាឈ្នានីស គឺការរិះគន់ផងច្រណែនឫស្សាផង ។

ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទនេះ ចូរអ្នកយកចិត្តទុកដាក់ដើម្បីត្រៀមឆ្លើយសំណួរទាក់ទងទៅនឹងប្រធានបទនៃអត្ថបទ ខ្លឹមសារនៃពាក្យសាមគ្គី អត្ថប្រយោជន៍នៃសាមគ្គីធម៌ ផលនៃសាមគ្គី។

គ. អត្ថបទ

សាមគ្គីធម៌ គឺសេចក្តីព្រមព្រៀងដោយស្រុះស្រួលគ្នា ប្រកបដោយក្តីស្មោះអស់អំពីចិត្ត ឥតកិច្ចកលប្រាសចាកសេចក្តីរង្កៀស រឱសហានរវាងមនុស្សនឹងមនុស្សក្នុងសង្គម។

សាមគ្គីធម៌កើតឡើងបានអាស្រ័យដោយចិត្តជាកត្តាកំណត់។ ចិត្តជាអ្នកដេញដោល រកហេតុផលឱ្យស្របទៅតាមឆន្ទៈរបស់ខ្លួន។ កាលបើចិត្តត្រិះរិះទៅហើយ ឃើញថាមានហេតុផលឃ្លាងពីឆន្ទៈនៃខ្លួន ចិត្តក៏អាក់អន់ ហើយងាកទៅរកហេតុផលដទៃដែលសមស្របទៅតាមប្រាថ្នាខ្លួនឯងវិញ។ កាលបើចិត្តត្រិះរិះទៅហើយឃើញមានហេតុផលសមតាមឆន្ទៈនៃខ្លួន ចិត្តក៏នឹងមានសេចក្តីរីករាយទទួលយ៉ាងត្រង នូវហេតុផលនោះទុកជាគតិប្រតិបត្តិនៃខ្លួនដោយមានទាំងកាយវាចាស្របទៅតាមផង។

ក្នុងការរក្សាចំណងសាមគ្គីឱ្យរឹងមាំ យើងម្នាក់ៗត្រូវមានសេចក្តីតស៊ូនិងអត់ធន់ ពុះពារគ្រប់ឧបសគ្គ ទោះបីជួបសេចក្តីនឿយលំបាកចង្អៀតចង្អល់យ៉ាងណាក៏ដោយ ក៏ត្រូវអត់ទ្រាំចំពោះកាតព្វកិច្ចនោះឱ្យទាល់តែសម្រេចផលតាមប្រាថ្នា។ យើងត្រូវមានសេចក្តីសន្តោស និងក្តីស្មោះស្មើ ចំពោះកិច្ចការដែលយើងធ្វើទៅហើយទោះបានផលតិចឬច្រើនយ៉ាងណាក្តី ឬមិនសមបំណងក្តី យើងត្រូវទទួលយកដោយរីករាយ។ លើសពីនេះ យើងមិនត្រូវមើលងាយជនណាមួយឡើយពោលគឺ មិនប្រកាន់វណ្ណៈពណ៌សម្បុរ។ ជាពិសេសយើងត្រូវចៀសឱ្យផុតនូវការប្រកួតប្រកាន់ច្រណែននិន្ទាឈ្នានីសចំពោះគ្នានិងគ្នាឡើយ ពោលគឺមានតែសេចក្តីស្មោះត្រង់ទៅវិញទៅមក។

មនុស្សម្នាក់ៗគប្បីហាត់ពត់ទូន្មានចិត្ត កុំប្រណាំងប្រជែងដណ្តើមយកឈ្នះ គួរបោះបង់អស្មិមានៈឱ្យជ្រះស្រឡះចាកចេញពីគំនិត ហើយបណ្តុះស្មារតីយោគយល់អធ្យាស្រ័យឱ្យមានជាដរាបក្នុងចិត្ត។ ការស្មោះស្ម័គ្ររកគ្នា មិនមានការច្រណែនឈ្នានីស គ្មានការប្រមាថជីពជន្មគ្នា ដោយឧបាយកលទុច្ចរិតផ្សេងៗជាកំណប់ទ្រព្យដ៏ប្រសើរសម្រាប់យើងទាំងអស់គ្នា។ យើងត្រូវស្រវាស្រទេញរួបរួមគ្នាជាធ្លុងមួយធ្វើការជាសាធារណប្រយោជន៍ជូនដល់មាតុភូមិយើងដូចសុភាសិតក្រឹត្យនាសតវត្សរ៍ទី ២ បាននិយាយថា"គេឱ្យកិត្តិយសទៅឃ្មុំពីព្រោះវាធ្វើការពុំមែនដើម្បីតែខ្លួនវាឡើយ គឺដើម្បីសម្បុកទាំងមូល"។

ជនទាំងឡាយត្រូវចងចាំថា សាមគ្គីអាចមានផលចម្រើនពីរយ៉ាងគឺមួយផលចម្រើនខាងល្អ និងមួយទៀតគឺចម្រើនខាងអាក្រក់ ។

ដូចនេះ សាមគ្គីធម៌ជាឧបករណ៍ឧត្តុង្គឧត្តមបំផុត និងជាអាវុធដ៏ពូកែស័ក្តិសិទ្ធិសម្រាប់មនុស្សទូទៅ ។ ការព្រមព្រៀងគ្នាដោយកាយវាចាចិត្ត ពិតជាកម្លាំងដ៏ខ្លាំងក្លាឥតមានបច្ចាមិត្តណាប្រមាថពាធាបំផ្លិចបំផ្លាញបានឡើយ ។ ដើម្បីរក្សាទឹកដី កេរដំណែលវប្បធម៌ សម្បត្តិធម្មជាតិ និងជាតិសាសន៍របស់ខ្លួន ខេមរបុត្រទាំងឡាយគប្បីបន្តនិងពង្រីកបន្ថែមនូវសាមគ្គីធម៌ក្នុងគោលបំណងរួមគឺថែរក្សាកម្ពុជទេសឱ្យរុងរឿងគង់វង្សស្ថិតស្ថេរទៅអនាគត ។

(ដកស្រង់ និងកែសម្រួលពីសៀវភៅបញ្ហាសាមគ្គី របស់សមាគមមិត្តសាលាបាលីកម្ពុជរដ្ឋ បោះពុម្ពឆ្នាំ១៩៥៣)

សំណួរ

១. ដូចម្តេចដែលហៅថាសាមគ្គីធម៌ ?

២. ចូររកប្រធានបទនៃអត្ថបទខាងលើ ?

៣. តើសាមគ្គីធម៌កើតឡើងបានអាស្រ័យទៅលើអ្វី ?

៤. តើយើងត្រូវធ្វើដូចម្តេចដើម្បីរក្សាចំណងសាមគ្គីភាពឱ្យរឹងមាំ ?

៥. តើសាមគ្គីធម៌មានផលចម្រើនប៉ុន្មានយ៉ាង ? អ្វីខ្លះ ? ចូរពន្យល់និងលើកឧទាហរណ៍ ។

៦. ចូររកអត្ថប្រយោជន៍នៃសាមគ្គីធម៌ ។

ដើមកំណើតទំនៀមផ្កាស្លាបី

ក. សិក្សាពាក្យគន្លឹះ

- សិល្បៈសាស្ត្រ (ន) : ក្បួនរៀនសិល្បៈ ចំណេះខាងជាង ខ្មែរច្រើននិយាយមន្តអាគមផ្សេងៗ ។
- ទិសាបាមោក្ខ (ន) : អាចារ្យជាប្រធានក្នុងទិស អាចារ្យធំដែលចេះវិជ្ជាគ្រប់ប្រភេទ អាចារ្យជាប្រធាននៃសិស្សគ្រប់ទិស ។
- ស័ក្តិសិទ្ធិ (ន) : សេចក្តីសម្រេចដែលវិសេសវិសាល ដែលពូកែឆុតឆាប់ ដែលខ្លាំងពូកែ ។
- មហាលាភ (ន) : លាភធំ ។
- ខ្ពួ (ន) : សំណុំផ្កាដួង ផ្កាដួងស្លាជាដើម ។

ខ. អភិវឌ្ឍន៍បំណិន

ពេលអ្នកអានអត្ថបទនេះ សូមអានដោយយកចិត្តទុកដាក់ ដើម្បីត្រៀមឆ្លើយសំណួរមួយចំនួនដែលទាក់ទងទៅនឹងការបញ្ចុះបញ្ចូល ការបង្ហាញមតិផ្ទាល់ខ្លួន អំពីប្រធានបទ នាមការក៍ ... ។

គ. អត្ថបទ

ក្នុងពិធីរៀបអាពាហ៍ពិពាហ៍របស់ខ្មែរ យើងឃើញមានបែបបទនិងពិធីជាច្រើនដូចជា ពិធីចូលស្តីដណ្តឹង កាត់សក់ កាត់ផ្កាស្លា សូត្រមន្ត សែនក្តួចចងដៃ សំពះផ្ទឹម ។ល។ ក្នុងពិធីសំពះផ្ទឹម គេឃើញមានផ្កាស្លាបីសំណុំសម្រាប់បាចក្នុងពិធីនេះ ។ រឿងដែលទាក់ទងនឹងផ្កាស្លាបីនេះមានដូចតទៅ ៖

មានកុមារកំព្រា៤នាក់ជាសម្លាញ់គ្នាមានឈ្មោះមិនប្រាកដ បានបបួលគ្នាទៅរៀនសិល្ប៍សាស្ត្រ។ លុះធ្វើដំណើរយូរទៅ ក៏ទៅជួបអាចារ្យទិសាបាមោក្ខម្នាក់ដែលជាអ្នកបង្រៀនសិល្ប៍វិជ្ជាគ្រប់មុខ។ កុមារទាំងបួននាក់ចូលទៅលើកដៃសំពះសុំស្នាក់នៅដើម្បីឱ្យអាចារ្យបង្រៀនសិល្ប៍សាស្ត្រ។ អាចារ្យព្រមទទួលកុមារទាំងបួន ឱ្យជ្រកកោនជាមួយ។ កុមារទាំងបួននោះខំយកចិត្តទុកដាក់ បម្រើអាចារ្យអស់រយៈពេល៥ឆ្នាំ មិនឱ្យអាក់អន់ស្រពន់ចិត្តអ្វីឡើយ។ អាចារ្យក៏មានមេត្តាបង្រៀនសិល្ប៍វិជ្ជាគ្រប់គ្នា គឺម្នាក់រៀនគម្ពីរហោរា ម្នាក់រៀនសិល្ប៍បាញ់ធ្នូ ស្នា ម្នាក់រៀនសិល្ប៍មុជទឹក ម្នាក់ទៀតរៀនសិល្ប៍ប្រស់ជីវិតមនុស្ស សត្វ ដែលស្លាប់ហើយឱ្យរស់ឡើងវិញបាន។ ទាំងបួននាក់រៀនចេះសិល្ប៍ដ៏វិសេសផ្សេងៗគ្នា។

សម័យថ្ងៃមួយ អ្នកទាំងបួនក៏គិតគ្នា "យើងទាំងអស់គ្នារៀនសិល្ប៍វិជ្ជាចេះគ្រប់ៗគ្នាហើយ រឹងខ្លួនក៏ធំពេញវ័យហើយដែរ ដូច្នេះពួកយើងនាំគ្នាទៅសុំលាព្រះគ្រូអាចារ្យ ទៅស្វែងរកទ្រព្យសម្បត្តិប្រពន្ធកូនរៀងៗខ្លួនចុះ"។ គិតព្រមគ្នារួចហើយ ក៏ចូលទៅក្រាបបង្គំលាព្រះអាចារ្យ។ លោកអាចារ្យក៏យល់ព្រមតាមសេចក្តីប្រាថ្នា ឥតបើឃាត់ឃាំងអ្វីឡើយ។ អ្នកទាំងបួន ក្រោយពីលាព្រះអាចារ្យរួច ហើយក៏ដើរទៅដល់សមុទ្រធំរកទូកឬសំពៅនឹងឆ្លងទៅត្រើយម្ខាង តែរកពុំបានក៏នាំគ្នាដេកសម្រាកក្រោមដើមឈើនាមាត់សមុទ្រនោះ។ អ្នកទាំងបីនាក់និយាយនឹងអ្នករៀនគម្ពីរហោរា "សម្លាញ់ ! សម្លាញ់ឯងបានរៀនខាងវិជ្ជាហោរាសាស្ត្រ យើងចង់ដឹងណាស់ថាតើវិជ្ជានេះ ពូកែស័ក្តិសិទ្ធិយ៉ាងណា? ម្យ៉ាងទៀតតើពួកយើងនឹងមានលាភអ្វីខ្លះ ?" បុរសដែលរៀនវិជ្ជាហោរាក៏ចាប់វាយលេខមើលសព្វគ្រប់ហើយទាយថា ស្អែកនេះនាពេលព្រឹកថ្ងៃពេញពន្លឺ យើងនឹងមានមហាលាភធំ តាមទំនាយថានឹងមានសត្វឥន្ទ្រី ចាប់ពាំកូនក្រមុំស្តេចមួយអង្គ ហើរឆ្លងសមុទ្រមកពីទិសបូព៌ាយ៉ាងប្រាកដ តើពួកអ្នកនឹងគិតដូចម្តេច ? បុរសចេះសិល្ប៍បាញ់ធ្នូទទួលវ៉ាប់រង "ត្រង់នេះទុកឱ្យខ្ញុំ ខ្ញុំនឹងបាញ់ដណ្តើមយកនាងនោះពីមាត់ សត្វនោះឱ្យបាន កុំបារម្ភ"។

លុះព្រឹកឡើងថ្ងៃរះពេញពន្លឺ ក៏មានសត្វឥន្ទ្រីពាំកូនក្រមុំស្តេច ហើរឆ្លងសមុទ្រមកមែន។ បុរសចេះបាញ់ធ្នូ ហេតុតែគ្រេកអរពេកឥតពិចារណាក៏បាញ់ទៅភ្លាម ត្រូវសត្វធ្លាក់ទាំងនាងក្រមុំក្នុងទឹកសមុទ្រ។ បុរសចេះមុជទឹកធានាខ្លួន "ខ្ញុំនឹងមុជទៅយកនាងមកឱ្យបានពីក្នុងសមុទ្រ" ហើយក៏លោតទឹកមុជស្រង់នាងនោះបានមកលើគោក តែនាងក្រមុំនោះរលត់សង្ខារទៅហើយ។ បុរសចេះសិល្ប៍ប្រស់ក៏សូត្រសែកសិល្ប៍វិជ្ជាប្រស់នាងនោះរស់ជីវិតឡើងវិញ។ ដោយនាងក្រមុំមានរូបរាងល្អល្អតល្អន់ឥតខ្ចោះ បុរសទាំងបួន ក៏តាំងដណ្តើមចង់យកធ្វើជាប្រពន្ធរៀងៗខ្លួន។

បុរសហោរា "នាងនេះត្រូវបានមកយើង ព្រោះហេតុដើមកើតមកពីយើងទាយ"។

បុរសចេះបាញ់ "អ្នកគ្រាន់តែទាយ កុំតែយើងបាញ់ធ្វើម្តេចនឹងបាន ដូចនេះត្រូវតែឱ្យនាងមកធ្វើជាប្រពន្ធយើង"។

បុរសចេះមុជទឹកតប "អ្នកបាញ់ធ្លាក់កណ្តាលសមុទ្រមែន កុំតែបានយើងមុជទឹកទៅយកមកធ្វើម្តេចនឹងបាន ត្រូវឱ្យនាងមកធ្វើជាប្រពន្ធយើង"។

បុរសចេះប្រស់ "អ្នកទៅយកបានពីក្នុងទឹកមែន តែនាងនោះអស់ជីវិតទៅហើយ បើកុំតែបានយើងចេះប្រស់ ធ្វើម្តេចនឹងបានរស់ឡើងវិញ ដូចនេះ នាងត្រូវបានមកជាប្រពន្ធយើង"។ បុរសទាំងបួនមិនសុខចិត្តរៀងៗខ្លួន ក៏នាំគ្នាបណ្តើរស្រីនោះទៅរកចៅក្រមកាត់ក្តីឱ្យ។ ក្រោយពីទទួលបណ្តឹងចៅក្រមក៏ឈ្វេងយល់ហើយបង្គាប់ទៅបុរសហោរានិងបុរសចេះប្រស់ឱ្យអង្គុយលើអាសនៈខ្ពស់ស្មើគ្នា បុរសចេះបាញ់ឱ្យអង្គុយបន្ទាប់ក្រោម បុរសចេះមុជទឹកឱ្យអង្គុយប្រារព្ធទីក្រោមបង្អស់។ បន្ទាប់មកក្រុមចៅក្រមក៏ប្រជុំកាត់សេចក្តីថា បុរសជាហោរាដែលចេះទាយត្រូវលើកជាឪពុកនាង បុរសចេះប្រស់ឱ្យរស់ជីវិតត្រូវទុកជាម្តាយនាង បុរសចេះបាញ់ធ្នូត្រូវទុកជាបងបង្កើតរបស់នាង ព្រោះបងត្រូវជួយការពារសង្គ្រោះប្អូនស្រី។ ចំណែកឯបុរសចេះមុជទឹកត្រូវទុកជាប្តីនាងនេះ ព្រោះគេបានទៅប៉ះពាល់ដល់រូបកាយនាងមុនគេ តាំងពីក្នុងទឹកមក។ បុរសទាំងបួនក៏យល់ព្រមតាមពាក្យចៅក្រមកាត់សេចក្តី។ ប៉ុន្តែបុរសទាំងបីតបថា លោកវៀបចំទុកជាក់យើងខ្ញុំ ជាឪពុកម្តាយ ជាបងនេះ យើងខ្ញុំសុខចិត្តហើយ តែសូមលោកមេត្តាជ្រើសរើសរបស់អ្វីដ៏ប្រសើរទុកជាតំណាងមង្គលតទៅមុខ ដើម្បីឱ្យកូនប្រសាគំនាប់ឪពុកម្តាយ និងបងក្នុងគ្រានោះផង។ ពេលនោះ គេក៏នាំគ្នាចាត់ចែង រកកាត់ផ្កាស្លាមួយខ្ពយកមករៀបតុបតែងចែកជាបីចំណែកតំណាងអ្នកទាំងបី។ ចំណែកដុំផ្កាស្លាបងត្រូវឪពុកទទួលផ្កាល់ពីដៃកូនប្រសា ចំណែកផ្កាស្លាកណ្តាលត្រូវម្តាយទទួល ចំណែកផ្កាស្លាពៅត្រូវបងបង្កើតទទួល។ ទំនៀមនេះជាប់ជារៀងរហូតមកដល់សព្វថ្ងៃនេះ។

(ដកស្រង់ និងកែសម្រួលពីប្រជុំរឿងព្រេងខ្មែរភាគ ៩ ឆ្នាំ១៩៧៤)

សំណួរ

១. តើអត្ថបទនេះដកស្រង់ពីសៀវភៅអ្វី ?

២. ចូររកប្រធានបទនៅក្នុងអត្ថបទខាងលើ។

៣. តើចៅក្រមបានបញ្ចុះបញ្ចូលដូចម្តេចខ្លះ ? ដើម្បីឱ្យកុមារទាំងបួនយល់ព្រមបញ្ចប់ជម្លោះដោយសន្តិវិធី ?

៤. តើអ្នកយល់ស្របតាមការកាត់ក្តីរបស់ចៅក្រមឬទេ ? ព្រោះអ្វី ?

៥. ចូរសង្ខេបអត្ថបទខាងលើ។

៦. ចូរស្រង់នាមការក៍ឱ្យបាន ៣ ពាក្យពីក្នុងអត្ថបទខាងលើ។

៧. តើទំនៀមទម្លាប់ ផ្កាស្លាបីបង្ហាញពីផ្នត់គំនិតខ្មែរដូចម្តេចខ្លះ ?

១ ទំនាស់



មនុស្សយើងរស់នៅក្នុងសង្គមជាមួយគ្នា ពេលខ្លះក៏មានជម្លោះទាស់ទែងគ្នា តែយើងក៏អាចដោះស្រាយជម្លោះ រឹងប៉ាប់ជម្លោះនោះបានដែរ និងទប់ជម្លោះនោះមិនឱ្យរាលដាលរហូតក្លាយជាសង្គ្រាមនោះឡើយ ។

ឥឡូវចូរអ្នកស្តាប់អត្ថបទ ដើម្បីត្រៀមឆ្លើយនឹងសំណួរខាងក្រោម ៖

១. ចូរដាក់ចំណងជើងអត្ថបទឱ្យបានសមស្រប ។

២. តើអត្ថបទនេះនិយាយពីអ្វីខ្លះ ?

៣. តាមរយៈអត្ថបទខាងលើ តើមនុស្សទាំងអស់ចង់បានអ្វីខ្លះ ?

៤. តើការចេះអត់ឱនគ្នាទៅវិញទៅមកអាចនាំមកនូវអ្វីខ្លះ ?

៥. ដើម្បីរក្សាសន្តិភាពឱ្យស្ថិតស្ថេរ តើអ្នកមានគំនិតយ៉ាងណាខ្លះ ?

ចូលរួមពិភាក្សាទិងបញ្ចេញមតិ

អ្នកធ្លាប់បានសិក្សាអំពីការនិយាយបង្ហាញពីប្រវត្តិខ្លួនឯង ពីការប្រើសង្ឃសព្ទ រាជសព្ទ ដោយប្រើពាក្យសម្តីផ្ទាល់ខ្លួន។ ឥឡូវអ្នកត្រូវសិក្សាអំពីការចូលរួមពិភាក្សាជាក្រុម ដើម្បីដោះស្រាយបញ្ហាមួយ ដែលមានក្រុមផ្សេងទៀតជាគូជជែកក្នុងប្រធានបទតែមួយ។ ការពិភាក្សាគ្នាជាក្រុមបានទទួលលទ្ធផលល្អ អាស្រ័យលើ ៖

- ការគោរពគ្នាទៅវិញទៅមក តាមឋានានុក្រម មានវិន័យ
- ការសហការ រួបរួមសាមគ្គីគ្នា ជួយគ្នាទៅវិញទៅមក
- ការប្រើអស់សមត្ថភាព លទ្ធភាព ចំណេះដឹង ជំនាញ
- ការចេះយល់ពីអារម្មណ៍គ្នាទៅវិញទៅមក
- ការដឹងពីចំណង់ចំណូលចិត្តគ្នាក្នុងក្រុម
- ការចេះស្តាប់យោបល់គ្នា ស្តាប់សំណូមពរអ្នកដទៃ ពិភាក្សាប្តូរយោបល់គ្នា ចេះជជែកវែកញែករកហេតុផល ពិគ្រោះគ្នាដោយមិនលាក់លៀម
- ការចេះរៀបលំដាប់ថ្នាក់ ផែនការច្បាស់លាស់ កំណត់ពេលច្បាស់លាស់ ប្រើប្រាស់ប្រភេទធនធានសមស្របតាមកាលៈទេសៈ
- ការចេះវិភាគលទ្ធផលនៃការងារដែលបានធ្វើរួច ហើយរកចំណុចខ្លាំង ចំណុចខ្សោយ ឧបសគ្គ ឬបញ្ហាប្រឈមដើម្បីកែលម្អសម្រាប់ការងារ ពេលក្រោយទៀត... វាយតម្លៃលទ្ធផលសម្រេចបានជាដើម។

ចូរអ្នកអានកិច្ចពិភាក្សាខាងក្រោម ៖

- **អ្នកសម្របសម្រួល** : សួស្តីមិត្តទាំងអស់គ្នា! ថ្ងៃនេះយើងជួបជុំគ្នាដើម្បីជជែកពិភាក្សាគ្នាអំពីប្រធានបទមួយដែលថា "ការបង្ការជំងឺអេដស៍"។ យើងទាំងអស់គ្នាបានដឹងរួចមកហើយ ជំងឺអេដស៍កើតឡើងដោយសារមេរោគអេដស៍(HIV)។ មេរោគអេដស៍បានរាតត្បាតនិងសម្លាប់មនុស្សនៅលើពិភពលោកអស់ច្រើនណាស់។ ប្រទេសកម្ពុជាយើងក៏ទទួលរងគ្រោះដោយសារជំងឺនេះដែរ។ មកដល់សព្វថ្ងៃនេះពុំទាន់មានអ្នកវិទ្យាសាស្ត្រណារកឃើញច្បាស់លាស់នូវថ្នាំសម្រាប់ព្យាបាលឡើយ។ ដោយសារជំងឺអេដស៍ជាបញ្ហាប្រឈមចំពោះយុវជនក៏ដូចជាមនុស្សទូទៅ ខ្ញុំសូមអញ្ជើញក្រុម "ក" និងក្រុម "ខ" ឡើងជជែកពិភាក្សាគ្នា ហើយផ្សព្វផ្សាយចំណេះដឹង និងបទពិសោធជូនដល់មិត្តភក្តិ ដើម្បីបញ្ចៀសពីការឆ្លងមេរោគអេដស៍។

- ឥឡូវនេះសូមក្រុម "ក" ឡើងបង្ហាញពីការយល់ដឹងរបស់ខ្លួនស្តីពី ហេតុដែលនាំឱ្យមានមេរោគអេដស៍ ជំងឺអេដស៍ !
  - ក្រុម "ក" ជាដំបូងខ្ញុំសូមបញ្ជាក់ថា អ្នកដែលធ្វើឱ្យមនុស្សងាយឆ្លងជំងឺអេដស៍ គឺអ្នកដែលរកស៊ីផ្លូវភេទ និងអ្នកដែលមានដៃគូស្នេហាច្រើន ឆ្លងដោយសារការប្រើប្រាស់ម្ជុល សឺរាុំង ឬប្រើសម្ភារៈទម្លុះស្បែកដែលមិនបានរំងាប់មេរោគ។ ក្រៅពីនេះ មានឧបករណ៍មួយចំនួនទៀតក៏អាចចម្លងមេរោគអេដស៍បានដែរដូចជា កន្ត្រៃកាត់ក្រចក ឡាម ដែកចារ (សាក់) ម្ជុលចោះត្រចៀក ជាដើមដែលគេមិនបានរំងាប់មេរោគជាមុន។
  - ក្រុម "ខ" ក្រុមខ្ញុំយល់ស្របនឹងចម្លើយនេះ ប៉ុន្តែក្រុមខ្ញុំសូមបន្ថែមគំនិតខ្លះៗ គឺការបញ្ជូលឈាមឱ្យអ្នកជំងឺក៏អាចឆ្លងជំងឺអេដស៍ដែរ ប្រសិនបើឈាមមានបញ្ហាឬម្ជុលមិនស្អាតមានជាប់មេរោគអេដស៍។ មានករណីខ្លះមេរោគអេដស៍អាចឆ្លងពីម្តាយទៅកូនក្នុងពេលដែលម្តាយកំពុងពពោះ ហើយក៏អាចឆ្លងដោយការបំបៅដោះកូនដែរ។
- **អ្នកសម្របសម្រួល** : ល្អណាស់ ! សូមអរគុណ ! ក្រុមទាំងពីរបានផ្តល់ព័ត៌មានច្បាស់ណាស់អំពីការឆ្លងជំងឺអេដស៍ តើនៅមានចំណុចសំខាន់អ្វីខ្លះទៀត ? ស្នើក្រុមនីមួយៗឆ្លើយឱ្យច្បាស់លាស់។
  - ក្រុម "ក" ចំណុចសំខាន់នោះគឺការឆ្លងមេរោគអេដស៍ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ដោយសារតែក្នុងចំណោមមនុស្សពីរនាក់នោះមានម្នាក់ផ្ទុកមេរោគអេដស៍ ហើយប្រើសម្ភារៈឧបករណ៍រួមគ្នា ដោយមិនបានសម្លាប់មេរោគ រួចយកមកប្រើប្រាស់សម្រាប់មនុស្សម្នាក់ទៀត ដែលជាហេតុឆ្លងតាមការមុតជិតជាមឈាមបន្តគ្នា។ រីឯការបញ្ជូលឈាមក៏ដូច្នោះដែរ គឺឆ្លងដោយសារថា ឈាមនោះមានមេរោគអេដស៍ជាដើម។
- **អ្នកសម្របសម្រួល** : ល្អណាស់ ! សូមអបអរសាទរ នេះជាចម្លើយបញ្ជាក់ច្បាស់លាស់។ ដើម្បីឱ្យកាន់តែមានភាពច្បាស់លាស់ថែមទៀត បន្តពីនេះសូមក្រុមទាំងពីរបញ្ចេញមតិអំពីការបង្ការជំងឺអេដស៍ ជាបន្តទៀត !
  - ក្រុម "ខ" ពាក្យស្លោកមួយឃ្លាថា "ការពារប្រសើរជាងព្យាបាល" ពាក្យនេះមានន័យល្អណាស់ គឺយើងត្រូវការពារកុំឱ្យធ្លាក់ក្នុងរណ្តៅនៃអ្នកផ្ទុកមេរោគអេដស៍ គឺមិនត្រូវរួមភេទជាមួយបុរស-ស្ត្រីដែលមានដៃគូស្នេហាច្រើន។
  - ក្រុម "ក" កុំប្រើប្រាស់របស់របរដែលអ្នកផ្ទុកមេរោគអេដស៍ធ្លាប់បានប្រើដូចជាម្ជុល សឺរាុំង ដែកចារជាដើម។

- ក្រុម "ខ" លើកពីវិធីបង្ការនេះបានត្រឹមត្រូវហើយ ខ្ញុំសូមបន្ថែមទៀត ៖ ចំពោះខ្ញុំសូមលើកចំណុចមួយចំនួនដែលទាក់ទងទៅនឹងយុវវ័យផ្ទាល់តែម្តង។ យើងនៅក្នុងវ័យសិក្សាត្រូវចៀសឱ្យឆ្ងាយពីគ្រឿងញៀន ព្រោះគ្រឿងញៀនធ្វើឱ្យយើងប្រើប្រាស់ឧបករណ៍ចាក់រួមគ្នាដូចជា ប្រើសឺរាុំង ចាក់ថ្នាំបញ្ចូលក្នុងខ្លួននោះ គឺងាយនឹងរងគ្រោះណាស់ ព្រោះអ្នកដែលរួមក្រុមជាមួយនឹងយើងអាចមានអ្នកផ្ទុកមេរោគអេដស៍ ... ការទទួលទានសុរា ស្រាបៀរក៏មានគ្រោះថ្នាក់ដែរ ព្រោះកាលណាយើងស្រវឹង យើងស្តេចខ្លួនហើយត្រូវគេអូសទាញឱ្យយើងទៅរួមភេទ ពេលនោះយើងអាចមិនបានប្រើស្រោមអនាម័យ។ ទាំងនេះក៏ជាហេតុនាំឱ្យឆ្លងមេរោគអេដស៍ដែរ។ តាមរយៈរឿងចន្ទអាប់រស្មី យើងបានឃើញថា វិទ្ធីត្រូវបានបូរ៉ា អូសទាញឱ្យទទួលទានស្រាទាល់តែស្រវឹង ហើយបានរួមភេទតែមួយដងសោះ ក៏ឆ្លងមេរោគអេដស៍ ហើយត្រូវផ្តាច់ពាក្យពីនាងសុរិយា ជាគូដណ្តឹងដែលស្រឡាញ់ស្មើជីវិត។ ក្នុងករណីមានអ្នកអូសទាញនោះយើងត្រូវ ប្រកាន់ឥរិយាបថម៉ឺងមាត់ តែក្នុងអារម្មណ៍ចេះគោរពគ្នាទៅវិញទៅមក ជាពិសេសប្រើពាក្យទន់ភ្លន់មិនឱ្យអ្នកដទៃមានការឈឺចាប់។
- ក្រុម "ក" បង្ហាញហេតុផលប៉ុណ្ណោះមិនអាចចាត់ទុកថាគ្រប់គ្រាន់នោះទេ ។ យុវវ័យត្រូវចៀសឱ្យផុតការសេពគប់មនុស្សអាក្រក់ ចូលចិត្តនាំដើរលេង មើលវីដេអូអាសអាភាស ហើយបង្ខំឱ្យទៅរួមភេទ ឬក៏មានស្រីកំដរ ដែលខ្លួនយើងកំពុងតែនៅសិក្សា។ បើយើងមានចិត្តងាយ យើងងាយនឹងរងគ្រោះណាស់ ព្រោះថាអ្នកទាំងនោះអាចមានផ្ទុកមេរោគអេដស៍ ព្រោះយើងមើលអ្នកកើតជំងឺនេះ ដោយភ្នែកទទេមិនឃើញឡើយ។
- ក្រុម "ក" ក្រុមខ្ញុំគិតថា យុវវ័យទាំងឡាយត្រូវខិតខំរៀន យកពេលវេលាដ៏មានតម្លៃទៅធ្វើរឿងល្អៗដូចជាជួយការងារចរាចរណ៍ ដូចជាជួយការងារសង្គមឱ្យចាកផុតពីគ្រោះថ្នាក់ចរាចរណ៍។ ហាត់កីឡា ស្រោចបន្លែ ស្រោចផ្កា ជួយការងារផ្ទះ ចូលបណ្ណាល័យ ធ្វើកិច្ចការមានប្រយោជន៍សម្រាប់មនុស្សទូទៅ ...ដើម្បីចៀសផុតពីគ្រឿងញៀន ការតប់ប្រមល់តានតឹងក្នុងអារម្មណ៍ ។ ជាពិសេសត្រូវធ្វើជាកូនល្អ សិស្សល្អ និងជាពលរដ្ឋល្អ ដើម្បីខ្លួនឯងក៏ដូចជាគ្រួសារ និងសង្គមដែរ។

- **អ្នកសម្របសម្រួល** : អរគុណណាស់ចំពោះការពិភាក្សាដែលប្រកបដោយអត្ថន័យយ៉ាងជ្រាលជ្រៅសម្រាប់យើងទាំងអស់គ្នា ។ ដោយសារដល់ពេលវេលាកំណត់ ខ្ញុំសូមឱ្យក្រុមនីមួយៗបង្ហាញកំណត់ត្រារបស់ខ្លួនដល់មិត្តភក្តិ ហើយពិនិត្យមើលថាតើក្រុមណាដែលនិយាយចំបញ្ហា និងផ្តល់ការអះអាងបានច្រើន គួរឱ្យជឿជាក់បាន ។

មិត្តភក្តិទាំងអស់បានឱ្យនិទ្ទេសល្អទៅក្រុមទាំងពីរ ហើយបន្ថែមការសរសើរទៅក្រុម "ក" ថាមានយោបល់ទាក់ទងជីវភាពជាក់ស្តែងច្រើនជាងក្រុម "ខ" ។

ការយល់ដឹងពីសុខភាពបន្តពូជនិងសុខភាពផ្លូវភេទ នាំឱ្យមានសុភមង្គលល្អនិងអនាគតរុងរឿង ។

(កែសម្រួលពីសៀវភៅអប់រំអំពីអេដស៍របស់ក្រសួងអប់រំឆ្នាំ ២០០៦)

សំណួរ

១. តើមេរោគអេដស៍ឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ដោយសារអ្វី ?

២. តើអ្នកមានជំងឺអេដស៍ និងអ្នកផ្ទុកមេរោគអេដស៍មានស្ថានភាពដូចគ្នាឬទេ ?

៣. ចូរបង្ហាញពីវិធីការពារកុំឱ្យមានមេរោគអេដស៍ ។

៤. តាមរយៈអត្ថបទខាងលើ ចូរអ្នកស្រង់ឃ្លាឬពាក្យដែលគិតថាជាភាសាបញ្ចុះបញ្ចូល ។

៥. តើត្រូវប្រើជំនួសពាក្យបែបណាខ្លះ ដើម្បីបដិសេធចំពោះការអួសទាញរបស់មិត្តអាក្រក់ដែលនាំទៅរកភាពវិនាស ?

លំហាត់

ចូរអ្នករៀបចំក្រុមពិភាក្សា ដែលក្រុមនីមួយៗមានគ្នាបីនាក់ ។ រួចជ្រើសរើសប្រធានបទដូចខាងក្រោមតាមការពេញចិត្តរបស់ក្រុមដោយអនុវត្តតាមលំនាំគំរូពិភាក្សាខាងលើ ដែលមានប្រើភាសាបញ្ចុះបញ្ចូល ។

- សាមគ្គីរស់ បែកបាក់សាមគ្គី គឺស្លាប់
- សាមគ្គីជាកម្លាំង ។

អត្ថបទបែបបញ្ចុះបញ្ចូល

អ្នកបានសិក្សារួចមកហើយពីការនិយាយអួសទាញបញ្ចុះបញ្ចូល ការឆ្លើយតបនឹងការបញ្ចុះបញ្ចូល ។

ឥឡូវនេះអ្នកនឹងសិក្សាអំពីការសរសេរអត្ថបទបែបបញ្ចុះបញ្ចូល ។ អ្នកបានដឹងហើយថា ការបញ្ចុះបញ្ចូល គឺជាការប្រើសិល្បៈវិធីអួសទាញទឹកចិត្ត មនោសញ្ចេតនា ដោយមធ្យោបាយផ្សេងៗដូចជា ការនិយាយលួងលោម ទាក់ទាញដោយពាក្យសំដី សម្ភារៈផ្សេងៗ ដើម្បីឱ្យអ្នកដទៃធ្វើតាម ជឿជាក់ ហើយសម្រេចចិត្តទៅតាមគោលបំណងណាមួយដែលអ្នកបញ្ចុះបញ្ចូលចង់បាន ។ ការបញ្ចុះបញ្ចូលមានគោលបំណងពីរយ៉ាង មួយគឺការអួសទាញ បញ្ចុះបញ្ចូលទៅរកផ្លូវល្អ មានប្រយោជន៍ និងមានកិត្តិយស ឯមួយទៀតគឺការអួសទាញបញ្ចុះបញ្ចូលទៅរកផ្លូវអាក្រក់ ដែលគ្មានប្រយោជន៍ មានគ្រោះថ្នាក់ នាំមកនូវមហន្តរាយដល់ខ្លួនឯង គ្រួសារ និងសង្គមថែមទៀតផង ។ ដូច្នេះ ដើម្បីចៀសវាងការចាញ់បោក ការលួងលោម ដែលនាំទៅរកទង្វើអាក្រក់ ឬនាំទៅរកគ្រោះថ្នាក់ អ្នកត្រូវចៀសវាង ហើយត្រូវពិចារណា ឱ្យបានល្អិតល្អន់ ប្រកបដោយភាពឈ្លាសវៃ កុំទន់ចិត្តទៅតាមការបញ្ជោរ លើកសរសើរលួងលោម ឬទិញទឹកចិត្តដោយទឹកប្រាក់ឬសម្ភារៈ ឬដោយមធ្យោបាយណាក៏ដោយ បើធ្វើដូច្នេះ នោះអ្នកនឹងអាចចៀសផុតពីគ្រោះថ្នាក់ ។

លំហាត់

១. ចូរសរសេរអត្ថបទបញ្ចុះបញ្ចូលដោយរើសយកប្រធានបទខាងក្រោម ៖

- ការបញ្ចុះបញ្ចូលមិត្តភក្តិឱ្យខំប្រឹងសិក្សា
- ការបញ្ចុះបញ្ចូលមិត្តភក្តិឱ្យចេះសាមគ្គីគ្នា ។

២. មុនសរសេរសូមអ្នកអនុវត្តតាមការណែនាំដូចខាងក្រោម ៖

- ជ្រើសរើសប្រធានបទ
- រៀបចំប្លង់ឬធ្វើគម្រោងព្រាង ។
  - សេចក្តីផ្តើម : រកគំនិតសំខាន់ៗទាក់ទងនឹងប្រធានបទ
  - តួសេចក្តី :
    + ធ្វើឃ្លាភ្ជាប់សេចក្តី

+ បង្ហាញពី មូលហេតុនៃការសិក្សា តម្លៃនៃចំណេះវិជ្ជា ឬការសាមគ្គី គំនិតអួសទាញ បញ្ចុះបញ្ចូល ដោយប្រើសំនួនអួសទាញ និងបង្ហាញហេតុផលដើម្បីឱ្យគេជឿជាក់ ផ្តល់អំណះអំណាងជាឧទាហរណ៍ ។

+ សន្និដ្ឋាន : ការសិក្សាឬសាមគ្គីពិតជាមានសារៈសំខាន់ចំពោះយុវជន គឺជាទ្រព្យកំណប់ជាប់នឹងខ្លួនដ៏វិសេសវិសាលឥតកាត់ថ្លៃបាន និងនាំឱ្យមានអនាគតល្អ ត្រួសារុងរឿង ប្រទេសជាតិថ្កុំថ្កើង ។

- បញ្ចប់សេចក្តី

+ មតិផ្ទាល់ខ្លួន

+ ឱ្យតម្លៃលើគំនិតអួសទាញបញ្ចុះបញ្ចូលនៃប្រធានបទខាងលើ

+ ឱ្យតម្លៃលើសារប្រយោជន៍នៃចំណេះវិជ្ជា និងការសាមគ្គី ។

៣. ពេលអ្នកសរសេរព្រាងរួច មុននឹងសរសេរសម្រេចអ្នកត្រូវ :

- ពិនិត្យខ្លឹមសារ និងលំដាប់លំដោយខ្លឹមសារនៃសំណេរ
- ពិនិត្យភាពជាប់ទាក់ទង ឬមិនទាក់ទងនឹងប្រធានបទ
- ពិនិត្យពាក្យខុស សញ្ញាសម្ព័ន្ធ ចៀសវាងកំហុសអក្ខរាវិរុទ្ធ ។

មេរៀនទី

ការកំណត់គោលដៅ

គោលដៅជាទិសឬចំណុចដែលកំណត់ទុកជាមុនថាត្រូវតែទៅឱ្យបានដល់ឬថាត្រូវតែសម្រេចឱ្យបាន។ ការកំណត់គោលដៅ គឺជាការរៀបចំផែនការសម្រាប់អនុវត្តក្នុងដំណើរជីវិតរបស់មនុស្សម្នាក់ៗ។ ការចេះកំណត់គោលដៅនាំមកនូវការសម្រេចបំណងប្រាថ្នា។ ប៉ុន្តែ ការចេះកំណត់គោលដៅតែមួយមុខពុំអាចជាការគ្រប់គ្រាន់ទេ គឺត្រូវមានការតស៊ូ អំណត់ព្យាយាម ការប្តេជ្ញាចិត្តមុតមាំនិងមានមោទនភាពចំពោះការងាររបស់យើងម្នាក់ៗទៀតផង។ មនុស្សដែលរស់នៅគ្មានគោលដៅ គឺជាមនុស្សដែលរស់នៅក្នុងភាពពុំប្រាកដប្រជា ធ្វើឱ្យជីវិតរសាត់អណ្តែតតាមយថាកម្ម។

ក្នុងមេរៀននេះ អ្នកនឹងសិក្សាអត្ថបទមួយចំនួនដែលទាក់ទងនឹងការកំណត់គោលដៅក្នុងជីវិតដែលជាបទពិសោធន៍ល្អៗសម្រាប់អ្នកសិក្សានិងជនទូទៅ។ ទន្ទឹមនឹងនេះ អ្នកនឹងសិក្សាផងដែរអំពីគំនិតសំខាន់បង្កប់និងគំនិតសំខាន់បង្ហាញត្រង់ក្នុងកំណាព្យ ការសូត្រកំណាព្យតាមបទផ្សេងៗ ចំណាប់ចួន ផ្ចួន រណ្តំ និងកាព្យមាត្រ កំណើតគុណនាម ន័យដូច ន័យផ្ទុយរបស់ពាក្យ និងសំណេរតែងកំណាព្យបទពំនោល។

ន័យដូចនិងន័យផ្ទុយ

នៅក្នុងមេរៀនមុន អ្នកបានសិក្សារួចមកហើយអំពីន័យចំនិងន័យធៀប ឬហៅថា អត្ថានុរូបនិងអត្ថាបដិរូប ដែលគេច្រើនប្រើនៅក្នុងការបកស្រាយអត្ថន័យពាក្យស្លោកឬសុភាសិត ។

ឥឡូវនេះ អ្នកនឹងសិក្សាអំពីន័យដូចនិងន័យផ្ទុយរបស់ពាក្យដែលមានលក្ខណៈខុសពីន័យចំនិងន័យធៀប ។ ក្នុងភាសាខ្មែរមានពាក្យជាច្រើនដែលមានន័យដូចគ្នាតែសំណេរឬរូបនិងសំណូរខុសគ្នា ។

១ . ន័យដូច

ចូរពិនិត្យពាក្យខាងក្រោម :

ពាក្យ	ន័យដូច
• ចម្រើន	លូតលាស់ អភិវឌ្ឍ ថ្កុំថ្កើង រុងរឿង ថ្កើងថ្កាន ... ។
• មើល	ទស្សនា ទត គយគន់ រំពៃ ... ។
• ឧបត្ថម្ភ	ជួយ ទំនុកបម្រុង ជ្រោមជ្រែង ឱ្យ ប្រទាន ... ។
• និពន្ធ	តែង សរសេរ តាក់តែង ... ។
• មរណៈ	ស្លាប់ សុគត ងាប់ លាចាកលោក សោយទិវង្គត ... ។
• កសាង	ស្ថាបនា សាងសង់ ... ។

"ពាក្យន័យដូច" ជាពាក្យទាំងឡាយណាដែលមានន័យដូចឬប្រហាក់ប្រហែលគ្នាតែសំណេរនិងសំណូរពុំដូចគ្នា ។ "ពាក្យន័យដូច" ក៏ជាពាក្យមួយប្រភេទដែលកំណត់ន័យដោយទីសេចក្តីដែរ ។ ពាក្យមួយអាចមានន័យដូចច្រើន ។ ក្នុងការប្រើប្រាស់ យើងអាចជ្រើសរើសពាក្យន័យដូចណាមួយមកប្រើបាន អាស្រ័យលើការកំណត់របស់ទីសេចក្តី ។

២ . ន័យផ្ទុយ

នៅក្នុងភាសាខ្មែរ អ្នកនឹងជួបប្រទះជាញឹកញាប់នូវពាក្យជាច្រើនដែលមានន័យប្រឈមឬផ្ទុយគ្នានេះហៅថា ន័យផ្ទុយ ។ ចូរពិនិត្យមើលពាក្យខាងក្រោម :

ពាក្យ	ន័យផ្ទុយ
• បុរាណ	ទំនើប ស៊ីវិល័យ ... ។
• កិត្តិយស	អពយស ថោកទាប ... ។

- ស្រស់ស្រាយ — ស្ងួតស្រពោន ក្រៀមស្ងួត ស្រពាប់ស្រពោន ... ។
- សុភមង្គល — អពមង្គល អាក្រក់ ... ។
- យុត្តិធម៌ — អយុត្តិធម៌ ... ។
- បរាជ័យ — ជោគជ័យ ជ័យជំនះ ... ។
- រស់ — ស្លាប់ ងាប់ មរណៈ សុគត ... ។
- មាន — ក្រ ទុរគត ខ្សត់ខ្សោយ ... ។
- សន្តិសុខ — អសន្តិសុខ សង្គ្រាម ភាពច្របូកច្របល់ ... ។
- សរសើរ — បង្អាប់ បន្ទុះបង្អាប់ បន្ទាបបន្ថោក ... ។
- ស្រឡាញ់ — ស្អប់

"ពាក្យន័យផ្ទុយ"ជាពាក្យទាំងឡាយដែលមានន័យប្រឈមគ្នាឬផ្ទុយគ្នា ។ ពាក្យន័យផ្ទុយក៏ជាពាក្យមួយប្រភេទដែលមានន័យកំណត់ដោយទីសេចក្តីដែរ ។

លំហាត់

១. ចូររកពាក្យន័យដូចនឹងពាក្យ "ពិសា អធិកអធម មោទនភាព ឧស្សាហ៍ ឧត្តុង្គឧត្តម" ។

២. ចូររកពាក្យន័យផ្ទុយនឹងពាក្យ មុខ ក្នុង ឃួរ ខ្លី ចាស់ ខ្ពស់ ។

៣. ចូរអានអត្ថបទដកស្រង់ខាងក្រោម រួចស្រង់ពាក្យន័យដូចនិងន័យផ្ទុយដែលមាននៅក្នុងអត្ថបទ :

ក្រឡេកមើលទង់ជាតិបក់រវិចៗ កណ្តាលរលកអាកាសវេហាស៍ ប្រជាជនខ្មែរតែងនាំគ្នាបណ្តែតអារម្មណ៍ទៅកាន់ប្រាសាទបុរាណដ៏មានកុំពូលស្រួចត្រដឹម បង្ហាញអរិយធម៌ត្រចះត្រចង់របស់ខ្មែរនាសម័យកាលដ៏រុងរឿងបំផុត ។ អង្គរវត្តជាប្រាសាទមួយ ដែលដូនតាយើងបានប្រើពេលវេលាដ៏យូរនិងបូជាជីវិតដ៏ច្រើនក្នុងការកសាងស្នាដៃទុកឱ្យកូនចៅជំនាន់ក្រោយ ។ ប្រជាជនទូទាំងសកលលោកតែងតែសរសើរខ្មែរពីការរចនាវត្ថុនិងបុរាណដ្ឋានទាំងឡាយ ។ កវី អ្នកនិពន្ធសឹងតែគ្រប់ប្រទេស ដែលស្ថិតនៅលើធរណីមណ្ឌលនេះ ហើយដែលបានមកទស្សនាអតីតសុវណ្ណភូមិនេះ សុទ្ធតែបានសរសេរវេចខ្ចប់ដោយផ្ទិតផ្ទង់នូវព័ត៌មានពីអង្គរវត្តដើម្បីយកទៅប្រាប់ប្រាប់អ្នកអានថាខ្លួនបានដឹងច្បាស់នូវលក្ខណៈអរិយធម៌ដ៏មានរស្មីរុងរោចន៍របស់ប្រទេសកម្ពុជា ។

(ដកស្រង់និងកែសម្រួលពីសៀវភៅសរសេរតាមអាន ចាំ វណ្ណា)

បណ្តាំឪពុក

ក. សិក្សាពាក្យគន្លឹះ

- ជីង (ន) : គ្រឿងប្រើប្រាស់ធ្វើដោយដែកមានដង មានផ្លែសម្រាប់ក្របែល ។
- ឆ្ងើយ (គុ) : ដែលងើយឡើង ឆ្គងខុសទំនង ដែលឆ្ងេងឥតសណ្តាប់ឥតបែបបទ ។
- មធ្យរ (គុ) : ផ្អែម ឆ្ងាញ់ ពីរោះ ។
- មូទ្ធ (គុ) : ដែលមានគំនិតរាក់ទាល មិនឈ្លាសវៃ ។
- ក្តី (ន) : ដំណើរហេតុការណ៍ទាស់ទែងគ្នា ។
- ព្រៀងលាន (ន) : អ្នកជនៃនៅភូមិជាមួយគ្នារាប់អានគ្នាទុកស្មើញាតិសន្តាន ។
- និន្ទា (ន) : ដំណើរតិះដៀល ការរិះគន់ ។
- ឧបមា (ន) : សេចក្តីប្រៀបធៀប ប្រៀបប្រដូច ។
- មជ្ឈ (ន) : ត្រីទាំងពួង ។
- ធម្ម (ន) : ធម៌ ។
- កល (ន) : ឧបាយយ៉ាងល្អិត ល្បិច ឧបាយកល ។

- កិច្ច (ន) : ការដែលត្រូវធ្វើ អំពើ ការរវល់ ។
- ព្យូហ៍ (ន) : ការត្រិះរិះរំពឹងទុកបំភ័យដោយឧបាយកលឱ្យរឹតតែភ័យ ឧបាយកលធ្វើឱ្យលង់គំនិត ។
- អាថិ (ន) : ការកំបាំង ។
- ពំនាក់ (ន) : ទីពឹងពាក់ ទីជ្រកអាស្រ័យ ។
- ឥរិយា (ន) : ឫកពា កិរិយា លំនាំឫកពា ។
- ពារ (គិ) : ប៉ះលើ ឬប៉ះត្រូវទាំងស្រុង ប៉ះចំលើ ។
- ស្តែង (កិ.វិ) : ជាក់ច្បាស់ ពិតប្រាកដ ។
- ជញ្ជឹង (កិឬកិ.វិ) : សម្រឹងទ្រឹងគិត រិះគិត ពិចារណា ត្រិះរិះ ។
- គាប់ (គុ) : ត្រូវ ឥតខុស ឥតទាស់ គាប់ចិត្ត ។

ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកសូត្រកំណាព្យខាងក្រោមនេះ អ្នកគប្បីសូត្រដោយយកចិត្តទុកដាក់ដើម្បីត្រៀមឆ្លើយសំណួរមួយចំនួនឱ្យបានត្រឹមត្រូវដែលទាក់ទងនឹងអត្ថន័យតម្លៃអប់រំរបស់កំណាព្យ ហើយបង្ហាញបានពីពាក្យចួន ផ្ទួន និងកាព្យមាត្រ ។

គ. អត្ថបទ

បណ្តាំឪពុក (បទកាកគតិ)

ហៅកូនពន្លក	ស្ងួនអើយមាសយក
បណ្តាំបិតា	ឪពុកនេះចាស់
ឥតអ្វីឱ្យបា	ស្ងួនអើយរក្សា

ពាក្យឪពុកនៅ ។

ឱកូនកម្សត់	រៀនឱនរៀនអត់
រៀនគិតក្នុងក្រៅ	រៀនឱនលំទោន
កុំឱ្យហ្មងសៅ	ដល់ខ្លួនកូនពៅ

កេរ្តិ៍ដល់ឪពុក ។

ជីងឆ្លើយត្បិតជង
កូនសោតវែងឆ្គង

ត្បិតតែឪពុក
ទ្រព្យគង់ត្បិតស្រី

ចេះរៀបជាក់ទុក
ប្រះដេកនាប់លក់

ត្បិតឥតបើគិត ។

ចំណេះទាំងឡាយ
កិច្ចកលដោះស្រាយ

ត្បិតតែគំនិត
ជីងកិច្ចជីងកល

ជីងឆ្ងាយជីងជិត
ដូចកលកាំបិត

កាប់ឆ្ការទម្លាយ ។

ល្មមទៅល្មមខាន
ល្មមដើរបំពាន

កុំគិតត្រង់ងាយ
ល្មមឈប់បង្គង់

ល្មមខានទៅអាយ
ក្តីក្រកុំស្រាយ

ក្តីងាយកុំធ្ងេស ។

សូវដើរកុំដេក
សូវថប់កុំត្រេក

សេចក្តីប្រហែស
សូវខានកុំពារ

ចិត្តចង់ចចេស
សូវចូលកុំភៀស

វាសរួចសិមគួរ ។

លឿនកុំបំបោល
ពាក្យព្រេងកុំចោល

ខឹងកុំមួទូ
ស្រាយចេញឱ្យនាប់

កុំទុកឱ្យយូរ
សេចក្តីមធូរ

នឹងជីងខុសត្រូវ ។

ដេកកុំដំណើច
គេក្រកុំសើច

គេភ័យកុំព្យហ៍
ទោះខឹងប៉ុន្មាន

ធ្វើជាឱ្យគួរ
តឹងគិតឱ្យធូរ

យូរគិតឱ្យនាប់ ។

សេចក្តីសម្រុង ពាក្យដើមពាក្យចុង
ប្រកាន់ឱ្យខ្ជាប់ សូរនឿយឯខ្លួន
កុំឱ្យបង់ទ្រព្យ សូរបង់ក្តីគាប់
កុំឱ្យខ្លួនស្លាប់ ។

សូរស្លាប់ទៅជា កុំបង់ធម្មា
ឥរិយាសីលគាប់ ឱ្យគិតជញ្ជឹង
រំពឹងឱ្យសព្វ ពាក្យស្លែងកុំស្ងប់
ពាក្យគាប់ឱ្យយក ។

ចង់គង់ឱ្យទុក ចង់បានក្តីសុខ
ឱ្យស្វែងដើររក ឃើញច្បាប់ធម៌អាថ៌
ឱ្យយកខ្លួនជ្រក ក្តីសោកមមោក
ឱ្យចៀសចេញផ្លាយ ។

កូនអើយលោកិយ នេះឱ្យរៀនក្តី
រៀនច្បាប់ទាំងឡាយ រៀនទាំងសម្តី
កុំបីរាយមាយ ក្តីក្រក្តីងាយ
ក្តីគួរក្តីសម ។

ឱកូនពុំងា ធម្មតាអ្នកជា
ឱ្យរៀនថែទាំ រៀនដាក់រៀនទុក
រៀនរៀបរៀនចំ រៀនរកៀនសម
លក់ចេញទិញចូល ។

មួយសោតឯច្បាប់ បើបាមានទ្រព្យ
មនុស្សផងមកមូល ពឹងពាក់ប្រាណណា
បាយកប្រមូល សន្សំផ្សំចូល
យកមកជាគ្នា ។

កូនអើយឯម្លប់ មនុស្សផងចូលឈប់
សម្រាន្តអាត្មា ព្រោះឈើមានម្លប់
ត្រសុំសាខា ម្តេចឡើយប្រែជា
ក្តៅជ្រកពុំបាន ។

មនុស្សផងរំលង
ចូលចតសម្រាន្ត
ត្រសាក់ក្បែមក្បាន្ត
រកម្លប់ទៀតហោង
ម្លប់នោះត្រជាក់
មនុស្សផងចូលថ្កាន

មិនមានហៅអាក់ ។

ឧបមាដូចទឹក
ជាទីសំណាក់
ចេញចូលពឹងពាក់
ជ្រាលជ្រៅពន្លឺក
មច្ឆោមច្ឆា
ព្រោះទឹកត្រជាក់

មិនមានហ្មងសៅ ។

ពុំគិតឡើយហោង
ម្តេចប្រែជាក្តៅ
ព្រាត់ព្រាយរត់ទៅ
ឯទឹកនោះផង
មច្ឆាទាំងឡាយ
រកទឹកទៀតនៅ

ពំនាក់អាត្មា ។

កូនអើយបើច្នោះ
ត្រូវត្រង់ខ្លួនបា
គេនឹងនិន្ទា
អសោចកេរ្តិ៍នោះ
ព្រៀងលានទាំងឡាយ
ដំនៀលដៀលថា

បាឯងពុំចេះ ។

អាប់ឥតប្រាជ្ញា
យោបល់ចំណេះ
អាប់ទាំងតម្រិះ
អាប់ទាំងឥរិយា
អាប់ទាំងមារយាទ
ត្បិតបាឯងនេះ

ពុំចេះរក្សា ។

គណនាដូចទឹក
ពុំមានមច្ឆា
នៅក្នុងគង្គា
កូនអើយបើល្ងីក
មួយគ្រាន់ពន្លៀក
ពុំរាប់ហៅជា

ប្រសើរឡើយហោង ។

មួយសោតអ្នកណា
បទបាធ្វើឆ្គង
រំពឹងដើមទង
គេមកប្រាប់ថា
បាគិតជញ្ជឹង
កុំបាកែងកោង

ក្អែងក្អាងពុំស្តាប់ ។

ទូកហួសកំពង់ រាចែវបង្គង់
ថយមកចូលចាប់ ពាក្យលឿនហួសខ្នាត
ហៅឥតគំនាប់ ថយមករងគាប់
ពុំបានឡើយណា ។

អង្គុយហួសសក្តិ សម្តីហួសថ្នាក់
បង់បោយហួសស្មា ពុំមើលប្រមាណ
នឹងប្រាណអាត្មា ហាហួសចង្កា
ថាហួសសេចក្តី ។

(ដកស្រង់ចេញពីប្រជុំ" ច្បាប់បណ្តាំបិតា"ទំព័រ១-៥ បោះពុម្ពឆ្នាំ១៩៨៧)

សំណួរ

១. តើកំណាព្យខាងលើដកស្រង់មកពីឯកសារណា ? ជាបទអ្វី ?

២. តើអត្ថន័យនៃបទកំណាព្យខាងលើនេះមានន័យដូចម្តេចខ្លះ ?

៣. តើពាក្យថា"ជីងកល ជីងកិច្ច វាសរួចសីមគូរ កុំព្យូហ៍ មធូរ"មានអត្ថន័យដូចម្តេច ?

៤. ចូរពន្យល់អត្ថន័យក្នុងវគ្គ

សូវស្លាប់ទៅជា	កុំបង់ធម្មា	ឥរិយាសីលគាប់
ឱ្យគិតជញ្ជឹង	រំពឹងឱ្យសព្វ	ពាក្យស្លែងកុំស្ងប់
	ពាក្យគាប់ឱ្យយក ។	
ចង់គង់ឱ្យទុក	ចង់បានក្តីសុខ	ឱ្យស្វែងដើរឆក
ឃើញច្បាប់ធម៌អាថិ	ឱ្យយកខ្លួនជ្រក	ក្តីសោកមមោក
	ឱ្យចៀសចេញឆ្ងាយ ។	

៥. ចូរបង្ហាញចំណាប់ចួន ផ្ទួនរបស់អត្ថបទកាព្យខាងលើ ។

៦. តើអត្ថបទកាព្យខាងលើមានគោលដៅអប់រំកូនចៅយ៉ាងដូចម្តេចខ្លះ ?

កំណើតរបស់គុណនាម

ក្នុងភាសាខ្មែរយើង គេអាចបង្កើតគុណនាមបានដោយប្រើវិធីច្រើនយ៉ាង។ ក្នុងមេរៀននេះអ្នកនឹងសិក្សាអំពីវិធីខ្លះៗនៃការបង្កើតគុណនាមដូចជា គុណនាមខ្លះអាចចេញមកពីនាម គុណនាម និងកិរិយា។ ចូរអ្នកពិនិត្យឧទាហរណ៍ខាងក្រោម

ក. នាម (ប្រើជាគុណនាម)

នាម	គុណនាម	នាម	គុណនាម
ស៊ុបទ្រុប	ឈើស៊ុបទ្រុប	ខ្នាំង	ចិត្តខ្នាំង
តំណាល	រឿងតំណាល	របឹប	ទ្រព្យរបឹប

ខ. គុណនាម

គុណនាម	គុណនាម	គុណនាម	គុណនាម
ពៀច	កំពៀច	ខ្ជិល	កម្ជិល
ស្ទក់	សំទក់	ចោទ	កញ្ចោត
ចាស់	កញ្ចាស់	ប៉ោង	កំប៉ោង

គ. កិរិយាសព្ទ

កិរិយាសព្ទ	គុណនាម	កិរិយាសព្ទ	គុណនាម
សំកាក	សក់សំកាក	លោភ	មនុស្សលោភ
ល្មើស	បទល្មើស	កំប្លែង	រឿងកំប្លែង
ស៊ីសង	ល្បែងស៊ីសង	សង្កត	ថ្មសង្កត

គុណនាមមានកំណើតពីនាមផង គុណនាមផង និងកិរិយាសព្ទផង។

លំហាត់

១. ចូររកនាមដែលប្រើជាគុណនាមឱ្យបាន ៥ ពាក្យដោយបង្កើតជាល្បះបញ្ជាក់ផង។

២. ចូរបង្កើតគុណនាមដែលចេញពី នាម គុណនាម កិរិយាសព្ទ ឱ្យបាន ៥។

៣. ចូរបង្ហាញវិធីកកើតនៃគុណនាម ដូចជា កំពុក កំប៉ោង កំពៀច កញ្ចោត កម្ជិល។

ការរុករករបស់លោក ក្រីស្តុប កូឡុំ

ក. សិក្សាពាក្យគន្លឹះ

- ទិសាលភាព (ន) : ភាពធំទូលាយ ប្រសើរគាប់ ។
- បស្ចិម (ន) : ទិសខាងលិច ។
- សណ្ឋាន (ន) : ទ្រង់ទ្រាយ រូបរាង រាងរៅ បែបភាព ។
- ធនធាន (ន) : ទ្រព្យធន ទ្រព្យសម្បត្តិ ទ្រព្យរបស់ផ្សេងៗដែលគង់នៅ ។
- រដ្ឋាភិបាល (ន) : អ្នកគ្រប់គ្រងរក្សាប្រទេស ។
- រដ្ឋសភា (ន) : ទីប្រជុំប្រឹក្សាការសម្រាប់ប្រទេស ។
- សៅហ្មង (គុ) : ដែលអាប់អួរ ដែលមានមន្ទិល ។
- នាវា (ន) : ទូក សំពៅ កប៉ាល់ ។
- ហាប្ញទ័យ (ន) : ដួងចិត្ត បេះដូង ចិត្ត ។
- ឆន្ទៈ (ន) : ទិសដៅ គោលបំណង ។
- មូលធន (ន) : ទ្រព្យដើម ប្រាក់ដើម ដើមទុន ។

- ឧបត្ថម្ភ (កិ) : ផ្គត់ផ្គង់ត្រាំទ្រ ។
- ផ្តោះផ្តង (កិ) : និយាយបញ្ឆិតបញ្ឆៀងសារសព្វអំពីហេតុដើមឬអំពីបំណងរបស់ខ្លួនដោយសេចក្តីមិនឱ្យគេចាប់ដំណើរបាន ។

ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទ "ការរុករករបស់លោក គ្រីស្តុប កូឡុំ" អ្នកគប្បីអានដោយយកចិត្តទុកដាក់ដើម្បីត្រៀមឆ្លើយនឹងសំណួរមួយចំនួនដែលទាក់ទងនឹងសេចក្តីលម្អិត ន័យដូច ន័យផ្ទុយរបស់ពាក្យនិងកំណើតគុណនាម ។

គ. អត្ថបទ

លោកគ្រីស្តុប កូឡុំ រស់នៅទីក្រុងសេនូ ។ លោកមានគោលដៅច្បាស់លាស់ ។ លោកយល់ថាពិភពលោកដ៏មានទិសាលភាពទូលំទូលាយនេះ មានសណ្ឋានមូល ។ ការយល់ឃើញរបស់លោក មានទំនាស់នឹងទស្សនៈក្នុងសម័យកាលនោះខ្លាំងណាស់ ព្រោះគេយល់ឃើញថា លោកដែលយើងអាស្រ័យនៅនេះ មានសណ្ឋានសំប៉ែត ។ តែលោកគ្រីស្តុប កូឡុំ យល់ថា បើធ្វើដំណើរចេញពីទ្វីបអឺរ៉ុប ដោយបែរមុខឆ្ពោះទៅទិសខាងកើត ពេលត្រឡប់មកកាន់ទីដើមវិញពីទិសបស្ចិម ។ ក្នុងដំណើរដូចគ្នានេះដែរ បើចេញដំណើរឆ្ពោះទៅកាន់ទិសបស្ចិម នៅទីបំផុតក៏នឹងត្រឡប់មកកាន់ទីពីដើមទិសខាងកើតវិញ ។ លោកគ្រីស្តុប កូឡុំ មានសេចក្តីសង្ឃឹមយ៉ាងមាំក្នុងចិត្តថា ត្រូវតែធ្វើការរុករកពិភពលោកនេះដើម្បីបញ្ជាក់ទ្រឹស្តីរបស់ខ្លួន តែលោកកូឡុំគ្មានមូលធនផ្ទាល់ខ្លួនសម្រាប់ធ្វើដំណើរសោះ ។ ដោយហេតុថាដើម្បីធ្វើដំណើររុករក លោកត្រូវមាននាវាយ៉ាងធំ រួមទាំងកម្មករនាវាជាច្រើននាក់ ព្រមទាំងត្រូវមានស្បៀងអាហារគ្រប់គ្រាន់ផង ។ ដូច្នេះ លោកកូឡុំ កំណត់ថាលោកត្រូវតែខំព្យាយាមត្រិះរិះរកមធ្យោបាយធ្វើដំណើររុករកតាមផែនការរបស់លោក ។ គ្រីស្តុប កូឡុំប្រឹងសរសេរគម្រោងនៃការធ្វើដំណើររុករកតាមផ្លូវសមុទ្រ ឱ្យបានសព្វគ្រប់ល្អិតល្អន់ ។ គាត់ធ្វើបែបនេះ ដើម្បីអង្វរសុំសេចក្តីអនុគ្រោះ ពីបុគ្គលមានធនធាន និងអ្នកធំៗក្នុងជួររដ្ឋាភិបាល ។ ជាដំបូង លោកគ្រីស្តុប កូឡុំ បានសុំជំនួយពីជនសំខាន់ៗក្នុងប្រទេសរបស់លោក ។ តមក ទើបលោកធ្វើលិខិតស្នើដល់រដ្ឋសភាព័រទុយហ្គាល់ អេស្ប៉ាញ និងរដ្ឋសភាអង់គ្លេស ។ ប៉ុន្តែគម្រោងរបស់លោកកូឡុំ ទទួលបានការចំអកឡកឡឺយ ផ្តោះផ្តង មើលងាយពីមហាជនយ៉ាងខ្លាំង ។ ជនទាំងនោះបាននាំគ្នានិយាយតិះដៀលកូឡុំថា ជាមនុស្សឆ្កួតជាមនុស្សលីលាមិនបានការ ។ គម្រោងនោះពិតជាទៅមិនរួចទេ ។ ដោយហេតុនេះហើយ ទើបលោកមិនបានទទួលការឧបត្ថម្ភទំនុកបម្រុងពីអ្នកណាមួយសូម្បីតែបន្តិចបន្តួច ។

លោកគ្រីស្តុប កូឡុំ មានសេចក្តីសៅហ្មងចិត្តយ៉ាងសម្បើម នៅពេលដែលលោកទទួលបានការមើលងាយយ៉ាងគួរឱ្យឈឺចាប់បំផុតនេះ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏លោកនៅតែមិនអស់សង្ឃឹមក្នុងការសម្រេចគោលដៅរបស់លោកឡើយ។ នៅទីបំផុត លោកបានទៅរកមិត្តរបស់លោកម្នាក់ដែលជាបុគ្គលសំខាន់និងមានកេរ្តិ៍ឈ្មោះក្នុងសភាទីប្រឹក្សារាជការអេស្ប៉ាញ ហើយជាទីប្រាសប្រណីរបស់ព្រះចៅ **ហ្វែរឌីណង់** របស់ប្រទេសអេស្ប៉ាញផង។ នេះអាចចាត់ទុកថា ជាជោគវាសនាឬការមិនព្រមរាថយក្នុងការរុករករបស់លោកក៏បានដែរ ព្រោះពេលនោះផែនការរបស់លោក គ្រីស្តុប កូឡុំ ត្រូវបានជាទីសព្វព្រះរាជហឫទ័យនៃព្រះនាង **អេលីសាបេឡា**។ ព្រះនាងបានប្រោសប្រទាននាវាដើរសមុទ្រ ៣គ្រឿង រួមទាំងកម្មករនាវាចំនួន ១ ២០០នាក់ហើយនិងគ្រឿងសម្ភារៈដែលចាំបាច់ផ្សេងៗទៀតសម្រាប់ធ្វើដំណើររុករកពិភពផែនដី។

ដោយឆន្ទៈមោះមុត លោកគ្រីស្តុប កូឡុំ ពុះពារចេញដំណើរឬហូតដល់៤លើកគឺ

លើកទី ១ ឆ្នាំ ១៤៩២-១៤៩៣

លើកទី ២ ឆ្នាំ ១៤៩៣-១៤៩៦

លើកទី ៣ ឆ្នាំ ១៤៩៨-១៥០០

លើកទី ៤ ឆ្នាំ ១៥០២-១៥០៤

ក្នុងដំណើររុករកទាំង៤លើក លោកគ្រីស្តុប កូឡុំ បានរកឃើញកោះ បាហាម៉ា ហៅគាណាហានី(តាមអ្នកស្រុកហៅថាសាំង សាវ៉ាហានី) កោះគូបា កោះហៃទី មួយផ្នែកនៃប្រទេសវ៉េណេស៊ុយអេឡា គឺហុងឌុយរ៉ាស់។

នៅទីបំផុត លោកគ្រីស្តុប កូឡុំ បានទទួលជោគជ័យ។ ដោយសារការរុករករបស់លោក កូឡុំបានប្រទះទ្វីបថ្មីមួយទៀត គឺទ្វីបអាមេរិកសព្វថ្ងៃនេះឯង។

(ដកស្រង់ពីសៀវភៅអច្ឆរិយបុគ្គលក្នុងពិភពលោក)

សំណួរ

១. តើអត្ថបទខាងលើនិយាយអំពីអ្វី ?

២. តើលោកគ្រីស្តុប កូឡុំមានការយល់ឃើញដូចម្តេចចំពោះលោកយើងនេះ ?

៣. តើអ្នកយល់ថា ទស្សនៈរបស់គាត់ត្រឹមត្រូវដែរឬទេ ? ព្រោះអ្វី ?

៤. តើលោកគ្រីស្តុប កូឡុំមានគោលដៅដូចម្តេចចំពោះទស្សនៈរបស់គាត់ ?

៥. ចូរពិនិត្យពាក្យមួយគូៗខាងក្រោមនេះ។ តើគូពាក្យណាមានន័យដូច គូពាក្យណាមានន័យផ្ទុយ ?

- ចេញដំណើរ ត្រឡប់វិញ ។ ខាងលិច ខាងតើត
- មូល សំបែត។ ធនធាន ទ្រព្យសម្បត្តិ។
- ឆ្កួត ជា។ ទំនុកបម្រុង ផ្គត់ផ្គង់។

៦. ចូរពន្យល់ពាក្យ"លោក"ក្នុងល្បះ "លោកដែលយើងអាស្រ័យនៅនេះ មានសណ្ឋានសំបែត"និងពាក្យ"មិនបានការ"ក្នុងល្បះ"ជនទាំងនោះនាំគ្នានិយាយ តិះដៀល កូឡុំថាជាមនុស្សឆ្កួត ជាមនុស្សលីលាមិនបានការ"។

៧. ចូររកពាក្យន័យដូចនឹងពាក្យ លិខិត មើល និងរកពាក្យន័យផ្ទុយនឹងពាក្យ : ដំបូង ធំ សរសើរ ស្រឡាញ់ គោរព។

៨. ចូរបង្កើតគុណនាមដោយប្រើគុណនាម : ឆ្កួត។

ទិសដៅនៃជីវិត

ក. សិក្សាពាក្យគន្លឹះ

- ទិសដៅ (ន) : ការកំណត់ ឬធ្វើឱ្យមានជាគ្រឿងសម្គាល់ ឬការសំដៅ តម្រង់ទៅលើអ្វីមួយដោយមានគោលបំណងច្បាស់លាស់ ។
- កិត្តិយស (ន) : យសសក្តិដែលល្បី កេរ្តិ៍ឈ្មោះដ៏រុងរឿងល្បីល្បាញ ។
- កិរិយា (ន) : អំពើ លំនាំ ឫកពា ។
- អាកប្បកិរិយា (ន) : អាការៈនៃរាងកាយឬឫកពា ។
- គោលបំណង (ន) : បំណងប្រាថ្នាជាចម្បង ជាធំ ។
- លទ្ធផល (ន) : ផលនៃការងារដែលបានសម្រេច ផលដែលបានសម្រេចហើយ ។
- ឥស្សរភាព (ន) : ភាពនៃអ្នកធំ ភាវៈជាឥស្សរៈ ។
- វិប្បដិសារី (ន) : ការស្តាយក្រោយ ការនឹកស្តាយក្រោយ ។
- វិទ្យាសាស្ត្រ (ន) : គម្ពីរប្រាប់ពីវិជ្ជាផ្សេងៗ ។ វិជ្ជាមួយប្រភេទដែលគេរកឃើញដោយការកែផ្សំ មានការផ្សំធាតុដើមរបស់អ្នកប្រាជ្ញក្នុងការបង្កើតអ្វីមួយ ។

- រចនា (ន) : ការតាក់តែង រៀបចំសម្ផិតសម្ផាង ការច្នៃលម្អ។
- ឧបករណ៍ (ន) : គ្រឿងសម្ភារៈ សម្រាប់ប្រើប្រាស់ទូទៅ។
- បរាជ័យ (ន) : ដំណើរចាញ់គេ ការចាញ់គេ។
- ឧត្តមភាព (ន) : ភាពល្អវិសេស ខ្ពង់ខ្ពស់ឧត្តុង្គឧត្តម ប្រពៃផ្លៃថ្លា។

ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទ "ទិសដៅនៃជីវិត"អ្នកគប្បីអានដោយយកចិត្តទុកដាក់ ដើម្បីត្រៀមឆ្លើយនឹងសំណួរមួយចំនួនទាក់ទងនឹងខ្លឹមសារ ឬគំនិតសំខាន់នៃអត្ថបទដើម្បីពង្រីកការយល់អត្ថន័យនៃអត្ថបទ តម្លៃអប់រំ និងសង្ខេបអត្ថបទឡើងវិញឱ្យបានត្រឹមត្រូវ។

គ. អត្ថបទ

ទិសដៅរស់របស់មនុស្ស គឺចង់ឱ្យខ្លួនបានល្អប្រសើរ ចង់ឱ្យខ្លួនមានកិត្តិយស កេរ្តិ៍ឈ្មោះ និងទទួលបានការរាប់អានច្រើន ពីសំណាក់អ្នកផងទាំងពួង។ យើងមិនចង់ឱ្យខ្លួនយើងរស់នៅក្នុងភាពអាប់ឱន គ្មានកិត្តិយសកេរ្តិ៍ឈ្មោះ និងគ្មានការរាប់អានពីសំណាក់អ្នកដទៃនោះឡើយ។ ក៏ប៉ុន្តែ អ្វីទាំងអស់នេះផ្តើមឡើងដោយយើងជាអ្នកចេះគោរពឱនលំទោនចំពោះអ្នកដទៃ មានកិរិយាសុភាពរាបសាទន់ភ្លន់ចេះបន្ទាបខ្លួនប្រកបដោយអាកប្បកិរិយាថ្លៃថ្នូរ ឫកពាសមរម្យដែលមិនធ្វើឱ្យអ្នកដទៃមើលទៅទាស់ភ្នែក។ ចូរយើងធ្វើការកត់សម្គាល់ថា ការតស៊ូចង់ឈ្នះលើជីវិតរបស់ខ្លួននោះ ទោះជានៅក្នុងករណីណាក៏ដោយ ឬក្នុងគោលបំណងអ្វីក៏ដោយ គឺការធ្វើយ៉ាងណាដើម្បីឱ្យខ្លួនយើងបានគាប់ប្រសើរ ឱ្យខ្លួនយើងទទួលបានការកោតសរសើរ មានមុខមាត់នៅក្នុងសង្គមជាដើម។ ការតស៊ូដោយប្រើអានុភាពនៃច្បាប់ និងសីលធម៌នឹងធ្វើឱ្យយើងទទួលបានជោគជ័យ ប្រកបដោយឥស្សរភាព រហូតដល់ទីបញ្ចប់នៃជីវិត។ ក្នុងការធ្វើអ្វីៗគ្រប់យ៉ាង យើងតែងតែចង់ឈ្នះឧបសគ្គទាំងអស់ក្នុងជីវិតរបស់យើង ដើម្បីធ្វើឱ្យជីវិតខ្លួនយើងមានភាពប្រសើរខ្ពស់ឡើងជាលំដាប់ មានឋានៈបុណ្យស័ក្តិ កិត្តិយសកេរ្តិ៍ឈ្មោះ ព្រមទាំងធ្វើឱ្យជីវិតខ្លួនប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ដល់អ្នកដទៃ និងសង្គមឱ្យមានភាពរុងរឿងជាអង្វែងទៀតផង។

ដើម្បីសម្រេចបានជោគជ័យក្នុងជីវិត លុះត្រាតែខ្លួនយើងរៀបចំនិងកំណត់គោលដៅទុកជាមុនសិន ។

ន័យនៃជីវិតមិនសំដៅត្រឹមតែលើភាពហ៊ឺហា ការដើរលេងសប្បាយឬមានប្រាក់កាសច្រើននោះទេ ការមានការងារល្អធ្វើនោះទេ ក៏ប៉ុន្តែ ជីវិតត្រូវតែមានគោលដៅច្បាស់លាស់និងប្រកបដោយឧត្តមគតិខ្ពង់ខ្ពស់ផងដែរ ។ ទាំងនេះជាខ្លឹមសារដ៏សំខាន់នៃជីវិត សម្រាប់ធ្វើឱ្យសង្គមមនុស្សនៅគ្រប់សម័យកាលទទួលស្គាល់និងឱ្យតម្លៃ ហើយគោលដៅនេះ ត្រូវតែជាគោលដៅដែលខ្លួនយើងត្រូវកំណត់ដោយផ្ទាល់ និងឱ្យស្របតាមស្ថានភាពជាក់ស្តែងនៃសង្គមនិងស្ថានភាពរបស់ខ្លួនផ្ទាល់ ។

គោលដៅ គឺជាគ្រឿងដឹកនាំស្មារតីឱ្យដើរតាមអ្វីដែលយើងបានកំណត់ ។ យើងត្រូវគិតថាយើងត្រូវតែព្យាយាមធ្វើនូវអ្វីដែលយើងបានគិត បើពុំនោះទេនឹងមិនទទួលបានលទ្ធផលដូចដែលយើងចង់បានឡើយ ។ បន្ទាប់ពីបានកំណត់គោលដៅហើយ ជំហានបន្តទៅទៀត គឺយើងត្រូវធ្វើផែនការសកម្មភាពដើម្បីញ៉ាំងទិសដៅនោះឱ្យសម្រេចបានជោគជ័យតាមការកំណត់ ។ ផែនការគឺគម្រោងសកម្មភាពការងារជាវិជ្ជមានដែលយើងកំណត់ពេលវេលាច្បាស់លាស់និងទំហំកិច្ចការឬថវិកាដែលអាចឱ្យការងារនោះប្រព្រឹត្តទៅបាន ។

ការកំណត់ទិសដៅនៃជីវិតរមែងមានភាពខុសៗគ្នាទៅតាមសង្គមនិងលទ្ធភាពមនុស្សម្នាក់ៗ ។ ដូច្នេះ ការធ្វើផែនការមានសណ្ឋានច្រើនបែបច្រើនយ៉ាងណាស់ សូម្បីតែការចង់ទិញវត្ថុអ្វីមួយតូចតាចដើម្បីយកមកប្រើប្រាស់ ក៏គេត្រូវគិតទុកជាមុនផងដែរ ។

ទីបំផុត ក្នុងការរស់នៅមនុស្សម្នាក់ៗត្រូវមានផែនការ ទើបយើងអាចដឹកនាំខ្លួនឱ្យធ្វើដំណើរទៅរកភាពល្អប្រសើរ ខ្ពស់ឡើងៗចាប់ពីពេលបច្ចុប្បន្នរហូតដល់ពេលអនាគត ។ យើងត្រូវកសាងជីវិតរស់នៅឱ្យមានការអភិវឌ្ឍសន្សឹមៗ ឆ្ពោះទៅរកឧត្តមភាពដែលនាំមកនូវប្រយោជន៍ដល់ខ្លួន ក៏ដូចជាដល់សង្គមជាតិទាំងមូលផងដែរ ។

សំណួរ

១. តើអត្ថបទខាងលើនិយាយពីអ្វី ?

២. ចូរបង្ហាញគំនិតសំខាន់នៃអត្ថបទ ។

៣. តើជីវិតដែលមានគោលដៅច្បាស់លាស់ ជាជីវិតដូចម្តេច ?

៤. តើអ្នកដែលគ្មានគោលដៅច្បាស់លាស់សម្រាប់ជីវិតនឹងជួបផលវិបាកអ្វីខ្លះ ?

៥. តើអ្នកត្រូវធ្វើដូចម្តេចខ្លះ ដើម្បីសម្រេចគោលដៅនោះ ?

៦. តើអត្ថបទមានតម្លៃអប់រំដូចម្តេច ?

៧. តើអ្នកកំណត់គោលដៅដូចម្តេចខ្លះចំពោះជីវិតសិក្សារបស់អ្នក ?

៨. ចូរអ្នកសង្ខេបអត្ថបទឡើងវិញ ។

ច្បាប់អរិយសត្ត

នៅពេលអ្នកស្តាប់កំណាព្យ "ច្បាប់អរិយសត្ត" ដែលលោកគ្រូ អ្នកគ្រូរបស់អ្នកអានឱ្យអ្នកស្តាប់ អ្នកត្រូវស្តាប់ដោយយកចិត្តទុកដាក់ ដើម្បីកត់ចំណាំគំនិតសំខាន់នៃអត្ថបទក្នុងកំណាព្យ ហើយឆ្លើយនឹងសំណួរ ។

សំណួរ

១. តើអ្នកនិពន្ធរូបណាដែលតែងអត្ថបទកំណាព្យនេះ ? តែងជាបទអ្វី ?

២. ចូរបង្ហាញគំនិតសំខាន់របស់កំណាព្យ ។

៣. តើកំណាព្យនេះមានតម្លៃអប់រំដូចម្តេចខ្លះ ?

៤. ចូរសង្ខេបគំនិតសំខាន់របស់កំណាព្យ ។

ការសូត្រកំណាព្យ

អ្នកធ្លាប់បានសិក្សាក្នុងមេរៀនមុនៗរួចមកហើយអំពីអត្ថបទកាព្យ បទព្រហ្មគីតិ បទកាកគតិ បទភុជង្គលីលា បទ៣ក្យ ៧ បទ៣ក្យ ៨ និងបទ៣ក្យ ៩ ។ល។

នៅមេរៀននេះអ្នកនឹងសិក្សាពីបទពំនោល ។

ជាបឋម ចូរអ្នកស្វែងយល់ពីក្បួនកំណាព្យបទពំនោលដែលមានចំណុចសំខាន់ៗមួយចំនួនដូចជា រង្វាស់កាព្យ ចំណាប់ចួន ចួនក្នុងវគ្គ ចួនឆ្លងវគ្គ ចង្វាក់ និងបរិយាកាសនៃបទនេះជាមុនសិន ។

បទពំនោលមានកំណើតតាំងពីសម័យអង្គរមកម្ល៉េះ ។ គេយកបទនេះទៅប្រើក្នុងការសម្តែងរបាំ ល្ខោន ហើយត្រូវបានគេប្រើច្រើនបំផុតនៅក្នុងរឿងរាមកេរ្តិ៍ ។ ពេលនោះ គេគ្រាន់តែយកក្បួនតែងកាព្យបែបជាបទពំនោលមកប្រើ ហើយមានឈ្មោះជាបទផ្សេងៗវិញ ។ រហូតមកដល់ដើមសម័យឧដុង្គ ទើបបទនេះមានឈ្មោះពិតថា "បទពំនោល" តាមរយៈកំណាព្យ "ល្បើកអង្គរវត្ត" របស់អ្នកប៉ាង ។ កាព្យសាស្ត្រក្នុងបទពំនោលមាន :

ក. រង្វាស់កាព្យ

ក្នុង ១វគ្គមាន ៣ឃ្លា ។

- ឃ្លាទី ១ មាន ៦ព្យាង្គ
- ឃ្លាទី ២ មាន ៤ព្យាង្គ
- ឃ្លាទី ៣ មាន ៦ព្យាង្គ ។

ខ. ចំណាប់ចួន

គំនូសតាងចំណាប់ចួន



ឧទាហរណ៍ :

ពុំឆ្អែតពុំឆ្អន់នេត្រា ត្រេកសោមនស្សា ពុំស្កប់ពុំស្កល់ចិត្តឡើយ ។
ចរចូលមៀងមើលរួចហើយ ពុំចង់ចេញឡើយ អាឡោះអាល័យពេកណា ។
ពុំយល់ជាថ្មសិលា លោកក៏រចនា សម្រេចសម្រួលប្រពៃ ។

(ល្បើកអង្គរវត្តរបស់ អ្នក ប៉ាង)

- ចួនក្នុងវគ្គ : ព្យាង្គទី ៦ នៃឃ្លាទី ១ ចួននឹងព្យាង្គទី ៤ នៃឃ្លាទី ២ ។
- ចួនឆ្លងវគ្គ : ព្យាង្គទី ៦ នៃឃ្លាទី ៣ នៃវគ្គទី ១ ចួននឹងព្យាង្គទី ៦ នៃឃ្លាទី ១ ក្នុងវគ្គទី ២ ចួននឹងព្យាង្គទី ៤ ឃ្លាទី ២ វគ្គទី ២ ។

គ. ចង្វាក់

បទពំនោលត្រូវសូត្រដោយទម្លាក់សំឡេងលើព្យាង្គទី ២ និងទី ៤ គ្រប់ឃ្លា ។

ឃ. បរិយាកាស

គេសូត្រឬប្រើបទពំនោលសម្រាប់បង្ហាញពីកំហឹងក្រេវក្រោធ សង្ឃឹកសន្ធាប់ គំរាមកំហែង រៀបរាប់ពីមហិទ្ធិឫទ្ធិរបស់អ្នកមានអំណាចខ្លាំង ឬពាក្យអង្វរក ការភ័យខ្លាចរបស់អ្នកទន់ខ្សោយ ។ ជួនកាលរៀបរាប់ពីជម្លោះចម្បាំង ។ ជួនកាលទៀត គេយកបទនេះទៅពោលក្នុងការសម្តែងរបាំដើម្បីធ្វើឱ្យនាដកនិងនាដកាធ្វើចលនានិងកាយវិការផ្សេងៗ ។

ឧទាហរណ៍ទី ១ : សម្តែងកំហឹងក្រេវក្រោធនិងការភ័យខ្លាច

អញនូវផ្តាញឱ្យក្ស័យជីពជន្ម	បុត្រពីងឱ្យអន្ត	រាយឥឡូវថ្នាត់ហោង ។
ព្រះបាទទសរថឆ្លើយឆ្លង	ហៅទេពឫសីត្រែង	ដោយនូវសត្យធម៌សោក ។
រីនាមបុត្រអញនេះណា	អញពុំប្រតិសាន៍	សន្ធតឱ្យឯងពិចិត្រ ។
មហាឫសីទាំងមួយសែនកោដិគិត	ជំនុំនូវសិល្ប៍សិទ្ធិ	មហាឫសីមុនីផង ។
ទើបអស់ជំនុំរាជឥសី	នូវទេពដ៏មុនី	ប្រកបព្រះនាមករពារ ។
ហៅព្រះរាមទេពដ៏បវរ	សិរិទ្ធបរិបូណ៌	បុណ្យហេតុដូច្នេះណា ។
ក្សិណនោះនាមបរមសូរយក្សា	រឹងក្រេវក្រោធា	មហាពន្លឺកមួយសា ។
ខេខឹងដ៏ត្រឆួនដោះដាល	ហិចហោះបីត្រកាល	ឆ្ពោះទៅនាទ័ពព្រះរាមា ។
ព្រះបាទទសរថរាជា	ភិតភ័យតក្កមា	ក៏ខ្លាចព្រះរាជបុត្រមរណ៍ ។
ស្តេចទ្រង់ព្រះកន្សែងគក់គរ	ទ្រូងក្រួតឧទរ	ទ្រហោហឫទ័យប្រះប្រាណ

(រាមកេរ្តិ៍ខ្មែរទី ១)

ឧទាហរណ៍ទី ២ : រៀបរាប់ពីចម្បាំង

ឯពលយក្ខសែនឯកករ	ពះពលពានរ	ប្រាំម៉ឺនប្រយុទ្ធខែងខំ ។
ដកដើមព្រឹក្សាដាលដំ	ខ្លះស្ទុះស្ទួយភ្នំ	ប្របោកប្របែកភ្លើងច្រាល ។
ពានរារុករានដេញដាល	ស្លុតស្លាប់ក្រាស់ក្រាល	រង្គាត់រង្គាលទាំងព្រៃ ។

(ល្បើកអង្គរវត្តរបស់អ្នកជាំង)

ឧទាហរណ៍ទី ៣ : រៀបរាប់ពីមហិទ្ធិឫទ្ធិ

ខ្ញុំមានក្រចកនិងធ្មេញ　　បើខ្ញុំបញ្ចេញ　　សត្វផងរអែងខ្ញុំណា ។
រហ័សប្រៀបបាននឹងខ្លា　　ខ្ញុំស្រែកកាលណា　　សម្រែកដូចជាខ្លាធំ ។
ឬដូចសន្ធាប់ខ្លាធំ　　មនុស្សសត្វពិតពុំ　　តយុទ្ធនឹងខ្ញុំដល់ម្តង ។
កណ្តុរខ្លាចខ្ញុំពេកហោង　　ខ្ញុំឡើងឈើផង　　រហ័សទាំងលោលោតចុះ ។
ចំណីមានឱជារស　　ខ្ញុំពាំបណ្តោះ　　ទៅលើដំបូលបរិភោគ ។

(វិជ្ជាខេមរភាសាទំព័រ ២៨ មុំក-សំឱក)

សំណួរ

១. តើបទពំនោលមានកំណើតពីពេលណា ?

២. តើបទពំនោលមានរង្វាស់កាព្យដូចម្តេច ? ចំណាប់ចួនដូចម្តេច ?

៣. តើគេសូត្រ ឬប្រើបទពំនោលសម្រាប់រៀបរាប់ពីអ្វីខ្លះ ?

លំហាត់

ចូរអ្នកអានអត្ថបទកាព្យដកស្រង់ខាងក្រោម ហើយជ្រើសរើសយកបទណាមួយមកសូត្រឱ្យបានត្រឹមត្រូវតាមការពេញចិត្តរបស់ខ្លួន :

១ . បទពំនោល

ព្រហ្មមុខបួន

ភ័ក្ត្រព្រហ្មញញឹមស្រស់ស្រាយ　　ទតទិសទាំងឡាយ　　រូផ្សាយព្រហ្មវិហារធម៌ ។
តំណាងទីកចិត្តបវរ　　ក្រេបផឹករសធម៌　　ព្រះពុទ្ធជិនស្រីភគវា ។
ភ័ក្ត្រមួយទតទិសបូព៌ា　　តំណាងមេត្តា　　ខេមរាអស្ចារ្យរូពិន ។
ភ័ក្ត្រមួយទតទិសទក្សិណ　　ករុណានៃជិន-　　ស្រីរ័ត្នត្រ័យម្កុដសោភា ។
ភ័ក្ត្រមួយទតទិសបច្ឆិមា　　តាងមុទិតា　　ពោធិសម្ភារបវរ ។
ភ័ក្ត្រមួយទតទិសឧត្តរ　　តំណាងព្រហ្មធម៌　　ឧបេក្ខាបីដ៏និមល ។

ក្បួរក្បាច់រំលេចសោតសល់ តម្កុំតម្កល់ ពីគល់ទ្រនាប់ខ្សាច់ក្រោម ។
កិន្នរូបល្អទាំងនោម ហាត្ថាកាន់កោ- មលមាសបីល្អដ៏ភិរម្យ ។
ត្របកមាត់ពានបទុម ក្តោបក្បាច់រាងក្បាំ ឧត្តមបីត្រកាលបញ្ចង់ ។
ក្បាច់ពេជ្រជើងកោសម្រើសទ្រង់ ទ្រតម្កល់អង្គ ព្រះប្រាង្គវិចិត្រវចនា ។

(ឧកញ៉ា សុត្តន្តប្រីជាឥន្ត កម្រងអត្ថបទអក្សរសិល្ប៍ថ្នាក់ទី ៥ក្រសួងអប់រំឆ្នាំ ១៩៨៤)

២ . បទព្រហ្មគីតិ

សម្រង់ចាកច្បាប់ប្រុស (បណ្ឌិត ម៉ឺន មៃ)

កុំខ្ជិលកុំច្រអូស ទៅងងូសរត់សុំគេ
គេមិនឱ្យឯងទេ តែគឺមោះព្រោះខ្ជិលដាំ ។
ទោះធ្វើស្រែចម្ការ ឱ្យឧស្សាហ៍មើលថែទាំ
កុំខ្ជិលកុំប្រថាំ ចបចូលជីកស្មៅវល្លិផង ។
កុំឱ្យបង់កម្លាំង ទោះខែប្រាំងប្រើឱ្យដង
ទឹកទៅស្រោចស្រប់ផង ឱ្យលូតលាស់មានផ្លែផ្កា ។
ធ្វើការកុំគិតព្រួយ ខ្លួនឯងមួយកុំឆ្លួញតែរ
ខ្លាំងខ្សោយកុំឱ្យល្ហែ ខ្លាចតែនឿយហើយមិនធ្វើ ។
ជាងយប់បិទបួសរ្បី តប្បាញជាល្ងីតៅកញ្ជើ
កុំឱ្យស្រីស្តីលើ ឥតអំពើធ្វើលេងទៅ ។
កុំទុកដៃទទេ ជាងទំនេរបោចស្មៅព្រៅ
ខាងផ្ទះខាងលំនៅ ឱ្យវាលកាលកើតសុខា ។
ឱ្យមានក្តីបារម្ភ ធ្វើស្រែកុំចោលចម្ការ
ដឹងដែកកាំបិតព្រា ទុកឱ្យជាកុំឱ្យបាត់ ។
ដេកយប់ឱ្យរាំងទ្វារ ទ្រព្យជាៗប្រុងប្រយ័ត្ន
ត្រចៀកចាំកុំភ្លាត់ កុំភ្លេចចោលមិនដឹងខ្លួន ។
ប្រយត្នប្រយោជន៍ឃួរ ទោះលក់ដូរមើលថែធួន
ទោះទ្រព្យរបស់ខ្លួន ឱ្យសួរកូនសួរប្រពន្ធ ។
កុំអាងឯងជាប្រុស ចាយរបស់មិនបានគន់
មិនដឹងដល់ប្រពន្ធ ព្រមព្រៀងគ្នាឥតបើថា ។

៣ . បទតុដ្ឋលីលា

សម្រង់ចាកច្បាប់ស្រី (បណ្ឌិត ម៊ឺន មៃ)

ហៅកូនស្រីស្ងួនមាសម្តាយ ក្រណាស់នាងអាយ តាមដោយច្បាប់ស្រី ។
ក្រមួយមិនបានសំដី ពាក្យទន់តិចនៃ ឱ្យញាតិចូលចិត្ត ។
ក្រមួយមិនចេះរិះគិត ឃើញញាតិឆ្ងាយជិត ហៅឡើងធឺស្លា ។
ទោះមានមិនមានក្តីណា ពាក្យផ្អែមចរចា ទើបគេស្រលាញ់ ។
កុំជួរចិត្តស្ងួរកំណាញ់ មិនមានអស់អញ្ញ នឹងញាតិសន្តាន ។
កើតយសរបស់ផងបាន កើតសុខក្សេមក្សាន្ត ពីព្រោះកូនស្រី ។
ទោះនឹងនិយាយហាស្តី ការកេរ្តិ៍ជាស្រី កុំស្តីឡេះឡោះ ។
ថាលេងដួចក្មេងញ៉ោះញ៉ោះ ឃើញប្រុសកំលោះ សសៀរចូលចិត្ត ។
សើចព្រៀងបញ្ឆៀងមិនគិត ប្រុសព្រើលបានចិត្ត វាហ៊ានដោយសារ ។
ហៅស្រីអប្រិយឥតការ ឥតមានឥរិយា មារយាទក្នុងខ្លួន ។
សើរីពុំធ្វើនឹងនួន ស្រដីមិនមួន មិនមានអៀនអន់ ។
ឃើញគេបៀតបែរគយគន់ សើចសួរចំអន់ ចំអកឱ្យប្រុស ។
ហៅស្រីអប្រិយទុរយស មិនខ្លាចខ្លួនខុស មារយាទក្រីត្យក្រម ។
ធ្វើការអង្គុយច្រឡំ នឹងសមពុំសម ផ្សារឯងជាស្រី ។
មិនកោតមិនខ្លាចចិត្តប្តី ឱ្យប្រុសដទៃ មាក់ងាយប្តីណា ។
ហៅស្រីឥតលក្ខិណា ឥតមានកិរិយា មារយាទពុំសម ។
ធ្វើការផងណាត្រូវខំ ទោះត្បាញចាក់ដំ នាងខំឱ្យហើយ ។
កុំទុកទៅមុខទៀតឡើយ ថាចាំបង្ហើយ កម្រណាស់ណា ។
ទោះធ្វើហូលគោមព្រៃផ្តា ដាក់ត្បាញហើយថា បានស្រេចសឹមធ្វើ ។

តែងកាព្យបទពំនោល

អ្នកបានសិក្សានិងជ្រើសរើសរួចមកហើយអំពីការសូត្រកំណាព្យដែលមានបទពំនោល បទព្រហ្មគីតិ និងបទភុជង្គលីលា ។

ចូរអ្នករំលឹកឡើងវិញអំពីធាតុសំខាន់ៗនៃកំណាព្យដូចជារង្វាស់កាព្យ ចំណាប់ចួន ចំណាប់ចួនក្នុងវគ្គ ចំណាប់ចួនឆ្លងវគ្គ ចង្វាក់ បរិយាកាស ដើម្បីតែងអត្ថបទកាព្យខ្លីមួយដែលមានចំនួន ៣ទៅ ៥វគ្គ។ ចូរពិនិត្យមើលរង្វាស់កាព្យនិងចំណាប់ចួននៃបទពំនោល :

ក.រង្វាស់កាព្យ

ក្នុង ១វគ្គមាន ៣ឃ្លា ។

- ឃ្លាទី ១ មាន ៦ព្យាង្គ
- ឃ្លាទី ២ មាន ៤ព្យាង្គ
- ឃ្លាទី ៣ មាន ៦ព្យាង្គ ។

ខ.ចំណាប់ចួន

គំនូសតាងនិងការចាប់ចុងចួនក្នុងវគ្គនិងឆ្លងវគ្គ :



- ចួនក្នុងវគ្គ

  ព្យ.៦.ឃ.១ ═══ ព្យ.៤.ឃ.២

- ចួនឆ្លងវគ្គ

  ព្យ.៦.ឃ.៣ វ.១ ═══ ព្យ.៦.ឃ.១ វ.២ ═══ ព្យ.៤.ឃ.២ .វ.២

លំហាត់

ចូរប្អូនតែងកំណាព្យបទពំនោលឱ្យបានយ៉ាងតិចចំនួន ៥វគ្គ ដែលមានខ្លឹមសារទាក់ទងនឹងប្រធានបទ "ការកំណត់គោលដៅក្នុងការសិក្សា" ។

មុនពេលសរសេរសូមប្អូនសរសេរសំណេរព្រាងនិងអនុវត្តតាមសេចក្តីណែនាំខាងក្រោម ៖

១. កំណត់ខ្លឹមសារសំខាន់ៗដែលទាក់ទងនឹងប្រធានបទ "ការកំណត់គោលដៅក្នុងការសិក្សា" ឱ្យបានច្បាស់លាស់ត្រឹមត្រូវ

២. កំណត់គំនិតសំខាន់ៗដែលទាក់ទងនឹងប្រធានបទដោយយ៉ាងហោចណាស់ក្នុង ១វគ្គឱ្យបាន ១ គំនិតសំខាន់និងអនុវត្តទៅតាមកម្មួនតែងកាព្យបទពំនោលឱ្យបានត្រឹមត្រូវ ទាំងរង្វាស់កាព្យ ទាំងចំណាប់ចួនដូចជា :

- រង្វាស់កាព្យ
  - ១ វគ្គ មាន ៣ឃ្លា
  - ឃ្លាទី ១ មាន ៦ព្យាង្គ
  - ឃ្លាទី ២ មាន ៤ព្យាង្គ
  - ឃ្លាទី ៣ មាន ៦ព្យាង្គ ។
- ចំណាប់ចួន
  - ព្យាង្គទី ៦នៃឃ្លាទី ១ ចួននឹងព្យាង្គទី ៤ នៃឃ្លាទី ២
  - ព្យាង្គទី ៦នៃឃ្លាទី ៣ ក្នុងវគ្គទី ១ ចួននឹងព្យាង្គទី ៦នៃឃ្លាទី ១ ក្នុងវគ្គទី ២ ចួននឹងព្យាង្គទី ៤ ឃ្លាទី ២ វគ្គទី ២ ។

៣. សរសេរតាមលំដាប់លំដោយគំនិតនិងស្របតាមប្រធានបទ ។

៤. ប្រើប្រាស់សញ្ញាសម្ព័ន្ធវេយ្យាករណ៍ឱ្យបានត្រឹមត្រូវ

៥. ចៀសវាងកំហុសអក្ខរាវិរុទ្ធ

៦. កែលំអសំណៅព្រាងដោយផ្ចិតផ្ចង់និងសរសេរសម្រេចឱ្យបានស្អាតល្អនិងឡើងបង្ហាញបានត្រឹមត្រូវ ។

ស្មារតីទទួលខុសត្រូវ



មនុស្សយើងធ្វើអ្វីក៏ដោយត្រូវមានស្មារតីទទួលខុសត្រូវចំពោះកាតព្វកិច្ច ភារកិច្ច បេសកកម្ម របស់ខ្លួន ដោយហ៊ានធ្វើការតស៊ូលះបង់យ៉ាងប្តូរផ្តាច់ដើម្បីជោគជ័យនិងហ៊ានបង្ហាញការពិតចំពោះទង្វើដែលខ្លួនបានប្រព្រឹត្ត ចេះកែកំហុសខ្លួនមករកផ្លូវត្រូវឬផ្លូវល្អ ដើម្បីធ្វើខ្លួនឱ្យក្លាយទៅជាមនុស្ស មានសមត្ថភាព មានមនសិការក្នុងការងារ មានសីលធម៌ មានសាមគ្គីភាព ចេះរួមរស់ជាមួយគ្នាប្រកបដោយភាពសុខដុម។ ទាំងនេះ គឺជាកត្តាដ៏សំខាន់ក្នុងការអភិវឌ្ឍគ្រួសារ សហគមន៍ និងសង្គមជាតិ។ ដូច្នេះ យើងត្រូវមានស្មារតីទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនជានិច្ច។

មេរៀននេះ ផ្តល់គំនិតវិសេសវិសាលលើរាល់ការសម្រេចចិត្តនិងការទទួលខុសត្រូវលើការងារផ្សេងៗដែលអ្នកជួបប្រទះ។ ទន្ទឹមនឹងនេះ អ្នកនឹងបានសិក្សាអំពីបំណិនដូចជាលក្ខណៈសម្គាល់រឿងល្ខោន ការបង្ហាញតួអង្គក្នុងរឿងល្ខោន ពាក្យបន្ថែមដើមនិងពាក្យបន្ថែមចុង ការសម្តែងតួ និងសំណេររឿងល្ខោន។

លក្ខណៈសម្គាល់រឿងល្ខោន

ខ្មែរយើងមានល្ខោនច្រើនប្រភេទ មានល្ខោនបាសាក់ ល្ខោនយីកេ ល្ខោនមហោរី ល្ខោននិយាយ ល្ខោនខោល ល្ខោនអាប៉េ ល្ខោនស្រមោល (ស្បែកតូច ស្បែកធំ)ជាដើម។

អត្ថបទល្ខោន គឺជាអត្ថបទអក្សរសិល្ប៍មួយប្រភេទ ដែលអ្នកនិពន្ធចងក្រងឡើងសម្រាប់យកទៅសម្តែងជាសិល្បៈល្ខោន។ អត្ថបទល្ខោនស្រដៀងគ្នានឹងអត្ថបទរឿងដែរ គឺមានធាតុសំខាន់ៗដូចជា ចំណោទបញ្ហា តួអង្គ កាលអាកាស និងមូលន័យ។

ទម្រង់សំណេររបស់អត្ថបទល្ខោនខុសពីទម្រង់សំណេររបស់អត្ថបទរឿង។ អត្ថបទល្ខោនចែកជា ឈុតនិងឆាក។ នៅខាងដើមអត្ថបទល្ខោននីមួយៗមានបញ្ជីរាយនាមតួអង្គនិងឋានៈ ឬប្រភពកំណើតរបស់តួអង្គ។ អត្ថបទល្ខោនអាចសរសេរជាពាក្យកាព្យ ឬពាក្យរាយនិងជាពាក្យពោល ឬការសន្ទនារវាងតួអង្គនិងតួអង្គ។ ក្នុងអត្ថបទល្ខោនអ្នកនិពន្ធសរសេរសេចក្តីបញ្ជាក់ពីលក្ខណៈរូប ទឹកមុខ កាយវិការ សម្តីឬសំឡេងរបស់តួអង្គក្នុងវង់ក្រចក។

ចូរអានវគ្គដកស្រង់ រឿង តេជោយ៉ត ដូចខាងក្រោម ៖

បញ្ជីរាយនាមតួអង្គ

- តេជោមាស : ស្វាមីជំទាវស្រែនមានងារជាតេជោបរមរាជត្រួតខេត្តកំពង់ស្វាយ។
- តេជោយ៉ត : សិស្សតេជោមាស មានងារជាតេជោត្រួតខេត្តកំពង់ស្វាយពេលតេជោមាសស្លាប់ទៅ។
- ជំទាវស្រែន : ភរិយាតេជោមាស ជាស្ត្រីដែលមានល្បិចឆ្លើមអាចចាប់ស្តេចសំរែយកទៅកាត់ទោសបាន។
- ព្រះចៅជ័យចេស្តា: មហាក្សត្រខ្មែរគង់នៅក្រុងឧដុង្គមានជ័យ។
- អ្នកម្នាងនួ : បងស្រីម៉ឺនចៃចុងរ៉ាក់និងជាអ្នកម្នាងរបស់ព្រះចៅជ័យចេស្តា។
- ស្តេចសំរែ : មេបះបោរបម្រុងដណ្តើមរាជ្យពីព្រះចៅជ័យចេស្តា។
- ឧកញ៉ាពិភា : មន្ត្រីជំនិតរបស់ស្តេចសំរែ។
- ឧកញ៉ាព្រះស្រីទ្វារប្រាសាទដប់ : បម្រើការងារជាមួយតេជោមាសនិងតេជោយ៉ត។
- នាងម៉ៃ : បុត្រីឧកញ៉ាព្រះស្រីទ្វារប្រាសាទដប់និងជាអ្នកស្រឡាញ់តេជោយ៉តតែមិនបានសម្រេចក្លាយទៅជាប្អូនធម៌របស់តេជោយ៉តទៅវិញ។
- នាយឈិត : ឈ្លើយសឹកសៀមនិងជាមេបះបោរប្រឆាំងនឹងព្រះរាជាខ្មែរ។
- ម៉ឺនចៃចុងរ៉ាក់ : ប្អូនអ្នកម្នាងនួ ប្រឆាំងនឹងតេជោយ៉តហើយត្រូវតេជោយ៉តចាប់ទៅសម្លាប់ចោលនិងមានតួអង្គរំឭកជាច្រើនទៀត។

ឆាកទី ១

តេជោមាស : ខ្ញុំឈ្មោះ "មាស" មានគោរមងារជាឧកញ៉ាតេជោបរមរាជ...(ច្រៀង) តាំងចិត្តប្តេជ្ញាការពារ ទឹកដីដូចជា ប្រស្រីក្នុងកែវនេត្រា (២ដង) ទោះត្រូវលះបង់អាយុសង្ខារ ក៏ចិត្តស្នេហាជាតិមិនរសាយ។ (និយាយ)ជិតដល់ពេលចេញដំណើរហើយតើ! ឯណាយ៉ត ?

យ៉ត : បាទលោកគ្រូ!

តេជោមាស : កងទ័ពរបស់យើងបានរៀបចំរួចរាល់ហើយ ឬនៅ ?

យ៉ត : បាទ! ខ្ញុំបាទត្រៀមរួចអស់ហើយ គឺយើងយកតែទ័ពសេះប៉ុណ្ណោះតាមការគ្រោងទុកណា៎លោកគ្រូ!

តេជោមាស : អឺ! ល្អហើយ (សូរសំឡេងសេះកញ្ជ្រៀវខ្ញៀវខ្ញារ...)។

ជំទាវស្រែន : បងគិតចេញដំណើរឥឡូវនេះឬ ?

តេជោមាស : ហ្នឹងហើយអូន! ដល់ពេលវេលាបងហើយណា៎!

ជំទាវស្រែន : នេះថ្នាំព្យាបាលរបួសដែលបងតែងដាក់តាមខ្លួន អូនបានរៀបចំជូនបងសព្វគ្រប់អស់ហើយ។

(ដកស្រង់ចេញពីល្ខោនបាសាក់សម្តែងតាមវិទ្យុ តេជោយ៉ត របស់លោក ទីជីហួត)

តាមរយៈអត្ថបទល្ខោនខាងលើបង្ហាញថា

- **សេចក្តីបញ្ជាក់របស់អ្នកនិពន្ធ** គឺ(សូរសំឡេងសេះកញ្ជ្រៀវខ្ញៀវខ្ញារ...)និង(ស្នូរជើងសេះចេញដំណើរ)។
- **បញ្ជីរាយនាមតួអង្គ** : តេជោមាស ជំទាវស្រែន តេជោយ៉ត ស្តេចសំរែ ...
- **ពាក្យពេចន៍ដែលតួអង្គនិយាយគ្នាគឺ** : ការសន្ទនា។

ចូរអានវគ្គដកស្រង់រឿង ថៅកែចិត្តចោរដូចខាងក្រោម ៖

បញ្ជីរាយនាមតួអង្គ

- នាយជានិត អាយុ ១៧ឆ្នាំ ធ្វើការក្នុងហាងឡាន
- ពូ ហាំ អាយុកណ្តាលមនុស្ស ជាតៃកុងឡាន
- ថៅកែឡាន នាងយ៉ាន ប្រពន្ធពូហាំ
- សុខ កម្មករឡាន , មាន កម្មករឡាន
- គង់ កម្មករឡាន , ទ្រី កម្មករឡាន
- ពួកក្រុមគរបាលបីនាក់

ឆាកទី ១

(គេឃើញជានិតនៅក្មេងរាងស្គមកំពុងកត់ត្រា ចុះបញ្ជីសៀវភៅធំមួយ ទើបពូ ហាំ ចំណាស់ ពាក់កណ្តាលមនុស្សដើរចូលមកលបៗ។ ជនទាំងពីរឃើញគ្នាសម្លឹងយូរបន្តិច ទើបពូ ហាំ និយាយ)។

ពូ ហាំ : លោកក្មួយមានរឿងអ្វី បានជាមើលពូតាំងពីក្បាលដល់ចុងជើង ហាក់ដូចជាមិនដែលស្គាល់គ្នា ?

ជានិត : ពូក្រែង... ក្រែងឡានពូ...

ហាំ : ថៅកែនៅហ្នឹង ឬទេ ?

ជានិត : ចេញបាត់តាំងពីព្រលឹមម្ល៉េះ!

ហាំ : យី! ថ្មើរម៉ានទៅទើបគាត់ត្រឡប់មកវិញ ពូមានរឿងប្រញាប់ជាមួយនឹងគាត់ផង។

ជានិត : មើលទៅបន្តិចទៀតគាត់នឹងអញ្ជើញមកវិញហើយ។

ហាំ : ទៅមើលពួកអាដែងអស់នោះមួយភ្លែតសិន! (ដើររួចទុចវិញ) ណ្លើយកុំឱ្យវាឃើញមុខនាំពិបាកចិត្តទេ។

ជានិត : អញ្ជើញអង្គុយទៅពូ (ពូហាំធ្វើតាម) ខ្ញុំឡើងទៅផ្ទះសិន (ជានិតក៏ដើរយ៉ាងលឿនចេញពីទីនោះហាក់ដូចជាខ្លាចមិនហ៊ានអង្គុយជាមួយតែកុង)។

ហាំ : លោកក្មួយកុំទៅណា អង្គុយនៅទីនេះហើយឱ្យបានពីរនាក់គ្រាន់បានជាគ្នា (ជានិតក៏ត្រឡប់មកអង្គុយវិញតែធ្វើជាបើកសៀវភៅធ្វើការ)។ (តែកុងឡាន ជក់ខ្លះ ហួចខ្លះ ច្រៀងខ្លះ ទើបនិយាយថា) យី! ចំតែម្តងហើយ ថៅកែទៅណាក៏ក្រមកម្ល៉េះ។ ក្មួយមានឮនរណាគេនិយាយថាអ្វីពីខ្ញុំទេ ?

ជានិត : ឮគេនិយាយតែរឿងហ្នុង!

ហាំ : រឿងស្អី រឿងហ្នុង ?

(ដកស្រង់ និងកែសម្រួលពីរឿង ថៅកែចិត្តចោរ ឆាកទី ១)

សំណួរ

១. តើអត្ថបទដកស្រង់រឿងតេជោយ៉តឆាកទី ១នេះនិយាយពីអ្វី ?

២. តើអត្ថបទល្ខោនដកស្រង់រឿងថៅកែចិត្តចោរឆាកទី ១នេះនិយាយពីអ្វី ?

៣. តើអត្ថបទល្ខោនដកស្រង់ខាងលើនេះមានតួអង្គណាខ្លះ ?

៤. តើតួអង្គនីមួយៗមានឋានៈនិងតួនាទីអ្វីខ្លះក្នុងរឿង ?

៥. តើគេអាចដឹងលក្ខណៈសម្គាល់រឿងល្ខោនតាមលក្ខណៈអ្វីខ្លះ ?

វិធីបង្ហាញតួអង្គក្នុងរឿងល្ខោន

ល្ខោនគឺ ជាសិល្បៈមួយប្រភេទដែលអ្នកនិពន្ធចងក្រងឡើងសម្រាប់យកទៅសម្តែងលើឆាក ។ រឿងល្ខោនមានទាំងអត្ថបទសំណេរនិងការសម្តែង ។ វិធីបង្ហាញតួអង្គក្នុងរឿងល្ខោនស្រដៀងគ្នានឹងប្រភេទរឿងផ្សេងៗទៀតដែរ ។ គេសង្កេតឃើញថា រឿងល្ខោនមានវិធីបង្ហាញតួអង្គបួនបែប គឺការបង្ហាញដោយអ្នកនិពន្ធ ការបង្ហាញដោយតួអង្គខ្លួនឯង ការបង្ហាញដោយតួអង្គដទៃនិងការបង្ហាញតួអង្គតាមរយៈដំណើររឿង ឬសកម្មភាពតួអង្គ ។

១ . វិធីបង្ហាញតួអង្គដោយអ្នកនិពន្ធ

សរសេររាយនាមតួអង្គ មុខងារ ប្រភពកំណើតរបស់តួអង្គនីមួយៗនៅខាងដើមអត្ថបទ ។ ក្នុងការសម្តែងវិញ វិធីបង្ហាញតួអង្គធ្វើឡើងដោយការប្រកាសឈ្មោះតួអង្គនៅក្នុងរឿងនិងឈ្មោះតួសម្តែងតំណាងនៅពេលចាប់សម្តែងល្ខោន ។

ឧទាហរណ៍ : រឿង រ៉ូមេអូនិងស៊ុលីយែត

រាយតួ

- អេស្កាលុស : ព្រះអង្គម្ចាស់នៅវ៉េរោន
- ប៉ារីស៍ : យុវអភិជនម្នាក់ជាញាតិវង្សព្រះអង្គម្ចាស់នៅវ៉េរោន
- ឧកញ៉ាម៉ុងតេហ្គុយ : មេនៃត្រកូលអភិជនដែលប្រឆាំងគ្នានឹងត្រកូលកាប់ពុយឡែត
- ឧកញ៉ាកាប់ពុយឡែត : មេនៃត្រកូលអភិជនដែលប្រឆាំងគ្នានឹងត្រកូលម៉ុងតេហ្គុយ
- មនុស្សចាស់ម្នាក់នៃត្រកូលកាប់ពុយឡែត
- រ៉ូមេអូ : បុត្រប្រុសនៃឧកញ៉ាម៉ុងតេហ្គុយ ...
- លោកសង្ឃឡូរ៉ិន : សង្ឃខាងសាសនាប្រៀង់សិស្កាំង
- លោកសង្ឃហ្សង់ : សង្ឃខាងសាសនាដូចគ្នា
- បាល់ថេហ្សារ : អ្នកបម្រើរបស់រ៉ូមេអូ ...
- លោកជំទាវម៉ុងតេហ្គុយ : ប្រពន្ធឧកញ៉ាម៉ុងតេហ្គុយ
- លោកជំទាវកាប់ពុយឡែត : ប្រពន្ធឧកញ៉ាកាប់ពុយឡែត
- ស៊ុលីយែត : កូនស្រីលោកឧកញ៉ាកាប់ពុយឡែត

- មេដោះនាងស៊ុលីយែត
- ពលរដ្ឋខ្លះនៅវៀរោន
- ញាតិនៃត្រកូលធំទាំងពីរ (ម៉ុងតេហ្គុយនិងកាប់ពុយឡែត)
- អ្នកពាក់មុខ ទាហាន អ្នកយាម និងអ្នកពោល ។

២ . វិធីបង្ហាញតួអង្គដោយតួអង្គខ្លួនឯង

ឧទាហរណ៍ : រឿងតេជោយ៉ត (ល្ខោនបាសាក់)

តេជោមាស : ខ្ញុំឈ្មោះ "មាស"មានគោរម្យ៉ងារជាឧកញ៉ាតេជោបរមរាជ ... ។

ស្តេចសំរែ : តាំងនាមខ្លួនឯងថា "ព្រះសំរែរាជាធិរាជ"មិនយូរមិនឆាប់យើងនឹងបានគ្រប់គ្រងរាជ្យសម្បត្តិ ... ។

នាងម៉ៃ : ខ្ញុំឈ្មោះម៉ៃអាយុ ១៨ឆ្នាំ ឪពុករបស់ខ្ញុំមានងារជាឧកញ៉ាព្រហ្មស្រីទ្វារប្រាសាទដប់ ... ។

ព្រះចៅជ័យចេស្តា : ទ្រង់ព្រះនាមសម្តេចព្រះរាជឱង្ការព្រះជ័យចេស្តាបរម មហាខត្តិយា រាមាធិបតី ព្រះស្រីសុរិយោពណ៌ មហាចក្រពត្រាធិរាជ ។

៣ . វិធីបង្ហាញតួអង្គដោយតួអង្គដទៃ

ឧទាហរណ៍ : រឿងផ្កាស្រពោន (ល្ខោននិយាយ)

មីងនួន : ហ៎ាក ចាន់បៀកស្លាមួយម៉ាត់ទៀតទៅ! កុំអៀនមាត់អៀនកអីអ្នកណា៎! អ្នកណាគេចង់ចូលម៉ោ ?

អ៊ំចាន់ : ចឹកណៃស៊ានណា៎!

មីងនួន : ណៃស៊ានណា៎អីចេះ ? ណៃស៊ានថៅកែកាណូតហ្នឹងហ្ន៎!

អ៊ំចាន់ : យហ៎! មានណៃស៊ានឯណាពីរបីបាត់ដំបងយើងហ្នឹង

មីងនួន : ហ៊ីសហ៊ី(សើច)ចឹកណៃស៊ាន ថៅកែណៃស៊ាន ថៅកែកាណូតដើរទន្លេសាប ថៅកែណៃស៊ាន ។ អូហ៎! ថៅកែណៃស៊ានមានកូនកំលោះហ្ន៎ ?

អ៊ំចាន់ : អឺ! កូនកំលោះតែមួយគត់ នួនឯងស្គាល់ទេណៃស៊ាតហ្នឹងណា៎!

មីងនួន : ណៃស៊ីតៗ ថៅកែណៃស៊ាន(សើច)ថៅកែណៃស៊ីត អូហ៎ហ៎ ថៅកែណៃស៊ាន ។...

(ដកស្រង់និងកែសម្រួលពីល្ខោននិយាយរឿងផ្កាស្រពោន របស់លោកមាសគកន្ធាំ ១៩៦១-១៩៦៥)

តាមរយៈឧទាហរណ៍នេះ គឺអ៊ំចាន់បានបង្ហាញពីឈ្មោះតួអង្គថៅកែណៃស៊ាននិងកូនប្រុសលោកថៅកែនេះឈ្មោះណៃស៊ីតប្រាប់ទៅមីងនួន ។

៤ . វិធីបង្ហាញតួអង្គតាមរយៈដំណើររឿងឬសកម្មភាពតួអង្គ

ឧទាហរណ៍ : រឿងតេជោយ៉ត(ល្ខោនបាសាក់)

យ៉ត : បាទ! ខ្ញុំបាទត្រៀម ... លោកគ្រូ!

តេជោមាស : អើ! ល្អហើយ(សួរសំឡេងសេះកញ្ជ្រៀវខ្ញៀវខ្ញារ)

ជំទាវស្រែន : បង! គិតចេញដំណើរឥឡូវនេះឬ ?

តេជោមាស : ហ្នឹងហើយអូន!.... ។

តាមរយៈឧទាហរណ៍ខាងលើនេះ តួអង្គជំទាវស្រែនលេចចេញមកដោយគ្មានអ្នកណាហៅនិងមិនបង្ហាញឈ្មោះខ្លួនឯងឡើយគឺបង្ហាញខ្លួនតាមដំណើររឿងតែម្តង ។

វិធីបង្ហាញតួអង្គ គឺជាការប្រាប់ពីឈ្មោះ អាយុ ឋានៈ ប្រភពកំណើតរបស់តួអង្គនីមួយៗ នៅក្នុងរឿងដើម្បីឱ្យអ្នកអានឬអ្នកទស្សនាបានស្គាល់ ។ វិធីបង្ហាញតួអង្គក្នុងរឿងល្ខោនមាន ៤បែបគឺ វិធីបង្ហាញតួអង្គដោយអ្នកនិពន្ធ វិធីបង្ហាញតួអង្គដោយតួអង្គខ្លួនឯង វិធីបង្ហាញតួអង្គដោយតួអង្គដទៃ និងវិធីបង្ហាញតួអង្គតាមរយៈដំណើររឿងឬសកម្មភាពតួអង្គ ។

សំណួរ

១. តើវិធីបង្ហាញតួអង្គក្នុងរឿងល្ខោនមានប៉ុន្មានបែប ? ចូររៀបរាប់ ។

២. ចូរអានអត្ថបទល្ខោនខាងក្រោម រួចបញ្ជាក់ពីវិធីបង្ហាញតួអង្គនីមួយៗឱ្យបានត្រឹមត្រូវ ។

លំហាត់

ចូរបង្ហាញពីវិធីបង្ហាញតួអង្គក្នុងរឿងសំបុកឥតមេបា ។

សម្បត្តិ : ស្ទឹទៀតហើយ ... រឿងវាយ៉ាងម៉េច ?

និម្មិត : បងសម្បត្តិអើយ ... បងរក្សា បងឈប់រក្សាសម្បត្តិ គិតរត់ឱ្យបាត់ចោលសម្បត្តិ ឈប់រក្សាសម្បត្តិទៀតហើយ ។

សម្បត្តិ : ស្ទប់អាគ្មិត កវីចំកួត និយាយឡើងតែពាក្យរដឹករណ្តំ អញស្តាប់មិនបានទេ ។

និម្មិត : បើបងសម្បត្តិស្តាប់មិនបាន មានតែសួរទៅបងរក្សាឱ្យគាត់សាសព្វសេចក្តីតាមការគួរនូវសំណួរបងសម្បត្តិឯងចុះ ... ។

សម្បត្តិ : អាគ្មិត កវីឡប់សង ថយចេញឱ្យឆ្ងាយ ។

រក្សា : ព្រឹកមិញ ក៏ដូចជាថ្ងៃមុនៗ ក្នុងផ្ទះនៅចំពោះមុខលោកប៉ា អ្នកម្តាយ ពុះទៀតហើយ បុរាណសម័យ ចំកួតសិល្បៈ វាប្រកាប់ប្រចាក់គ្នាក្នុងសំបុកឥតមេបា ។

និម្មិត : ជាមួយនឹងករណីយកិច្ចរុះរើ

រក្សា : អើ ... ជាក់ឈ្មោះស្ទឹចឹងក៏បានដែរ វាប្រជែងប្រជល់គ្នាទៀតហើយ ធ្វើឱ្យគេហដ្ឋានដ៏សូប់ស្ងាត់ ពុះពោរ រំជួយរកប្រៀបពុំបាន ឱផ្ទះ ... ទាំងឡាយ អ្នកនឹងនរតែខាងក្រៅ ឯខាងក្នុងពុះពោរដូចផ្ទះនេះដែរឬ ហើយធ្វើឱ្យបងអស់សង្ឃឹមចង់រត់ចោលអូន ... ។ បងថា បងរត់ចោលទៅបាន តែនិម្មិតគេថាបងទៅមិនបាន បានជាបងទៅឱ្យគេមើល ទើបវាទង្គិចនឹងអូនឯងដើរចូលមក ។

និម្មិត : ក៏ត្រលប់ជាមិនបានទៅ ទៅវិញ

សម្បត្តិ : ឱលោកប៉ា អ្នកម៉ាក់អើយ អត់ពីលោកប៉ា អ្នកម៉ាក់ទៅ ក្នុងគ្រួសារនេះ ដូចជាគ្រួសារកូនក្មេង ម្នាក់ៗគ្មានគំនិតឱ្យនឹងនរ គ្មានតុល្យភាពសោះ ដើរឆ្វេងតែសព្វខ្លួន ។ បងទម្លាប់គិតតែពីបុរាណ ម្ហូស្លាទៀនធូប មន្តអាគម អន្លក់ទឹកត្រឿង ។ មីក្តែតគិតពីទំនើប ស៊ីញ្ញគ្លោម ពិចនិច ហ្ស៊ីប ខោរីត រូម៉ង់ដាមួរ ។ អាគ្មិត កវីទាល់ប្រាជ្ញា ស៊ីដេក ច្រៀងមិនពីរោះ ដេញថាប៊ីកញ្ចាស់ ចេះភ្លេងក៏មិនជាក់ ច្រៀងក៏មិនជាក់ ល្ងោនខ្លះ កុនខ្លះ គំនួរខ្លះ តែលតោល រស់តែពាក្យ ធ្វើអីមិនកើត ព្រួយតែនឹងជីវិតវិល ឬឈប់វិល ... ។

រីបងឯណោះ ឃើញជីវិតដូចឯងឥតទាំងអស់ គុងទឹន កុងស៊ីបញ្ចាំ ថ្លៃទឹក ថ្លៃភ្លើង ម៉ែៗភ័យតែគ្មាន ១០០រៀល ។ ខ្ញុំមិនដូចអ្នកទាំងអស់គ្នាទេ ធម្មតាបើកភ្នែកឡើងឃើញយ៉ាងម៉េច ក៏ស្រាយតាមយ៉ាងនោះទៅ ។ ថ្ងៃណាមានពិបាក ព្រួយខ្លះទៅ ថ្ងៃណាស្រួលសប្បាយញញឹមខ្លះទៅ មិនបណ្តោយខ្លួនខ្ញុំឱ្យស្ថិតក្រោមផ្តត់អាក្រក់អ្វីមួយ នេះហើយជីវិត និងផ្លូវស្រាយ ។

រក្សា : អើ ឯងពូកែស្រាយ ស្រាយទៅ ហ៊ាបញ្ហាអីចឹង បងទម្លាប់អណ្តែត រួចលោកកវីសិល្បករឯណោះថែមទាំងបណ្តាំខ្មោចលោកប៉ា អ្នកម្តាយ ចោទអីចឹងហើយឥឡូវ ...ស្រាយទៅ ។

សម្បត្តិ : ងាយសោះ (សើច) គិតរៀបការឱ្យហើយទាំងអស់គ្នា ដូចបណ្តាំលោកប៉ា អ្នកម៉ាក់ទៅ ...បងទម្លាប់ជាមួយនឹងអាចារ្យភីម ។

(ដកស្រង់ពីរឿងល្ខោននិយាយ សំបុកឥតមេបា របស់អ្នកនិពន្ធ ហង្ស ធន់ហាក់)

កំហុសអ្នកណា

ក. សិក្សាពាក្យគន្លឹះ

- បាវ (ន) : ទាស:ឬទាសី គឺខ្ញុំប្រុសខ្ញុំស្រី។ សម័យបច្ចុប្បន្ននេះឈប់ប្រើពាក្យបាវ ហើយ គឺមានតែឈ្នួល(មនុស្សស៊ីឈ្នួល)និងកម្មករ, កម្មការិនីឬថាប្រុសបម្រើ, ស្រីបម្រើប៉ុណ្ណោះ។
- ផ្ទួរ (ន) : ពំនូកដីដែលពួនលើរណ្តៅសាកសព។
- អង្កេត(បារាំង) (ន) : ការស៊ើបសួរបញ្ជាក់សាក្សី ដំណើរស៊ើបសួរសង្កេតអ្នកដឹងការពិត។ ខ្មែរប្រើជា កិ-ឬគុ- ក៏មាន : ចាត់អាជ្ញាទៅអង្កេត អាជ្ញាអង្កេត។
- ភ័ស្តុតាង (ន) : របស់ជាតិកតាង ជាគ្រឿងសម្គាល់ ជាសម្ពាង។
- បរិពារ (បរិវារ) (ន) : អ្នកចោមរោមកំដរ អ្នកបែហាមជាកិត្តិយស អ្នកត្រៀមខ្លួនរង់ចាំបម្រើអ្នកបម្រើ។
- ចេតិយ (ន) : ទីដែលគេគោរពបូជា គឺទីណាមួយទោះមានដើមឈើធំជាប្រធានជាទីសម្គាល់ក្តី មានថ្មធំៗ ជាទីចំណាំក្តី ដែលអ្នកផងគេសន្មត គេជឿថាជាទីស័ក្តិសិទ្ធិ គេតែងធ្វើសក្ការបូជាគោរព ក៏ហៅចេតិយទាំងអស់។

- ទស្សនីយភាព (ន) : ភាពដែលគួរមើលគួរឃើញ អ្វីៗដែលគួរឱ្យចង់មើលចង់ឃើញ ។
- និរទេស (ន) : ដំណើរបំបរបង់ឱ្យចេញពីស្រុក ពីនគរខ្លួនទៅនៅស្រុក នគរឯទៀត ។
- ព្រហាម (ន) : វេលាដែលអរុណទើបនឹងរះស្រាងៗ ពេញបំព្រាង(បច្ចូសកាល) ។
- បាបត្រោះ (ន) : ត្រោះអាក្រក់ ត្រោះកាច ។
- អកុសលកម្ម (ន) : កម្មអាក្រក់ ។
- អាថិកំបាំង (ន) : សេចក្តីបាំងបាត់មើលមិនឃើញ ។
- សង្ស័យ (ន) : សេចក្តីឆ្ងល់ ដំណើរងឿងឆ្ងល់ ដំណើរមិនអស់មិនហើយក្នុងចិត្ត ។
- សក្តីភាព (ន) : ដំណើរជាសាក្សី ។
- ឧក្រិដ្ឋ (គុ.គុកិ) :ធ្ងន់ យ៉ាងធ្ងន់ យ៉ាងធំ យ៉ាងតឹងតែង យ៉ាងម៉ឺងម៉ាត់ ។
- សម្បជញ្ញៈ (ន) : សេចក្តីដឹងខ្លួន ការមិនភ្លេចខ្លួន ការប្រុងប្រយ័ត្នជានិច្ច ការត្រិះរិះរំពឹងដឹងខ្លួនជាដរាប ។
- ឱកាស (ន) : ហេតុការណ៍ ស្ថាន ទី ទីទំនេរ ចន្លោះ វេលា វេលាទំនេរ ពេលគ្រួសារ ផ្លូវទំនង សិទ្ធិជោគ ការនិយម ការអនុលោម សេចក្តីអនុញ្ញាតឱ្យ ការយល់ព្រមតាម ។
- ភក្តី (ន) : ការចែក បំណែក ការសេពគប់ សេចក្តីរាប់អាន សេចក្តីស្រឡាញ់ស្មោះត្រង់ សេចក្តីស្លូតត្រង់ សេចក្តីគោរព ។
- កុដិ (ន) : ខ្ទម ផ្ទះ លំនៅរបស់អ្នកបួស ។
- យុទ្ធសិល្ប៍ (ន) : ក្បួនមន្តអាគមផ្សេងៗ ។
- ឥទ្ធិពល (ន) : កម្លាំងនៃឫទ្ធិ ។
- ពលិកម្ម (ន) : ការបូជា ការសង្គ្រោះ ចំណែកបុណ្យ ។
- អាជ្ញា (ន) : អំណាច ការគ្រប់គ្រង ពាក្យបង្គាប់ ការបង្គាប់បញ្ជា បញ្ញត្តិ ច្បាប់បញ្ញត្តិមានកម្រិត ។
- គ្រូហ្ម (ន) : អ្នកចេះមើលជំងឺ អ្នកចេះថ្នាំរំងាប់រោគ គ្រូមើលជំងឺ ពេទ្យ ។
- សត្រូវ (ន) : អ្នកបៀតបៀនគេ អ្នកដែលប្រទូស្ត ដែលចងទោសឬចងគំនុំរកគ្នា ដែលមានបំណងនឹងធ្វើអាក្រក់ដល់គ្នា ដែលរករឿងគ្នាបច្ចាមិត្ត ។
- ញាតិវង្ស (ន) : តំណនៃញាតិ ពួកញាតិ ។
- ជំនួន (ន) : របស់ដែលជួន ។

- សំណាំ (គុ) : ដែលធំហាំ ដែលហាំសមរម្យ ។
- កិត្តិនាម (ន) : កេរ្តិ៍ឈ្មោះ នាមល្បីល្បាញ ។
- គូអភ័ព្វ(ឬគូកម្ម) (ន) : បុរសនិងស្ត្រីបានគ្នាជាប្តីប្រពន្ធហើយព្រាត់គ្នាទៅវិញក្នុងកាលរហ័សឆាប់ ។
- សន្តិភាព (ន) : ភាពឬដំណើរសូប់ សាន្តត្រាណ សេចក្តីរាបទាប ។
- ព្រឹត្តិការណ៍ (ន) : ហេតុឬដំណើរដែលប្រព្រឹត្តទៅតាមប្រក្រតី ហេតុដែលតែងមានជាធម្មតា ។

ខ. អភិវឌ្ឍន៍បំណិន

នៅពេលអានអត្ថបទនេះ ចូរអ្នកយកចិត្តទុកដាក់ដើម្បីត្រៀមឆ្លើយសំណួរទាក់ទងទៅនឹងការបង្ហាញតួអង្គ បុគ្គលិកលក្ខណៈតួអង្គ និងគំនិតសំខាន់ៗ(ការទទួលខុសត្រូវរបស់តួអង្គ) ។

គ. អត្ថបទ

(បាវទ្រង់ប៉ារីស៍នាំទាហានចូលមក)

បាវ : (ចង្អុលផ្នូរ) នុះហ្ន៎ ទីកន្លែងដែលមានភ្លើងចន្លុះនោះ ។

ទាហានទី ១ : នៅមាត់ផ្នូរ ជីសុទ្ធតែឈាមតោងដែកទ្វារនេះ ។ ទៅច្រើនគ្នាឃើញចម្លែក (ទាហានច្រើនចេញ) រូបភាពធ្វើឱ្យពិបាកចិត្ត នុះហ្ន៎ទ្រង់ស្លាប់ ... ស៊ុលីយែតសុទ្ធតែឈាមនៅក្តៅនៅឡើយ ទើបនឹងស្លាប់អំបាញ់មិញសោះ ! នាងដែលបានយំពីរថ្ងៃមកហើយ ... នរណាម្នាក់ទៅទូលព្រះអង្គម្ចាស់ ។ រត់ទៅជម្រាបពួកកាប់ពុយឡែត ទៅជាស់ពួកម៉ុងតេហ្គុយ ... អ្នកឯទៀតខំរក(ទាហានឯទៀតចេញទៅ) ។ យើងរកកន្លែងដែលមានគ្រោះឃើញហើយ តែមូលហេតុនៃគ្រោះនេះទាល់តែធ្វើអង្កេតទៀត ទើបរកឃើញ ។

(ទាហានបីបួននាក់ចាប់បាល់ថេហ្សារចូលមក)

ទាហានទី ២ : នេះជាបាវរបស់រ៉ូមេអូ យើងបានឃើញនៅមាត់ទ្វារកប់ខ្មោចនេះ ។

ទាហានទី ១ : ទុកវាឱ្យជាប់ ចាំដល់ព្រះអង្គម្ចាស់យាងមក ។

(ទាហាននាំព្រះសង្ឃឡូរ៉ិនចូលមក)

ទាហានទី ៣ : នេះជាព្រះសង្ឃញ័រអស់ទាំងប្រាណ ដកដង្ហើមធំហើយយំ។ យើងចាប់បានទាំងដែកគាស់ ចប ហើយគាត់ចេញមកពីទិសខាង ... កន្លែងកប់ខ្មោចនេះ។

ទាហានទី ១ : ជាភ័ស្តុតាងដ៏ធ្ងន់ធ្ងរ តោងឃាត់លោកសង្ឃនេះទុកដែរ។
(ថ្ងៃចាប់រះ ព្រះអង្គម្ចាស់ និងបរិពារចូលមក)

ព្រះអង្គម្ចាស់ : ម្តេចក៏មានសម្រែកស្រែកហៅរន្ធឺពាសពេញដូច្នេះ ?

ជំទាវកាប់ពុយខ្មែត : ពលរដ្ឋតាមផ្លូវស្រែកថា រ៉ូមេអូ ស៊ុលីយែត ប៉ារីស៍ ហើយទាំងអស់គ្នាស្ទាំងស្ទេករត់សំដៅចេតិយនេះ។

ព្រះអង្គម្ចាស់ : តើដំណឹងអាសន្នដែលជាភ័យនេះជាស្តី ?

ទាហានទី ១ : (ចង្អុលទៅសព)ព្រះអង្គម្ចាស់ នុះហ្ន៎ទ្រង់ប៉ារីស៍ដែលត្រូវគេសម្លាប់។ នុះហ្ន៎ រ៉ូមេអូក៏ស្លាប់។ នុះហ្ន៎ ស៊ុលីយែតបានស្លាប់ទៅហើយដែលយើងទាំងអស់គ្នាបានយំ ឥឡូវស្រាប់តែខ្លួននៅក្តៅដូចទើបតែត្រូវស្លាប់អំបាញ់មិញនេះដែរ។

ព្រះអង្គម្ចាស់ : តោងដែកគ្រប់កន្លែង រកមើលហេតុដែលនាំឱ្យមានការកាប់សម្លាប់ដ៏សម្បើមនេះ។

ទាហានទី ១ : នេះព្រះសង្ឃមួយអង្គ និងបាវខ្មោចរ៉ូមេអូ គេរកឃើញនៅទីនេះមានដែកគាស់និងចបជាប្រដាប់សម្រាប់បើកផ្នូរទាំងនេះ។

កាប់ពុយខ្មែត : ឱ ម្ចាស់សួគ៌! នែ ប្រពន្ធមើលណេះ! កូនជិតដាមដោយឈាមកាំបិតនេះសំបកស្រោមនៅឯចង្កេះពួកម៉ុងតេហ្គុយ ផ្លែវានៅលើដើមទ្រូងកូនយើង។

ជំទាវកាប់ពុយខ្មែត : ឱ ម្ចាស់សួគ៌! ទស្សនីយភាពអាក្រក់បែបនេះនឹងនាំឱ្យរាប់ទៅកាន់មរណភាពដែរហើយ។ (ម៉ុងតេហ្គុយនិងបរិពារចូលមក)

ព្រះអង្គម្ចាស់ : មកលោកម៉ុងតេហ្គុយ លោកក្រោកពីព្រហាម ដើម្បីមកមើលត្រកូលលោកដែលចាកឋានពីកុមារ។

ម៉ុងតេហ្គុយ : ឱ ព្រះអង្គម្ចាស់អើយ! ប្រពន្ធខ្ញុំបានចែកឋានយប់មិញនេះឯង។ ការនិរទេសកូនគេ ធ្វើឱ្យគ្នាស្លាប់ដោយក្តីព្រួយ។ ឥឡូវមានបាបគ្រោះថ្មីអីទៀតមកលើរូបខ្ញុំ ?

ព្រះអង្គម្ចាស់ : (ចង្អុលផ្លូវ) មើលទៅគង់ជ្រាបទេ!

ម៉ុងតេហ្គុយ : (ឃើញរ៉ូមេអូ) ឱ! អកុសលកម្ម! តួរអីឱ្យកូននៅក្មេងទៅផ្លូវមុនឪពុកដែលថាស់។

ព្រះអង្គម្ចាស់ : ទាំងអស់គ្នាសុំនៅស្ងៀមសិនដើម្បីឱ្យយើងបំភ្លឺអាថ៌កំបាំង ស្គាល់ជម្រៅហេតុនិងការប្រទាក់ទងអាថ៌កំបាំងនេះ។ គឺខ្ញុំនេះឯងដែលត្រូវមានទុក្ខជាងគេរហូតដល់ស្លាប់ផង។ តែឥឡូវសង្កត់ចិត្តសិន ហើយនាំមនុស្សដែលសង្ស័យឱ្យចូលមក។ (ទាហាននាំព្រះគ្រូឡូរ៉ិននិងបាល់ថេហ្សារ)

ឡូរ៉ិន : អាត្មាថ្វីត្បិតតែឥតខុស ជាមនុស្សគួរឱ្យសង្ស័យជាងគេ ពីព្រោះពេលនិងកន្លែងប្រជាប់ប្រជាជាសក្ខីភាពបញ្ជាក់ឱ្យឃើញច្បាស់នូវអំពើឧក្រិដ្ឋនេះ។ ដូច្នេះ អាត្មាត្រូវចោទខ្លួនឯងផងដើម្បីការពារ។ ត្រូវចាប់ទោសដើម្បីសម្ពាតសម្បជញ្ញៈ។

ព្រះអង្គម្ចាស់ : មានព្រះវាចាឱ្យរាប់ ព្រះតេជគុណជ្រាបរឿងអីខ្លះក្នុងរឿងនេះ?

ឡូរ៉ិន : អាត្មានិយាយតែខ្លី ព្រោះជីវិតអាត្មាខ្ញើចហើយគ្មានឱកាសចែងឱ្យវែងពីរឿងវ៉ាវដ៏ខ្មៅនេះទេ។ រ៉ូមេអូដែលស្លាប់នេះ ជាប្តីរបស់ស៊ុលីយែត។ ស៊ុលីយែតដែលស្លាប់នេះជាប្រពន្ធភក្តីរបស់រ៉ូមេអូ អាត្មាបានរៀបការគេទាំងពីរដោយលួចលាក់។ ថ្ងៃនោះឯងទីបល្ហត្រូវស្លាប់ រ៉ូមេអូត្រូវមានទោស ហើយត្រូវនិរទេសចេញពីក្រុង។ ស៊ុលីយែត យំពីព្រោះរ៉ូមេអូមិនមែនយំពីព្រោះទីបល្ហទេ (និយាយទៅកាន់កាប់ពុយឡែត) លោក! ដើម្បីរំលត់ទុក្ខកូន បានបង្ខំគ្នាឱ្យរៀបការជាមួយទ្រង់ប៉ារីស៍។ រឿងហ្នឹង នាងក៏មកជួបអាត្មាភ័យយ៉ាងខ្លាំងឱ្យអាត្មាជួយរកផ្លូវទប់កុំឱ្យមានការរៀបការលើកទីពីរកើតឡើង មិនដូច្នេះទេ នាងសម្លាប់ខ្លួនក្នុងកុដិអាត្មានេះឯង។ ម្ល៉ោះហើយ តាមវិជ្ជាយុទ្ធសិល្ប៍ អាត្មាក៏ឱ្យថ្នាំមួយទៅនាងផឹកហើយមានឥទ្ធិពលដូចតែខ្លួននាងស្លាប់។ ពេលនោះអាត្មាសរសេរសំបុត្រទៅរ៉ូមេអូឱ្យមកដល់នៅយប់នេះជួយបើកផ្លូវបញ្ចេញនាងស៊ុលីយែតពេលដែលថ្នាំអាត្មាអស់ឥទ្ធិពល។ សំបុត្រអាត្មាត្រូវលោកសង្ឃហ្សង់យកទៅឱ្យរ៉ូមេអូ តែគ្រោះថ្នាក់ គេហាមមិនឱ្យលោកចេញពីក្រុង លោកយកសំបុត្រនោះមកឱ្យអាត្មាវិញ។ ដូច្នេះ

អាត្មាតោងមកខ្លួនឯងគាស់ផ្នូរចាំនាំនាងស៊ុលីយែតទៅលាក់ទុកឯកុដិ សិន រហូតដល់មានពេលឱ្យដំណឹងទៅរ៉ូមេអូឱ្យមកនាំនាងទៅ។ ប៉ុន្តែដល់អាត្មាមកដល់ទីនេះបីបួននាទីមុនដែលនាងត្រូវភ្ញាក់ អាត្មាអង្វរនាងឱ្យទ្រាំនៅរស់តាមឆន្ទៈព្រះម្ចាស់សួគ៌ ... ប៉ុន្តែឮសូរមានមនុស្សមកអាត្មាក៏រត់ចេញទៅ។ ស៊ុលីយែតអស់សង្ឃឹម មានចិត្តភក្តី មិនទៅតាមអាត្មា ម្ល៉ោះហើយក៏សម្លាប់ខ្លួនឯង។ នេះជារឿងដែលអាត្មាដឹង។ មេដោះក៏បានដឹងអាថ៌កំបាំងអាពាហ៍ពិពាហ៍នេះដែរ។ ក្នុងរឿងទាំងនេះ បើបាបគ្រោះមានដោយកំហុសអាត្មា យកជីវិតចំណាស់អាត្មាទៅធ្វើពលិកម្មចុះ ដើម្បីគោរពទៅតាមអាជ្ញាច្បាប់។

ព្រះអង្គម្ចាស់ : យើងធ្លាប់តែស្គាល់ព្រះអង្គជាមនុស្សប្រកបដោយធម៌ ... ឯណាទៅបាវរ៉ូមេអូ ? តើឯងបានដឹងអីទៀតទេ ?

បាល់ថេហ្សារ : ខ្ញុំយកដំណឹងថានាងស៊ុលីយែតស្លាប់ ទៅជម្រាបម្ចាស់ខ្ញុំ។ មួយរំពេចនោះគាត់ចេញពីម៉ង់ទូមកទីនេះភ្លាម ហើយបង្គាប់ខ្ញុំឱ្យទៅយកសំបុត្រនេះទៅជូនលោកឪពុកឱ្យបានពីព្រឹក ទើបគាត់ដើរសំដៅចេតិយដោយបញ្ជាខ្ញុំថាបើលបមើលគាត់ គាត់នឹងសម្លាប់ហើយ។

ព្រះអង្គម្ចាស់ : ឱ្យសំបុត្រមកយើង យើងចង់មើល ឯណាទៅបាវទ្រង់ប៉ារីស៍ដែលទៅហៅទាហាន ? នែ តើថៅហ្វាយឯងមកទីនេះធ្វើអ្វី ?

បាវ : គាត់យកផ្កាមករោយលើផ្នូរសង្សារគាត់ ហើយឱ្យខ្ញុំថយទៅឆ្ងាយ ខ្ញុំក៏ថយ។ បន្តិចមក មានមនុស្សកាន់ភ្លើងមកដើម្បីបើកផ្នូរ រួចបានឃើញថៅហ្វាយខ្ញុំចាក់ដាវនឹងគេ ពេលនោះឯងដែលខ្ញុំរត់ទៅហៅទាហាន។

ព្រះអង្គម្ចាស់ : (មើលសំបុត្រ) សំបុត្រនេះបញ្ជាក់នូវព្រះវាចាព្រះសង្ឃ ... នេះហើយជារឿងរ៉ាវចិត្តស្នេហារបស់គេ។ ពេលគេដឹងថានាងស្លាប់គេសរសេរថា ពេលនោះរកទៅទិញថ្នាំពុលពីគ្រូឱ្យដ៏ក្រម្នាក់ ហើយរត់មកផ្នូរភ្លាមដើម្បីស្លាប់ជិតនាងស៊ុលីយែត (ងាកមើលចុះឡើង)ឯណាទៅត្រកូលសត្រូវទាំងពីរ ? កាប់ពុយឡែត ម៉ុងតេហ្គុយឃើញទេ ព្រះអង្គម្ចាស់សួគ៌ដាក់ទណ្ឌកម្មយ៉ាងណាលើទោសយើងនេះ ? យកស្នេហាមកធ្វើ

ជាហេតុសម្លាប់សុភមង្គល ... ចំណែកយើង ដើម្បីសម្រុះសម្រួលអ្នក
ទាំងពីរយើងត្រូវបាត់ញាតិវង្សពីរអង្គ។ យើងទាំងអស់គ្នាសុទ្ធតែត្រូវ
ទណ្ឌកម្ម។

កាប់ពុយខ្មែត : ឱ លោកបងម៉ុងតេហ្គុយ! សុំហាត្លាលោកបងមក ចំពោះកូនស្រីខ្ញុំ
ខ្ញុំគ្មានត្រូវការទារជំនួនអ្វីពីបងទេ។

ម៉ុងតេហ្គុយ : តែខ្ញុំនឹងជូនឱ្យសំណាំតាមតម្លៃ គឺយកមាសសុទ្ធមកសាងរូបស៊ុលីយែត
ទុក ពីព្រោះវ៉ៃរោនទាំងមូលចង់គោរពក្សាកិត្តិនាមភរិយាដែលភក្តី។

កាប់ពុយខ្មែត : ខ្ញុំចង់ឱ្យមានរូបរ៉ូមេអូនៅជិតនឹងរូបប្រពន្ធគេ។ គួអភ័ព្វដោយយើង
ឈ្លោះគ្នា។

ព្រះអង្គម្ចាស់ : ព្រឹកនេះ នាំសន្តិភាពក្នុងក្តីក្រៀមក្រំ ព្រះសុរិយាបាំងភ័ក្ត្រដ៏មានទុក្ខ។
ទៅយើង ... បន្តការសន្ទនាពីរឿងវ៉ាវដ៏ទុក្ខនេះតទៅទៀត។ មានអ្នក
ត្រូវរួចខ្លួន មានអ្នកត្រូវមានទោស។ លោកអើយគ្មានព្រឹត្តិការណ៍ឱ្យ
សម្បើមដូចរឿង រ៉ូមេអូនិងស៊ុលីយែតទេ។ (ចេញទាំងអស់គ្នាទៅ)

(ដកស្រង់ និងកែសម្រួលពីរឿងរ៉ូមេអូនិងស៊ុលីយែតទំព័រ ១៥៤-១៦១ប្រែសម្រួលដោយលោក ហង្ស ធុនហាក់)

សំណួរ

១. តើអត្ថបទនេះជាប្រភេទអត្ថបទអ្វី ? ចូរបង្ហាញ។

២. ចូរប្រាប់ពីវិធីបង្ហាញតួអង្គនៅក្នុងអត្ថបទខាងលើនេះ។

៣. តើអត្ថបទខាងលើមានតួអង្គឈ្មោះអ្វីខ្លះ ?

៤. ចូរបង្ហាញពីបុគ្គលិកលក្ខណៈរបស់តួអង្គព្រះសង្ឃឡូរិន។

៥. តើនរណាខ្លះទទួលខុសត្រូវចំពោះមរណភាពរបស់រ៉ូមេអូនិងស៊ុលីយែត ?

៦. តើអត្ថបទដកស្រង់ខាងលើមានតម្លៃអប់រំដូចម្តេចខ្លះ ?

៧. ចូរនិយាយពីលក្ខណៈល្ខោននិយាយ។

រំឭកបញ្ញត្តិ

ក. បុគ្គលិកលក្ខណៈតួអង្គ

លក្ខណសម្បត្តិរបស់តួអង្គសំដៅលើរូបសម្បត្តិ។ លក្ខណៈទាំងពីរនេះស្តែងចេញតាមរយៈ កាយវិការ សកម្មភាព ការពណ៌នារបស់អ្នកនិពន្ធ ការពណ៌នាពីតួអង្គដទៃ។ លក្ខណៈសម្បត្តិតួអង្គចែកជាពីរគឺ គុណសម្បត្តិនិងគុណវិបត្តិ។

ខ. គំនិតសំខាន់ៗក្នុងរឿង

ក្នុងរឿងនីមួយៗ បង្កប់នូវគំនិតជាច្រើន។ គំនិតទាំងនោះ មានគំនិតបន្ទាប់បន្សំនិងគំនិតសំខាន់ៗ។ គំនិតសំខាន់តែងផ្តោតទៅលើបញ្ហាសំខាន់របស់រឿង។ គំនិតសំខាន់ៗក្នុងរឿង គឺជាគំនិតឬព្រឹត្តិការណ៍សំខាន់ៗរបស់សាច់រឿង។

ពាក្យបន្ថែមដើមនិងពាក្យបន្ថែមចុង

ក្នុងមេរៀនមុនអ្នកបានសិក្សារួចមកហើយអំពីពាក្យក្លាយ។ នៅក្នុងមេរៀននេះ អ្នកនឹងបានសិក្សាអំពីពាក្យផ្សំដោយបន្ថែមដើមនិងពាក្យផ្សំដោយបន្ថែមចុង។

ក. ពាក្យបន្ថែមដើម

ពាក្យបន្ថែមដើមគឺជាពាក្យសម្រាប់បន្ថែមមកខាងដើមនៃពាក្យឫស។ ពាក្យបន្ថែមដែលធ្លាប់ប្រើរួចមកហើយមាន ការ សេចក្តី អ្នក ជន ភាព សភាព។

- ពាក្យបន្ថែមដើម "ការ" សម្រាប់ប្រើនៅខាងដើមកិរិយាស័ព្ទសម្គាល់សកម្មរបស់នាម ៖

ពាក្យបន្ថែមដើម		កិរិយាស័ព្ទ		ពាក្យផ្សំ
ការ	+	ពិនិត្យ	>	ការពិនិត្យ
ការ	+	អនុវត្ត	>	ការអនុវត្ត
ការ	+	អភិវឌ្ឍ	>	ការអភិវឌ្ឍ

- ពាក្យបន្ថែមដើម "សេចក្តី"សម្រាប់ប្រើនៅខាងដើមគុណនាម ឬនាមសម្គាល់សកម្មរបស់នាម ៖

ពាក្យបន្ថែមដើម		គុណនាម		ពាក្យផ្សំ
សេចក្តី	+	ចម្រើន (គុ)	>	សេចក្តីចម្រើន
សេចក្តី	+	សុខ (គុ)	>	សេចក្តីសុខ
សេចក្តី	+	វេទនា (ន)	>	សេចក្តីវេទនា

- គេអាចប្រើពាក្យបន្ថែមដើម "សភាព ឬភាព" ជំនួសសេចក្តី

ពាក្យបន្ថែមដើម		គុណនាម		ពាក្យផ្សំ
ភាព ឬសេចក្តី	+	ធាត់ (គុ)	>	ភាពធាត់
ភាព ឬសេចក្តី	+	ស្គម (គុ)	>	ភាពស្គម
ភាព ឬសេចក្តី	+	សមរម្យ (គុ)	>	ភាពសមរម្យ

- ពាក្យបន្ថែមដើម "អ្នក" សម្រាប់ប្រើនៅខាងដើមកិរិយាស័ព្ទ ឬនាមសម្គាល់នាមការក៍ ៖

ពាក្យបន្ថែមដើម		កិរិយាស័ព្ទ		ពាក្យផ្សំ
អ្នក	+	លេង	>	អ្នកលេង
អ្នក	+	ស៊ី	>	អ្នកស៊ី
អ្នក	+	ជីក	>	អ្នកជីក

ពាក្យបន្ថែមដើម		គុណនាម		ពាក្យផ្សំ
អ្នក	+	ក្រ	>	អ្នកក្រ
អ្នក	+	មាន	>	អ្នកមាន
អ្នក	+	ឧស្សាហ៍	>	អ្នកឧស្សាហ៍

ពាក្យបន្ថែមដើម		នាម		ពាក្យផ្សំ
អ្នក	+	ស្រែ	>	អ្នកស្រែ
អ្នក	+	ទីក្រុង	>	អ្នកទីក្រុង
អ្នក	+	ជំនួញ	>	អ្នកជំនួញ

- ពាក្យបន្ថែមដើម"ជន"សម្រាប់ប្រើនៅខាងដើមគុណនាមឬនាមសម្គាល់នាមការក៍ ៖

ពាក្យបន្ថែមដើម		គុណនាមឬនាម		ពាក្យផ្សំ
ជន	+	បរទេស	>	ជនបរទេស
ជន	+	អកតញ្ញូ	>	ជនអកតញ្ញូ
ជន	+	ទុច្ចរិត	>	ជនទុច្ចរិត

២. ពាក្យបន្ថែមចុង

ពាក្យបន្ថែមចុង គឺជាពាក្យសម្រាប់បន្ថែមខាងចុងពាក្យឫស។ ពាក្យបន្ថែមដែលធ្លាប់ប្រើរួចមក ហើយមាន កម្ម កិច្ច ភាព ធម៌ ករ ការី ជន បុរស បុគ្គល នារី ទិទ្ធ។

- ពាក្យបន្ថែមចុង "កម្ម"សម្រាប់សម្គាល់កម្មរបស់នាម ៖

កិរិយាស័ព្ទឬនាម		ពាក្យបន្ថែមចុង		ពាក្យផ្សំ
ផលិត	+	កម្ម	>	ផលិតកម្ម (ការបង្កើតផល)
ពលិ	+	កម្ម	>	ពលិកម្ម (ការបូជា)
ហត្ថ	+	កម្ម	>	ហត្ថកម្ម (ការធ្វើដោយដៃ)

- ពាក្យបន្ថែមចុង "កិច្ច" សម្រាប់សម្គាល់កម្មដែលតម្រូវឱ្យធ្វើ ៖

នាម		ពាក្យបន្ថែមចុង		ពាក្យផ្សំ
កាតព្វ	+	កិច្ច	>	កាតព្វកិច្ច
ករណីយ	+	កិច្ច	>	ករណីយកិច្ច
ភារៈ	+	កិច្ច	>	ភារកិច្ច

- ពាក្យបន្ថែមចុង "ភាព"សម្រាប់សម្គាល់សភាពទូទៅល្អក្តី អាក្រក់ក្តី ៖

នាម		ពាក្យបន្ថែមចុង		ពាក្យផ្សំ
ជីវ	+	ភាព	>	ជីវភាព
មិត្ត	+	ភាព	>	មិត្តភាព
ស្ថាន	+	ភាព	>	ស្ថានភាព

- ពាក្យបន្ថែមចុង "ធម៌"សម្រាប់សម្គាល់ភាពល្អ ៖

នាម		ពាក្យបន្ថែមចុង		ពាក្យផ្សំ
មនុស្ស	+	ធម៌	>	មនុស្សធម៌
សប្បុរស	+	ធម៌	>	សប្បុរសធម៌
គុណ	+	ធម៌	>	គុណធម៌

- ពាក្យបន្ថែមចុង "ករ ឬ ការី"សម្រាប់សម្គាល់នាមការក៍(ប្រាប់មុខងារ ឬ មុខរបរ) ៖

នាម		ពាក្យបន្ថែមចុង		ពាក្យផ្សំ
កម្ម	+	ករ	>	កម្មករ
ឱសថ	+	ការី	>	ឱសថការី
ពល	+	ករ	>	ពលករ

- ពាក្យបន្ថែមចុង "ជន បុរស បុគ្គល នារី" សម្រាប់សម្គាល់នាមការក៍ ៖

នាម		ពាក្យបន្ថែមចុង		ពាក្យផ្សំ
វីរៈ	+	បុរស	>	វីរបុរស
អច្ឆរិយ	+	បុគ្គល	>	អច្ឆរិយបុគ្គល
វីរៈ	+	ជន	>	វីរជន

- ពាក្យបន្ថែមចុង " វិទូ"សម្រាប់សម្គាល់មនុស្សអ្នកមានវិជ្ជាអ៊ីមួយ ៖

នាម		ពាក្យបន្ថែមចុង		ពាក្យផ្សំ
ទស្សនៈ	+	វិទូ	>	ទស្សនវិទូ
ប្រវត្តិ	+	វិទូ	>	ប្រវត្តិវិទូ
សេដ្ឋ	+	វិទូ	>	សេដ្ឋវិទូ

- ពាក្យបន្ថែមចុង "និយម"សម្រាប់សម្គាល់ទស្សនៈ ៖

នាម		ពាក្យបន្ថែមចុង		ពាក្យផ្សំ
ពុទ្ធ	+	និយម	>	ពុទ្ធនិយម
សង្គម	+	និយម	>	សង្គមនិយម
ទស្សនៈ	+	និយម	>	ទស្សននិយម

លំហាត់

ក. ចូរស្រង់ពាក្យបន្ថែមដើម និងពាក្យបន្ថែមចុង ដាក់ក្នុងតារាងខាងក្រោមឱ្យបានត្រឹមត្រូវ ។

អ្នកចម្រៀង សេចក្តីចម្រើន អ្នកចម្បាំង ភាពរីករាយ ការការពារ ដំណាំ សេចក្តីថ្លៃថ្នូរ អ្នកនេសាទ ការលំបាក ភារកិច្ច ប្រជាជន ជនជាតិ ភាសាវិទូ អាកាសយានិក កម្មការិនី និយោជិត ទឹកជំនន់ ពលកម្ម ទេសភាព កម្មករ ការអនុវត្ត អក្សរសិល្ប៍ សុភាវធម៌ ប្រទាញ ភាពជរា កិច្ចការ ពិធីការ ។

ពាក្យបន្ថែមដើម	ពាក្យបន្ថែមចុង
អ្នកចម្រៀង	ភារកិច្ច
.....	.....

ខ. ចូររកពាក្យបន្ថែមដើមឱ្យបាន ២០ និងពាក្យបន្ថែមចុងឱ្យបាន ២០ ។

ក. សិក្សាពាក្យគន្លឹះ

- មហោស្រព (ន) : របាំយ៉ាងធំ ការលេងល្បែងរបាំគគ្រឹកគគ្រេង ។
- ទស្សនីយភាព (ន) : ភាពដែលគួរមើលគួរឃើញ អ្វីៗដែលគួរឱ្យចង់មើលចង់ឃើញ ។
- នាដ្យកថា (ន) : របាំ ល្ខោន ។
- ទត (កិ) : មើល
- និយោជក (ន) : អ្នកដឹកនាំ អ្នកបង្គាប់ឬប្រើឱ្យគេធ្វើការផ្សេងៗ ។

ខ. អភិវឌ្ឍន៍បំណិន

នៅពេលអានអត្ថបទនេះ ចូរអ្នកយកចិត្តទុកដាក់ដើម្បីត្រៀមឆ្លើយសំណួរទាក់ទងនឹង ល្ខោនខ្មែរ ប្រភេទល្ខោនខ្មែរ តម្លៃអប់រំ ។

គ. អត្ថបទ

តាមវចនានុក្រមខ្មែរ ល្ខោនគឺជាមហោស្រពមួយប្រភេទលេងរាំរឿងផ្សេងៗ : មើលល្ខោនលេងល្ខោន ... ។ តាមអ្នកស្រាវជ្រាវខ្លះថា ល្ខោនជាទស្សនីយភាពមួយ ចិតនៅចំពីមុខទស្សនិកជន ។ ល្ខោនបញ្ចូលត្រប់ទម្រង់នៃការកម្សាន្តសប្បាយ ។ ម្យ៉ាងវិញទៀត តាមការកំណត់ពីបរមបុរាណមក ល្ខោនជាទម្រង់សិល្បៈមួយបែបដែលនៅក្នុងនោះ នាដ្យកថា ... បានត្រូវសម្តែងឡើង ។

នៅប្រទេសកម្ពុជាយើងមានទម្រង់ល្ខោនជាច្រើន (ជាងម្តៃ) ដែលនៅក្នុងនោះទម្រង់ល្ខោនខ្លះនៅរស់រានៅឡើយ ... ។ ទម្រង់ខ្លះកំពុងទ្រុឌទ្រោមហើយឈានទៅដល់ការបាត់បង់ ។ ឯទម្រង់មួយចំនួនទៀតបានបាត់បង់រួចទៅហើយនៅសល់តែឈ្មោះ និងព័ត៌មានទាក់ទងតែបន្តិចបន្តួចប៉ុណ្ណោះ ។ ទម្រង់ល្ខោនទាំងនោះមាន ៖

- ល្ខោនស្រមោល "ស្បែកធំ"
- ល្ខោនស្រមោល "ស្បែកតូច"
- ស្បែកពណ៌ "ស្បែកសម្តែងពេលថ្ងៃ"
- ល្ខោនខោល (ល្ខោនប្រុស ឬល្ខោនពាក់មុខ)
- ល្ខោនព្រះរាជទ្រព្យ
- ល្ខោនមហោរី
- ល្ខោន ចាប៉ីរឿង និទានរឿង ខ្សែជៀវរឿង
- ល្ខោនបាសាក់
- ល្ខោនពោលស្រី
- ល្ខោនប្រាមោទ្យ ឬប្រាមោទ័យ
- ល្ខោនអាប៉េ
- ល្ខោនតែន
- ល្ខោនបើកបទ
- ល្ខោនភ្លេងការ
- ល្ខោនតុក្កតា
- ល្ខោននិយាយ
- ល្ខោនចម្រុះ
- ល្ខោនកំណាព្យ

- យីកេ
- អាយ៉ៃរឿង
- សៀកសម្តែងជារឿង ... ។

បន្តទៅទៀតនេះ អ្នកនឹងបានសិក្សាទម្រង់ល្ខោនមួយចំនួនខាងក្រោមនេះ ។

- **ល្ខោនអាប៉ែ**

តាមការស្រាវជ្រាវ វង់តន្ត្រីល្ខោនអាប៉ែ មានដើមកំណើតនៅខេត្តកំពង់ចាម (ស្រុកមេមត់) នៅខេត្តតាកែវភាគខាងត្បូង នៅកំពត និងនៅព្រះបរមរាជវាំង។ ទម្រង់ល្ខោនអាប៉ែនេះ ក៏មានប្រជាប្រិយភាពណាស់ដែរ។ ល្ខោននេះច្រើនសម្តែងក្នុងពិធីបុណ្យប្រជាពលរដ្ឋ។

ឧបករណ៍ភ្លេង : ស្គរដៃ ស្គរយីកេ ឈិង ទ្រអ៊ូ ក្រាប។

- **ល្ខោនមហោរី**

ល្ខោនមហោរីមានប្រជាប្រិយភាពក្នុងចំណោមប្រជាជនខ្មែរ។ វង់ភ្លេងមហោរីនេះ មានដើមកំណើតបន្ទាប់ពីវង់តន្ត្រីមហោរី គឺកើតនៅក្នុងព្រះបរមរាជវាំងតែម្តង។ ល្ខោននេះ អាចសម្តែងរឿងបុរាណខ្លះដូចជា ពុទ្ធប្រវត្តិ ព្រះវេស្សន្តរ ក្រុងសុភមិត្រ ប្រវត្តិសាស្ត្រជាតិ និងពពួកសត្វ (ប្រៀបធៀបមកមនុស្ស) និងរឿងកំប្លុកកំប្លែងទុក្ខសោកព្រាត់ប្រាសក្នុងបច្ចុប្បន្នកាលនេះផង។ ឯការសម្តែងគឺភ្លេងនិងចម្រៀងនាំមុខ បន្ទាប់ពីនោះ ត្រូវមានអ្នកពោលបន្ថែមបង្ហាញតួអង្គនីមួយៗផង។ ល្ខោននេះច្រើនសម្តែងក្នុងពិធីបុណ្យប្រជាពលរដ្ឋ ឬថ្វាយព្រះរាជាទតកម្សាន្ត ... ។

- **ល្ខោនប្រាមោទ្យ ឬបាមោជ្ជ ឬប្រាមោទ័យ ឬបាមោទ័យ**

តាមវចនានុក្រមភាគ ១ ភាគ ២ ត្រង់ទំព័រ ៦២៦ បាមោជ្ជ (ប៉ាម៉ោច ជៈ ឬប៉ាម៉ោច) ន. (ប៉ា. សំ. ប្រាមោទ្យ)សេចក្តីរីករាយ សេចក្តីពេញចិត្តខ្លាំង។ អ្នកខ្លះហៅថា ល្ខោនប្រាមោទ័យ ឬភ្លេងប្រាមោទ័យ។

ល្ខោនប្រាមោទ័យ ឬប្រាមោទ្យ ជាទម្រង់ល្ខោនមួយបែបដែលសម្តែងរឿងខ្លីៗ ប្រកបដោយបរិយាកាសរីករាយមិនសម្តែងរឿងកម្សត់ព្រាត់ប្រាស ឬការប្រើវេទមន្តច្បាំងគ្នាខ្លាំងក្លាអ្វីឡើយ។ តាមអ្នកស្រាវជ្រាវ ល្ខោនប្រាមោទ្យ ឬប្រាមោទ័យនេះ មានវត្តមាននៅលើទឹកដីកម្ពុជាយើងតាំងពីមុនសម័យអង្គរមកម្ល៉េះ។ តែល្ខោននេះទើបតែមានឥទ្ធិពលខ្លាំងនៅសម័យចតុមុខ។ ការសម្តែងសាច់រឿងនីមួយៗច្រើនមានអត្ថន័យ ស្នេហាពោរពេញទៅដោយកាយវិការទន់ភ្លន់ និងពាក្យពេចន៍ផ្អែមល្ហែម។ ល្ខោននេះ ច្រើនសម្តែងជូនភ្ញៀវកិត្តិយស និងទស្សនិកជនទូទៅទស្សនាផងដែរ។

- **ល្ខោនបាសាក់**

ល្ខោនបាសាក់ ជាទម្រង់ល្ខោនមួយប្រភេទដែលមានដើមកំណើតនៅខេត្តបាសាក់ កម្ពុជាក្រោម។ ដើមឡើយល្ខោននេះមានឈ្មោះថា "ល្ខោនទ្រើងឃ្លោក" ព្រោះគេហាត់រៀនក្រោមទ្រើងឃ្លោក។ លុះមកដល់ឆ្នាំ ១៩៣០ ទើបល្ខោនបាសាក់ចូលមកដល់រាជធានីភ្នំពេញ ហើយសម្តែងជាលើកដំបូងនៅលើទូកប៉ុកចាយ (មុខវត្តឧណ្ណាលោម)។

ល្ខោននេះសម្តែងរឿងបុរាណដូចជារឿង សង្ខសិល្បជ័យ ព្រះជិនវង្ស ... ។ ល្ខោននេះ ច្រើនសម្តែងនៅក្នុងពិធីបុណ្យផ្សេងៗតាមវត្តអារាម ឬតាមស្រុកភូមិ។

កំណត់សម្គាល់

កាយវិការក្នុងទម្រង់ល្ខោនបាសាក់មានពីរបែបគឺកាយវិការធម្មតាសម្រាប់រំលេចន័យខ្លឹមសាររបស់ពាក្យសម្តី និយាយ ឬចម្រៀង និងកាយវិការក្បាច់ (ក្បាច់គុណចិន និងខ្មែរចម្រុះ) ដែលភាសាបច្ចេកទេសក្នុងទម្រង់ល្ខោនបាសាក់ហៅថា "ហួន"។

- **ល្ខោនខោល**

ល្ខោនខោល ជាទម្រង់សិល្បៈល្ខោនម្យ៉ាងដែលតួរាំសុទ្ធតែប្រុស។ ល្ខោនខោលមានចំណាស់មិនខុសពីរបាំ ឬល្ខោនក្បាច់បុរាណខ្មែរឡើយ។ ក្រោយអរិយធម៌ដ៏មហារុងរឿងអង្គរបានធ្លាក់ចុះ ល្ខោននេះស្ទើរតែបាត់បង់ដូចទម្រង់សិល្បៈដទៃទៀតដែរ។ ក្រោយមក គេឃើញល្ខោនខោលនេះចាប់កំណើតឡើងវិញនៅវត្តដ៏រីស ខេត្តបាត់ដំបងនិងវត្តស្វាយអណ្តើក ស្រុកល្វាឯម ខេត្តកណ្តាល។

កាលដើមឡើយ ល្ខោនខោលសម្តែងតែរឿង "រាមកេរ្តិ៍" តែក្រោយមក ដោយមានប្រជាប្រិយភាពក្នុងចំណោមមហាជន ល្ខោននេះក៏សម្តែងរឿងដទៃទៀតដូចជា រឿងព្រះវេស្សន្តរ រឿងព្រះសុធនកែវមនោរាហ៍ ។ ល្ខោននេះច្រើនសម្តែងក្នុងពិធីបុណ្យសាសនានៅតាមវត្តអារាម ឬនៅក្នុងព្រះបរមរាជវាំង។

- **ល្ខោននិយាយ**

ល្ខោននិយាយ ជាទម្រង់សិល្បៈល្ខោនម្យ៉ាងដែលមានប្រភពមកពីបរទេស (អឺរ៉ុប)។ ល្ខោននិយាយច្រើនសម្តែងរឿងសម័យទំនើប ទាក់ទងនឹងបញ្ហាវណ្ណៈអ្នកមាននិងអ្នកក្រ កម្មករនិងនិយោជក ឬរឿងល្បីៗផ្សេងៗ។

ឧទាហរណ៍ : រឿងល្ខោននិយាយដែលគេធ្លាប់បានផ្សព្វផ្សាយរួចមកហើយ គឺរឿងចៅកែចិត្តចោរ រឿងសំបុកឥតមេបា រឿងជនកំណាញ់ក្រៅតម្រា ... ។ ល្ខោននេះច្រើនចាក់ផ្សាយតាមវិទ្យុដើម្បីអ្នកស្តាប់កម្សាន្តសប្បាយ។

- ល្ខោនយីកេ

អ្នកស្រាវជ្រាវខ្លះបានឱ្យដឹងថា ល្ខោនយីកេនេះ មានដើមកំណើតមកពីស្រុកជ្វា ឬមល៉ាយូ ហើយទំនងជាចូលមកស្រុកខ្មែរតាមរយៈព្រះបាទជ័យវរ្ម័នទី ២ឬតាមរយៈពួកចាម។ ល្ខោនយីកេនេះ សម្តែងរឿងបុរាណក៏បាន រឿងទំនើបក៏បាន (*ឧទាហរណ៍* យីកេរឿងទុំទាវ)។ គេសម្តែងល្ខោនយីកេ នៅពេលបុណ្យទានតាមភូមិ ឬតាមវត្តអារាម ឬនៅពេលទំនេរពីការងារស្រែចម្ការ។

- ល្ខោនស្រមោល (ស្បែកធំ និងស្បែកតូច)

នៅក្នុងពិភពលោក គេសង្កេតឃើញមានប្រភេទល្ខោនស្រមោលនេះនៅច្រើនប្រទេសដូចជា អ៊ីរ៉ង់ តួកគី ឥណ្ឌា កម្ពុជា ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ថៃ។ល។ សិល្បៈល្ខោនស្រមោលនៅកម្ពុជាមានពីរ ប្រភេទគឺ សិល្បៈស្បែកធំនិងសិល្បៈស្បែកតូចដែលគេនិយមហៅថា "អាយ៉ង"។ តាមការសិក្សាស្រាវ ជ្រាវនិងការប្រៀបធៀបទៅនឹងទម្រង់សិល្បៈធំៗដទៃទៀតរបស់ខ្មែរ គេអាចសន្និដ្ឋានបានថា ល្ខោន ស្រមោលនេះមានអាយុមុនសម័យអង្គរឆ្ងាយណាស់។ រូបចម្លាក់ស្បែកធំជារូបចម្លាក់នឹងថ្ពល់គ្មាន ចលនាទេ ឯរូបចម្លាក់ស្បែកតូចវិញមានចលនារស់រវើក អាចបត់ដៃ បត់ជើង ហាមាត់និយាយបាន។

ល្ខោនស្បែកធំ ត្រូវគេអនុញ្ញាតឱ្យសម្តែងតែរឿងរាមកេរ្តិ៍មួយគត់ (មានរូបចម្លាក់ទាំងអស់ ១៥៤ផ្ទាំង)។ សិល្បៈស្បែកតូច ឬអាយ៉ង អាចសម្តែងរឿងព្រះជិនវង្ស ព្រះលក្សិណវង្ស សង្ខសិល្បីជ័យ ព្រះសុធនានាងកែវមនោរាហ៍... និងរឿងសម័យ ពិសេសរឿងដែលកើតមាននៅក្នុងសង្គមដូចជាការជិះជាន់របស់សក្តិភូមិនិងពួកអាណានិគមមកលើប្រជាជនស្លូតត្រង់ឬការចំអកពេបជ្រាយ រិះគន់ចំពោះអ្នកជិះជាន់ទៀតផង។ គេសម្តែងល្ខោនស្បែកធំក្នុងពិធីផ្សេងៗដូចជា ពិធីសុំទឹកភ្លៀង ចម្រើនព្រះជន្មថៅអធិការ ឬមាតាបិតាជាដើម។ គេសម្តែងល្ខោនស្បែកតូចក្នុងពិធីបុណ្យទានទូទៅនៅតាមភូមិ ឬតាមវត្តអារាម។

(ដកស្រង់ និងសម្រួលពីវប្បធម៌-អរិយធម៌ខ្មែរ
របស់អ្នកនិពន្ធលោក សួរ មុយឃៀង និងលោក ទិត សៀង ឆ្នាំ ២០០៥)

១ រឿងតេជោយ័ត

នៅក្នុងការស្តាប់អត្ថបទរឿងនេះ ចូរអ្នកយកចិត្តទុកដាក់ដើម្បីត្រៀមឆ្លើយសំណួរទាក់ទងនឹងល្ខោន ឈុត ឆាក ការបង្ហាញតួអង្គ ការពណ៌នាតួអង្គ បុគ្គលិកលក្ខណៈតួអង្គ និងគំនិតសំខាន់ៗក្នុងរឿង ។

សំណួរ

១. តើអត្ថបទនេះជាប្រភេទអត្ថបទអ្វី ? ចូរពន្យល់ ។

២. តើរឿងនេះមានប៉ុន្មានឆាក ? តើគេបែងចែកឆាកនីមួយៗយ៉ាងដូចម្តេច ?

៣. ចូរបកស្រាយពីវិធីបង្ហាញតួអង្គក្នុងរឿង ដោយលើកអំណះអំណាងមកបញ្ជាក់ ។

៤. តើរឿងនេះមានតួអង្គប៉ុន្មាន ? តើតួអង្គនីមួយៗ ធ្វើសកម្មភាពអ្វីខ្លះ ?

៥. ចូរបង្ហាញបុគ្គលិកលក្ខណៈរបស់តួអង្គ តេជោមាស តេជោយ័ត ជំទាវស្រែន និងស្តេចសំរែ ។

៦. តើរឿងនេះបង្កប់គំនិតសំខាន់ៗអ្វីខ្លះ ?

ការសម្តែងតួតាមអត្ថបទល្ខោន

អ្នកធ្លាប់បានអានរឿងល្ខោនមួយចំនួនដូចជារឿងវង្សត្រកូលកម្សត់ រឿងតេជោយ៉ត រឿងរ៉ូមេអូ និងស៊ុលីយែត ដែលរឿងទាំងនោះជាប្រភេទល្ខោននិយាយនិងល្ខោនបាសាក់។ គេអាចយករឿងល្ខោនទៅសម្តែងលើឆាកដែលមានការរៀបចំត្រឹមត្រូវដូចជា តួអង្គត្រូវតុបតែងមុខ តុបតែងសម្លៀកបំពាក់ ប្រើកាយវិការ ធ្វើសកម្មភាព និយាយ ច្រៀង...ទៅតាមប្រភេទរឿង។ ប្រសិនបើមានឈុតឬឆាកច្រើនដែលត្រូវសម្តែង តួអង្គត្រូវផ្លាស់ប្តូរសម្លៀកបំពាក់ កែមុខ ប្តូរឆាកទៅតាមលក្ខណៈសកម្មភាពតួឯក តួរង... ដោយមានការនិយាយឆ្លងឆ្លើយ និយាយម្នាក់ឯង ច្រៀង...តាមប្រភេទរឿងដែលគេបានកំណត់ ព្រមទាំងមានភ្លេងកំដរផង។ ក្រៅពីនេះ រឿងល្ខោនមួយចំនួនក៏ត្រូវបានគេយកមកតាក់តែងក្នុងសៀវភៅសម្រាប់អានដូចសៀវភៅប្រលោមលោកធម្មតាដែរ តែមានទម្រង់ខុសគ្នាទេ។ ខាងក្រោមនេះជាការណែនាំមួយសម្រាប់ការសម្តែងរឿងល្ខោន។

១. ការរៀបចំមុនសម្តែង

- ជ្រើសរើសតួឱ្យសមនឹងឥរិយាបថ សកម្មភាព ដំណើររឿង
- រូបរាងកាយ និងសំឡេងរបស់តួអង្គ
- ការប្រមូលអារម្មណ៍លើសាច់រឿង
- របៀបសម្តែងរបស់តួអង្គ
- ចលនានិងកាយវិការផ្សេងៗដែលត្រូវធ្វើក្នុងពេលសម្តែង

២. ការរៀបចំតុបតែងតួសម្តែង (សម្តែងលើឆាក)

- រៀបចំសម្លៀកបំពាក់ឱ្យត្រូវដំណើររឿង សម័យកាល
- ផាត់មុខ ជាក្មេង ចាស់ យក្ស អាក្រក់ ស្អាត ស្គមជ្រីវជ្រួញ ពាក់ពុកមាត់ ពុកចង្កា...

៣. ការសម្តែង

- សម្តែងសាកល្បងដោយយកឯកសារកត់ត្រាសម្តីតួនីមួយៗមកអាន
- សម្តែងតួដោយប្រើសម្តីផ្ទាល់ខ្លួនទៅតាមដំណើររឿងដោយមិនប្រើឯកសារកត់ត្រាឡើយ ហើយនៅពេលសម្តែងតួទាំងអស់ត្រូវ :
  - ចងចាំបទសន្ទនាឬសម្តីតួអង្គដែលអ្នកដើរតួ
  - ដាក់អារម្មណ៍ទៅតាមស្ថានភាពតួអង្គនៅក្នុងរឿង

- ប្រើពាក្យពេចន៍ កាយវិការ ចរិតលក្ខណៈឱ្យសមតាមតួអង្គនីមួយៗក្នុងដំណើររឿង
- ប្រមាណពេលវេលាសម្តែងឱ្យបានសមស្រប
- មិនគួរបញ្ចេញពាក្យពេចន៍ឱ្យហួសពីសាច់រឿងខ្លាំងពេកឬប្រើពាក្យពេចន៍អសីលធម៌ឡើយ ។

ឥឡូវ ចូរអ្នកសម្តែងរឿងល្ខោនរ៉ូមេអូនិងស៊ុលីយែត (តាមបែបល្ខោននិយាយ)ទៅតាមអត្ថបទអំណានទី ១ ដោយប្រើសំឡេងទៅតាមបុគ្គលិកលក្ខណៈតួអង្គនីមួយៗ ។

សំណួរ

១. តើគេអាចរៀបចំរឿងល្ខោនជាប៉ុន្មានបែប ? ចូរប្រាប់ពីរបៀបសម្តែងតួតាមបែបនីមួយៗផង ។

២. តើគេជ្រើសរើសតួអង្គបែបណាសម្រាប់សម្តែងលើឆាក ?

៣. ពេលសម្តែងនៅលើឆាកឬតាមវិទ្យុ តើតួអង្គនីមួយៗត្រូវទទួលខុសត្រូវលើចំណុចអ្វីខ្លះ ?

លំហាត់

ចូររកដៃគូដើម្បីសម្តែងជាតួអង្គសន្ទនាដោយយកចិត្តទុកដាក់ និងមានទំនួលខុសត្រូវទៅតាមបុគ្គលិកលក្ខណៈតួអង្គតាមរយៈរឿងតេជោយ៉ត រឿងថៅកែចិត្តចោរ រឿងផ្កាស្រពោន ... ដែលមានក្នុងមេរៀននេះ ។

ការតែងរឿងល្ខោន

អ្នកបានសិក្សារួចមកហើយ អំពីទម្រង់សំណេរអត្ថបទរឿងល្ខោន។ នៅពេលនេះ អ្នកនឹងតាក់តែងរឿងល្ខោនខ្លីមួយ។ ដូច្នេះ អ្នកត្រូវស្គាល់ចំណុចសំខាន់ៗមួយចំនួនរបស់រឿងល្ខោន។ ខ្មែរយើងមានល្ខោនច្រើនប្រភេទដូចជា ល្ខោនបាសាក់ ល្ខោនយីកេ ល្ខោនមហោរី ល្ខោននិយាយ ល្ខោនខោល ល្ខោនអាប៉េ ល្ខោនស្រមោល។ល។ អត្ថបទល្ខោន គឺជាអត្ថបទអក្សរសិល្ប៍មួយប្រភេទដែលអ្នកនិពន្ធចងក្រងឡើងមានឆាក ឈុត សម្រាប់យកទៅសម្តែងជាសិល្បៈល្ខោន។ អត្ថបទល្ខោនស្រដៀងគ្នាន៏ងប្រភេទអត្ថបទរឿងផ្សេងៗទៀតដែរ ដូចជាធាតុសំខាន់ៗមានជាអាទិ៍ចំណោទបញ្ហា តួអង្គ កាលអាកាសនិងមូលន័យ។ល។

ទម្រង់សំណេររបស់អត្ថបទល្ខោនខុសពីទម្រង់សំណេររបស់អត្ថបទរឿង។ អត្ថបទល្ខោន ចែកជា ឈុតនិងឆាក។ នៅខាងដើមអត្ថបទល្ខោននីមួយៗមានបញ្ជីរាយនាមតួអង្គនិងឋានៈ ឬប្រភពកំណើតរបស់តួអង្គ។ អត្ថបទល្ខោនអាចសរសេរជាពាក្យកាព្យ ពាក្យរាយ ពំនោល ឬរបៀបជាការសន្ទនារវាងតួអង្គនិងតួអង្គ។ ដោយឡែកក្នុងអត្ថបទល្ខោននិយាយ អ្នកនិពន្ធសរសេរសេចក្តីបញ្ជាក់រូបរាង ទឹកមុខ កាយវិការ ឬសំឡេងរបស់តួអង្គក្នុងវង់ក្រចក។

របៀបតែងរឿងល្ខោន

- ប្រភេទរឿងល្ខោន (ល្ខោនបាសាក់ ល្ខោននិយាយ ល្ខោនយីកេ ...)
- កំណត់ចំណងជើងរឿងល្ខោន (ខ្លីៗ ...)
- កំណត់ខ្លឹមសាររឿង (បញ្ហាចោទ និងដំណោះស្រាយ)
- កំណត់តម្លៃអប់រំ។

១ . ផ្តើមរឿង

- រាយឈ្មោះតួអង្គ (តួឯក តួរង តួបន្ទាប់បន្សំ ...)
- អាចមានអ្នកពោល ឬសរសេរដំណើររឿង សកម្មភាពតួអង្គ ... ក្នុងវង់ក្រចក។

២ . ត្រួរឿង

- សរសេរជាឈុត-ឆាក
- វិធីតែងដោយប្រើ
  - ឯកវាទវិធី : តួអង្គនិយាយ ឬគិតម្នាក់ឯង ច្រៀងម្នាក់ឯង ...

- សំវាទវិធី : តួអង្គសន្ទនា ជជែក ច្រៀងឆ្លើយឆ្លង ផ្តោះផ្តងគ្នា ...
- សរសេរសកម្មភាព អាកប្បកិរិយា កាយវិការ ...ក្នុងវង់ក្រចក ... ។

៣ . បញ្ចប់រឿង

- ឱ្យតួអង្គជួបជុំគ្នា រីករាយ សុភមង្គល
- ឱ្យតួអង្គដឹងកំហុស កែខ្លួន
- ឱ្យតួអង្គព្រាត់ប្រាស កម្សត់ សោកនាដ្យកម្ម ...ទៅតាមប្រធានរឿងដែលកំណត់ ។

ឧទាហរណ៍ : ល្ខោនខ្លីរឿងសារភាព

- វាយតួ :
  - សុថា
  - ម្តាយសុថា
  - បូណា
  - វ៉ាវី
  - បងធី

ឈុតទី ១

(ក្មេងៗពីរបីនាក់កំពុងលេងបាល់ស្រាប់តែ ប៉ុង! ប៊ឹប! បុរសម្នាក់ដួល)

បូណា : អូបងធីដួលហើយ! អាថា! ឯងគប់បាល់ចំបងធី!

សុថា : ទេ!មិនមែនខ្ញុំទេ! អាវីទេ ។

វ៉ាវី : ឯងជាអ្នកគប់ត្រូវបងធី ។ ម៉េចមកចោទយើងវិញ ?

សុធី : (ងើបអង្គុយ)នរណាជាអ្នកគប់ត្រូវខ្ញុំវាមិនសំខាន់ទេ! ព្រោះខ្ញុំមិនមានរបួសធ្ងន់ធ្ងរទេ ។ ខ្ញុំអាចដើរទៅផ្ទះបាន ។ ចូរឃ្លួនចាំចុះថាយប់នេះ អ្នកប្រព្រឹត្តខុសមិនព្រមទទួលសារភាពកំហុសនឹងដេកមិនលក់ទេ!

ឈុតទី ២

ម្តាយសុថា : ម៉េចក៏មុខឯងអាក្រក់មើលម្ល៉ះ! មានរឿងអីហ្នែ! ទៅងូតទឹកទៅ រួចហូបបាយ ។

សុថា : បាទ! (ដើរទៅងូតទឹក)

(រាត្រីនោះ)

សុថា : ហេតុអីបានជាអញដេកមិនលក់ហ្ន៎! (គេនឹកទៅដល់រឿងពីថ្ងៃ ស្រាប់តែស្រមៃឃើញថាខ្លួនឯងសើចចំអកនិងស្តីបន្ទោសឱ្យខ្លួនឯង) "ឯងជាមនុស្សកំសាកណាស់ ធ្វើខុសហើយមិនហ៊ានសារភាព។ ឯងជាមនុស្សអន់បំផុតហ៊ានប្រកែកទាំងបំពាន ហើយថែមទាំងទម្លាក់កំហុសឱ្យអ្នកដទៃ។ ឯងនឹងមានវិប្បដិសារីអស់មិនខាន"(ស្រែកខ្លាំងៗ)ទេ! មិនគួរទេ! ខ្ញុំខុសហើយ! ខ្ញុំសុំទោស!

ម្តាយសុថា : មានរឿងអីបានជាស្រែកឮខ្លាំងម្ល៉េះ?

សុថា : (រត់មកឱបម្តាយ)ម៉ែ! ម៉ែ! កូនភ័យណាស់។

ម្តាយសុថា : (ឱបកូន)រឿងអីហ៎!

សុថា : ខ្ញុំខុសហើយម៉ែ! កូនខុសព្រោះមិនបានសារភាពថាគប់បាល់ត្រូវបងធី។ មួយទៀត កូនបានឆ្លើយដាក់វ៉ារីទៀត

ម្តាយសុថា : (អង្អែលក្បាលកូន)មិនអីទេកូន! ព្រឹកនេះឯងទៅសុំការអភ័យទោសពីបងធីនិងវ៉ារីទៅណ៎ា! ពួកគេប្រាកដជាអភ័យទោសឱ្យកូនមិនខាន។ ការទទួលស្គាល់កំហុសដែលខ្លួនបានធ្វើគឺជាការទទួលខុសត្រូវយ៉ាងខ្ពស់បំផុតនៃជីវិតរបស់យើង។ ថ្ងៃក្រោយលេងអ៊ីក៏ដោយ ធ្វើអ៊ីក៏ដោយ កូនត្រូវមានការប្រុងប្រយ័ត្នដើម្បីកុំឱ្យមានការខុសឆ្គងក្នុងរឿងដដែលៗទៀតណ៎ា!

សំណួរ

១. តើនរណាជាតួអង្គឯក? តួអង្គរង?

២. តើរឿងខ្លីនេះជាប្រភេទល្ខោនបែបណា?

៣. ចូរប្រាប់វិធីតែងរឿងខាងលើដោយលើកយកឧទាហរណ៍មកបញ្ជាក់ផង។

៤. តើរឿងនេះបានបញ្ចប់ដោយវិធីណា?

៥. តើរឿងនេះបានអប់រំដូចម្តេចខ្លះ?

លំហាត់

ចូរជ្រើសរើសយកប្រធានបទមួយក្នុងចំណោមប្រធានរឿងខាងក្រោមមកតាក់តែងរឿងល្ខោនខ្លីតាមទម្រង់ខាងលើដែលទាក់ទងទៅនឹងការបញ្ឈប់អំពើហិង្សាក្នុងគ្រួសារ ប្រឆាំងការប្រើប្រាស់ជួញដូរគ្រឿងញៀន ទប់ស្កាត់ការជួញដូរផ្លូវភេទ កសិករភ្នាក់រឭក សិស្សពូកែ។

មេរៀនទី

ការជឿជាក់

មនុស្សយើងម្នាក់ៗមានទស្សនៈ ការគិតនិងជំនឿមិនដូចគ្នាទេ ។ អ្នកខ្លះជឿស៊ប់ងប់ងុលទៅលើអ្វីមួយដោយខ្វះការពិចារណា ។ អ្នកខ្លះទៀតមានជំនឿដែរ តែមានការពិចារណាទៅលើអ្វីមួយដោយមានហេតុផល ។ មនុស្សមួយចំនួនទៀតមានគំនិតជឿលើខ្លួនឯងថា ខ្លួនមានសមត្ថភាពអាចធ្វើបាន ។ មនុស្សទាំងអស់នឹងបានទទួលផលតាមការជ្រើសរើសនិងការជឿជាក់របស់ខ្លួន ។

ក្នុងមេរៀននេះ អ្នកនឹងបានសិក្សាអំពីការជឿជាក់ដោយសមហេតុផល សេចក្តីសម្រេចចិត្តត្រឹមត្រូវព្រមទាំងការអត់ធន់ព្យាយាមប្រកបដោយក្តីសង្ឃឹមយ៉ាងមុតមាំ ។

ទន្ទឹមនឹងនេះ អ្នកនឹងបានសិក្សាបន្ថែមទៀតអំពីវេយ្យាករណ៍ ប្រភេទពាក្យក្លាយ សំណេរបំពេញពាក្យសុំប្រឡង សំណេរតែងសេចក្តីអធិប្បាយពន្យល់... ។

អំពីពាក្យក្លាយ

នៅក្នុងភាសាខ្មែរមានវិធីបង្កើតពាក្យច្រើនបែបយ៉ាងដូចជាវិធីកម្លាយជាដើម។ ពាក្យក្លាយមានពីរប្រភេទ គឺកម្លាយដោយផ្តត់ដើមនិងកម្លាយដោយផ្តត់ជែក។

១ . វិធីបង្កើតពាក្យក្លាយ

ក. វិធីកម្លាយដោយផ្តត់ដើម

- ផ្តត់ដើមក្នុងទម្រង់ "ព-" គឺ [ក-] [ច-] [ត-] [ប-] [ស-] ...

  ឧទាហរណ៍ :

  បាំង > ក្បាំង

  បួត > ច្បួត

  រៀប > ត្រៀប

  រាយ > ប្រាយ

  កក > ស្កក

- ផ្តត់ដើមក្នុងទម្រង់<ពស-> គឺ [ក-] [ច-] [ត-] [ប-] [ស-] ...

  ឧទាហរណ៍ :

  កាយ > ककាយ

  ចឹក > ចចឹក

  ពួន > ពពួន

  បោស > បបោស

  សិត > សសិត

- ផ្តត់ដើមក្នុងទម្រង់ [ពសព-] គឺ [កង់-] [ចង់-] [បង់-] [សង់-] [អង់-]

  ឧទាហរណ៍ :

  រៀច > កង្រៀច

  គ្រោង > ចង្គ្រោង

  អួត > បង្អួត

  កើត > បង្កើត

  កិន > សង្កិន

  កាច់ > អង្កាច់

- ផ្តត់ដើមក្នុងទម្រង់ "ពពស-" គឺ [ប្រ-] [ស្រ-] ...

ឧទាហរណ៍ :

ទាញ > ប្រទាញ

ចាក់ > ប្រចាក់

ទន់ > ស្រទន់

២. វិធីកម្លាយដោយផ្តត់ជែក

- ផ្តត់ជែកក្នុងទម្រង់ "-ព-" គឺ [-ន-] [-ម-] [-ប-]

ឧទាហរណ៍ :

កើយ > ខ្នើយ

ចាំ > ផ្ទាំ

ជួញ > ឈ្មួញ

លោត > ល្បោត

- ផ្តត់ជែកក្នុងទម្រង់"-សព-" គឺ [-អ៊ម-] [-អ៊ិម-] [-អ៊ង-] [-អ៊ិង-] [-អ៊ន-] [-អ៊ិន-]

ឧទាហរណ៍ :

ក្រង > កម្រង

គ្រប > គម្រប

ព្រាយ > ពង្រាយ

ខ្លះ > កន្លះ

ភ្លឺ > ពន្លឺ

- ផ្តត់ជែកក្នុងទម្រង់ "-ស/ព-" គឺ [-អ៊ិ/ន-] [-អ៊ិ/ប-]

ឧទាហរណ៍ :

រាប > រនាប

រាំង > រនាំង

រុក > រនុក

រាំង > របាំង

រក > របក

រាប់ > របាប់

រាំ > របាំ

• ផ្នត់ជែកក្នុងទម្រង់ "-សព/ព-" គឺ [-អ៊ម/ន-] ឬ [-អ៉ម/ ន-] [-អ៊ីម/ន-]

ឧទាហរណ៍ :

កក > កំណក

បន់ > បំណន់

ចែក > ចំណែក

បែក > បំណែក

គូរ > គំនូរ

ទួល > ទំនួល

ពឹង > ពំនឹង

២ . ថ្នាក់និទនំយសេចក្តីរបស់ពាក្យភ្លាយ

• ពាក្យភ្លាយជានាម

- ផ្នត់ដើម [អ៊ង-] សម្គាល់គ្រឿងឧបករណ៍

ឧទាហរណ៍ : គប់ > អង្គប់ , រុត > អង្រុត

- ផ្នត់ដើម [ក៉ញ-] [ក-] សម្គាល់ការសង្កត់ន័យ

ឧទាហរណ៍ : ឈ្មោះឆយ > កញ្ឆយ , ឈ្មោះយ៉ាន > ខ្យ៉ាន

- ផ្នត់ជែក [-ន-]សម្គាល់គ្រឿងឧបករណ៍

ឧទាហរណ៍ : កើយ > ខ្នើយ , ជួត > ឈ្នួត

- ផ្នត់ជែក [-អ៊ី /ប-] [-ប-] សម្គាល់អ្វីដែលគេធ្វើ

ឧទាហរណ៍ : រៀន > របៀន , លេង > ល្បែង

- ផ្នត់ជែក [-អ៊ី /ប-] [-ប-] [-អ៊ី /ន-] សម្គាល់ឧបករណ៍

ឧទាហរណ៍ : រុញ > របុញ , រាំង > រនាំង , លក > ល្បក

- ផ្នត់ជែក [-អ៊ី /ប-] [-ប-] សម្គាល់នាមករណ៍

ឧទាហរណ៍ : រក > របក , លះ > ល្បះ

- ផ្នត់ជែក [-ម-] សម្គាល់នាមការក៍

ឧទាហរណ៍ : ជួញ > ឈ្មួញ , សួម > ស្នួម

- ផ្តត់ជែក [-អ៑ម /ណ-] [-អ៊ិ៑ម /ន-]

ឧទាហរណ៍ : កត់ > កំណត់ , គុំ > គំនុំ

• ពាក្យក្លាយជាគុណនាម

- ផ្តត់ដើម [ក៑ម-] [ក៑ញ-] សម្គាល់ន័យទ្រគោះ

ឧទាហរណ៍ : ពៀច > កំពៀច , ចាស់ > កញ្ចាស់

• ពាក្យក្លាយជាកិរិយា

- ផ្តត់ដើម [ប-] សម្គាល់ន័យញុំាងអំពើ

ឧទាហរណ៍ : ដេក > ផ្តេក , អាប់ > ផ្អាប់

- ផ្តត់ដើម [ប្រ-] សម្គាល់ន័យតបតទៅវិញទៅមក

ឧទាហរណ៍ : កាប់ > ប្រកាប់ , វាយ > ប្រវាយ , ទាញ > ប្រទាញ

- ផ្តត់ដើម [ប៑ន-] [ប៑ង-] [ប៑ញ-] សម្គាល់ន័យញុំាងអំពើ

ឧទាហរណ៍ : ដើរ > បណ្តើរ , ហើរ > បង្ហើរ , ជាក់ > បញ្ជាក់

- ផ្តត់ដើម [ក-] [ច-] [ត-] [ប-] សម្គាល់ន័យច្រើនដង

ឧទាហរណ៍ : កាយ > កកាយ , ចឹក > ចចឹក , តះ > តតះ ,

បោស > បបោស

- ផ្តត់ជែក [-អ៑ម-] [-អ៊ិ៑ម-] សម្គាល់ន័យញុំាងអំពើ

ឧទាហរណ៍ : ក្តៅ > កម្តៅ , ខ្ទេច > កម្ទេច , ទ្រឹង > ទម្រឹង

• ពាក្យក្លាយជាគុណកិរិយា

- ផ្តត់ដើម [អ៑ន-] សម្គាល់ន័យ ច្រើនដង

ឧទាហរណ៍ : ត្រើក > អន្ត្រើក , ត្រុក > អន្ត្រុក , ទ្រក់ > អន្ទ្រក់

ពាក្យក្លាយគឺជាពាក្យបង្កើតចេញពីពាក្យឫស ដោយប្រើផ្តត់(បទ) ជាមួយពាក្យឫស នោះ ។

សំណួរ

១. តើពាក្យស្លាយខុសពីពាក្យឫសត្រង់ណា ?

២. តើថ្នាក់ពាក្យស្លាយទាំងពីរប្រភេទមានអ្វីខ្លះ ? ចូររៀបរាប់ ។

លំហាត់

១. ចូររកពាក្យស្លាយក្នុងចំណោមពាក្យមួយចំនួនខាងក្រោម :

- ល្អួន មេឃ ដី ប្រជីក ដើរ ឆ្មាំ ត្មាត ដុំ ផ្តេក ចចឹក ។

២. ចូរញែកពាក្យស្លាយ ដើម្បីរកពាក្យឫស និងផ្នត់នៃពាក្យខាងក្រោមដោយដាក់តាមប្រភេទ :

- ខ្ទើយ គម្រប សន្សើម ច្បង ជម្រើស កង្វល់ ល្បាក់ កំបាក់ កញ្ឆេវ ។

៣. ចូររកពាក្យស្លាយពីពាក្យឫស "កើត" ដោយប្រាប់ផ្នត់ ពាក្យស្លាយ ទម្រង់ ថ្នាក់ពាក្យ និងន័យ របស់ពាក្យស្លាយនីមួយៗ ។

១. ចូរជ្រើសរើសពាក្យស្លាយដែលមាននៅក្នុងអត្ថបទខាងក្រោម :

បើយើងបានដាំដើមឈើមួយដើមមុនពេលអនិច្ចកម្ម ទង្វើបែបនេះពិតជាពុំឥតប្រយោជន៍ឡើយ ព្រោះយើងបានបន្សល់ឈើមួយដើមដល់មនុស្សជាតិ ។ ដើមឈើនោះនឹងផ្តល់ផ្លែផ្កា ឬយ៉ាងហោច ណាស់ក៏បានជាម្លប់ត្រជាក់ត្រជុំ សម្រាប់មនុស្សជំនាន់ក្រោយដែរ ។ រុក្ខជាតិមួយដើម ឧបករណ៍មួយ សៀវភៅមួយ បដិមាមួយ ផ្ទាំងគំនូរវិចិត្រមួយ តក្កកម្មវិទ្យាសាស្ត្រមួយ សុទ្ធតែជារបស់យើងម្នាក់ៗ ដែលយើងអាចមានលទ្ធភាពបង្កើតបានដើម្បីបញ្ចូលជាសម្បត្តិរួមរបស់មនុស្សជាតិ ។

ដូច្នេះ យើងម្នាក់ៗគប្បីខំប្រឹងឱ្យអស់សមត្ថភាពដើម្បីឱ្យកូនចៅជំនាន់ក្រោយរបស់យើងបាន ទទួលសេចក្តីសុខក្សេមក្សាន្តជាងយើងសព្វថ្ងៃ ។

អត្ថបទយោសនា

ក. សិក្សាពាក្យគន្លឹះ

- កម្មវត្ថុ (ន) : រឿងនៃការងារ សេចក្តីបំប្រួញរឿងក្នុងសំបុត្រស្នាមផ្សេងៗដើម្បីឱ្យដឹងថាជារឿងនេះឬរឿងនោះ ។
- អង្គាស (កិ) : យោសនាគ្នា ប្រកាសប្រាប់គ្នា ឱ្យចូលប្រាក់កាស ឬទេយ្យទានផ្សេងៗតាមសទ្ធាក្នុងការធ្វើទាន ។
- ចតុប្បច្ច័យ (ន) : គ្រឿងសម្រាប់អាស្រ័យបួនយ៉ាងគឺ ចីវរ(គ្រឿងស្លៀកដណ្តប់) បិណ្ឌបាត(អាហារ) សេនាសន:(លំនៅ) គិលានភេសជ្ជ:(ថ្នាំរំងាប់ជំងឺ រំងាប់រោគ) (ពាក្យសម្រាប់ប្រើក្នុងវិន័យព្រះពុទ្ធសាសនា) ។
- ហិង្សា (ន) : ការបៀតបៀន ការពាធា ការធ្វើអាក្រក់រកគ្នា ការធ្វើទុក្ខគ្នា ។
- ជួញដូរ (កិ) : លក់ ប្តូរសារពើទំនិញដោយយកផលចំណេញ ឬឱ្យរបស់ទៅវិញទៅមកដោយទុកតម្លៃជាស្មើគ្នា ។
- អតិថិជន (ន) : ភ្ញៀវ អ្នកដទៃក្រៅពីគ្នាឯង ដែលគេមករក មកសួរនាំ ... ។
- គុណភាព (ន) : របស់ដែលមានអនុភាពសក្តិសិទ្ធិ ។
- ប្រសិទ្ធភាព (ន) : ភាពដែលអាចធ្វើឱ្យសម្រេចហើយធ្វើឱ្យពូកែ ។
- បញ្ជើចបញ្ជើ (កិ) : ពោលពាក្យលើកសរសើរហួសហេតុ ហួសទំនង ។

- សន្យា (កិ) : ប្តេជ្ញា សន្មត ។
  (ន) : សេចក្តីប្តេជ្ញា ការសន្មត ។
- រង្វាន់ (ន) : របស់ដែលថែមឱ្យដោយឡែកផ្សេងលើសពីកំណត់ដែលត្រូវបាន របស់ជាបំណាច់ដែលត្រូវថែមឱ្យ ព្រោះគាប់ចិត្ត ឬដើម្បីបំពេញចិត្ត ។
- លួងចិត្ត (កិ) : ល្បួងឱ្យស្រួលចិត្ត ។
- សតិ (ន) : ស្មារតី គឺសេចក្តីនឹកឃើញ ... ការប្រុងប្រយ័ត្នមិនឱ្យភ្លេច ការរឭកបាន ការរឭកឃើញមិនភ្លេច ការចាំបាន ដំណើរស្វាងរុងរឿងនៃគំនិត ។

ខ. អភិវឌ្ឍន៍បំណិន

ពេលអ្នកអានអត្ថបទនេះ អ្នកគប្បីអានដោយយកចិត្តទុកដាក់ ដើម្បីត្រៀមឆ្លើយសំណួរមួយចំនួនដែលទាក់ទងនឹងខ្លឹមសារអត្ថបទព័ត៌មាន អត្ថបទឃោសនា អត្ថប្រយោជន៍នៃអត្ថបទព័ត៌មាន និងអត្ថបទឃោសនា លក្ខណសម្បត្តិអ្នកឃោសនាជាដើម ។

គ. អត្ថបទ

ការឃោសនាគឺជាការប្រកាសផ្សាយដំណឹងឱ្យសាធារណជនដឹងឮសព្វសាយពីកម្មវត្ថុណាមួយ ។ ពាក្យឃោសនា បើប្រើតាមទម្លាប់ គឺសំដៅលើការប្រកាសអង្គាសវត្ថុផ្សេងៗក្នុងពិធីបុណ្យទាន ដោយប្រើជាសំបុត្រឃោសនា អាចារ្យឃោសនាចង្ហាន់ ឃោសនារកបច្ច័យសម្រាប់សាងសង់វត្តអារាម ។ បច្ចុប្បន្ន គេនិយមប្រើការឃោសនាបំផុសមាតាបិតាឱ្យនាំកូនគ្រប់អាយុទៅចុះឈ្មោះចូលរៀននៅដើមឆ្នាំសិក្សា ឬឃោសនាឱ្យមនុស្សគ្រប់គ្នាយល់ដឹង និងប្រយុទ្ធប្រឆាំងជំងឺអេដស៍ ជំងឺផ្តាសាយបក្សី ជំងឺគ្រុនចាញ់ គ្រុនឈាម ជំងឺរបេង ។ល។ ឃោសនាឱ្យមនុស្សធ្វើការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន គ្រឿងស្រវឹង ការប្រើអំពើហិង្សាក្នុងគ្រួសារ អំពើជួញដូរមនុស្ស ការជួញដូរផ្លូវភេទ កុមារ និងស្ត្រី អំពើពុករលួយជាដើម ។ គេក៏បានប្រើសេចក្តីឃោសនាក្នុងការរកសំឡេងឆ្នោតដើម្បីគាំទ្រគំនិតទស្សនៈក្រុមឬគណបក្សនយោបាយសម្រាប់អាណត្តិនៃរដ្ឋាភិបាលផងដែរ ។ សេចក្តីឃោសនាដែលគេឃើញញឹកញាប់ជាងគេ គឺការឃោសនាផ្សព្វផ្សាយពាណិជ្ជកម្ម ។

មធ្យោបាយដែលគេប្រើសម្រាប់ឃោសនាផ្សព្វផ្សាយមានច្រើនបែបយ៉ាងដូចជាការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ កាសែត (សារព័ត៌មាន) ទស្សនាវដ្តី សំបុត្រ អ៊ីនធឺណេត អ៊ីមែល វ៉ិបសាយ រថយន្ត ការហែក្បួនឬចងបដាខាងមុខរោងបុណ្យ រោងពិធីជាដើម ។ រាល់សេចក្តីឃោសនាដែលយើងបានស្តាប់ ឮ អាន និងឃើញ ខ្លះអាចជាការពិត ខ្លះអាចពិតពាក់កណ្តាល ហើយខ្លះទៀតជាការឡៃគំនិត ។ ប៉ុន្តែ គេខិតខំធ្វើយ៉ាងណាឱ្យអ្នកស្តាប់ អ្នកអាន អ្នកទស្សនាមើលជឿជាក់ទុកចិត្តលើគ្រប់

ព័ត៌មានឃោសនាទាំងអស់ ។ ចំពោះអ្នករៀបចំសេចក្តីសម្រាប់ឃោសនាគឺជាអ្នកដែលមានថ្វីដៃពូកែក្នុងការតាក់តែងពាក្យឃោសនា រូបភាពឃោសនា ហើយផ្សំជាមួយអ្នកនិយាយដែលមានថ្វីមាត់ផ្សព្វផ្សាយពីកម្មវត្ថុរបស់អត្ថបទឃោសនាដោយប្រើពាក្យសម្តីទាក់ទាញអារម្មណ៍ទឹកចិត្តអតិថិជនឱ្យជឿលើគុណភាព ប្រសិទ្ធភាព អត្ថប្រយោជន៍នៃកម្មវត្ថុដោយ ការបញ្ចើចបញ្ចើ ការសន្យាការលើកទឹកចិត្ត ការជូនរង្វាន់លួងចិត្តផ្សេងៗជាដើម ពោលគឺគេឃោសនាយ៉ាងណាធ្វើឱ្យអ្នកស្តាប់អ្នកមើលជឿ ចង់ដឹង ចង់សាកល្បង ចង់បាន ចង់ចូលរួម ... ។

គេតែងប្រើបច្ចេកទេសមួយចំនួនសម្រាប់អត្ថបទឃោសនាដូចជា ៖

- បង្ហាញកម្មវត្ថុជាក់លាក់មួយដែលគួរជាទីរីករាយ
- បង្ហាញពីភាពចាំបាច់នៃកម្មវត្ថុនោះ
- ប្រើពាក្យទាក់ទាញប្រកបដោយភាពរំជើបរំជួល
- ប្រើពាក្យបំផុសអារម្មណ៍ឱ្យរំភើប
- បញ្ជាក់ពីគុណភាព ប្រសិទ្ធភាពនៃកម្មវត្ថុនោះជាដើម ។

ដូច្នេះ រាល់ព័ត៌មានដែលផ្សព្វផ្សាយឃោសនា គឺជាបំណងរបស់ម្ចាស់កម្មវត្ថុឆ្ពោះទៅរកផលចំណេញនិងជោគជ័យសម្រាប់មុខរបរ ក្រុម ពួក បក្ស មនុស្សជាតិ ។ ចំណែកអ្នកស្តាប់ អ្នកតាមដានអ្នកឃើញការឃោសនាត្រូវមានការពិនិត្យពិចារណាដោយប្រើសតិបញ្ញាវែកញែកហេតុផលដោយប្រុងប្រយ័ត្នឬព័ត៌មានពិតនិងមិនពិត មុននឹងសម្រេចចិត្តជ្រើសរើសប្រើប្រាស់ផលិតផល ។

សំណួរ

១. តើអ្វីទៅហៅថាការឃោសនា ?

២. ចូររកសំនួនពាក្យដែលបញ្ជាក់ពីការបញ្ចើចបញ្ចើឱ្យបានពីរឃ្លានិងការពិតឱ្យបានពីរឃ្លាសម្រាប់ការឃោសនា ។

៣. តើការឃោសនាមានសារៈសំខាន់ដូចម្តេចខ្លះ ? បើអ្នកជាពាណិជ្ជករធំ តើអ្នកប្រើការឃោសនាដែរឬទេ ? ព្រោះអ្វី ?

៤. តើអត្ថបទព័ត៌មានខុសពីអត្ថបទឃោសនាត្រង់ចំណុចណា ?

៥. តើយើងអាចដឹងទេថា ការឃោសនាបែបណាដែលល្អ ការឃោសនាបែបណាដែលមិនល្អ ?

៦. តើអត្ថបទឃោសនាខាងលើមានតម្លៃអប់រំយើងដូចម្តេចខ្លះ ?

ជីវិតគឺជាការតស៊ូ

ក. សិក្សាពាក្យគន្លឹះ

- ជនមាតុភូមិនិវត្តន៍ (ន) : ជន ឬមនុស្សដែលវិលត្រឡប់មកកាន់ស្រុកកំណើតវិញ ។
- លាចាកលោក (កិ) : ស្លាប់ ។
- ការដ្ឋាន (ន) : កន្លែងធ្វើការ ទីនៃការងារ ។
- លទ្ធភាព (ន) : ភាពនៃអ្វីៗដែលបានសម្រេចហើយ ភាពដែលនឹងត្រូវបាន ត្រូវមាន ផ្លូវ ឬដំណើរទំនងដែលនឹងអាចធ្វើឱ្យកើតការ ការដែលអាចធ្វើ ឬប្រព្រឹត្តទៅបាន ។
- រាជរដ្ឋាភិបាល (ន) : រដ្ឋាភិបាលនៃព្រះរាជាណាចក្រ ។
- ជីវភាព (ន) : ភាពនៃការរស់នៅ ការចិញ្ចឹមជីវិត ។
- អារម្មណ៍ (ន) : គ្រឿងតោង គ្រឿងព្យួរ គ្រឿងទាញ ឬទាញទាក់ គ្រឿងតោងរបស់ចិត្ត គំនិត ការដឹង ... ។
- ភស្តុតាង (ន) : របស់ជាគឺកតាង ជាគ្រឿងសម្គាល់ ជាតំណាង ។
- ទ្រលុកទ្រលន់ (គុ) : ដែលធាត់សាច់ទន់ ដែលមើលឃើញបែបណែនហើយរលោងទន់ ។

ខ. អភិវឌ្ឍន៍បំណិន

ពេលអានអត្ថបទនេះ ចូរអ្នកយកចិត្តទុកដាក់ដើម្បីត្រៀមឆ្លើយសំណួរដែលទាក់ទងទៅនឹងប្រភេទអត្ថបទ ការជួយខ្លួនឯង(ការតស៊ូ)ការសង្ខេបអត្ថបទ រកពាក្យភ្ជាយ តម្លៃអប់រំ ជាដើម។

គ. អត្ថបទ

"ជីវិតគឺជាការតស៊ូ" នេះជាសម្តីបងស្រីមេម៉ាយម្នាក់ ក្នុងចំណោមជនមាតុភូមិនិវត្តន៍ ដែលបានស្ម័គ្រចិត្តចូលមករួមរស់នៅក្នុងមាតុភូមិវិញ។ ប្តីបងស្រីបានលាចាកលោកនេះបាត់ទៅហើយ ដោយបន្សល់ទុកកូនប្រាំនាក់ ឱ្យរស់នៅកំព្រាឪពុកជួបនឹងការលំបាកលំបិនក្រៃពេកជាមួយបងស្រី។ រាជរដ្ឋាភិបាលក៏ដូចជាអ្នកដឹកនាំខេត្តបានជួយឧបត្ថម្ភគ្រួសារនេះ ដោយផ្តល់ដីមួយកន្លែងដែលជាដីប្រកបដោយជីជាតិ។ ប៉ុន្តែ ដីនេះជាដីព្រៃ មានកូនឈើដុះច្រើនទ្រុបទ្រុល។ បងស្រីបាននាំកូនកម្ស្ត់កាប់ឆ្ការរានដីនោះ ដើម្បីដាំដំណាំដោះស្រាយជីវភាព។

ដោយកូនរបស់បងស្រីនៅតូចៗ បងស្រីជួបការលំបាកក្នុងជីវភាពកាន់តែខ្លាំងឡើងៗ ទើបដាច់ចិត្តឱ្យកូនស្រីពីរនាក់ទៅរស់នៅជាមួយបងប្អូនឯរាជធានីភ្នំពេញដើម្បីបន្ថយការលំបាកមួយកម្រិត។ សព្វថ្ងៃ បងស្រីរស់នៅជាមួយកូនស្រីតូចៗបីនាក់ ដែលកូនស្រីបងមានអាយុទើបតែ ៨ឆ្នាំប៉ុណ្ណោះ។ បងស្រីបានតាំងចិត្តចាប់យកមុខរបរកសិកម្មដោយបានកាប់គាស់រានដីបណ្តើរ ដាំដំណាំបណ្តើរ ហើយឆ្លៀតពេលទៅធ្វើការឱ្យគេថែមទៀត។

គួរឱ្យសង្វេគពន់ពេក ! ពេលខ្លះបងស្រីត្រូវទៅធ្វើការងារនៅកន្លែងឆ្ងាយដើម្បីយកអង្ករមកផ្គត់ផ្គង់ជីវភាពគ្រួសារ ហើយបងស្រីបានទុកកូនតូចៗទាំង ៣នាក់ឱ្យនៅចាំផ្ទះ។ នៅពេលបងស្រីត្រលប់ពីការដ្ឋានមកដល់ផ្ទះវិញ មេឃចាប់ងងឹតទៅហើយ បងស្រីត្រូវដាំបាយធ្វើម្ហូបឱ្យកូនថែមទៀត។ នៅថ្ងៃណាគ្មានអង្ករ គាត់ក៏គាស់ដំឡូងដែលដាំនៅក្បែរផ្ទះ ស្ងោរឱ្យកូនៗបរិភោគជំនួសបាយ ហើយនាំកូនសម្រាក។ បងស្រីយល់ច្បាស់ណាស់អំពីប្រយោជន៍នៃការងារដាំដុះ។ ដូច្នេះ បងស្រីខិតខំឆ្លៀតដាំដំណាំបន្ថែម មើលថែទាំនិងស្រោចដំណាំមិនដែលអាក់ខានឡើយ ដើម្បីដោះស្រាយជីវភាពជាបន្តទៀតទៅថ្ងៃក្រោយ។ ពីមួយថ្ងៃទៅមួយថ្ងៃ ការងារពលកម្មលើកផ្លូវក៏កាន់តែឆ្ងាយពីផ្ទះ។ បងស្រីត្រូវទៅធ្វើការចម្ងាយប្រាំគីឡូម៉ែត្រ។ ហេតុនេះបងស្រីក្រោកពីព្រលឹមដើម្បីទៅកាន់ការដ្ឋាន និងប្រញាប់មកវិញដើម្បីមើលកូន។ ពេលនោះ បងស្រីទៅធ្វើការមួយថ្ងៃវែកដីបានពី១ម៉ោងទៅ ២ម៉ោង។ លុះបានកន្លះខែទើប

បងស្រីលើកអង្ករបានម្តង ។ អារម្មណ៍បងស្រីនៅតែនឹកកូន ព្រោះខ្លាចកូនលង់ទឹក សត្វខាំ ឬដើរវង្វេងបាត់ ។ បងស្រីនិយាយថា "ទោះបីជាយ៉ាងណាក៏ដោយ ក៏ខ្ញុំមិនដើរសុំទានគេដែរ ខ្ញុំសុខចិត្តប្រើកម្លាំងដ៏ស្តួចស្តើងរបស់ខ្ញុំកាប់គាស់ដាំដំណាំយកផលចិញ្ចឹមកូនវិញ" ។ នេះជាការពិតណាស់ ដំណាំរបស់បងស្រីកំពុងតែលូតលាស់ល្អណាស់នៅជុំវិញផ្ទះបងស្រីដែលជាភស្តុតាងជាក់ស្តែងបញ្ជាក់ពីភាពអំណត់ព្យាយាមប្រកបដោយស្មារតីតស៊ូយ៉ាងថ្លៃថ្នូរគួរឱ្យគោរពសរសើរ ។ ជាពិសេសកូនទាំងបីរបស់បងស្រី ថ្វីត្បិតតែជាកូនអ្នកក្រីក្រក៏ពិតមែន ប៉ុន្តែពួកគេមានសាច់ឈាមស្រស់ថ្លាទ្រលុកទ្រលន់គួរឱ្យស្រឡាញ់ ។ នេះបញ្ជាក់ថាពួកគេបានបរិភោគអាហារប្រកបដោយជីវជាតិគ្រប់គ្រាន់ ។

សកម្មភាពរបស់បងស្រីជាគំរូមួយដ៏ល្អដែលជាបទពិសោធន៍គួរឱ្យយើងរៀនសូត្រតាម ហើយមិនត្រូវបណ្តែតបណ្តោយខ្លួនទៅតាមយថាកម្មនោះឡើយ ។ ម្នាក់ៗត្រូវតែប្រើអស់លទ្ធភាពដែលខ្លួនមាន ដើម្បីអនាគតរបស់ខ្លួន និងគ្រួសារឱ្យមានភាពរុងរឿងនិងរស់នៅក្នុងភាពថ្លៃថ្នូរ ។

សំណួរ

១. ចូរស្រង់គំនិតសំខាន់និងសេចក្តីលម្អិតរបស់អត្ថបទ ។

២. តើមានតឹកតាងអ្វីខ្លះដែលបញ្ជាក់ថាបងស្រីជាមនុស្សតស៊ូក្នុងជីវិត ?

៣. តើអត្ថបទខាងលើមានតម្លៃអប់រំដូចម្តេចខ្លះ ?

៤. ចូរសង្ខេបអត្ថបទឡើងវិញ ។

៥. ចូររកពាក្យភ្ជាយ ផ្ទត់ ទម្រង់ និងន័យសេចក្តី នៃពាក្យឫស "ដើរ" ។

តម្លៃនៃការជឿទុកចិត្ត



ក. សិក្សាពាក្យគន្លឹះ

- លទ្ធផល (ន) : ផលនៃការងារដែលបានសម្រេច ផលដែលបានសម្រេចហើយ ។
- សាច់ញាតិ (ន) : អ្នកដែលជាប់ជាញាតិនឹងគ្នា ក្រសែញាតិ ។
- ប្រសិទ្ធភាព (ន) : ភាពដែលសម្រេចរួចរាល់ហើយយ៉ាងល្អប្រសើរ ។
- ផលិតកម្ម (ន) : ការបង្កើតផល ការធ្វើឱ្យបានផល ។
- សុភនិច្ឆ័យ (ន) : ការរិះគិតល្អ គំនិតត្រឹមត្រូវ ។
- សាធារណៈ (គុ) : ដែលទូទៅ ដែលមិនចំពោះណាមួយ ។
- និយោជក (ន) : អ្នកដឹកនាំ អ្នកបង្គាប់ឬប្រើឱ្យគេធ្វើការផ្សេងៗ ។
- និយោជិត (ន) : អ្នកដែលគេប្រើឱ្យធ្វើការ កូនឈ្នួល កម្មករ ។

ខ. អភិវឌ្ឍន៍បំណិន

ចូរអ្នកអានអត្ថបទខាងក្រោមនេះ ដោយយកចិត្តទុកដាក់និងកត់ចំណាំសេចក្តីលម្អិតសំខាន់ ខ្លឹមសារនៃអត្ថបទ ដើម្បីពង្រីកការយល់ន័យអត្ថបទនិងចេះសង្ខេបអត្ថបទបានត្រឹមត្រូវ ។

គ. អត្ថបទ

ខ្ញុំគិតថា មានកត្តាសំខាន់ៗជាច្រើនក្នុងការធ្វើឱ្យអ្នកបម្រើការងារនៅតាមបណ្តាក្រុមហ៊ុន ឬក៏តាមបណ្តាហាងលក់ទំនិញយកលក្ខណៈល្អៗរបស់ខ្លួនមកប្រឹងប្រែងធ្វើការឱ្យបានពេញលេញ។ កត្តាដែលសំខាន់បំផុតគឺការដែលយើងទុកចិត្តមនុស្សនោះ។ មនុស្សយើង ប្រសិនបើគេទុកចិត្តហើយនោះងាយស្រួលធ្វើការណាស់។ ការធ្វើបណ្តើរនិងមានគេតាមដានការងារបណ្តើរ ដោយសារតែគេមានការសង្ស័យនោះ ទោះជានរណាក៏ដោយ ក៏ប្រាកដជាពិបាកនឹងប្រឹងប្រែងឱ្យអស់ពីកម្លាំងកាយចិត្តណាស់។ ជាការពិតណាស់ ប្រសិនបើគេទុកចិត្តហើយ អ្នកណាក៏ដោយ ក៏មានទឹកចិត្តរីករាយនឹងប្រឹងប្រែងឱ្យអស់ពីកម្លាំងចិត្តរបស់ខ្លួនដើម្បីធ្វើការឱ្យបានជឿនលឿនទៅមុខ ហើយព្រមទាំងអាចធ្វើឱ្យការងារនេះបានទទួលលទ្ធផលជាផ្លែផ្កាយ៉ាងល្អប្រសើរទៀតផង។ ប៉ុន្តែ មនុស្សយើងច្រើនមានទិដ្ឋិមួយ គឺមិនងាយជឿទុកចិត្តលើអ្នកដទៃឡើយ។ ចំណុចហ្នឹងហើយដែលជាការបង្កឱ្យមានបញ្ហាកើតឡើង។

ទំនិញដែលក្រុមហ៊ុនផលិតគ្រឿងអគ្គិសនី MATSUSHITA បានផលិតដំបូងបង្អស់គឺសម្ភារៈប្រើប្រាស់ក្នុងផ្ទះដើរដោយចរន្តអគ្គិសនីមានឈ្មោះថា ឆ្នាប់ចរន្ត(ឌុយភ្លើង)។ ផលិតផលនេះល្បីថាល្អខ្លាំងណាស់ ហើយលក់ដាច់មែនទែន។ ដូច្នេះហើយ ក្រោយពីបានចាប់ផ្តើមផលិតទំនិញនេះមក ក្រុមហ៊ុនមានការមមាញឹកខ្លាំង ទើបខ្ញុំជួលមនុស្សបួនប្រាំនាក់បន្ថែមទៀតមកធ្វើការ។ កាលពីមុននេះមានសមាជិកក្នុងក្រុមគ្រួសារខ្ញុំតែបីនាក់ប៉ុណ្ណោះដែលបានចាត់ចែងធ្វើការងារក្រុមហ៊ុន ប៉ុន្តែការងារក្នុងក្រុមហ៊ុនចេះតែរវល់ច្រើនឡើងៗ យើងក៏ជួលអ្នកក្រៅមកជួយថែមទៀត។ ក្នុងពេលនោះមានបញ្ហាមួយបានកើតឡើង។ នោះគឺជាបញ្ហាដែលថា យើងត្រូវធ្វើដូចម្តេចដើម្បីរក្សាទុករូបមន្តផលិតជាការសម្ងាត់ ដោយមិនឱ្យរូបមន្តផលិតនេះ សាយភាយដល់ក្រុមហ៊ុនឯទៀតដឹងឡើយ។ ក្រៅពីម្ចាស់រោងចក្រគឺមានត្រឹមតែមនុស្សក្នុងគ្រួសារ ដូចជាបងប្អូនបង្កើត ឬសាច់ញាតិជាដើមដែលបានដឹងពីរូបមន្តនៃការផលិតនេះ ហើយពួកគេទាំងនេះត្រូវទទួលបន្ទុកលើដំណើរការផលិតកម្ម។ ប៉ុន្តែ តាមការយល់ឃើញរបស់ខ្ញុំថា ការធ្វើបែបនេះមិនសូវមានប្រសិទ្ធភាពទេ ព្រោះការរក្សាទុកជាការសម្ងាត់នូវរូបមន្តផលិតកម្មដោយហាមឃាត់មិនឱ្យគេចូល មិនត្រឹមតែគ្មានប្រសិទ្ធភាពប៉ុណ្ណោះទេ ហើយបញ្ហាមិនមែនមានតែប៉ុណ្ណឹងឡើយ។ ទោះជាខ្ញុំហៅគេថាជាអ្នកក្រៅក៏ដោយ ធាតុពិតគេជាអ្នកធ្វើការងារជាមួយយើងក្នុងរោងចក្រតែមួយ។ ថ្វីត្បិតតែគេជាអ្នកធ្វើការជាមួយយើង ប៉ុន្តែយើងត្រូវមើលពីជំហរការងារនិងអត្តចរិតល្អឬមិនល្អផងដែរ។ ខ្ញុំបានគិតសព្វគ្រប់ពីប្រការនេះ ហើយផ្តើមចេញពីលទ្ធផលនៃការគិតនេះ ខ្ញុំឈានដល់ការសន្និដ្ឋានមួយ។ ខ្ញុំសម្រេចចិត្តឈប់រក្សារូបមន្តនៃការផលិតជាការ

សម្ងាត់នៅក្នុងរង្វង់គ្រួសារតទៅទៀតហើយ ។ ខ្ញុំនឹងចាប់ផ្តើមបង្រៀនរូបមន្តនោះដល់បណ្តាបុគ្គលិកទាំងអស់ដែលខ្ញុំបានជួលមកធ្វើការ សូម្បីតែអ្នកដែលទើបនឹងចូលមកធ្វើការក្នុងថ្ងៃនេះក៏ដោយ ។ លទ្ធផលដែលបានមកពីការអនុវត្តបែបនេះ ហាក់ដូចជាធ្វើឱ្យបរិយាកាសក្នុងរោងចក្រមានភាពរីករាយស្រស់ថ្លាកើនឡើងមួយកម្រិត ។

ម្យ៉ាងទៀត បុគ្គលដែលយើងឱ្យទទួលបន្ទុកលើដំណើរការផលិតកម្មរហូតមកដល់ពេលបច្ចុប្បន្ននេះ បានធ្វើឱ្យការងារកាន់តែរីកចម្រើនទៅមុខប្រកបដោយភាពរស់រវើក ។ យើងទទួលបានលទ្ធផលគួរជាទីគាប់ចិត្តក្រៃលែង ។ ប៉ុន្តែក្នុងសង្គមមួយ ការយល់របស់មនុស្សយើងមានច្រើនបែប ច្រើនសណ្ឋានខុសៗគ្នា ។ គេបានដាស់តឿនខ្ញុំថា "របៀបអនុវត្តរបស់លោក MATSUSHITA ពិតជាប្រថុយប្រថានពេកហើយ ។ ការបង្រៀនរូបមន្តផលិតដល់បុគ្គលិកដែលសូម្បីទើបតែចូលធ្វើការបានមួយថ្ងៃ គឺប្រៀបដូចជាការផ្សព្វផ្សាយជាសាធារណៈនូវការសម្ងាត់ផ្នែកបច្ចេកវិទ្យាអីចឹង ។ យើងនឹងប្រឈមជាមួយនឹងចំនួននៃអ្នកប្រកបរបរដូចគ្នា ដែលនឹងមានការកើនឡើង ។ ប្រសិនបើដូច្នេះ នោះនឹងក្លាយទៅជាការខាតបង់ចំពោះក្រុមហ៊ុនអគ្គិសនី MATSUSHITA ឬទេអ្វី" ។

ការបារម្ភនេះគឺជាការសមហេតុផលមួយផ្នែក ដែលយើងមិនអាចនិយាយថាមិនឱ្យមានការបារម្ភបែបនេះទាល់តែសោះនោះទេ ។ ខ្ញុំគ្រាន់តែបង្រៀននិយោជិតក្រុមហ៊ុនគ្រឿងអគ្គិសនី MATSUSHITA ទេតើ! ។ ខ្ញុំគ្មានបំណងបង្រៀនដល់អ្នកក្រៅដែលមិនធ្លាប់ស្គាល់ទាល់តែសោះនោះឡើយ ។ ផ្តើមចេញពីការគិតយ៉ាងដូច្នេះ ខ្ញុំបានជម្រាបអ្នកដែលបារម្ភនោះថា ៖ ខ្ញុំសូមថ្លែងអំណរគុណចំពោះការដាស់តឿននេះ ។ ប៉ុន្តែខ្ញុំយល់ថារឿងដែលលោកព្រួយបារម្ភនោះមិនអាចកើតមានទេ ។ បានសេចក្តីថានិយោជិតក៏ដឹងដែរថារូបមន្តនៃការផលិតគឺត្រូវរក្សាទុកជាការសម្ងាត់ ។ ពួកគេដឹងច្បាស់ណាស់ពីការខាតបង់របស់រោងចក្រ ប្រសិនបើពួកគេទម្លាយការសម្ងាត់នេះឱ្យអ្នកដទៃទៀតដឹង ។ ដូច្នេះហើយ ខ្ញុំយល់ថាទោះបីជាពួកគេបានទទួលការបង្រៀនពីយើងក៏ដោយ ក៏ការដែលពួកគេទម្លាយការសម្ងាត់នេះឱ្យអ្នកផ្សេងទៀតដឹង ច្បាស់ជាមិនអាចកើតមានឡើយ ។

កត្តាដែលសំខាន់ជាងនេះទៅទៀតនោះ គឺការជឿទុកចិត្តគ្នាទៅវិញទៅមក ។ ខ្ញុំមានទំនុកចិត្តលើនិយោជិតរបស់ខ្ញុំ ហើយបង្រៀនរូបមន្តនៃការផលិតដល់ពួកគេ ។ ដូច្នេះយើងខ្ញុំយល់ថា ជាការឆ្លើយតបទៅនឹងទំនុកចិត្តនេះ ពួកនិយោជិតក៏រក្សារូបមន្តនេះជាការសម្ងាត់ផងដែរ ហើយពួកគេក៏កាន់តែខិតខំប្រឹងប្រែងធ្វើការឱ្យយើងថែមទៀត ។ ជាក់ស្តែង ពួកគេគ្រប់គ្នាកំពុងខិតខំប្រឹងប្រែងធ្វើការងារឱ្យក្រុមហ៊ុនពិតមែន ។

ក្រោយពីស្តាប់ការរៀបរាប់របស់ខ្ញុំរួចហើយ ខ្ញុំមិនដឹងថាអ្នកនោះយល់អស់សេចក្តីឬយ៉ាងណានោះទេ។ ខ្ញុំហាក់មានអារម្មណ៍ថា គាត់បាននិយាយឆ្លើយតបវិញដោយសម្តែងទឹកមុខយល់ស្របបាន ពាក់កណ្តាល រីឯពាក់កណ្តាលទៀត គាត់នៅតែមិនអាចយល់ស្របបានឡើយ។ ប៉ុន្តែអ្វីដែលខ្ញុំចង់និយាយមិនមែនសំដៅទៅលើបញ្ហារក្សាទុករូបមន្តនៃការផលិតទុកជាការសម្ងាត់នោះទេ គឺខ្ញុំសំដៅទៅលើប្រការជឿទុកចិត្តលើនិយោជិត។

តាមសេចក្តីសន្និដ្ឋានជាទូទៅ មនុស្សលោកយើងនេះ ប្រសិនបើត្រូវគេជឿទុកចិត្តហើយគឺគេមិនក្បត់សេចក្តីជឿទុកចិត្តនេះឡើយ។ ដូច្នេះហើយ ការជឿទុកចិត្តនេះធ្វើឱ្យបុគ្គលិកដែលមិនចាប់អារម្មណ៍លើខ្លួនឯង ក្លាយជាមានលក្ខណៈសមស្របជាបុគ្គលិកពិតៗ។ ការជឿជាក់បែបនេះជាលក្ខណៈមួយគួរឱ្យកោតសរសើរចំពោះមនុស្សយើងម្នាក់ៗ។

(ដកស្រង់ និងកែសម្រួលពីឯកសារ វិធីសាស្ត្រនៃការគ្រប់គ្រង និងប្រើប្រាស់មនុស្សឱ្យអស់ពីសមត្ថភាព

របស់លោក ម៉ាស៊ីសិតា កូណូស៊ីកិ ទំព័រ ១៣-១៦ បោះពុម្ពនៅខែ កុម្ភៈ ឆ្នាំ ២០០៣)

សំណួរ

១. តើអត្ថបទខាងលើនិយាយពីអ្វី ?

២. ចូរបង្ហាញខ្លឹមសារសំខាន់នៃអត្ថបទ ?

៣. តើអ្វីទៅជាតម្លៃនៃការជឿជាក់ ?

៤. ហេតុអ្វីបានជាប្រធានក្រុមហ៊ុនហ៊ានទម្លាយការសម្ងាត់របស់ក្រុមហ៊ុនប្រាប់ដល់និយោជិតរបស់គាត់ ? តើការសម្ងាត់នោះជាអ្វី ?

៥. ប្រសិនបើអ្នកជាប្រធានក្រុមហ៊ុនឬប្រធានអង្គភាពមួយ តើអ្នកត្រូវធ្វើដូចម្តេច ដើម្បីឱ្យបុគ្គលិក ឬ មន្ត្រីក្រោមឱវាទមានទំនុកចិត្ត និងមានការជឿជាក់មកលើខ្លួន ?

៦. តាមរយៈអត្ថបទ តើបទពិសោធអ្វីដែលប្រធានក្រុមហ៊ុនទទួលបានពីបុគ្គលិករបស់គាត់និងធ្វើឱ្យគាត់មានការជឿជាក់ ?

៧. ចូរសង្ខេបអត្ថបទឡើងវិញ។

១ អ្នកនិយាយទូរទស្សន៍

នៅពេលអ្នកស្តាប់អត្ថបទ "អ្នកនិយាយទូរទស្សន៍" ចូរត្រៀមឆ្លើយនឹងសំណួរខាងក្រោម។ ទន្ទឹមនឹងនេះដែរ ចូរអ្នកកត់ចំណាំគំនិតដែលទាក់ទងនឹងប្រធានបទ ឬចំណុចមិនទាក់ទងគ្នា មិនស៊ីចង្វាក់គ្នាក្នុងសាច់រឿង។

សំណួរ

១. តើអត្ថបទនេះនិយាយពីអ្វី ?

២. តើអ្នកនិយាយតាមទូរទស្សន៍ជាមនុស្សដូចម្តេច ?

៣. តើមុនពេលផ្សាយនិងកំពុងផ្សាយតាមទូរទស្សន៍ អ្នកនិយាយតាមទូរទស្សន៍ត្រូវធ្វើដូចម្តេចខ្លះ ?

៤. តើអ្នកនិយាយតាមទូរទស្សន៍និងទស្សនិកជនមានភាពជិតស្និទ្ធគ្នាដូចម្តេច ?

៥. ចូរសង្ខេបអត្ថបទឡើងវិញ។

បំពេញទម្រង់បែបបទប្រើប្រាស់ប្រចាំថ្ងៃ

អ្នកធ្លាប់បានសិក្សារួចមកហើយអំពីសំណេរបំពេញសលាកបត្រព័ត៌មាន ជីវប្រវត្តិ ពាក្យសុំចូលរៀន ព័ត៌មានផ្ទាល់ខ្លួនសិស្ស បំពេញអត្តសញ្ញាណប័ណ្ណសិស្ស ។

ឥឡូវនេះអ្នកនឹងសិក្សាពីសំណេរបំពេញទម្រង់បែបបទប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃគឺសំណេរបំពេញពាក្យសុំចុះឈ្មោះប្រឡង ។

ចូរអ្នកអានគំរូសំណេរពាក្យសុំចុះឈ្មោះជាបេក្ខជនប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ចំណេះទូទៅដូចខាងក្រោម ៖

តែមប្រ៊ីយ៍ ៣០០ រៀល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ពាក្យសុំចុះឈ្មោះជាបេក្ខជនប្រឡងសញ្ញាបត្រមធ្យមសិក្សា បឋមភូមិចំណេះទូទៅ

ខ្ញុំបាទ / នាងខ្ញុំ ឈ្មោះ.....“ឈ្មោះជាអក្សរឡាតាំង.....” ភេទ.....
ជនជាតិ..... សញ្ជាតិ.....កើតនៅថ្ងៃទី..... ខែ.....ឆ្នាំ.....
នៅឃុំ / សង្កាត់.....ស្រុក / ខណ្ឌ.....ខេត្ត / ក្រុង.....
ឪពុកឈ្មោះ.....មុខរបរសព្វថ្ងៃ.....
ម្តាយឈ្មោះ.....មុខរបរសព្វថ្ងៃ.....
ជាសិស្សថ្នាក់ទី.....នៃវិទ្យាល័យ ឬអនុវិទ្យាល័យ.....
ទីលំនៅបច្ចុប្បន្ន..... ។

សូមគោរពជូន

ឯកឧត្តម រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

តាមរយៈ : - លោកនាយកវិទ្យាល័យ ឬអនុវិទ្យាល័យ ..... ។
- លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុង ..... ។

សូមឯកឧត្តម មេត្តាអនុញ្ញាតចាត់ឱ្យចុះឈ្មោះខ្ញុំបាទ / នាងខ្ញុំក្នុងបញ្ជីបេក្ខជនប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ នាសម័យប្រឡងថ្ងៃទី..... ខែ.....ឆ្នាំ.....នៅមណ្ឌល.....
ខេត្ត / ក្រុង.....ដោយជ្រើសរើសយកភាសា..... សម្រាប់មុខវិជ្ជាភាសាបរទេសដោយអនុគ្រោះ ។

ខ្ញុំបាទ / នាងខ្ញុំសូមសន្យាចំពោះឯកឧត្តមថា ខ្ញុំបាទ / នាងខ្ញុំនឹងទទួលយល់ព្រមពីការលុបឈ្មោះចេញពីបញ្ជីបេក្ខភាពប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ បើខ្ញុំមិនគោរពលក្ខខណ្ឌបេក្ខភាពរបស់បេក្ខជន ។

សូមជូនភ្ជាប់មកជាមួយ

- សណាកបត្រឯកត្តជនទំហំ ១៥ ស.ម × ២១ ស.ម មានបិទរូបថត ៤ × ៦ ចំនួន ០២សន្លឹក
- សណាកបត្រពិន្ទុប្រចាំឆ្នាំទំហំ ១៥ ស.ម × ២១ ស.ម .....ចំនួន ០២សន្លឹក
- រូបថត ថតថ្មី ថតពីមុខទំហំ ៤ × ៦"រូបថតដែលបានបិទលើសណាកបត្រឯកត្តជន"ចំនួន ០២សន្លឹក
- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត.....ចំនួន ០១ច្បាប់
- បង្កាន់ដៃបង់សិទ្ធិប្រឡង.....ចំនួន ០១ច្បាប់

សូមឯកឧត្តមមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ / នាងខ្ញុំ ។

ធ្វើនៅ .....ថ្ងៃទី.....ខែ.....ឆ្នាំ.....

ហត្ថលេខានិងឈ្មោះ

សំណួរ

១. តើសំណេរពាក្យសុំចុះឈ្មោះជាបេក្ខជនប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិចំណេះទូទៅខាងលើនេះរៀបរាប់ពីអ្វីខ្លះ ?

២. តើអ្នកត្រូវបំពេញសំណេរពាក្យសុំនេះយ៉ាងដូចម្តេច ដើម្បីចៀសវាងការខុសឆ្គង ?

៣. តើចំណុចសំខាន់ៗដែលត្រូវបំពេញមានអ្វីខ្លះ ?

លំហាត់

ចូរប្អូនបំពេញសំណេរពាក្យសុំចុះឈ្មោះជាបេក្ខជនប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិចំណេះទូទៅដូចគំរូខាងលើនេះឡើងវិញឱ្យបានត្រឹមត្រូវ ។

សេចក្តីណែនាំ

ពេលអ្នកសរសេរបំពេញ :

- អ្នកត្រូវយកចិត្តទុកដាក់បំពេញឱ្យបានពេញគ្រប់ចំណុចនិងព័ត៌មានដែលត្រូវបង្ហាញដូចលំនាំគំរូខាងលើ ។
- អ្នកត្រូវបំពេញឱ្យបានត្រឹមត្រូវចៀសវាងកំហុសពាក្យ ថ្ងៃ ខែ ឆ្នាំកំណើត អាស័យដ្ឋាន ឱ្យបានច្បាស់លាស់តាមព័ត៌មានផ្ទាល់ខ្លួន ។
- ពេលបំពេញរួចត្រូវចុះហត្ថលេខានិងឈ្មោះខ្លួនឯងឱ្យបានត្រឹមត្រូវ ។

តែងសេចក្តី

អត្ថាធិប្បាយពន្យល់

តែងសេចក្តីមានច្រើនប្រភេទដូចជាតែងសេចក្តីពណ៌នា និទាន សរសេរសំបុត្រ អត្ថាធិប្បាយជាដើម។ តែងសេចក្តីអត្ថាធិប្បាយមាន អត្ថាធិប្បាយពន្យល់ ពិភាក្សា ប្រៀបធៀប ... ។ ក្នុងមេរៀននេះអ្នកនឹងសិក្សាពីសំណេរអត្ថាធិប្បាយពន្យល់។

សំណេរអត្ថាធិប្បាយពន្យល់ គឺការបកស្រាយបំភ្លឺមតិគំនិតនរណាម្នាក់ ទស្សនៈរបស់អ្នកប្រាជ្ញណាម្នាក់ឬបង្ហាញការយល់ឃើញរបស់ខ្លួនផ្ទាល់ស្របតាមគំនិតប្រធាន។ ក្នុងការពន្យល់ អ្នកត្រូវវិភាគរកហេតុផលមកធ្វើជាអំណះអំណាង ហើយប្រើសិល្បៈវិធីធ្វើយ៉ាងណាឱ្យគេយល់ច្បាស់ពីខ្លឹមសារអត្ថន័យនៃមតិទស្សនៈ ឬបញ្ហានោះ។ ទស្សនៈ បញ្ហា អត្ថន័យ ... ដែលបានចោទនៅក្នុងប្រធានប្រភេទនេះ ច្រើនមានលក្ខណៈជឿនលឿនសកម្មរួចជាស្រេចទៅហើយដោយពុំមានមតិឬយោបល់ណាមួយមកខ្ចាស់នឹងអត្ថន័យ ឬទស្សនៈនោះបានឡើយ។ អត្ថន័យជឿនលឿន ឬសកម្មមានន័យថាប្រធាននោះមានខ្លឹមសារវិជ្ជមានគ្រប់គ្រាន់ក្នុងការអប់រំនិងបម្រើជីវភាពរស់នៅរបស់មនុស្សនៅក្នុងសង្គម។

ចូរអ្នកអានសំណេរខាងក្រោមនេះ ៖

ប្រធាន : គេថា "ចៅចិត្រក្នុងរឿងកុលាបប៉ៃលិន ជាយុវជនថ្លៃថ្នូរ"។ ចូរពន្យល់។

សេចក្តីអធិប្បាយ

រឿងកុលាបប៉ៃលិន គឺជាអក្សរសិល្បៈទំនើបបែបប្រលោមលោក និពន្ធឡើងដោយលោក ញ៉ុក ថែម នៅក្នុងសម័យអាណានិគមនិយមបារាំង។ ក្រោយពីបានសិក្សារឿងនេះចប់ មានមតិមួយលើកឡើងថា "ចៅចិត្រក្នុងរឿងកុលាបប៉ៃលិន ជាយុវជនថ្លៃថ្នូរ"។ តើចំណុចត្រង់ណាខ្លះ ដែលបញ្ជាក់ឱ្យឃើញថា ចៅចិត្រជាយុវជនថ្លៃថ្នូរ ?

ដើម្បីជាជំនួយដល់ការបំភ្លឺចំពោះបញ្ហាខាងលើ ជាបឋមគប្បីស្វែងយល់ពាក្យ "យុវជនថ្លៃថ្នូរ" ជាមុនសិន។ យុវជនថ្លៃថ្នូរ គឺយុវជនដែលមានកិត្តិយស មានតម្លៃខ្ពស់ធ្វើឱ្យអ្នកដទៃទុកចិត្តស្រឡាញ់រាប់អានហើយចាត់ទុកថា ជាមនុស្សត្រឹមត្រូវ។ ចំពោះមតិប្រធានមានន័យថា ចៅចិត្រនៅក្នុងរឿងកុលាបប៉ៃលិនជាយុវជនមួយរូបដែលមានកិត្តិយសនិងតម្លៃខ្ពស់ស័ក្តិសមជាកុលបុត្រដ៏ប្រពៃ។

ជាការជាក់ស្តែង នៅក្នុងវ័យសិក្សាក្រោមការគ្រប់គ្រងរបស់តាចឹមជាឪពុក ចៅចិត្រពុំដែលប្រព្រឹត្តអំពើផ្តេសផ្តាសធ្វើឱ្យឪពុកពិបាកចិត្តដោយសារខ្លួនម្តងណាឡើយ។ អាស្រ័យដោយសេចក្តីព្យាយាមក្នុងការសិក្សា ចៅចិត្របានប្រឡងជាប់ប្រកាសនីយបត្រដែលជាសញ្ញាបត្រមួយដ៏មានតម្លៃក្នុង

សម័យនោះ។ ព្រមជាមួយនេះដែរ ថៅចិត្របានខិតខំរៀនសូត្រចំណេះបច្ចេកទេសខាងបើកបរនិង ជួសជុលរថយន្តបន្ថែមទៀត។ នេះបញ្ជាក់ឱ្យឃើញថា ថៅចិត្រគឺជាយុវជនចេះដឹងមួយរូបគួរឱ្យ សរសើរ។ នៅពេលដែលតាចឹមផ្លាក់ខ្លួនមានជំងឺជាទម្ងន់ ថៅចិត្របានយកចិត្តទុកដាក់ថែទាំបម្រើ ឪពុកតាំងពីបាយទឹក ម្ហូបចំណីព្រមទាំងទៅអញ្ជើញលោកគ្រូពេទ្យមកពិនិត្យព្យាបាលថែមទៀត។ ជា ពិសេសទៅទៀតក្រោយពេលតាចឹមចែកឋានទៅ ថៅចិត្របានរៀបចំធ្វើបុណ្យសពឪពុកតាមទំនៀម ទម្លាប់ប្រពៃណីជាតិយើង។ នេះបញ្ជាក់ថា ថៅចិត្រជាកូនកតញ្ញូមួយរូបដែលបានបំពេញកិច្ចតបស្នង គុណឪពុកទៅតាមលទ្ធភាពរបស់ខ្លួន។

ក្រោយពេលដែលឪពុកស្លាប់ទៅ ថៅចិត្រពុំអស់សង្ឃឹមក្នុងជីវិតឡើយ។ គ្រប់កាលៈទេសៈ ថៅ ចិត្រតែងយកបណ្តាំ "អត្តាហិអត្តនោនាថោ" របស់ឪពុកមកអនុវត្តជានិច្ច ពោលគឺបានពឹងផ្អែកលើ សមត្ថភាពខ្លួនឯងជាធំ។

ចំពោះបញ្ហាការងារថៅចិត្រពុំមានការរើសអើង ឬប្រកាន់ថា ការងារនេះថោកទាប ឬការងារ នោះថ្លៃថ្នូរឡើយ។ ពិតមែនតែថៅចិត្រមានប្រកាសនីយបត្រ ដែលបញ្ជាក់ថាគេមានចំណេះវិជ្ជាកម្រិត វប្បធម៌ទូទៅយ៉ាងបង្គួរ ប៉ុន្តែ ថៅចិត្របានសម្រេចចិត្តចូលធ្វើកម្មករជីកត្បូងនៅផ្ទះលោកហ្លួងរតន សម្បត្តិដោយមិនគិតថា ជាការងារតូចតាចឡើយ។ ក្នុងឋានៈជាកម្មករជីកត្បូងថៅចិត្របានយកចិត្តទុក ដាក់បំពេញភារកិច្ចរបស់ខ្លួនបានល្អដោយមិនទាមទារការឈប់សម្រាកថ្ងៃអាទិត្យឬថ្ងៃបុណ្យឡើយ។ ទោះបីការងារនោះលំបាកធ្ងន់ធ្ងរ ប្រឡាក់ភក់ ហាលថ្ងៃ ហាលភ្លៀង ហាលខ្យល់ក៏ដោយ ក៏ថៅចិត្រ នៅតែតស៊ូព្យាយាមក្នុងការងារដោយគ្មានធ្វេសប្រហែស។ នេះហើយដែលធ្វើឱ្យថៅហ្វាយនាយនិង កម្មករដទៃទៀតស្រឡាញ់រាប់អាន។ សេចក្តីថ្លៃថ្នូរនេះគឺជាកិត្តិយសមួយដែលថៅចិត្រទទួលបាន ព្រោះកម្មករទាំងនោះពុំបានមើលស្រាលថៅចិត្រទេ ផ្ទុយទៅវិញគេបានរាប់អាននិងឱ្យតម្លៃ ហើយ ទទួលស្គាល់នូវសមត្ថភាពពិតរបស់ថៅចិត្រ។

ចំពោះបញ្ហាស្នេហាវិញថៅចិត្រតែងប្រកាន់ខ្ជាប់នូវភាពថ្លៃថ្នូរជានិច្ច។ គេបានចាប់ចិត្តស្រឡាញ់ ឃុនានីដែលជាបុត្រីបណ្តូលចិត្តតែមួយគត់របស់លោកហ្លួងរតនសម្បត្តិ។ ប៉ុន្តែគេពុំដែលប្រព្រឹត្តអំពើ ពុំគប្បីចំពោះនាងឡើយ។ ទន្ទឹមនឹងអាកប្បកិរិយាដ៏សមរម្យនេះថៅចិត្របានបង្ហាញឱ្យឃើញនូវភក្តី ភាពរបស់ខ្លួនដ៏ស្មោះចំពោះគ្រួសារនាងថែមទៀត។ ជាក់ស្តែងពេលមានអាសន្នត្រូវចោរប្លន់នៅ កណ្តាលព្រៃនិងនៅផ្ទះហ្លួងរតនសម្បត្តិ ថៅចិត្របានយកអាយុជីវិតរបស់ខ្លួនទៅប្តូរដើម្បីការពារអាយុ ជីវិតនិងទ្រព្យសម្បត្តិរបស់ថៅហ្វាយនាយ។ ដោយមើលឃើញថា ថៅចិត្រជាយុវជនមួយរូបដែល មានចំណេះវិជ្ជានិងមានសីលធម៌ល្អមិនពាលអាវ៉ាសែទើបលោកហ្លួងរតនសម្បត្តិសម្រេចចិត្តឱ្យថៅ

ចិត្ររៀបការនិងនាងឃុនានីជាគូស្វាមីភរិយា ។ ចាប់ពីពេលនោះ មកថៅចិត្រក៏បានក្លាយខ្លួនជាកូនប្រសាលោកហ្លួងរតនសម្បត្តិនិងជាថៅកែតួងនៅស្រុកប៉ៃលិន ។ ការឡើងឋានៈពីទាបទៅខ្ពស់ដ៏ឆាប់រហ័សនេះ គឺជាកិត្តិយសមួយដែលថៅចិត្រសមនឹងទទួលបាន ។

រួមសេចក្តីមកថៅចិត្រថ្វីត្បិតតែគ្មានទ្រព្យសម្បត្តិ គ្មានបុណ្យស័ក្តិប៉ុន្តែមានចំណេះវិជ្ជាជ្រៅជ្រះដឹងគុណនិងស្តាប់តាមឱវាទរបស់ឪពុកនិងមិនរើសអើងការងារមិនពាលាអារ៉ាំសែ មិនរំលោភសិទ្ធិនារីភេទហើយមានភក្តីភាពចំពោះថៅហ្វាយនាយក៏ដូចជាកម្មករដទៃទៀត ។ គុណសម្បត្តិនេះបញ្ជាក់ថាថៅចិត្រជាយុវជនថ្លៃថ្នូរពិតប្រាកដមែន ។

សរុបសេចក្តីមក ឆ្លងតាមការបកស្រាយនិងការបង្ហាញខាងលើរួចមក យើងអាចវាយតម្លៃជាចុងក្រោយថា ថៅចិត្រជាយុវជនថ្លៃថ្នូរមួយរូបដែលចេះកសាងខ្លួនឯងដោយឈរលើចំណេះដឹងជ្រៅជ្រះនិងសីលធម៌ល្អឱ្យក្លាយជាមនុស្សដែលមានគេស្រឡាញ់ រាប់អានគ្រប់គ្នា ។ អាស្រ័យហេតុនេះយុវជននិងយុវនារីទាំងឡាយគប្បីខិតខំរៀនសូត្របង្កើនចំណេះដឹងនិងកសាងខ្លួនឱ្យសមជាពលរដ្ឋល្អ ហើយចៀសវាងនូវអំពើណាដែលមិនថ្លៃថ្នូរ ហើយប្រព្រឹត្តនូវអំពើថ្លៃថ្នូរទើបប្រទេសយើងអាចរីកចម្រើនជឿនលឿនបាន ។

សំណួរ

១. តើសំណេរខាងលើនេះនិយាយពីអ្វី ? តើមានផ្នែកសំខាន់ៗអ្វីខ្លះ ?

២. តើកថាខណ្ឌទី ១ របស់សំណេរបង្ហាញពីអ្វី ?

៣. តើក្នុងតួសេចក្តីមានប៉ុន្មានកថាខណ្ឌ ? កថាខណ្ឌនីមួយៗនិយាយពីអ្វី ?

៤. តើសេចក្តីបញ្ចប់របស់សំណេរនិយាយពីអ្វី ?

លំហាត់

ចូរប្អូនជ្រើសរើសប្រធានបទណាមួយក្នុងចំណោមប្រធានបទខាងក្រោមដែលប្អូនពេញចិត្តដើម្បីបកស្រាយ ។

- សុភាសិតខ្មែរមួយចែងថា "ដឹងឆ្លើយត្បិតជង កូនសោតរែងឆ្គងត្បិតតែឪពុក " ។
- គេតែងនិយាយថា "យុវជនជាទំពាំងស្នងឫស្សី" ។ តើមតិនេះមានអត្ថន័យយ៉ាងណា ?
- សុភាសិតមួយឃ្លាថា "ជួយខ្លួនឯងបានទើបទេវតាជួយជាក្រោយ" ។ តើសុភាសិតនេះមានន័យដូចម្តេច ?

មេរៀនទី

សេចក្តីព្យាយាម



ដើម្បីរៀបចំជីវិតឱ្យរស់នៅស្រួល មានសេចក្តីសុខចម្រើន សមតាមបំណងប្រាថ្នា មនុស្សម្នាក់ៗត្រូវតែមានការតស៊ូ អំណត់ ព្យាយាម ហ៊ានពុះពារជម្នះគ្រប់កិច្ចការលំបាក និងឧបសគ្គគ្រប់យ៉ាង។ ទង្វើនេះបានស្តែងឡើងតាមរយៈកម្លាំងកាយ ចិត្ត ប្រាជ្ញាស្មារតី។ ពិសេស ការមានជំនឿលើសមត្ថភាពខ្លួនឯង មានស្មារតីសុទិដ្ឋិនិយម ស្នេហាជាតិ សាមគ្គីភាព និងការទទួលខុសត្រូវប្រកបដោយឆន្ទៈក្លាហាន មោះមុត ពុះពារការលំបាកទាំងឡាយ អ្នកនឹងអាចជម្នះបានលើបញ្ហាគ្រប់បែបយ៉ាងដែលកើតមានឡើង រហូតទទួលបានជោគជ័យយ៉ាងពិតប្រាកដ។ ក្នុងមេរៀននេះ អ្នកនឹងសិក្សាពីការព្យាយាមដែលនឹងបង្ហាញឡើងតាមរយៈអត្ថបទមួយចំនួន ដែលនិយាយពីមនុស្សសំខាន់ៗក្នុងលោក។ លើសពីនេះ អ្នកនឹងសិក្សាផងដែរអំពី កម្មវត្ថុ ទម្រង់ និងធាតុសំខាន់ៗនៃអត្ថបទណែនាំ និងការណែនាំដែលមានលំដាប់លំដោយ ការរៀបចំនិងឡើងនិយាយដោយប្រើអត្ថបទណែនាំ ការវាយតម្លៃភាពច្បាស់លាស់ ប្រសិទ្ធភាពនៃការប្រើប្រាស់សំឡេងនិងល្បឿននិយាយសមស្របនិងបានត្រឹមត្រូវ និងសិក្សាអំពីប្រភេទពាក្យផ្សំ។

ពាក្យផ្សំ

អ្នកធ្លាប់បានសិក្សារួចមកហើយអំពី នាម គុណនាម កិរិយា កាលរបស់កិរិយា សព្វនាម ល្បះពាក្យក្លាយ នាមផ្សំបែបខ្មែរ និងបាលីសំស្ក្រឹត ។ល។

ឥឡូវនេះអ្នកនឹងសិក្សាបន្ថែមទៀតអំពីពាក្យផ្សំ ។

តើអ្វីទៅជាពាក្យផ្សំ ?

មុននឹងសិក្សាអំពីពាក្យផ្សំ អ្នកគួរស្វែងយល់ថាអ្វីទៅជា "ពាក្យ" ។

ចូរអ្នកអានឧទាហរណ៍ខាងក្រោម ៖

ឧទាហរណ៍ : សិស្សទៅសាលារៀន ។

បើយើងបំបែកល្បះខាងលើ យើងឃើញថា ល្បះខាងលើមានឯកតាមានន័យ ៣គឺសិស្ស ទៅ សាលារៀន ។ ឯកតានីមួយៗសុទ្ធតែមានន័យច្បាស់លាស់នេះគេហៅថា "ពាក្យ" ។

កំណើតពាក្យមានលក្ខណៈខុសៗគ្នា ។ ពាក្យខ្លះបានមកពីការបង់ក្លាយពាក្យបូសដោយប្រើផ្តត់

ឧទាហរណ៍ :

- សើម ជាពាក្យបូស របស់ពាក្យសន្សើម
- ខូច ជាពាក្យបូស របស់ពាក្យកំហូច
- កាយ ជាពាក្យបូស របស់ពាក្យកំណាយ

ពាក្យខ្លះបានមកពីការផ្សំរវាងពាក្យក្លាយជាមួយពាក្យបន្ថែម ។

ឧទាហរណ៍ :

- ការចម្លង ចេញពីពាក្យ ការ + ចម្លង
- ការបង្កើត ចេញពីពាក្យ ការ + បង្កើត

ពាក្យខ្លះទៀតជាពាក្យក្លាយដែលកើតចេញពីពាក្យបូសដោយការបន្ថែមផ្តត់ដើមឬផ្តត់ជែក ដែលអ្នកបានសិក្សាក្នុងមេរៀនមុនរួចមកហើយ ។

ពេលនេះចូរប្អូនសង្កេតមើលឧទាហរណ៍នៃពាក្យផ្សំខាងក្រោម :

១ . ពាក្យផ្សំបែបទី ១

ក. ពាក្យបន្ថែមខាងដើម

គឺពាក្យសម្រាប់បន្ថែមខាងដើមពាក្យឫសមានដូចជា

- ការ	+	សិក្សា	(កិ)	>	ការសិក្សា
	+	អប់រំ	(កិ)	>	ការអប់រំ
	+	ប្រឡង	(កិ)	>	ការប្រឡង
	+	ព្យាយាម	(កិ)	>	ការព្យាយាម ។
- សេចក្តី	+	ថ្លៃថ្នូរ	(គុ)	>	សេចក្តីថ្លៃថ្នូរ
	+	ចម្រើន	(គុ)	>	សេចក្តីចម្រើន
	+	ព្យាយាម	(គុ)	>	សេចក្តីព្យាយាម
	+	សុខ	(គុ)	>	សេចក្តីសុខ ។
- អ្នក	+	ស្រែ	(ន)	>	អ្នកស្រែ
	+	ចម្ការ	(ន)	>	អ្នកចម្ការ
	+	ជំនួញ	(ន)	>	អ្នកជំនួញ
	+	ក្រ	(គុ)	>	អ្នកក្រ
	+	ជំនាញ	(គុ)	>	អ្នកជំនាញ
	+	លេង	(កិ)	>	អ្នកលេង
	+	ផឹក	(កិ)	>	អ្នកផឹក
	+	រៀន	(កិ)	>	អ្នករៀន
- ជន	+	បរទេស	(ន)	>	ជនបរទេស
	+	សុចរិត	(ន)	>	ជនសុចរិត
	+	កំណាញ់	(ន)	>	ជនកំណាញ់
	+	កំហូច	(ន)	>	ជនកំហូច
- ភាព	+	សមរម្យ	(គុ)	>	ភាពសមរម្យ
	+	ស្តុកស្តម្ភ	(គុ)	>	ភាពស្តុកស្តម្ភ
	+	ជឿនលឿន	(គុ)	>	ភាពជឿនលឿន
	+	ជ្រួលជ្រើម	(កិ)	>	ភាពជ្រួលជ្រើម

២. ពាក្យបន្ថែមខាងចុង

គឺពាក្យសម្រាប់បន្ថែមខាងចុងពាក្យឫសមានដូចជា

កម្ម កិច្ច ភាព ធម៌ ករ ការី ជន បុរស បុគ្គល នារី វិទូ ។ល។

- "កម្ម" សម្រាប់សម្គាល់សកម្មរបស់នាម ។

ឧទាហរណ៍ : ផលិតកម្ម វិវាទកម្ម ពលិកម្ម ហត្ថកម្ម សិប្បកម្ម ... ។

- "កិច្ច" សម្រាប់សម្គាល់សកម្មដែលតម្រូវឱ្យធ្វើ

ឧទាហរណ៍ : កាតព្វកិច្ច ករណីយកិច្ច បដិសណ្ឋារកិច្ច អធិការកិច្ច ភារកិច្ច ... ។

- "ភាព" សម្គាល់សភាពទូទៅទោះល្អក្តី ឬអាក្រក់ក្តី

ឧទាហរណ៍ : មិត្តភាព ជីវភាព មនុស្សភាព ស្ថានភាព គុណភាព ទេវភាព ។

- "ធម៌"សម្រាប់សម្គាល់សភាពល្អ

ឧទាហរណ៍ : មនុស្សធម៌ សីលធម៌ អរិយធម៌ គុណធម៌ វប្បធម៌ វឌ្ឍនធម៌ ... ។

- "ករ" ឬ "ការី" សម្រាប់សម្គាល់នាមការក៍ (ប្រាប់មុខងារឬមុខរបរអ្វីមួយ)

ឧទាហរណ៍ : កម្មករ កសិករ សិប្បករ សិល្បករ ពលករ ផលិតករ វិចិត្រករ យន្តករ បេឡាធិការី ។ល។

- "ជន បុគ្គល បុរស នារី" សម្រាប់សម្គាល់នាមការក៍ បញ្ជាក់ពីសភាពលក្ខណៈបែបណាមួយ

ឧទាហរណ៍ : បុព្វជន វីរជន អច្ឆរិយបុគ្គល វីរនារី វីរបុរស ព្រឹទ្ធបុរស ។ល។

- "វិទូ"សម្រាប់សម្គាល់អ្នកមានវិជ្ជាខ្ពង់ខ្ពស់

ឧទាហរណ៍ : ទស្សនវិទូ គណិតវិទូ រូបវិទូ ប្រវត្តិវិទូ ភាសាវិទូ ។

តាមឧទាហរណ៍នៃពាក្យបន្ថែមដើម និងពាក្យបន្ថែមចុងខាងលើនេះ យើងឃើញថា ពាក្យទាំងនោះបង្កើតបានជាពាក្យផ្សំបែបទី១ ។

២ . ពាក្យផ្សំបែបទី ២

ពាក្យដែលបានមកពីការផ្សំពាក្យក្នុងថ្នាក់ពាក្យតែមួយឬក៏ផ្សំជាមួយពាក្យក្នុងថ្នាក់ពាក្យដទៃទៀត ។

ចូរពិនិត្យឧទាហរណ៍ ៖

- ពាក្យផ្សំដែលចេញពី នាម + នាម

  ឧទាហរណ៍ :

  - ជើងគោ ជើងចាប ជើងមាន់ ជើងក្រាស

  - ដំឡូងវល្លិ ដំឡូងដៃខ្លា មេអណ្តើក ដំឡូងទៀន ស្រកីអណ្តែង ដំឡូងទឹក អណ្តើកមាស អំពិលអាចម៍ឆ្មា ដំឡូងពស់ ភ្លៅកង្កែប ប្រមោយដំរី អណ្តាតឆ្លាម

- ពាក្យផ្សំដែលចេញពី នាម + គុណនាម

  ឧទាហរណ៍ :

  - ឈើត្រង់ ឈើទាល ឈើស្រួច ទឹកខ្មៅ

  - ជីស ដៃខ្មៅ(ខ្មៅដៃ) ... ។

- ពាក្យផ្សំដែលចេញពី នាម + កិរិយា

  ឧទាហរណ៍ :

  - ត្បាល់កិន ក្តារបោក

  - ដែកខួង ដែកឆាប ដែកឈូស ដែកគាស់ ដែកចារ ... ។

- ពាក្យផ្សំដែលចេញពី គុណនាម + នាម

- គុណនាម + នាម

  ឧទាហរណ៍ : ក្តៅចិត្ត ឆ្អួតចិត្ត សប្បាយចិត្ត ធ្ងន់ត្រចៀក ឆ្អួតជ្រូក

- ពាក្យផ្សំដែលចេញពី កិរិយា + នាម

  ឧទាហរណ៍ : ដើរតួ ដើរទា ទាញព្រ័ត្រ ចាប់ចិត្ត ចាប់មាត់ លាក់កន្សែង លើកមុខ ដាល់អំបុក លោតអង្រែ បូតសណ្តែក ចុះប្រេង បាក់សាច់ បាក់ជ័របាយ បាក់ផ្តៅ បាក់ដំឡូង កាច់សង្រែក ។

តាមឧទាហរណ៍ខាងលើយើងឃើញថា ពាក្យផ្សំបែបទី ២ កើតឡើងដោយនាមផ្សំជាមួយនាម នាមផ្សំជាមួយគុណនាម នាមផ្សំជាមួយកិរិយា គុណនាមផ្សំជាមួយនាម និងកើតឡើងពីកិរិយាផ្សំជាមួយនាម ។

ពាក្យផ្សំ គឺជាពាក្យដែលកើតឡើងដោយការយកពាក្យពីរឬច្រើនមកដាក់ឱ្យនៅជាប់ក្បែរគ្នា ហើយពាក្យនោះមានន័យផ្សេង ពីពាក្យឫសដើមនិងពាក្យបន្ថែមដើម ឬពាក្យបន្ថែមចុង ។

សំណួរ

១. ដូចម្តេចដែលហៅថាពាក្យ ?

២. ដូចម្តេចដែលហៅថាពាក្យផ្សំ ?

៣. តើពាក្យផ្សំមានប៉ុន្មានបែប ? ចូរបង្ហាញ និងលើកឧទាហរណ៍ ។

ឧត្តមគតិបុគ្គលសំខាន់



ក. សិក្សាពាក្យគន្លឹះ

- ឧត្តមគតិ (ន) : គតិឬប្រាជ្ញាញាណដ៏ខ្ពង់ខ្ពស់ ល្អប្រសើរ ថ្លៃថ្លា ។
- លទ្ធិ (ន) : ជំនឿ សេចក្តីជឿ ការប្រកាន់តាមយោបល់របស់ខ្លួន ឬតាមទម្លាប់តាមបែបបទ តាមការនិយម ។
- អតិបរមា (ន) : កម្រិតយ៉ាងច្រើន យ៉ាងក្រៃលែង ដ៏លើសលប់បំផុត ។
- សារមន្ទីរជាតិ (ន) : មន្ទីរដាក់របស់ឬវត្ថុមានតម្លៃ មានប្រយោជន៍ សំខាន់របស់ជាតិ ។
- មហាសាល (គុ) : ធំធេង មហាធំ ។
- ឧបសគ្គ (ន) : គ្រឿងរារាំងដំណើរ ។
- ពង្សាវតារ (ន) : រឿងរ៉ាវតាមលំដាប់វង្សត្រកូល ប្រវត្តិដែលឆ្លងពីសង្កាត់មួយទៅសង្កាត់មួយ ដំណើរសេចក្តីសម្តែងពីតំណវង្សត្រកូល ។
- សមិទ្ធិ (ន) : សេចក្តីសម្រេច សេចក្តីសម្រេចជាផល ។
- វឌ្ឍនភាព (ន) : ភាពរីកចម្រើន សេចក្តីរីកចម្រើនលូតលាស់ ។
- ពលានុភាព (ន) : អំណាច សេចក្តីអង់អាច សេចក្តីក្លាហាន ។
- សមត្ថភាព (ន) : ភាពនៃសេចក្តីអាចហ៊ាន សេចក្តីមោះមុត ។
- បុគ្គលិកលក្ខណៈ (ន) : លក្ខណៈរបស់បុគ្គលម្នាក់ៗ លក្ខណៈឬកំណត់ចំណាំរបស់បុគ្គល ។
- អាណាចក្រ (ន) : អំណាចដែលប្រព្រឹត្តទៅក្នុងការគ្រប់គ្រង អំណាចគ្រប់គ្រង ។
- សម្បជញ្ញៈ (ន) : សេចក្តីដឹងខ្លួន ការមិនភ្លេចខ្លួន ការប្រុងប្រយ័ត្ន ការត្រិះរិះ រំពឹងដឹងខ្លួនជាដរាប ។

- ប្រសិទ្ធភាព (ន) : ភាពដែលធ្វើឱ្យសម្រេចជោគជ័យ ។
- អាទិទេព (ន) : ទេពតាខាងដើម ទេពតាមុនបង្អស់ ដែលគេជឿថាជាព្រះជាអ្នកបង្កើត លោកជាអ្នករក្សាការពារឱ្យសេចក្តីសុខដល់មនុស្សលោក សត្វលោក ។
- កេរ្តិ៍ (ន) : សេចក្តីសរសើរ ភាពល្បី ការល្បីលេចឮខ្ចរខ្ចាយ កេរ្តិ៍ឈ្មោះល្បីខ្ចរខ្ចាយ គួរឱ្យសរសើរ ។
- បុគ្គល (ន) : ចិត្ត វិញ្ញាណ រាងកាយ ខ្លួនប្រាណ សត្វលោកទូទៅទាំងអស់ដែលមានចិត្ត មានវិញ្ញាណ បុគ្គលប្រុសស្រី ។
- រុងរោចន៍ (គុ) : ដែលរុងរឿងថ្លៃថ្លា ភ្លឺចិញ្ចែងចិញ្ចាច ។
- ថ្កុំថ្កើង (គុ) : ដែលខ្ពង់ខ្ពស់ឧត្តុង្គឧត្តមមានយសបរិវារ មានគេចុះចូលរាប់អានច្រើន ។
- កច្ចាយនបូបត្តម្ភក: (ន-បា) : ឈ្មោះក្បួនវេយ្យាករណ៍មួយប្រភេទយកតាមនាមព្រះមហាថេរមួយព្រះអង្គជាអ្នកតាក់តែងក្បួនវេយ្យាករណ៍បាលីសម័យដើម ។ ក្បួនវេយ្យាករណ៍នេះរៀបរៀងឡើងដោយព្រះសម្តេចសុមេធាធិបតី ជួន ណាត កាលដែលសម្តេចមានសមណស័ក្តិជាព្រះគ្រូសង្ឃសត្តា ។
- សាមណេរវិន័យ (ន) : ក្បួនវិន័យសម្រាប់បព្វជិត អ្នកបួស (លោកនេន)ប្រតិបត្តិតាម ។
- បាដិមោក្ខ (បា-សំ) : ឈ្មោះបាលីពុទ្ធប្បញ្ញត្តិដែលជាសិក្ខាបទមួយៗសម្រាប់ភិក្ខុ (លោកភិក្ខុ) *ឧទាហរណ៍* សម្តែងបាដិមោក្ខ ។
- រាជបរិពារ (ន.បា-សំ) : អ្នកបម្រើឬអ្នកសែហាមស្តេច ។
- អនាថា (គុ) : ដែលកំព្រាគ្មានទីពឹង ។
- កន្ទៀត (ន) : ជនៃ ក្រៅពីសាច់ញាតិ ... ។
- សេវកាមាត្យ (ន) : មន្ត្រីអ្នកគាល់បម្រើព្រះរាជាឬរាជការជិតព្រះរាជា ។
- សាធុជន (ន) : ជនទាំងឡាយ ជនដ៏ប្រពៃ ... ។

២. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទ "ឧត្តមគតិបុគ្គលសំខាន់" ខាងក្រោមនេះ អ្នកគប្បីអានដោយយកចិត្តទុកដាក់ដើម្បីត្រៀមឆ្លើយនឹងសំណួរមួយចំនួនដូចជា ទម្រង់ និងធាតុសំខាន់ៗនៃអត្ថបទណែនាំ ហើយឆ្លើយនឹងសំណួរពង្រីកការយល់ដឹង ដើម្បីយល់ន័យនៃអត្ថបទ គំនិតសំខាន់ និងតម្លៃអប់រំក្នុងអត្ថបទឱ្យបានត្រឹមត្រូវ ។

គ. អត្ថបទ

១. សម្តេចព្រះសង្ឃរាជ ជួន ណាត ទ្រង់ប្រសូតនៅថ្ងៃ អង្គារ ១១ រោជ ខែ ផល្គុន ឆ្នាំ រកា ឆស័ក ពុទ្ធសករាជ ២៤២៧ ត្រូវនឹងថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៨៨៣ នៅភូមិកំរៀង សង្កាត់រកាកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។ អាស្រ័យដោយសេចក្តីព្យាយាមដ៏មោះមុត ការសិក្សារបស់ព្រះអង្គចេះតែមានវឌ្ឍនភាពជឿនលឿនជានិច្ចរហូតព្រះអង្គក្លាយជាមហាបណ្ឌិតដឹកនាំពុទ្ធបរិស័ទនិងជាអ្នកប្រាជ្ញចម្បងផ្នែកអក្សរសាស្ត្រក្នុងព្រះរាជាណាចក្រកម្ពុជា។ ស្នាព្រះហស្តដែលព្រះអង្គបានព្រះរាជនិពន្ធមានដូចជា វចនានុក្រម កច្ចាយនបូបត្ថម្ភកៈ គហិបដិបត្តិ សាមណេរវិន័យ អត្ថបទជាច្រើនក្នុងទស្សនាវដ្តីកម្ពុជសុរិយាដូចជា បាដិមោក្ខសង្ខេប កាព្យលោកធម៌ និងឯកសារជទៃទៀតជាច្រើន។ ដោយព្រះគុណសម្បត្តិនិងព្រះសមត្ថភាពដ៏កំពូលខាងវិស័យអក្សរសាស្ត្រនេះហើយទើបសម្តេចបានឡើងជាបណ្ឌិតអក្សរសាស្ត្រនៅថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ១៩៦៧។

(សង្ខេបពីស្នាព្រះហស្តចុងក្រោយរបស់ព្រះសុមេធាធិបតី ជួន ណាត)

២. ព្រះនាងឥន្ទ្រទេវីត្រូវបានព្រះបាទជ័យវរ្ម័នទី ៧ សព្វព្រះរាជហឫទ័យ ហើយរៀបអភិសេកជាអគ្គមហេសីរបស់ព្រះអង្គ។ ព្រះនាងទ្រង់ជំរុញវិស័យសិល្បៈ អក្សរសាស្ត្រ វប្បធម៌ជាតិឱ្យមានសន្ទុះរីកចម្រើនជឿនលឿនយ៉ាងខ្លាំងក្លានាសម័យនោះព្រមទាំងបង្កើតឱ្យមានសាលាបាលីជាន់ខ្ពស់ទៀតផង។ ព្រះនាងត្រូវបានព្រះរាជាតែងតាំងជាសាកលវិទ្យាធិការនៅសាកលវិទ្យាល័យមួយឈ្មោះ "ទិលកគុត្តរៈ" ហើយព្រះនាងបង្ហាត់បង្រៀនស្ត្រីខ្មែរ រាជបរិវារអំពីវិជ្ជាខាងព្រះពុទ្ធសាសនានៅក្នុងវត្តមួយឈ្មោះ នរេន្ទ្រាស្រម។ ទន្ទឹមនឹងនេះ ព្រះនាងទ្រង់ព្រះរាជនិពន្ធកាព្យ ភាសាសំស្ក្រឹតជាច្រើន។ ស្នាព្រះហស្តរបស់ព្រះនាងត្រូវបានសិល្បករនាសម័យនោះចារឹកទុកលើផ្ទាំងថ្មមួយក្នុងប្រាសាទភិមានអាកាសរួមទាំងអស់មាន ១០២វគ្គ។ ក្រៅពីព្រះរាជកិច្ចតែងនិពន្ធ ព្រះនាងតែងមានសទ្ធាជ្រះថ្លាក្នុងការបំពេញកុសលធម៌និងបុណ្យទានផ្សេងៗតាមលក្ខណៈព្រះពុទ្ធសាសនា។ ក្នុងកុសលកម្មទាំងនេះ គេអាចរាប់បានដូចជាការបង្កើតមន្ទីរសង្គ្រោះដែលប្រមូលផ្តុំក្មេងស្រីអនាថា ការធ្វើអំណោយទាន ការកសាងបដិមាមួយចំនួននៃរាជវង្ស ... ។

(ប្រវត្តិអក្សរសាស្ត្រខ្មែរ លាងហាប់អាន ១៩៦៧)

៣. ឧត្តមគតិរបស់អតីតព្រះមហាក្សត្រខ្មែររាជវង្សស្រីមារៈ បានចារទុកលើផ្ទាំងសិលាចារឹកនៃប្រាសាទវ៉ូកាញ់ បង្ហាញពីទឹកព្រះទ័យសន្តោសប្រោសប្រណីប្រកបដោយព្រហ្មវិហារធម៌ថា "កាលបើកូនខ្ញុំក្តី បងប្អូនខ្ញុំក្តីមិនមែនអ្នកកន្ទៀតទេ បានសម្រេចបំណងខ្លួនហើយ (បានសោយរាជ្យតទៅ) ខ្ញុំសូមឱ្យកសម្បត្តិខ្ញុំទាំងអស់ ប្រាក់មាស សង្ហារិមក្តី អសង្ហារិមក្តី ទៅប្រើជាវត្ថុសម្រាប់ជាទីរីករាយនិងជាប្រយោជន៍ដល់សត្វលោកទាំងឡាយ។ នេះជាសេចក្តីបញ្ជារបស់ខ្ញុំ។ សូមព្រះរាជាទាំងឡាយ

នៅក្នុងអនាគតប្រតិបត្តិតាមព្រះរាជបញ្ជាខ្ញុំនេះកុំបីខាន ។ ហើយចូរប្រឹក្សាជាមួយសេវកាមាត្យឈ្មោះ វីរ ...របស់ខ្ញុំ" ។

(ដកស្រង់ពីសិក្ខាប្រវត្តិអក្សរសាស្ត្រខ្មែរលាងហាប់អានសម័យនគរភ្នំដល់សម័យឧត្តុង្គសតវត្សរ៍ទី ១-១៨៥៩)

៤. ព្រះភិក្ខុវិរយបណ្ឌិតគោប៉ាងខាត់ បានប្រែសៀវភៅស្រីហិតោបទេសរបស់កវីនារាយណ បណ្ឌិតពីភាសាសំស្ក្រឹត មកជាភាសាខ្មែរដែលយើងទាំងអស់គ្នាបានចាត់ទុកជាសម្បត្តិទិព្វ វិសេស សម្រាប់ជនជាតិខ្មែរ ។ ឧត្តមគតិដ៏ថ្លៃថ្លានៅក្នុងបទនីមួយៗនៃសៀវភៅស្រីហិតោបទេសចាត់ទុកជាក្បួន ច្បាប់ទូន្មានដល់សាធុជនទាំងឡាយឱ្យប្រកាន់នូវសីលធម៌ ច្បាប់បុរាណនឹងមានប្រាជ្ញាចេះដោះស្រាយ បញ្ហាប្រកបដោយសន្តិវិធី ។ "មនុស្សរឹងរូសវិនាសយស មនុស្សមានចិត្តមិនស្មើគ្នា បាត់មិត្តភាព មនុស្សវិកលឥន្ទ្រិយមិនមានត្រកូល មនុស្សល្មោភមិនមានធម៌ មនុស្សធ្វើសេចក្តីអន្តរាយខាតផលវិជ្ជា មនុស្សកំណាញ់វិនាសសេចក្តី ឯព្រះនរាធិបតីមានតែអាមាត្យខ្ជែបខ្ជបស្រឹង លាភយស វិនាសរាជ្យ" ។

(ស្រីហិតោបទេសភាគទី ២ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥៣៨)

៥. បុគ្គលសំខាន់ៗក្នុងលោកដូចជា ម៉ាទិនឡូធើរ ប្រើវេលាក្នុងនាកជីវិត និពន្ធសៀវភៅដល់ទៅ ៤៤៥ រឿង ថែមទាំងបង្កើតលទ្ធិនិកាយប្រូតេស្តង់ទៀតផង ។ ត្បុកអះ វេល្លិងតិន បុគ្គលសំខាន់របស់អង់គ្លេស ធ្លាប់ច្បាំងឈ្នះណាប៉ូឡេអុង ប៉ូណាប៉ាតនៅទូលូ ក៏ដោយសារសេចក្តីព្យាយាមខ្ពះខ្ពែងតស៊ូធ្វើការងារជាអតិបរមា ។ មានសៀវភៅជាច្រើនដែលលោកបាននិពន្ធតាំងតែពីអាយុ ១៣ឆ្នាំ ។ សៀវភៅទាំងនោះបានរក្សាទុកក្នុងសារមន្ទីរជាតិរហូតមកដល់សព្វថ្ងៃនេះ ។

នេះបញ្ជាក់ឱ្យយើងឃើញច្បាស់ថា មនុស្សដែលមានសេចក្តីសម្រេចយ៉ាងមហាសាលក្នុងនាកជីវិតរបស់ខ្លួននោះ សុទ្ធតែជាមនុស្សធ្វើការងារយ៉ាងជោកជាំ ហ៊ានពុះពារឧបសគ្គគ្រប់យ៉ាងនិងជាអតិបរមា ។

៦. លោកស៊ីវិលទ័រស្កត់ អ្នកនិពន្ធជាតិអង់គ្លេសតែងប្រកាន់ទស្សនៈ "កុំនៅស្ងៀមដោយមិនបានធ្វើអ្វី" ។ រូប៊ឺតស័ន អ្នកប្រាជ្ញពង្សាវតារល្បីឈ្មោះក៏ប្រកាន់ទស្សនៈ "កុំនៅស្ងៀមដោយមិនបានរៀនអ្វី" ។ វ៉ុលទែរអ្នកប្រាជ្ញជនជាតិបារាំង ក៏មានទស្សនៈសម្រាប់ខ្លួនគេថា "តោងនៅនឹងការងារជាដរាប" ។

សំណួរ

១. តាមរយៈអត្ថបទនេះ តើមានបុគ្គលសំខាន់ៗណាខ្លះ ?

២. ចូរបង្ហាញពីឧត្តមគតិរបស់ព្រះនាងឥន្ទ្រទេវីតាមរយៈអត្ថបទនេះ ។

៣. តើអតីតព្រះមហាក្សត្រខ្មែររាជវង្សស្រីមារៈ មានឧត្តមគតិដូចម្តេចដែរ ?

៤. ចូរពន្យល់ "មនុស្សរឹងរូសវិនាសយស" ឱ្យបានក្បោះក្បាយ ។

អាលីយូស្សា



ក. សិក្សាពាក្យគន្លឹះ

- កន្លៀត (ន) : កៀនកំបាំង ទីចង្អៀតកៀនកោះ ។
- រន្ធាន់ (ន) : ដែលមានអាការៈញាប់ខ្ជាប់ ។

ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទខាងក្រោមនេះ អ្នកគប្បីអានដោយយកចិត្តទុកដាក់ដើម្បីត្រៀមឆ្លើយសំណួរមួយចំនួនទាក់ទងខ្លឹមសារអត្ថបទ វត្ថុបំណងនៃអត្ថបទ គំនិតសំខាន់ និងតម្លៃអប់រំនៃអត្ថបទឱ្យបានត្រឹមត្រូវ ។

គ. អត្ថបទ

ម៉ាកស៊ីមគ័រគី (MAXIM GORKI) ជាអ្នកនិពន្ធដ៏ល្បីល្បាញម្នាក់នៅលើសកលលោក ។

កាលពីកុមារភាព លោកមានឈ្មោះថា **អាលីយូស្សា ប៉េស្កូវ** ជាកុមារកំព្រាឪពុក ។ ម្តាយរបស់**អាលីយូស្សា**បានយកស្វាមីមួយទៀត ។ ចំណែកអាលីយូស្សាក៏បានទៅរស់នៅជាមួយជីដូនជីតាខាងម្តាយរបស់ខ្លួន ។ ប៉ុន្តែ ជីដូនជីតា**អាលីយូស្សា** មានជីវភាពខ្វះខាត ពុំអាចធានាចិញ្ចឹមថៅបាន ក៏ស្វែងរកការងារឱ្យអាលីយូស្សាធ្វើដើម្បីចិញ្ចឹមជីវិត ។

កាលនោះ អាលីយូស្សាបានទៅបម្រើស្ត្រីម្នាក់ឈ្មោះម៉ុកទ្រីយោណា ដើម្បីរៀនជាមួយកូនប្រុសរបស់ស្ត្រីនោះ។ អាលីយូស្សា ត្រូវបំពេញការងារយ៉ាងយ៉ាប់យ៉ឺនបំផុត ហើយត្រូវម្ចាស់ផ្ទះទាំងអស់ស្តីបន្ទោសឥតឈប់ឈរ។ ទោះជាយ៉ាងណាក៏ដោយ ក៏អាលីយូស្សានៅតែចូលចិត្តអានសៀវភៅជានិច្ច។

ថ្ងៃមួយនៅពេលដែលអាលីយូស្សា កំពុងរត់លេងចុះឡើង នៅច្រកជណ្តើរដ៏ងងឹតតែម្នាក់ឯង ស្រាប់តែអាលីយូស្សា ឮសូរសំឡេងក្អេងយំ។ សំឡេងនេះ ជាសំឡេងរបស់កុមារីម្នាក់ ឈរយំនៅលើកាំជណ្តើរដោយវង្វេងផ្លូវ។ អាលីយូស្សាស្គាល់ច្បាស់កុមារីនោះថា ជាកូនរបស់គ្រួសារមួយជួលផ្ទះនៅអគារខាងក្រោម។ អាលីយូស្សាក៏បាននាំកុមារីទៅជូនម្តាយរបស់នាងវិញ ដោយរៀបរាប់តាមដំណើររឿង។ ម្តាយកុមារីស្តាប់ហើយសម្លឹងមុខអាលីយូស្សា ដោយយកចិត្តទុកដាក់ រួចថ្លែងអំណរគុណដល់អាលីយូស្សាដោយវាចាថា ៖ "អ៊ំអរគុណក្មួយប្រុសណាស់ តើអ៊ំបានអ្វីសងគុណក្មួយហ៎ ?
អាលីយូស្សាឆ្លើយ ៖ " ក្មួយមិនចង់បានអ្វីពីអ៊ំស្រីទេ ប៉ុន្តែបើអ៊ំស្រីមានសៀវភៅឱ្យក្មួយខ្ចីអាននោះ ក្មួយត្រេកអរណាស់ហើយ"។

អ៊ំស្រីឮដូចនេះ ញញឹមបន្តិច រួចក៏ដើរចូលទៅយកសៀវភៅមួយហុចទៅឱ្យអាលីយូស្សា។

អាលីយូស្សាសប្បាយចិត្តណាស់ បើកទំព័រដំបូងអានភ្លាមឃើញ "ផ្ទះសំបែងក៏ដូចជាមនុស្ស អ្វីៗក៏មានភាពខាងក្រៅផ្សេងរបស់វា" ល្បះនេះត្រូវណាស់ ធ្វើឱ្យអាលីយូស្សាភាំងស្មារតី។

យប់នោះនៅពេលដែលម្ចាស់ផ្ទះទាំងអស់ទៅសូត្រធម៌នៅព្រះវិហារអាលីយូស្សាយកសៀវភៅទៅអង្គុយអានក្បែរចង្កៀនយ៉ាងជក់ចិត្ត ដិតអារម្មណ៍ភ្លេចអស់អ្វីៗដែលនៅជុំវិញវា។ មួយរំពេចនោះ ស្រាប់តែកុមារភ្ញាក់ព្រើត ដោយឮសូរកណ្តឹងរោទ៍យ៉ាងរន្ធាន់នៅមាត់ទ្វារ។ អាលីយូស្សាភ័យញញឹញញ័រ រត់ចុះឡើងរកកន្លែងលាក់សៀវភៅ ហើយក៏ប្រញាប់ប្រញាល់រត់ទៅបើកទ្វារ។ ក្រោយពេលដែលមនុស្សម្នាក្នុងផ្ទះចូលដំណេកស្ងាត់អស់អាលីយូស្សា ក្រោកដើរលបៗ ទៅយកសៀវភៅដែលខ្លួនលាក់ទុកនៅកន្លៀតចង្កៀន បម្រុងអានបន្តនៅក្បែរបង្អួច ក្រោមពន្លឺព្រះចន្ទ។ ប៉ុន្តែ អក្សរនៅក្នុងសៀវភៅតូចៗពេក អាលីយូស្សា ពុំអាចមើលឃើញទេ។ ចិត្តកុមារសែនអន្ទះអន្ទែងពុះកញ្ជ្រោលចង់អានសៀវភៅបន្ត ... តើត្រូវធ្វើដូចម្តេច ? អាលីយូស្សាគិតមួយសន្ទុះ ក៏ទៅយកបន្ទះស្លាន់មួយមកសាកល្បងបញ្ចាំងពន្លឺដាក់សៀវភៅ តែវិតតែពិបាកអានជាងមុន។ ដូចនេះ អាលីយូស្សាត្រូវឡើងឈរលើកៅអី ផ្អែកខ្លួនទៅនឹងជញ្ជាំងខំជំនះអាន ... អានរហូតទន់ត្របកភ្នែក អង្គុយចុះ ហើយដេកលក់នៅលើកៅអី។

ព្រឹកស្អែកឡើងម្ចាស់ផ្ទះសួរអាលីយូស្សាថា ៖

- ឯងបានសៀវភៅនេះពីណាមក ?

- បាទ! ជាសៀវភៅរបស់ព្រះសង្ឃ "កុមារឆ្លើយដោយភ័យ" ។

ឮដូចនេះ ទាំងអស់គ្នាក៏ដើរចេញ ហើយអាលីយូស្សាក៏បានរួចខ្លួន ។ ទីបំផុតកុមារក៏បង្ខំចិត្តយកសៀវភៅទៅសងម្ចាស់គេវិញ ។ ម្ចាស់សៀវភៅពុំបានដឹងទេថា សៀវភៅមើលរបស់ខ្លួនមានខ្លឹមសារល្អ និងមានតម្លៃដូចនេះផង ។

ក្រោយៗមក អាលីយូស្សាតែងតែឆ្លៀតជួលសៀវភៅផ្សេងៗទៀតមើល នៅរាល់ពេលដែលកុមារទៅទិញនំប៉័ងឱ្យម្ចាស់ផ្ទះហូបពេលព្រឹក ។

ថ្ងៃអាទិត្យមួយ ពេលម្ចាស់ផ្ទះទៅធ្វើបុណ្យ អាលីយូស្សាដាក់ដាំទឹកតាមបង្គាប់របស់ម្ចាស់ផ្ទះរួចចូលទៅអានសៀវភៅនៅក្នុងបន្ទប់ ។ មួយសន្ទុះក្រោយមក ស្រាប់តែឮសូរផ្ទុះយ៉ាងខ្លាំងខុសធម្មតា ។ អាលីយូស្សាស្ទុះប្រញាប់ប្រញាល់ទៅផ្ទះបាយ ។ កុមារភិតភ័យយ៉ាងខ្លាំង ដោយឃើញកំសៀវទឹកផ្ទុះខូច ។ ពេលជាមួយគ្នានោះ ម្ចាស់ផ្ទះក៏ត្រឡប់មកដល់វិញល្មម ។ ស្ត្រីម្ចាស់ផ្ទះខឹងណាស់ស្តីបន្ទោសហើយកន្ត្រាក់អុសមួយយ៉ាងធំវាយវាត់ទៅលើខ្នងកុមារ ។ អាលីយូស្សាត្រូវមាត់យ៉ាងខ្លាំងនិងរងរបួសយ៉ាងដំណាំ ។ យប់នោះខ្នងរបស់អាលីយូស្សាហើមពុរ កុមារដេកថ្ងូររហ៊ឺ ។ ស្អែកឡើង ថ្ងៃត្រង់ទើបម្ចាស់ផ្ទះប្រុសដឹកកុមារទៅមន្ទីរពេទ្យ ។

ក្រោយពីពិនិត្យជំងឺកុមាររួច លោកគ្រូពេទ្យនិយាយដោយម៉ឺងម៉ាត់ថា មុនដំបូងត្រូវធ្វើកំណត់ហេតុ ស្តីពីការធ្វើទុក្ខទោសកុមារនេះសិន រួចលោកគ្រូពេទ្យបែរមកសួរកុមារ "តើក្មួយមានបំណងប្តឹងផ្តល់អ្វីទេ ?"

អាលីយូស្សាពើតផ្សាពេញទាំងខ្លួន ប៉ុន្តែកុមារឆ្លើយដោយទន់ភ្លន់ថា ក្មួយមិនរកឿងអ្វីទេ សូមតែលោកអំជួយព្យាបាលរបួសក្មួយឱ្យឆាប់ជាបានហើយ ។

លោកគ្រូពេទ្យបញ្ជូនកុមារទៅបន្ទប់មួយផ្សេងទៀត រួចដាក់កុមារឱ្យដេកពោបនៅលើតុមួយ ។ លោកគ្រូពេទ្យយកចន្ទាសតូចមួយ ដកកម្ទេចឈើដែលនៅជាប់និងខ្នងកុមាររួចនិយាយថា ៖ "កម្ទេចឈើចំនួន ៤២ បានដកចេញពីខ្នងក្មួយអស់ហើយ! ស្អែកនេះក្មួយត្រឡប់មកមន្ទីរពេទ្យម្តងទៀតដើម្បីលាងរុំរបួសសាជាថ្មី" ។

លោកគ្រូពេទ្យនាំអាលីយូស្សា ទៅជួបនឹងម្ចាស់ផ្ទះប្រុស រួចពោលថា ៖ "ខ្ញុំសុំប្រគល់កុមាររងគ្រោះនេះទៅលោកវិញ នេះចាត់ទុកជាភ័ព្វសំណាងរបស់លោកហើយដែលកុមារនេះមានចិត្តធម៌មិនរកឿងហេតុប្តឹងផ្តល់តបនឹងលោកវិញ" ។

នៅពេលត្រឡប់មកដល់ផ្ទះវិញ សមាជិកក្នុងគ្រួសារទាំងអស់រាក់ទាក់ទទួលកុមារ ដូចជាក្នុងពិធីបុណ្យខួបកំណើតរបស់អាលីយូស្សា ។

ស្ត្រីទាំងពីរនាក់ សុំឱ្យកុមារនិយាយរៀបរាប់ឡើងវិញតាមសម្តីរបស់គ្រូពេទ្យដែលបានព្យាបាលកុមារ ។ ទាំងអស់គ្នាអង្គុយស្តាប់ដោយយកចិត្តទុកដាក់ហើយលាន់មាត់គ្រប់ៗគ្នាពីការអត់ធ្មត់ និងចិត្តល្អរបស់**អាលីយូស្សា**ចំពោះគ្រួសារគេ ។

អាលីយូស្សាឃើញម្ចាស់ផ្ទះទាំងអស់ពេញចិត្តនឹងខ្លួន ដែលពុំប្តឹងផ្តល់អ្វីក៏ឆ្លៀតឱកាសសុំច្បាប់ពីម្ចាស់ផ្ទះ អានសៀវភៅ នៅពេលសម្រាកពីការងារ ។ គ្មាននរណាម្នា ក់ហ៊ានប្រឆាំងនឹងសំណូមពររបស់កុមារឡើយ លើកលែងតែស្ត្រីចាស់ជាម្ចាស់ផ្ទះដែលភ្ញាក់ផ្អើល ហើយស្រែកឡើង ៖

- អាឯងនេះចំជាចង្រៃមែន !

បុរសម្ចាស់ផ្ទះញញឹម រួចពោល ៖

- ក្មួយឯងចំជាក្មេងមានឧន្តីអំណាត់អត់ធន់មែន ក្មួយនឹងក្លាយទៅជាមនុស្សល្អនៅពេលអនាគតដែលយើងមិនអាចដឹងបាន ។

សំណួរ

១. តើអាលីយូស្សាបានធ្វើអ្វី ទើបទទួលបានសៀវភៅ ? តើអាលីយូស្សាមានអារម្មណ៍ដូចម្តេចចំពោះសៀវភៅនោះ?

២. ហេតុអ្វីបានជាគេធ្វើទារុណកម្មក្មេងនេះ ? តើអ្នកយល់ដូចម្តេច ចំពោះទារុណកម្មបែបនេះ ? ចូររកអំណះអំណាងគាំទ្រគំនិតរបស់អ្នក ។

៣. តើនៅទីបញ្ចប់អាលីយូស្សាបានទទួលលទ្ធផលដូចម្តេចខ្លះ ?

៤. ចូរអ្នកបង្ហាញតម្លៃអប់រំរបស់អត្ថបទ ។

៥. តើល្បះខាងក្រោមនេះបង្ហាញអារម្មណ៍របស់តួអង្គអាលីយូស្សាដូចម្តេចខ្លះ ? "មួយសន្ទុះក្រោយមកស្រាប់តែឮសូរផ្ទុះយ៉ាងខ្លាំងខុសធម្មតា ។ អាលីយូស្សាស្ទុះប្រញាប់ប្រញាល់ទៅផ្ទះបាយ ។ កុមារភិតភ័យយ៉ាងខ្លាំង ដោយឃើញកំសៀវទឹកផ្ទុះខូច" ។

ការមិនលះបង់សេចក្តីព្យាយាម



នៅពេលប្អូនស្តាប់អត្ថបទ "ការមិនលះបង់សេចក្តីព្យាយាម" ដែលលោកគ្រូ អ្នកគ្រូរបស់ប្អូន នឹងអានឱ្យស្តាប់ ចូរប្អូនស្តាប់ដោយយកចិត្តទុកដាក់ដើម្បីត្រៀមឆ្លើយសំណួរមួយចំនួនដូចខាងក្រោម ៖

សំណួរ

១. តើអត្ថបទនេះនិយាយពីអ្វី ?

២. ហេតុអ្វីត្រូវមានសេចក្តីព្យាយាម ?

៣. តើសេចក្តីព្យាយាមមានប្រយោជន៍អ្វីខ្លះដល់មនុស្ស ?

៤. តើការមិនលះបង់សេចក្តីព្យាយាមបានណែនាំអ្នកឱ្យធ្វើអ្វីខ្លះ ? មិនឱ្យធ្វើអ្វីខ្លះ ?

៥. តើអ្នកអាចវាយតម្លៃលើភាពច្បាស់លាស់នៃអត្ថបទបានយ៉ាងដូចម្តេចខ្លះ ?

៦. ចូរអ្នកឡើងបង្ហាញដោយសង្ខេបនូវអត្ថន័យនៃអត្ថបទណែនាំ ដែលអ្នកបានស្តាប់ដោយប្រើប្រាស់សំឡេងនិងល្បឿនក្នុងការនិយាយបានត្រឹមត្រូវ ។

ការបង្ហាញពីការណែនាំមួយ

ការបង្ហាញពីការណែនាំមួយ គឺជាការនិយាយណែនាំឱ្យអ្នកដទៃស្គាល់ ដឹង មើលឃើញ ធ្វើបាន... ប្រកបដោយលក្ខណៈច្បាស់លាស់ ត្រឹមត្រូវ និងមានលំដាប់លំដោយ។ ការបង្ហាញដែលមានលក្ខណៈច្បាស់លាស់និងមានលំដាប់លំដោយល្អលុះត្រាតែ អ្នកបង្ហាញរៀបរាប់បញ្ជាក់ឱ្យបានច្បាស់លាស់ពីចំណុចចាប់ផ្តើម ចំណុចបន្តបន្ទាប់ រហូតដល់ចំណុចបញ្ចប់ដោយប្រើពាក្យប្រាប់លំដាប់បានត្រឹមត្រូវ។

ដូចម្តេចដែលហៅថា ពាក្យប្រាប់លំដាប់? ពាក្យប្រាប់លំដាប់ ជាពាក្យសម្រាប់បញ្ជាក់តំណាក់នៃលំនាំសកម្មភាពធ្វើអ្វីមួយ តាមលំដាប់លំដោយពីការចាប់ផ្តើមរហូតដល់ទីបញ្ចប់។

ពាក្យប្រាប់លំដាប់មានដូចជា

- ការចាប់ផ្តើម : មុនដំបូង ជាបឋម ជាដំបូង ចំណុចចាប់ផ្តើម មុនគេបង្អស់... ។
- ដំណើរការ : បន្ទាប់មក ជាបន្ត បន្ទាប់មកទៀត ជាបន្តទៅទៀត ជាបន្តទៅនេះ ក្រោយមក ក្រោយមកទៀត បន្តិចក្រោយមក ខាងក្រោមនេះ បន្តិចទៀតនេះ... ។
- ការបញ្ចប់ : ទីបំផុត ចុងក្រោយ ជាទីបញ្ចប់ ចុងបញ្ចប់... ។

ខាងក្រោយនេះ ជាការណែនាំគំរូមួយ ស្តីពីលំនាំនៃការលេងល្បែងប្រជាប្រិយខ្មែរមួយ គឺ ល្បែងគ្រុបមាន់។

ល្បែងគ្រុបមាន់

ក. ស្ថានភាពនិងពេលវេលា

ល្បែងគ្រុបមាន់ ជាល្បែងប្រជាប្រិយមួយប្រភេទរបស់ខ្មែរយើងតាំងពីយូរលង់ណាស់មកហើយ។ ពីបុរាណ ល្បែងនេះ ជាល្បែងកម្សាន្តមួយប្រភេទ ដែលកុមារ ឬក្មេងជំទង់ៗតាមភូមិ ស្រុក តែងលេងនៅពេលទំនេរពីការងារនាវេលាយប់ខែភ្លឺ។

លំនាំនៃការលេងល្បែងគ្រុបមាន់មានដូចខាងក្រោម

ខ. ការជ្រើសរើសមនុស្សសម្រាប់លេង

ដំបូងគេត្រូវប្រមូលគ្នីគ្នាសម្រាប់លេង មានស្រី មានប្រុសយ៉ាងហោចណាស់ឱ្យបានគ្នាចំនួនពី ១០នាក់ឡើងទៅ គឺក្រុមប្រុសៗ ៥នាក់ ក្រុមស្រីៗ ៥នាក់។

គ. របៀបលេង

បន្ទាប់ពីប្រមូលគ្នាមានប្រុសស្រីបានគ្រប់ចំនួនហើយ គេក៏ចាប់ផ្តើមលេងដោយក្រុមប្រុសៗជ្រើសរើសគ្នាគេម្នាក់ឱ្យធ្វើជាមាន់ ចំណែកក្រុមស្រីៗក៏ជ្រើសរើសមាន់ដូចក្រុមប្រុសៗដែរ។ បន្ទាប់មក គេឱ្យមាន់ទាំងពីរក្រាបបែរក្បាលរកគ្នា រួចយកកំណាត់សំពត់ ឬក្រមាមកគ្របឱ្យជិតខ្លួនតាំងពីក្បាលដល់ចុងជើង។ ចំណែកឯសមាជិកដទៃទៀតសម្ងំលាក់ខ្លួនក្បែរនោះ។ បន្ទាប់មកទៀត ក្រុមប្រុសៗចាត់តំណាងម្នាក់ទៅគោះខ្នងមាន់ខាងស្រីឱ្យរងាវ។ មាន់ខាងស្រីរងាវ "កិកកិកែកឹត" ឡើងដោយខំធ្វើសំឡេងឱ្យខុសពីធម្មតាចៀសវាងកុំឱ្យខាងប្រុសទាយសំឡេងត្រូវ។ ករណីអ្នកគោះខ្នងមាន់ស្តាប់សំឡេងមាន់មិនទាន់បាន គេអនុញ្ញាតឱ្យគោះខ្នងមាន់ម្តងទៀត ប៉ុន្តែបានតែបីដងប៉ុណ្ណោះ។ ចំណែកក្រុមស្រីៗក៏ធ្វើសកម្មភាពដូចក្រុមប្រុសៗដែរ។ កាលណាគេទាយតាមសំឡេងចំឈ្មោះមនុស្សប្រុស ឬស្រីដែលគេស្គាល់បានត្រឹមត្រូវ គេត្រូវយកមាន់នោះមកទុកជារបស់ក្រុមគេ។ ប៉ុន្តែ បើក្រុមម្ខាងទៀតទាយសំឡេងមាន់ត្រូវវិញនោះ គេអាចសងមាន់នោះមកក្រុមដើមវិញ។ គេធ្វើរបៀបនេះរហូតដល់ក្រុមនីមួយៗមានការខាតបង់ ឬការទទួលបានមាន់ច្រើន ឬក៏អស់មាន់ពីក្រុមខ្លួន។

ឃ. ការកំណត់អ្នកឈ្នះ ឬចាញ់

ចុងបញ្ចប់នៃល្បែងនេះ គឺការកំណត់អ្នកចាញ់និងអ្នកឈ្នះ។ ការកំណត់ចាញ់ ឈ្នះអាស្រ័យទៅលើការទាយសំឡេងមាន់របស់ក្រុមម្ខាងៗ។ បើក្រុមណាទាយត្រូវច្រើន គឺបានមាន់ច្រើននឹងត្រូវចាត់ជាអ្នកឈ្នះ។ ចំណែក ក្រុមដែលទាយមាន់ត្រូវតិច ត្រូវបង់ខាតមាន់ច្រើន ឬអស់មាន់ត្រូវចាត់ទុកជាអ្នកចាញ់។ ក្រោយពីកំណត់បានអ្នកឈ្នះ និងអ្នកចាញ់រួចហើយ គេក៏ចាប់ផ្តើមលេងសាជាថ្មីឡើងវិញ រហូតពេលឈប់លេង។

ង. សារប្រយោជន៍

ក្រៅពីការកម្សាន្តសប្បាយរបស់កុមារា កុមារី និងយុវវ័យ ល្បែងគ្របមាន់ជាល្បែងសម្រាប់ហ្វឹកហាត់បញ្ញា ស្មារតី គំនិត ការទស្សន៍ទាយសំឡេងធ្វើឱ្យមានភាពវាងវៃ និងជួយពង្រឹងបំណិនស្តាប់។

សំណួរ

១. តើគេច្រើនលេងល្បែងប្រជាប្រិយនេះនៅវេលាណា ?

២. តើគេត្រូវការមនុស្សប៉ុន្មាននាក់ក្នុងការលេងល្បែងនេះ ?

៣. ចូរបង្ហាញពីរបៀបលេងល្បែងគ្របមាន់នេះ ។

៤. តើគេកំណត់ការឈ្នះនិងចាញ់ដូចម្តេចខ្លះ ក្នុងការលេងល្បែងគ្របមាន់?

៥. តើបុព្វបុរសខ្មែរបង្កើតល្បែងនេះឡើងមានគុណប្រយោជន៍ដូចម្តេចខ្លះ ?

៦. តើគេបង្ហាញចំណុចអ្វីខ្លះ ក្នុងការលេងល្បែងគ្របមាន់ខាងលើ ?

លំហាត់

ចូរអ្នកឡើងបង្ហាញពីលំនាំនៃការលេងល្បែងប្រជាប្រិយខ្មែរមួយចំនួនដូចខាងក្រោម ៖

+ លាក់កន្សែង
+ ទាញព្រ័ត្រ
+ បាយខុម
+ ឈូង ។

ពេលឡើងបង្ហាញ អ្នកគប្បីបង្ហាញតាមលំដាប់លំដោយដូចខាងក្រោម :

១. ស្ថានភាពនិងពេលវេលា

- តើល្បែងនេះជាល្បែងដូចម្តេច ?
- តើគេច្រើនលេងល្បែងនេះនៅពេលណា ? វេលាណា ?

២. ការជ្រើសរើសមនុស្សសម្រាប់លេង

- តើល្បែងនេះត្រូវការមនុស្សប៉ុន្មាននាក់ ?
- តើគេបែងចែកជាក្រុម ឬពួកដែរឬទេ ? បើមានប៉ុន្មានក្រុម ?

៣. របៀបលេង

- តើគេលេងល្បែងនោះរបៀបណា ?
- តើគេចែកជាប៉ុន្មានសកម្មភាព ?

៤. ការកំណត់អ្នកឈ្នះ ឬចាញ់

- តើល្បែងនោះមានការកំណត់ចាញ់ ឈ្នះដែរឬទេ ?
- តើគេកំណត់ចាញ់និងឈ្នះដូចម្តេច ?
- បើគ្មានកំណត់ការចាញ់ឈ្នះ តើគេបញ្ចប់ល្បែងដូចម្តេច ?

៥. សារប្រយោជន៍

- តើល្បែងនេះមានប្រយោជន៍ដូចម្តេចខ្លះ ?

នៅពេលបង្ហាញ អ្នកគប្បីប្រើប្រាស់សម្ដីឱ្យបានសមរម្យ រៀបរាប់តាមលំដាប់លំដោយត្រឹមត្រូវ ដោយប្រើពាក្យប្រាប់លំដាប់បានត្រឹមត្រូវនិងច្បាស់លាស់ ។

មេរៀនទី

ជោគជ័យនៃជីវិត

ជោគជ័យនៃជីវិត គឺជាការឈ្នះ ជាការសម្រេចបំណង ឬជ័យជំនះលើឧបសគ្គទាំងឡាយក្នុងដំណើរជីវិតរស់នៅរបស់យើង។ ប៉ុន្តែការឈ្នះសម្រាប់ជីវិតរបស់មនុស្សម្នាក់ៗអាស្រ័យលើការតស៊ូព្យាយាមអំណត់អត់ធន់ មានមនសិការខ្ពង់ខ្ពស់ប្រកបដោយគុណធម៌ សីលធម៌ល្អប្រពៃរបស់មនុស្សនោះថែមទៀត។ ជោគជ័យមួយចំនួនក៏បានមកពីបទពិសោធន៍ពីភាពបរាជ័យខ្លះផងដែរ។ បរាជ័យក៏ជាបទពិសោធន៍មួយនៃជីវិត។ បទពិសោធន៍ក្នុងការរស់នៅរបស់មនុស្សជាឈ្នាន់សម្រាប់ឈានទៅរកជោគជ័យនៅទីបញ្ចប់។

ក្នុងមេរៀននេះ អ្នកនឹងសិក្សាពីអត្ថបទមួយចំនួនដែលបង្ហាញពីបទពិសោធន៍ជីវិតដ៏សម្បូរបែបដែលនាំទៅដល់ជោគជ័យ។ ទន្ទឹមនេះ អ្នកក៏សិក្សាផងដែរអំពីប្រភេទអត្ថបទកំណាព្យ ចំណាប់ចួនផ្ទួន រណ្តំ គំនិតសំខាន់បង្កប់និងគំនិតសំខាន់បង្ហាញត្រង់ ពង្រីកការយល់ដឹងអត្ថន័យកំណាព្យ ការសូត្រកំណាព្យ ការតែងកាព្យបទភុជង្គលីលា និងបទបន្ទោលកាក។

កំណាព្យបទភុជង្គលីលា

ក្នុងមេរៀនមុនអ្នកបានសិក្សារួចមកហើយ ពីកំណាព្យបទព្រហ្មគីតិ បទកាកគតិ បទបន្ទោលកាក បទពាក្យ ៧ បទពាក្យ ៨ បទពាក្យ ៩ និងបទពំនោល។

ឥឡូវនេះ អ្នកនឹងសិក្សាកំណាព្យបទថ្មីមួយទៀតគឺបទភុជង្គលីលា។ បទភុជង្គលីលាគឺជាកំណាព្យមួយប្រភេទដែលបុព្វបុរសអ្នកកវីនិពន្ធខ្មែរយើងបានបង្កើតឡើងសម្រាប់រៀបរាប់ពីដំណើរចរលីលា រៀបរាប់ពីព្រៃព្រឹក្សាឬសរសើរពីសម្រស់ធម្មជាតិរៀបរាប់ដំណើរកិច្ចការនានាជាដើម។ បទនេះមានន័យថា "នាគដើរ ឬដំណើរនាគ"។

បទភុជង្គលីលា មានធាតុនិងលក្ខណៈពិសេសៗខុសពីបទកំណាព្យដទៃទៀត ទាំងរង្វាស់កាព្យ ចំណាប់ចុងចួន ផ្ចួន រណ្តំ ចង្វាក់និងបរិយាកាស។

ចូរប្អូនអានអត្ថបទកាព្យខាងក្រោម ៖

[...]ធ្វើការផងណាច្រើនខំ ទោះត្បាញចាក់ដំ នាងខំឱ្យហើយ។
កុំទុកទៅមុខទៀតឡើយ ចាំថាបង្ហើយ កម្រណាស់ណា។
ទោះធ្វើហូលគោមព្រៃផ្តា ជាក់ត្បាញហើយណា បានស្រេចសឹមធ្វើ។
ធ្វើឱ្យកើតកេរ្តិ៍ប្រសើរ ហើយកុំឱ្យដើរ លេងផ្ទះគេណា។
ឱ្យស្ងួនខ្លឹមខ្លួនរក្សា នាងខំធ្វើការ ទាន់ខ្លួនក្រមុំ។
មានប្តីបានអ្វីជាខំ រវល់កូនយំ កម្រចេះឆ្លៀត។
ព្រួយចិត្តគំនិតចង្អៀត មួយហើយមួយទៀត យំទាតែឆី។
រឹងព្រួយទាំងមួយទាំងពីរ រកបានឱ្យស៊ី ទើបវាបាត់មាត់។
ទោះកាន់ការអ្វីឱ្យស្ទាត់ ហូលគោមគាតកាត់ អន្ទងត្បាញទៅ។
កុំទុកក្នុងស្មុកស្មួញនៅ ក្រែងដល់ឃ្លួរទៅ ខាតខូចអសារ។
ហៅកូនស្រីស្ងួនមាតា ចូរចាំរក្សា កុំភ្លេចស្មារតី។

(ដកស្រង់ពីច្បាប់ស្រីរបស់បណ្ឌិតម៉ឹន ម៉ៃ)

យើងឃើញថាបទភុជង្គលីលាមានធាតុនិងលក្ខណៈសំខាន់ៗខុសពីកំណាព្យបទដទៃទៀតដូចជា

ក. រង្វាស់កាព្យ

រង្វាស់កាព្យគឺជាការរាប់ចំនួនព្យាង្គដែលមាននៅក្នុងឃ្លានិងការរាប់ចំនួនឃ្លាដែលមាននៅក្នុងវគ្គនីមួយៗ។ បទភុជង្គលីលាមានរង្វាស់កាព្យ :

- ក្នុង ១វគ្គ មាន ៣ឃ្លោ
- ឃ្លោទី ១ មាន ៦ ព្យាង្គ
- ឃ្លោទី ២ មាន ៤ ព្យាង្គ
- ឃ្លោទី ៣ មាន ៤ ព្យាង្គ ។

ខ. ចំណាប់ចួន

បទភុជង្គលីលា មានចំណាប់ចួនដូចខាងក្រោម ៖

- ព្យាង្គទី ៦ នៃឃ្លោទី ១ ចួននឹងព្យាង្គទី ៤ នៃឃ្លោទី ២
- ព្យាង្គទី ៤ នៃឃ្លោទី ៣ ក្នុងវគ្គទី ១ ចួននឹងព្យាង្គទី ៦ នៃឃ្លោទី ១ ក្នុងវគ្គទី ២ និង-
  ព្យាង្គទី ៤ នៃឃ្លោទី ២ ក្នុងវគ្គទី ២ ។
- តំនូសតាង



- សញ្ញាចាប់ចុងចួន
  - ព្យាង្គទី ៦ ឃ្លោទី ១ ⟷ ព្យាង្គ ៤ ឃ្លោ ២
  - ព្យាង្គទី ៤ ឃ្លោ ៣ វគ្គទី ១ ⟷ ព្យាង្គទី ៦ ឃ្លោទី ១ វគ្គទី ២ ⟷ ព្យាង្គទី ៤ ឃ្លោទី ២
    ក្នុងវគ្គទី ២ ឬវគ្គបន្ត ។
- ចួនក្នុងវគ្គ
  - ព្យាង្គទី ៦ នៃឃ្លោទី ១ ចួននឹងព្យាង្គទី ៤ នៃឃ្លោទី ២ ។
- ចួនឆ្លងវគ្គ
  - ព្យាង្គទី ៤ នៃឃ្លោទី ៣ ក្នុងវគ្គទី ១ ចួននឹងព្យាង្គទី ៦ នៃឃ្លោទី ១ និងព្យាង្គទី ៤ នៃឃ្លោទី ២ ក្នុង
    វគ្គទី ២ ។

គ. ចង្វាក់

ចំពោះការសូត្រកំណាព្យបទនេះ គេត្រូវលើកដាក់សំឡេងតាមដំណើរចរលីលា(នាគ) ទន់ភ្លន់ទំនងដូចជានាគលូនដែរ ឬដំណើរដូចទឹករលកពេលមានខ្យល់ជំនោរ ។ ការសូត្រត្រូវទម្លាក់សំឡេងលើព្យាង្គទី ២ និងទី ៤ រៀងរាល់ឃ្លោ ។

ឃ. បរិយាកាស

បទភុជង្គលីលាមានលក្ខណៈទន់ភ្លន់ បុរាណប្រើបទនេះក្នុងពេលដែលមានដំណើរចរលីលា ។ ជួនកាល ក៏ប្រើសម្រាប់ការរៀបរាប់ព្រៃព្រឹក្សា ឬសរសើរពីសម្រស់ធម្មជាតិជាដើម ។

ឧទាហរណ៍ :

[...] មាសថ្លៃរំពៃមើលរ៉ា	អុញហ្ន៎សត្វា	កៀងគួឈ្មោលញី ។
ដូចបងត្រកងប្អូនស្រី	នែបន្ទូវឥន្ទ្រីយ	ពុំឱ្យឃ្លាតឃ្លា ។
ប្អូនតន់គួរគន់ពញ្ហ	ពញ្ហក់រេរា	រេរកលំនៅ ។
ប្អូនភ្លាមើលរ៉ាចចៅ	ចាចាតហើរទៅ	ហើរទាបហើយយំ ។
មាសថ្លៃមើលឯស្រគំ	ស្រកា[1] ហើរទំ	ហើរទៅខ្ពបខ្ពាំង ។
ប្អូនអើយនោះហើយក្រសាំង	ក្រសារសំកាំង	សំកុលកន្ទុយ ។
ប្អូនមាសរវាសមើលគុយ	មើលគួកហើរព្រុយ	ហើរព្រាតរៀងរាយ ។
ប្អូនពៅមើលទៅប្រពាយ	ពពេចប្រញាយ	ប្រញាប់ទំផ្ដាស ។
ប្អូនស្រីរំពៃមើលទាស	មើលទៀវទំជ្រាស	ជ្រៀវជ្រើសជ្រប់ជ្រក ។
ប្អូនតន់គួរគន់មើលធ្លក	មើលតុំហើរមក	ហើរមីរវិលវង់ ។
ទេវីស្រស់ស្រីមើលខ្លុង	មើលខ្លែងរេរង់	រេរាសន្សឹម ។
ស្រីស្រស់មើលអស់ទទឹម	ទទាទំដ្ឋឹម	ទំផ្ចាប់គួវា ។
ស្រីស្រស់មើលអស់ម្រឹគា	ម្រឹគីនានា	ច្រើនណាស់ក្រាស់ក្រៃ ។

(ដកស្រង់ពីរឿងកាកី របស់ព្រះបាទអង្គឌួង)

សំណួរ

១. តើអត្ថបទកាព្យនេះនិយាយពីអ្វី ?

២. តើអត្ថបទកាព្យនេះ និពន្ធដោយនរណា ? ជាបទអ្វី ?

លំហាត់

១. តើបទភុជង្គលីលាមានរង្វាស់កាព្យ ចំណាប់ចុងចួន និងការលើកដាក់សំឡេងដូចម្ដេចខ្លះ ?

២. ចូរប្អូនសាកល្បងតែងកំណាព្យបទភុជង្គលីលា ឱ្យបានយ៉ាងតិច ៣ វគ្គដែលមានអត្ថន័យទាក់ទង និងការព្យាយាម ។

---

(១) ស្រកា គឺសារិកា

វិស្ដាជាទ្រព្យ



ក. សិក្សាពាក្យគន្លឹះ

- ទ្រព្យ (ន) : វត្ថុ ធនធាន សម្បត្តិ (ទ្រព្យធន ទ្រព្យសម្បត្តិ) ។
- ឥតខ្ចោះ (គុ) : ដែលឥតមានទាស់ឆ្គងត្រង់ណា ។
- ខ្សោះ (គុ) : ដែលស្ងួតសោះ ផ្ដោះឥតរសជាតិ ។
- ធនធាន (ន) : ទ្រព្យរបស់ផ្សេងៗដែលគង់នៅ ។
- ឃ្មាតខ្មី (កិ) : ខំប្រឹង សង្វាតខ្លាំង ឃ្មាតខ្មីធ្វើការ ។
- ឧបសគ្គ (ន) : ដំណើររាំងស្ទះ គ្រឿងរារាំងជំទាស់ ។
- អប្រិយ (គុ) : ដែលពុំគួរឱ្យស្រឡាញ់ ដែលមិនជាទីស្រឡាញ់ ។
- ក្បួន (ន) : តម្រា សេចក្ដីតាក់តែងជាបែបបទកំណត់ជាគោលចារឹក ។
- ពណ្ណរាយ (គុ) : ដែលមានពន្លឺរស្មីរុងរឿង ភ្លឺថ្លា ល្អប្រពៃ ។
- ខ្ជរខ្ជាយ (កិ) : សុះសាយ កេរ្តិ៍ឈ្មោះល្អរបស់អ្នកល្បី ឮគ្រប់តំបន់ ។
- សង្វាត (កិ) : ខំប្រឹងខ្លាំង ខិតខំស្រវាស្រទេញ សង្វាតធ្វើការ សង្វាតរៀន ។
- និរន្តរ (គុឬកិ.វិ) : ដែលឥតមានចន្លោះ ជានិច្ច ឥតស្រាក ឥតឈប់ ។

ខ. អភិវឌ្ឍន៍បំណិន

នៅពេលដែលប្អូនអានអត្ថបទកាព្យខាងក្រោម សូមប្អូនអានដោយយកចិត្តទុកដាក់ ដើម្បីឆ្លើយសំណួរដែលទាក់ទងនឹងរង្វាស់កាព្យ ចំណាប់ជួន ផ្ទួន អត្ថន័យនៃកំណាព្យគំនិតសំខាន់ និងតម្លៃអប់រំ ។

គ. អត្ថបទ

ចំណេះវិជ្ជាជាទ្រព្យ	សម្បត្តិល្អជាប់	ជាងទ្រព្យសម្ភាយ ។
ទៅមកមិនបាច់វេចស្ពាយ	ទោះនឹងចាយវាយ	មិនងាយនឹងអស់ ។
ចាយច្រើនកើនច្រើនឥតខ្ចោះ	មិនដែលរឹងខ្សោះ	មិនអស់ខាតខាន ។
គ្មានចោរមកប្លន់ឆក់បាន	ជាទ្រព្យរុញច្រាន	ឱ្យបានពន្លឺ ។
វិជ្ជាជាទ្រព្យរន្ទឺ	នាំយើងឱ្យភ្លឺ	ឈប់ឈឺងងឹត ។
កូនអើយចូរនាងរិះគិត	ចង់បាត់ងងឹត	ប្រឹងគិតរៀនសូត្រ ។
កើតមានធនធានរហូត	មិនអាចរបូត	បាត់បង់ឡើយណា ។
ចូរកូនខិតខំសិក្សា	ឃ្លាតខ្ទឹឧស្សាហ៍	ជីវិតជោគជ័យ ។
ឈ្នះគ្រប់ឧបសគ្គចង្រៃ	អវិជ្ជាអប្រិយ	វិនាសសាបសូន្យ ។
លើកស្ទួយជីវិតរលូន	មាគ៌ាជាកូន	ជីវិតពណ្ណរាយ ។
កេរ្តិ៍ឈ្មោះរន្ទឺខ្ចរខ្ចាយ	លេចឮសុះសាយ	ល្បីពេញលោកា ។
ដោយក្តីសង្វាតឧស្សាហ៍	កើតពីកិច្ចការ	បង្កើតទ្រព្យា ។
រួចមានគំនិតការពារ	គង់វង្សធានា	និរន្តរៀងទៅ ។
កាព្យនេះសូមផ្តាំកូនចៅ	ទូន្មានទុកទៅ	ត្រូវធ្វើឱ្យបាន ។
កើតយសរបស់ផងមាន	កើតសុខក្សេមក្សាន្ត	បានជោគជយា ។

(ដកស្រង់ និងកែសម្រួលពីសៀវភៅ "សិល្បៈតែងកំណាព្យ" របស់លោក ពេជ្រ ខុំ ក្រវិល ចោះពុម្ពឆ្នាំ ១៩៨៥ ដោយវោងពុម្ព "វប្បធម៌" ទំព័រទី ៣៩)

សំណួរ

១. តើអត្ថបទកាព្យខាងលើនេះនិយាយពីអ្វី ?

២. តើអត្ថបទកាព្យខាងលើនេះ និពន្ធឡើងជាបទអ្វី ? ជាស្នាដៃរបស់នរណា ?

៣. ចូរគូសគំនូសតាងចំណាប់ចុងចួន ក្នុងវគ្គទី១ ដល់ទី៣ ។

៤. ចូររកគំនិតសំខាន់របស់អត្ថបទកាព្យខាងលើ ។

៥. តើអត្ថបទកាព្យខាងលើនេះមានតម្លៃអប់រំដូចម្តេច ?

អំពីល្បះផ្សំ

អ្នកធ្លាប់សិក្សារួចមកហើយអំពីបែបឬប្រភេទនៃល្បះដូចជា ល្បះសំណួរ ល្បះបញ្ជា ល្បះបញ្ជាក់ ល្បះឧទាន។ ឯល្បះមានបីយ៉ាង គឺល្បះទោល ល្បះផ្សំ និងល្បះក្រង។

ឥឡូវនេះអ្នកនឹងសិក្សាបន្តទៀតអំពីល្បះផ្សំ តែមុននឹងសិក្សាអំពីល្បះផ្សំ ចូរអ្នករំឭកឡើងវិញខ្លះៗអំពីល្បះទោល ។

១ . ល្បះទោល

ល្បះទោលមានទម្រង់សំខាន់ៗដូចខាងក្រោម ៖

- ល្បះ(ល) → កន្សោមនាម(កន) ១ + កិរិយាសព្ទ(កិ)

  ឧទាហរណ៍ : សុខដើរ ។

- ល្បះ(ល) → កន្សោមនាម(កន) ១ + កិរិយាសព្ទ(កិ) + កន្សោមនាម(កន)

  ឧទាហរណ៍ : សុខាទៅស្រែ ។

- ល្បះ(ល) → កន្សោមនាម(កន) ១ + កិរិយាសព្ទ(កិ) + កន្សោមមានផ្ដាក់(កមធ)

  ឧទាហរណ៍ : បុប្ផានិយាយនឹងខ្ញុំ ។

- ល្បះ(ល) → កន្សោមនាម(កន) ១ + កិរិយាសព្ទ(កិ) កន្សោមនាម(កន) ២ + កន្សោមមានផ្ដាក់(កមធ)

  ឧទាហរណ៍ : សំថែទាំបន្លែក្នុងសួន ។

  យើងសង្កេតឃើញថា ៖

- ល្បះទី ១ មានទម្រង់ :
  - កន្សោមនាម ១ (កន១) គឺសុខ
  - កន្សោមកិរិយា (កិ) គឺដើរ ។
- ល្បះទី ២ មានទម្រង់ :
  - កន្សោមនាម ១ (កន១) គឺសុខា
  - កន្សោមកិរិយា (កិ) គឺទៅ
  - កន្សោមនាម ២ (កន ២) គឺស្រែ ។

- ល្បះទី ៣ មានទម្រង់ :
  - កន្សោមនាម ១ (កន១) គឺបុប្ផា
  - កន្សោមកិរិយា (កិ) គឺ និយាយ
  - កន្សោមមានផ្ចាក់ (កមធ) គឺ "នឹង" (ផ្ចាក់) "ខ្ញុំ"(កន) ។
- ល្បះទី ៤ មានទម្រង់ :
  - កន្សោមនាម ១(កន១) គឺសំ
  - កន្សោមកិរិយា (កិ) គឺ ថែទាំ
  - កន្សោមនាម ២ (កន ២) គឺបន្លែ
  - កន្សោមមានផ្ចាក់ (កមធ) គឺក្នុងសួន ។

ដូច្នេះ យើងឃើញថា ល្បះទោលមានកន្សោមនាមប្រធាន (កនប្រ) កន្សោមកិរិយា(កិ) និង អាចមានកន្សោមនាម(កន) និងកន្សោមមានផ្ចាក់ (កមធ) ជាធាតុសំណង់របស់ល្បះ ។

ឧទាហរណ៍ : គំនូសតាងល្បះទោល

គំនូសតាងជាមែកធាង



គំនូសតាងក្នុងប្រអប់



២ . ល្បះផ្សំ

ល្បះផ្សំមានទម្រង់ដូចគ្នានេះដែរ ប៉ុន្តែមានធាតុសំណង់ណាមួយនៃល្បះ ដែលជាឃ្លា ឬជាល្បះ ឬក្នុងធាតុសំណង់ណាមួយ ដែលជាពង្រីករបស់ល្បះដើម ។

យើងអាចនិយាយបានថា ក្នុងល្បះផ្សំមាន "ឃ្លា"(ឃ) ។

- "ឃ្លា" ជាធាតុរបស់ "ល្បះ"
- "ឃ្លា" ជាពង្រីករបស់ :
  - កន្សោមនាម(កន) របស់ល្បះ
  - កន្សោមកិរិយាឬកិរិយា(កកិ ឬកិ)របស់ល្បះ ។

ដូចនេះតើដូចម្តេចទៅហៅថា " ល្បះផ្សំ" ? តើល្បះផ្សំមានទម្រង់ដូចម្តេច ?

ចូរពិនិត្យឧទាហរណ៍ខាងក្រោម ៖

- សុខាជឹងថាឪពុកវា ខំប្រឹងធ្វើការណាស់ ។
- យើងគោរពឪពុកម្តាយ ដែលមានគុណចំពោះយើង ។
- យើងខំធ្វើការងារដើម្បីប្រទេសយើងថ្កុំថ្កើង ។

- **ល្បះផ្សំបែបទី ១**



- **ល្បះផ្សំបែបទី ២**



- **ល្បះផ្សំបែបទី ៣**



តាមឧទាហរណ៍ទាំង ៣ ក្នុងល្បះផ្សំបែបទី ១ , ២ និងទី ៣ខាងលើបានបញ្ជាក់ឱ្យឃើញថា ក្នុងល្បះផ្សំមាន :

- ឃ្លា(ឃ)រណប កន្សោមនាម(កន) ឬឃ្លានាម
- ឃ្លារណប បែបកន្សោមគុណនាម ឬឃ្លាគុណនាម
- ឃ្លារណប បែបកន្សោមមានផ្ទាក់ (កមធ) ទេសកាល ឬឃ្លាទេសកាល(ហៅឃ្លាគុណកិរិយាក៏បាន) ។

ល្បះផ្សំ គឺជាល្បះដែលកើតឡើងពីការពង្រីកល្បះទោលដែលមានធាតុសំណង់ណាមួយនៃល្បះ ជាឃ្លា ឬជាល្បះសម្រាប់ពង្រីកល្បះដើម ។

ឃ្លារណប អាចជាឃ្លានាម ឃ្លាគុណនាម ឃ្លាទេសកាល ។ល ។

លំហាត់

១. ដូចម្តេចហៅថាល្បះផ្សំ ?

២. តើល្បះផ្សំមានធាតុសំណង់សំខាន់ៗអ្វីខ្លះ ?

៣. ចូរគូសគំនូសតាងល្បះជាមែកធាង និងជាប្រអប់ដូចខាងក្រោម

- ដារាសង្ឃឹមថា គេនឹងប្រឡងជាប់នៅឆ្នាំនេះ ។
- យើងគោរពលោកគ្រូ អ្នកគ្រូ ដែលប្រៀបដូចឪពុកម្តាយទី ២ របស់យើង ។
- ប្រជាពលរដ្ឋយើងខិតខំធ្វើការ ដើម្បីប្រទេសជាតីរីកចម្រើន ។

ជ័យជម្នះរបស់លោកគ្រូបែតាំង



ក. សិក្សាពាក្យគន្លឹះ

- កីឡា (ន) : ការលេងល្បែង ល្បែងកម្សាន្តផ្សេងៗ ។
- កិត្តិសព្ទ (ន) : សេចក្តីសរសើរដល់កេរ្តិ៍ឈ្មោះ ។
- អត្តពលករ (ន) : អ្នកបញ្ចេញអត្តពលកម្ម បំណងដើម្បីឱ្យដឹងច្បាស់លាស់ ។
- វិញ្ញាសា (ន) : ការសាកល្បងមើលនូវអ្វីមួយ ។
- បាតុកម្ម (ន) : ការរើបម្រះ ការតស៊ូបះបោរ ។
- ប្រារព្ធ (ន) : ការចាប់ផ្តើម ផ្តួចផ្តើម ។
- ព្យុហយាត្រា (ន) : ការដង្ហែក្បួន ។
- និមិត្តរូប (ន) : រូបជាតំណាង ។
- បុរី (ន) : ប្រទេស ។
- អធិកអធម (គុ) : ដែលក្រៃលែង ដែលលើសលន់ ។
- កិត្តិយស (ន) : យសស័ក្តិដែលល្បីទូទៅ កេរ្តិ៍ឈ្មោះដ៏រុងរឿង ។
- កីឡដ្ឋាន (ន) : ទីកន្លែងសម្រាប់លេងល្បែងផ្សេងៗ ។
- សោភណភាព (ន) : ភាពល្អ ហ្មត់ហ្មង ប្រសើរ ក្រៃលែងប្រសើរលើសលន់ ។
- វិចិត្រករ (ន) : ជាងគំនូរ អ្នកគូរឆ្លាក់រូបភាព ។

- សមាជ (ន) : មហាសន្និបាតឬការប្រជុំនៃមហាជន ឬអ្នកពិភាក្សាពីបញ្ហាផ្សេងៗ ដែលមានប្រយោជន៍ទូទៅ
- ទេវៈ (ន) : ទេវតា ។
- ទស្សនិកជន (ន) : អ្នកដែលចូលរួមទស្សនា អ្នកទស្សនា អ្នកមើល ។
- កីឡាករ (ន) : អ្នកកីឡា ។
- អតិបរមា (គុ) : ដែលច្រើនបំផុត ច្រើនលើសក្រៃណា ក្រៃលែង ។
- ឯតទគ្គភាព (ន) : អ្នកដែលគេលើកថា លើសលែងប្រសើរជាងគេខាងមុខការឬចំណេះ ។
- លទ្ធផល (ន) : ផលនៃការងារដែលបានសម្រេច ផលដែលបានសម្រេចហើយ វិជ្ជាណាមួយ ។
- សមត្ថភាព (ន) : ភាពនៃសេចក្តីអាច ហ៊ាន សេចក្តីមោះមុត ។
- បច្ចេកទេស (ន) : ចំណេះដឹងផ្នែកចំណេះវិជ្ជាអ្វីមួយជាច់មុខ ។
- ទិន្នផល (ន) : ផលដែលសម្រេចបាន ផលដែលគេផ្តល់ឱ្យ ។
- ទស្សនីយភាព (ន) : ភាពដែលគួរឱ្យចង់មើល អ្វីៗដែលគួរឱ្យចង់មើល ។
- ភាតរភាព (ន) : ភាពជាបងប្អូន សេចក្តីរាប់អានរកគ្នាដូចជាបងប្អូន ។
- មកុដ (ន) : គ្រឿងប្រដាប់ធ្វើដោយមាសសុទ្ធ រាងក្រឡុម មានកំពូលរំលេចដោយក្បាច់ រចនាល្អវិចិត្រ ជាតំបូងសម្រាប់ក្សត្រទ្រង់រាជ្យ ទ្រង់ពាក់ព្រះសិរសា(ពាក់ក្បាល) ។
- អភិជន (ន) : ត្រកូល ជាតិ វង្ស មនុស្សខ្ពង់ខ្ពស់ ។

ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទខាងក្រោម សូមអ្នកអានដោយយកចិត្តទុកដាក់ដើម្បីត្រៀមឆ្លើយសំណួរមួយចំនួនទាក់ទងនឹងគំនិតសំខាន់បង្ហាញត្រង់ មូលន័យនៃអត្ថបទ និងតម្លៃអប់រំ ។

គ. អត្ថបទ

អភិជនបារាំង**ព្យែរ គូប៊ែតាំង** ជាជនជាតិបារាំង ។ នៅសម័យនោះ ប្រទេសបារាំងមិនសូវយកចិត្តទុកដាក់ចំពោះការអប់រំកាយនៅឡើយ ។ លោក**គូប៊ែ តាំង** ស្រមៃចង់អញ្ជើញយុវជនក្នុងពិភពលោកឱ្យធ្វើកីឡាដើម្បីឱ្យគេស្គាល់កីឡានិងដើម្បីលើកតម្កើងឡើងវិញនូវកីឡាដែលធ្លាប់មានកិត្តិសព្ទល្បីល្បាញ កាលពីពីរពាន់ឆ្នាំមុននៅប្រទេសក្រិក ។ ជាពិសេស តាមរយៈការប្រកួតកីឡា លោកសង្ឃឹមថានឹងប្រមូលមនុស្សគ្រប់សញ្ជាតិ គ្រប់សាសន៍ គ្រប់ស្រទាប់សង្គមឱ្យស្គាល់គ្នាទៅវិញទៅមកបានច្បាស់ និងចេះស្រឡាញ់គ្នាផង ។

បន្ទាប់ពីឆ្លងកាត់ការលំបាក ការតស៊ូប្រឈមនឹងភាពសោះអង្គើយ ឬការចំអកឡកឡឺយមក នៅឆ្នាំ ១៨៩៤ លោកក៏សម្រេចប្រមូលអ្នកតំណាង ១៤ប្រទេស មកចូលរួមក្នុងសមាជ ដើម្បីរៀបចំ ល្បែងអូឡាំពិក និងសម្រេចបំណងដ៏ស្រួចស្រាល់របស់គាត់ ។

នៅឆ្នាំ ១៨៩៦ បាតុកម្មទី១ក៏បានប្រព្រឹត្តទៅក្នុងក្រុងអាថែនដែលជាក្រុងនិមិត្តរូបនៃកំណើត ល្បែង ។ ប្រទេស ១៣ទៀតក៏បានចុះឈ្មោះ ហើយអត្តពលករ ២៨៥នាក់ ក៏បានចូលរួមប្រកួតក្នុង វិញ្ញាសាកីឡាប្រាំបួន ។ លុះដល់ឆ្នាំ ១៩៦៤ ក្នុងឱកាសល្បែងអូឡាំពិក នៅតូក្យូ ប្រទេសដែលចូលរួម រហូតដល់ ១០៤ ហើយអត្តពលករបានចូលរួមជាផ្លូវការប្រហែល ៨ ៥០០នាក់ ។ ក្នុងរយៈពេល ត្រៀមល្បែងអូឡាំពិក(ដែលត្រូវប្រព្រឹត្តទៅក្នុងរយៈពេលបួនឆ្នាំម្តង) កីឡាកររាប់សែននាក់នៃប្រទេស នានា បានចូលរួមហ្វឹកហាត់យ៉ាងគគ្រឹកគគ្រេង ។

នៅឆ្នាំ១៩៦៨ ល្បែងនេះត្រូវបានរៀបចំឡើងនៅក្នុងប្រទេសម៉ិកស៊ិក ។ ក្នុងកម្មវិធីមានល្បែង ២០ប្រភេទ ហើយទន្ទឹមនឹងនោះ ក៏មានកម្មវិធីបង្ហាញវប្បធម៌ចំនួន ២០ដែរ ដើម្បីជានិមិត្តរូបនៃ ឯកភាពទាំងកាយនិងស្មារតី ។

នៅប្រទេសក្រិកបុរាណ ពិធីបុណ្យអូឡាំពិក មានចាប់តាំងពីឆ្នាំ ៧៧៦ មុនគ.ស. ។ ពិធីបុណ្យ សាសនាទាំងអស់សុទ្ធតែមានល្បែងអត្តពលកម្ម ។ ទូតខាងសាសនាបានធ្វើដំណើរពេញពិភពក្រិក ដើម្បីជូនដំណឹងពីថ្ងៃបើកពិធី ព្រមទាំងប្រកាសផ្អាកការធ្វើសង្គ្រាមរវាងគ្នាទៅវិញទៅមក ដែលតែង តែកើតមានជាញឹកញាប់រវាងបុរីក្រិក ។ សូម្បីតែតំបន់អេលីដ ដែលជាទីតាំងនៃភ្នំ "អូឡាំ" ទីកន្លែង សម្រាប់ប្រារព្ធពិធី ក៏ត្រូវហាមប្រាម មិនឱ្យកងទ័ពចូលដែរ ។ ពិធីបុណ្យមានរយៈពេលប្រាំថ្ងៃ ។ នៅ ថ្ងៃទីមួយ អ្នកចូលរួមទាំងអស់នាំគ្នាហែព្យុហយាត្រាយ៉ាងគគ្រឹកគគ្រេង ។ បីថ្ងៃបន្ទាប់មកទៀតគឺជាទិវា ល្បែង ។ នៅថ្ងៃចុងក្រោយ អ្នកឈ្នះម្នាក់ៗបានទទួលធ្នឹតស្លឹកឆ្មោតមួយ និងមកុដមែកអូលីវមួយ ហើយបានចូលរួមក្នុងពិធីហែក្បួនព្យុហយាត្រាដ៏អធិកអធមនិងបន្តដោយពិធីជប់លៀង ។ នៅពេល វិលត្រឡប់នៅកាន់បុរីរបស់ខ្លួនវិញ កីឡាករឈ្នះនឹងត្រូវបានគេទទួល និងផ្តល់កិត្តិយសខ្ពង់ខ្ពស់ ។

ល្បែងបានប្រព្រឹត្តនៅក្នុងកីឡដ្ឋាន អត្តពលករទាំងអស់ត្រូវដោះសម្លៀកបំពាក់ចេញ ដើម្បីឱ្យ អ្នកផងស្ងើចសរសើរសោភណភាពនៃរាងកាយរបស់គេ ។ នារីមិនត្រូវគេអនុញ្ញាតឱ្យចូលក្នុងកីឡដ្ឋាន ទេ ។

នៅពេលជាមួយគ្នានេះដែរ វិចិត្រករ កវី អ្នកនិពន្ធក៏បានយកស្នាដៃរបស់គេ មកបង្ហាញជូន មហាជនក្នុងកីឡដ្ឋានអូឡាំពិកបានស្គាល់ដែរ ។

ដូចនេះ ពិធីបុណ្យល្បែងដ៏អធឹកអធមនេះ បានផ្តល់ឱកាសដល់ពួកក្រិកឱ្យជួបជុំគ្នាក្នុងសន្តិភាព ដើម្បីលើកតម្កើងព្រះទេវៈនិងអ្នកឈ្នះ ដែលដណ្តើមបានកិត្តិយសសម្រាប់បុរីកំណើតរបស់ខ្លួន ។ ប៉ុន្តែ ពិធីនេះ អនុញ្ញាតឱ្យចូលរួមតែចំពោះជនជាតិក្រិកសុទ្ធនិងអ្នកជាតែប៉ុណ្ណោះ ។ រីឯទាសករនិងជន បរទេសពុំមានសិទ្ធិចូលប្រកួតបានឡើយ ។

ថ្វីបើល្បែងទំនើបយកតាមលំនាំពួកបុរាណ ក៏នៅតែមានភាពខុសពីគ្នាស្រឡះ។ ល្បែងឥឡូវនេះបើកទូលាយចំពោះអ្នកស្នេហាកីឡាទាំងឡាយ ដោយមិនគិតសញ្ជាតិ ជាតិសាសន៍ សាសនា នយោបាយ ឬឋានៈសង្គមឡើយ។ ឯនារីក៏អាចចូលរួមបានដែរ។

ទស្សនិកជនល្បែងអូឡាំពិក ដែលកីឡាករតែងហៅថា "អ្នកគាំទ្រ" អ្នកកាន់ជើងបានចេញមកពីទ្វីបទាំងប្រាំ ហើយមធ្យោបាយផ្តល់ព័ត៌មានដ៏អស្ចារ្យ (ការសែត វិទ្យុ ទូរទស្សន៍)ក៏បានធ្វើឱ្យមនុស្សរាប់លាននាក់យកចិត្តទុកដាក់ចំពោះល្បែងនេះ។

ជនជាតិជាច្រើនបានបង្កើតក្រុមប្រឹក្សាអូឡាំពិកអន្តរជាតិ (ក.អ.អ.)។ រដ្ឋាភិបាលបានយកចិត្តទុកដាក់ចំពោះល្បែង តែងរៀបចំយុវជនឱ្យចូលរួមក្នុងការប្រកួត ដែលបង្ហាញឱ្យឃើញពីភាពអង់អាចក្លាហាន និងការរីកចម្រើន។

ឯការប្រជាល់នៅតែជាការតស៊ូ រវាងបុគ្គលជាមួយនឹងបុគ្គល ប៉ុន្តែក្នុងល្បែង គេបានផ្តល់តួនាទីយ៉ាងសំខាន់ដល់កីឡាសមូហភាព។ ការដណ្តើមយកជើងឯករវាងកីឡាករ បានជំរុញឱ្យគេខិតខំជាអតិបរមា។ ឯតទគ្គភាពរបស់គេ គឺជាលទ្ធផលនៃការត្រៀមដ៏យូរ សំដៅបង្កើនសមត្ថភាព បច្ចេកទេសបង្ហាត់ ដើម្បីទទួលទិន្នផលខ្ពស់ ខាងការធ្វើឱ្យរាងកាយមាំមួន ប្រកបដោយសុខភាព និងគាំទ្រដោយឆន្ទៈតស៊ូមោះមុត។ គេស្វែងរកឈ្នះគូប្រកួតតិចជាងឈ្នះពេលវេលា ចម្ងាយ ទំនាញផែនដី ការហាត់នឿយ ការឈឺចាប់ និងការឈ្នះខ្លួនឯង ដោយការសុខចិត្តបង្ខំចិត្តទទួចធ្វើឱ្យកាន់តែប្រសើរឡើង ដើម្បីទទួលជោគជ័យក្នុងវិញ្ញាសា ដែលកាន់តែលំបាកឡើងជាលំដាប់។

យើងសូមអរគុណលោកគូប៊ែតាំង ដែលបានធ្វើឱ្យល្បែងអូឡាំពិកកើតឡើងវិញ។ ទស្សនីយភាពល្បែងនេះ បានធ្វើឱ្យយុវជនប្រកបដោយសុខភាព ឯកភាព បំណិនប្រសប់ និងភាតរភាព។ នេះគឺជាជោគជ័យដ៏ធំមួយក្នុងជីវិតរបស់គូប៊ែតាំង។

សំណួរ

១. តើអត្ថបទនេះនិយាយអំពីអ្វី ?

២. តើហេតុអ្វីបានជាលោកគូប៊ែតាំងចង់ឱ្យយុវជនក្នុងពិភពលោកធ្វើកីឡា ?

៣. តើលោកគូប៊ែតាំងបានបង្កើតល្បែងកីឡាតាំងពីពេលណាមក ?

៤. តើលោកគូប៊ែតាំងបានសម្រេចជោគជ័យក្នុងការបង្កើតល្បែងកីឡាអូឡាំពិកយ៉ាងដូចម្តេចខ្លះ ?

៥. តើអត្ថបទនេះមានតម្លៃអប់រំអ្វីខ្លះ ?

៦. ចូរបង្ហាញមូលន័យនៃអត្ថបទ។

៧. ចូរស្រង់ល្បះផ្សំដែលមានក្នុងអត្ថបទឱ្យបាន១ ឬ ២ ល្បះ។

កំណាព្យបទបន្ទោលកាក

អ្នកធ្លាប់សិក្សារួចមកហើយពីកំណាព្យបទផ្សេងៗដូចជា បទកាកគតិ បទព្រហ្មគីតិ បទពំនោល បទពាក្យ ៧ បទពាក្យ ៨ បទពាក្យ ៩ជាដើម។

ក្នុងមេរៀននេះ អ្នកនឹងបានសិក្សាកំណាព្យបទថ្មីមួយទៀត គឺបទបន្ទោលកាក។ បទបន្ទោលកាក ជាប្រភេទកំណាព្យមួយបែបទៀតដែរ ក្នុងចំណោមបទកំណាព្យនានាដែលដូនតាយើងបានបង្កើតនិងតាក់តែងឡើងដោយមានក្បួនខ្នាត ភាព្យសាស្ត្រត្រឹមត្រូវច្បាស់លាស់ ទាំងរង្វាស់ភាព្យ ចំណាប់ចុងចួន ផ្ទួន រណ្តំ ចង្អាក់ និងបរិយាកាសក្នុងការប្រើប្រាស់ថែមទៀតផង។

ចូរអ្នកអានអត្ថបទភាព្យខាងក្រោម ៖

ថ្លែងដោយទំនង ដំណើរត្រីផងយាត្រា
ពើបនឹងជុចណា ត្រីស្រែកថារើយចៀសចេញ។
ជុចថាអះអើ បុណ្យអ្នកឯងតើម្តេចមិញ
ក៏មកប្រើអញ ចៀសចេញអ្នកមកជាល្បែង។
ត្រីថាបើច្មោះ អញនឹងទម្លុះចៅឯង
ឱ្យឈប់ជាក់ស្តែង ត្បិតឯងមកនៅរាំងផ្លូវ។
ជុចថាអើហោង បើខឹងចង់ល្បែងឥឡូវ
នេះហើយសមត្រូវ នឹងម្ហូរប្រហើរសាអាំង។
ត្រីថាអះអើ ប៉ើងរ៉ើងទេតើម្តេចខ្លាំង
អួតមានកម្លាំង គិតស្មានថាអញខ្លាចហោង។
ជុចថាបើច្មោះ អញ្ជើញមកចុះចង់លង
ឱ្យជឹងនេះម្តង ឫទ្ធិតេជៈតេជដៃ។
ត្រីស្ទុះភ្លាមចូល ក្នុងជុចរមួលហើយនៃ
ជំពាក់ក្រក្រី ថយក្រោយពុំរួចឡើយណា។

(សាស្ត្រា ជុចនិងត្រីរបស់ វិសេស ដួង)

តាមអត្ថបទភាព្យដកស្រង់ខាងលើនេះ យើងឃើញថាបទកំណាព្យខាងលើនេះ គឺជាបទបន្ទោលកាក។

យើងសង្កេតឃើញថា បទបន្ទោលកាកនេះមានធាតុ និងលក្ខណៈពិសេសៗដូចជា ៖

ក. រង្វាស់កាព្យ

រង្វាស់កាព្យគឺជាការរាប់ចំនួនព្យាង្គនៅក្នុងឃ្លា និងការរាប់ចំនួនឃ្លានៅក្នុងវគ្គ។

បទបន្ទោលកាកមានរង្វាស់កាព្យ :

- ក្នុង ១វគ្គ មាន៤ឃ្លា
- ឃ្លាទី ១ មាន ៤ព្យាង្គ
- ឃ្លាទី ២ មាន ៦ព្យាង្គ
- ឃ្លាទី ៣ មាន ៤ព្យាង្គ
- ឃ្លាទី ៤ មាន ៦ព្យាង្គ។

ខ. ចំណាប់ចួន

បទបន្ទោលកាកមានចំណាប់ចួន

- ព្យាង្គទី ៤នៃឃ្លាទី១ ចួននឹងព្យាង្គទី ៤នៃឃ្លាទី ២ គ្រប់ៗវគ្គ
- ព្យាង្គទី ៦នៃឃ្លាទី ២ ចួននឹងព្យាង្គទី ៤នៃឃ្លាទី ៣ ហើយចួននឹងព្យាង្គទី ២ឬព្យាង្គទី ៤នៃឃ្លាទី៤
- ព្យាង្គទី ៦នៃឃ្លាទី៤នៃវគ្គទី១ ចួននឹងព្យាង្គទី ៦នៃឃ្លាទី ២ ហើយចួននឹងព្យាង្គទី ៤នៃឃ្លាទី ៣ ចួននឹងព្យាង្គទី ២ ឬទី ៤នៃឃ្លាទី ៤ នៃវគ្គទី ២។
- គំនូសតាង



- សញ្ញាចាប់ចុងចួន
  - ព្យាង្គទី ៤ ឃ្លាទី ១ ⟷ ព្យាង្គទី ៤ឃ្លាទី ២ គ្រប់វគ្គ
  - ព្យាង្គទី ៦ ឃ្លាទី ២ ⟷ ព្យាង្គទី ៤ឃ្លាទី ៣ ⟷ ព្យាង្គទី ២ឬ៤នៃឃ្លាទី ៤
  - ព្យាង្គទី ៦ នៃឃ្លាទី ៤ វគ្គទី ១ ⟷ ព្យាង្គទី ៦នៃឃ្លាទី ២ វគ្គទី ២ ⟷
  - ព្យាង្គទី ៤ឃ្លាទី ៣ វគ្គទី ២ ⟷ ព្យាង្គទី ២ ឬ៤ ឃ្លាទី ៤នៃវគ្គទី ២ ឬវគ្គបន្ត។

គ. ចង្វាក់ (ឬការទម្លាក់សំឡេង)

បទបន្ទោលកាក ត្រូវសូត្រ និងមានការសង្កត់សំឡេងត្រង់ :

- ឃ្លាទី ១និងឃ្លាទី ៣ : ត្រូវសង្កត់សំឡេងលើព្យាង្គទី ២
- ឃ្លាទី ២និងឃ្លាទី ៤ : ត្រូវសង្កត់សំឡេងលើព្យាង្គទី ២ និង៤

ឃ. បរិយាកាស

បទបន្ទោលកាក ជាទូទៅច្រើនសូត្រឬប្រើនៅពេលមានការសន្ទនា ឬផ្តោះផ្តងគ្នាពីរនាក់ ។

លំហាត់

១. តើបទបន្ទោលកាក មានរង្វាស់កាព្យ ចំណាប់ចួន និងចង្វាក់ដូចម្តេច ?

២. ចូរអានអត្ថបទកាព្យ ហើយឆ្លើយសំណួរដូចខាងក្រោម ៖

ជុចថាអើម្ល៉េះ	កម្លាំងប៉ុណ្ណេះទេណា
អួតឯងបំពារ	ទម្លុះទម្លាយមិញតើ ។
ត្រីថាម្ចាស់ផ្លែ	ពាក្យខ្ញុំនេះនៃបញ្ជើ
ឥឡូវនេះតើ	អ្នកមានឫទ្ធីក្រាស់ក្រៃ ។
ជុចថាឫទ្ធី	តេជៈបារមីអ្វីនៃ
ឯងកុំចេះស្តី	ចំអកចំអន់ឱ្យគ្នា ។
ត្រីថាម្ចាស់ផ្លែ	អស់ពាក្យនេះនៃខ្ញុំថា
ជាល្បែងទៅណា	អ្នកម្ចាស់កុំយកទោសឡើយ ។
ជុចថាល្បែងៗ	ឯងអួតគគ្រែងស្រេចហើយ
ពិតកុំលង់ឡើយ	ឯងស្ទុះបំពារតេជដៃ ។
ត្រីថាខ្ញុំម្ចាស់	សេចក្តីពុំសមមែននៃ
អ្នកជុចម្ចាស់ផ្លែ	ម្ចាស់អើយលែងខ្ញុំទៅរ៉ា ។

(ល្បើកជុចនិងត្រីរបស់លោក ឱសេសដួង)

- តើអត្ថបទកាព្យខាងលើនេះនិយាយពីអ្វី ?
- តើអត្ថបទកាព្យខាងលើនេះតែងឡើងជាបទអ្វី ?
- ចូរគូសចំណាប់ចួន នៅវគ្គទី ១និងទី ២ ។

៣. ចូរតែងបទបន្ទោលកាក ទាក់ទងនឹងភាពជោគជ័យឱ្យបានយ៉ាងតិច ៤វគ្គ ។

កាព្យផ្តោះផ្តង



ក. សិក្សាពាក្យគន្លឹះ

- រាជការ (ន) : ការរបស់ព្រះរាជា ការផែនដី ការរក្សាប្រទេស។
- នាម៉ឺន (ន) : អ្នកធ្វើការក្នុងរាជការដែលមានបណ្តាស័ក្តិខ្ពស់។
- ក្រវើន (កិ) : ឧស្សាហ៍ ដាស់តឿន។
- គូលី (ន) : អ្នកស៊ីឈ្នួលធ្វើការឱ្យគេ។
- ទំនួល (ន) : ការទទួល។
- នគរ (ន) : ប្រទេស។
- គៀច (កិ.គុ) : ទម្រន់ ក្រាញ មិនព្រមទៅ។
- ក្រាញ (កិ) : គៀច តម្ឹង ក្រាញមិនចង់ទៅ។
- ប្រាជ្ញា (ន) : ការយល់ជាក់ច្បាស់។

ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទឆ្លើយឆ្លងរវាងតួអង្គទាំងពីរខាងក្រោម ចូរអ្នកអានដោយយកចិត្តទុកដាក់ ដើម្បីត្រៀមឆ្លើយសំណួរមួយចំនួនខាងក្រោមឱ្យបានត្រឹមត្រូវ។

គ. អត្ថបទ

ឯងចេះប្រសើរ　　ម្តេចក៏មិនធ្វើរាជការ
បើធ្វើរាល់គ្នា　　អ្នកណាធ្វើស្រែរកស៊ី ។
ឯងធ្វើនាម៉ឺន　　ឯអញក្រវើនវាតទី
ធ្វើជាគូលី　　ម៉ែអញខឹអញក៏ស្រួល ។
ឯងស្តីនេះត្រូវ　　ប៉ុន្តែមិនសូវទំនួល
ឃើញតែខ្លួនស្រួល　　មិនឃើញប្រយោជន៍នគរ ។
រាជការរៀបចំ　　តាត់តែងថែទាំឱ្យល្អ
កំពុងតែក　　មិនទាន់បង្កើតបានគ្រប់ ។
ទើបអញនេះណា　　ខំធ្វើរាជការថ្វៃយប់
មិនមានធុញថប់　　គៀចក្រាញនឹងកិច្ចរាជការ ។
ដូច្នេះស្រុកយើង　　នឹងបានថ្កុំថ្កើងដោយសារ
កម្លាំងហាត្ថា　　ហើយនឹងប្រាជ្ញាវៃវាង ។
ឯងមានសក្តិយស　　ថាអ្វីមិនខុសមិនល្មៀង
ធ្វើការព្រមព្រៀង　　នេះក៏ប្រពៃណាស់ហោង ។

(និពន្ធដោយលោក ម៉ុក សំនិក ទស្សនាវដ្តីស្រុកខ្មែរលេខ ៩ ទំព័រទី ២០ ឆ្នាំ ១៩២៩ ដកស្រង់ពីសៀវភៅកំណាព្យខ្មែរភាគ ១ ក្រសួងអប់រំទំព័រទី ៦២ បោះពុម្ពឆ្នាំ ១៩៨៥)

សំណួរ

១. តើអត្ថបទកាព្យនេះតែងឡើងជាបទអ្វី ? និពន្ធដោយនរណា ?
២. តើអត្ថបទកាព្យខាងលើនេះនិយាយឆ្លើយឆ្លងគ្នាពីអ្វី ?
៣. តើអត្ថន័យនៃកំណាព្យខាងលើនេះមានន័យដូចម្តេច ?
៤. ចូរបង្ហាញពីចំណាប់ចុងចួននិងរង្វាស់កាព្យក្នុងវគ្គទី ១ និងទី ២ ?
៥. តើចង្វាក់និងការលើកដាក់សំឡេងក្នុងអត្ថបទកាព្យខាងលើស្ថិតនៅត្រង់ណា ? ចូរបង្ហាញ ។
៦. ចូររកតម្លៃអប់រំក្នុងអត្ថបទកាព្យខាងលើ ។

ល្បែក ជុច និងត្រី



នៅពេលលោកគ្រូ អ្នកគ្រូរបស់អ្នកសូត្រអត្ថបទកំណាព្យដកស្រង់ល្បែកជុចនិងត្រីត្រង់វគ្គបន្ត ទៀតនេះ សូមប្តូនយកចិត្តទុកដាក់ស្តាប់ដោយស្ងៀមស្ងាត់និងយកចិត្តទុកដាក់ដើម្បីត្រៀមឆ្លើយសំណួរ មួយចំនួនទាក់ទងនឹងគំនិតសំខាន់បង្ហាញត្រង់ គំនិតសំខាន់បង្កប់និងតម្លៃអប់រំរបស់អត្ថបទឱ្យបានត្រឹមត្រូវ។

សំណួរ

១. តើអត្ថបទនេះដកស្រង់ពីណា ? សូត្រជាបទអ្វី ? អ្នកណាជាអ្នកនិពន្ធ ?

២. តើអត្ថន័យនៃបទកំណាព្យនិយាយពីអ្វី ?

៣. តើទង្វើរបស់ជុចនិងត្រីជាទង្វើដូចម្តេច ?

៤. តើត្រីជាតួអង្គដូចម្តេច ? ជុចជាតួអង្គដូចម្តេច ?

៥. ចូរបង្ហាញគំនិតសំខាន់បង្កប់និងគំនិតសំខាន់បង្ហាញត្រង់ក្នុងអត្ថបទកាព្យខាងលើ ?

៦. តើអត្ថបទកាព្យដកស្រង់ខាងលើនេះមានតម្លៃអប់រំអ្វីខ្លះ ?

ការសូត្រកំណាព្យ

នៅក្នុងមេរៀនមុនៗអ្នកធ្លាប់សិក្សាពីកាព្យជាច្រើនបទតាំងពីការអាន ការសូត្រហួតដល់ការតែងកំណាព្យថែមទៀតដែលមាន កំណាព្យបទកាកគតិ បទព្រហ្មគីតិ បទពំនោល បទបន្ទោលកាក បទភុជង្គលីលា បទពាក្យ ៧ ពាក្យ ៨ និងពាក្យ ៩ ជាដើម។

នៅពេលនេះ អ្នកត្រូវសិក្សាពីរបៀបសូត្រកំណាព្យឱ្យបានត្រឹមត្រូវតាមបទនិងស្តាប់គេសូត្រដោយយកចិត្តទុកដាក់។

ការសូត្រកំណាព្យខុសពីការអានអត្ថបទកំណាព្យដែលពុំបានគិតពីបែបបទក្នុងការសូត្រទេ។ ការសូត្រកំណាព្យគឺជាការសូត្រទៅតាមបែបបទ ឬតាមបទនីមួយៗទៅតាមចង្វាក់ ឬការលើកដាក់សំឡេងឱ្យបានត្រឹមត្រូវដូចជា :

- **បទភុជង្គលីលា :** សូត្ររបៀប ឬទំនងដូចដំណើរនាគលូន ឬដំណើរដូចទឹករលក ហើយចង្វាក់នៃបទនេះត្រូវសូត្រដោយទម្លាក់សំឡេងលើព្យាង្គទី ២ និងទី ៤ គ្រប់ឃ្លា។
- **បទពំនោល :** ត្រូវសូត្រតាមរបៀបជាការរៀបរាប់ពីកំហឹងក្រេវក្រោធ សង្ឃឹក គំរាមកំហែង រៀបរាប់ពីមហិទ្ធិឫទ្ធិរបស់អ្នកមានអំណាចខ្លាំង ពីជម្លោះ ពីចម្បាំង។ ពេលខ្លះទៀតគេយកបទនេះទៅពោលក្នុងការសម្តែងរបាំដើម្បីធ្វើឱ្យនាដកនិងនាដកាធ្វើចលនានិងកាយវិការផ្សេងៗតាមដំណើររឿងរ៉ាវនៃអត្ថបទកាព្យ។ បទនេះត្រូវសូត្រដោយមានទម្លាក់សំឡេងនៅព្យាង្គទី ២ និងទី ៤ ។
- **បទពាក្យ ៧ :** បទនេះសូត្របានគ្រប់បរិយាកាសទាំងអស់។ សូត្រពេលរៀបរាប់ពីកំហឹង ការតស៊ូ រៀបរាប់ពីទុក្ខសោក និរាសព្រាត់ប្រាស ភាពសប្បាយរីករាយ សូត្របែបការសន្ទនាឆ្លើយឆ្លង ផ្តោះផ្តង ឬការពណ៌នាពីសម្រស់ធម្មជាតិ សម្រស់តួអង្គ។ល។ បទពាក្យ ៧ ត្រូវសូត្រដោយមានការទម្លាក់សំឡេងលើព្យាង្គទី ២ និងទី ៤ គ្រប់ឃ្លា។
- **បទកាកគតិ :** បទនេះមានចង្វាក់ស្មើមិនលើកមិនដាក់តែរន្ទើនៗមានទំនងដូចជា ដំណើរក្អែក ហើយត្រូវសូត្រទម្លាក់សំឡេងលើព្យាង្គទី ២ គ្រប់ឃ្លា។
- **បទព្រហ្មគីតិ :** សូត្រក្នុងពេលសម្តែងភាពលន្លង់លន្លោច សេចក្តីទុក្ខសោក ការព្រាត់ប្រាស ការប្រដៅ ផ្តែផ្តាំ ឬការឈឺចាប់ចំពោះអំពើជិះជាន់ផ្សេងៗ។ បទនេះត្រូវសូត្រទម្លាក់សំឡេងលើព្យាង្គទី ២ ចំពោះឃ្លាដែលមាន ៥ ព្យាង្គនិងសូត្រទម្លាក់សំឡេងលើព្យាង្គទី ៣ ចំពោះឃ្លាដែលមាន ៦ ព្យាង្គ។ បទនេះមានន័យថា ចម្រៀង ឬទំនួញព្រហ្ម។

លំហាត់

ចូរប្អូនជ្រើសរើសអត្ថបទកំណាព្យដកស្រង់បទផ្សេងៗដូចខាងក្រោមតាមការពេញចិត្តរបស់ប្អូន ហើយសូត្រឱ្យបានត្រឹមត្រូវតាមចង្វាក់នៃបទនីមួយៗ :

បទបន្ទោលកាក

ថ្លែងដោយទំនង ដំណើរត្រីផងយាត្រា
ពើបនឹងជុចណា ត្រីស្រែកថារើយចៀសចេញ ។
ជុចថានេះអើ បុណ្យអ្នកនេះតើម្តេចមិញ
ក៏មកប្រើអញ ចៀសចេញឱ្យអ្នកជាល្បែង ។
ត្រីថាបើថ្នោះ អញនឹងទម្លុះចៅឯង
ឱ្យឈប់ជាក់ស្តែង ត្បិតឯងមកនៅរាំងផ្លូវ ។
ជុចថាអើហោង បើខឹងចង់លងឥឡូវ
នេះហើយសមត្រូវ នឹងម្ហូរប្រហើរសាអាំង ។
ត្រីថានេះអើ ប៉ើងរ៉ើងទេតើម្តេចខ្លាំង
អួតមានកម្លាំង គិតស្មានថាអញខ្លាចហោង ។
ជុចថាបើថ្នោះ អញ្ជើញមកចុះចង់លង
ឱ្យដឹងនេះម្តង ឫទ្ធិតេជៈតេជដៃ ។
ត្រីស្ទុះភ្លាមចូល ក្នុងជុចរមួលហើយនៃ
ជំពាក់ក្រកែ្រ ថយក្រោយពុំរួចឡើយណា ។

(នាគផ្តោះផ្តងជុចនិងត្រីក្នុងល្បើកជុចនិងត្រីរបស់លោក វិសេស ម៉ួង កំណាព្យខ្មែរភាគ ១ក្រសួងអប់រំ ឆ្នាំ ១៩៨៤)

បទភុជង្គលីលា (ច្បាប់ស្រី)

ហែកូនខ្លីមខ្លួនមាតា ជាស្រីនេះណា កម្រណាស់នាង ។
មិនថាត្បិតល្អរូបរាង មិនរើសត្បិតជាង ចេះការទាំងគ្រប់ ។
មិនបានស្គាល់ការគោរព ស្គាល់តែឧបទ្រព ទាំងដប់ប្រការ ។
ហៅតែនឹងល្អរូបា ពិតហើយចេះការ គួរកោតដោយយ៉ាង ។
មួយល្អរូបសសន្លាង ឥតគេផ្ទឹមខាង ច្បាប់ផងមិនចេះ ។
ល្អពិតគំនិតមិនផេះ ទោះខ្មៅក្រងេះ ការសោតសមគួរ ។
គឺទោះនាងនោះមិនជួ ចេះដឹងសមគួរ ស្គាល់អស់ឥរិយា ។
នេះឯងពីព្រេងលោកថា ហៅល្អរូបា កបកល្យាណី ។

(ដកស្រង់ចេញពីច្បាប់ស្រីរបស់បណ្ឌិត ម៉ឺន ម៉ៃ ប្រជុំច្បាប់ឆ្នាំ ១៩៨៧ ទំព័រ ៤៣-៤៤)

បទព្រហ្មគីតិ (ច្បាប់ប្រុស)

នឹងដើរដូចភុជង្គ ឱ្យឱនអង្គអាចបារម្ភ
ឱ្យត្រូវនឹងច្បាប់ក្រម គួរប្រតិបត្តិកុំឱ្យឆ្គង ។
រៀនបទរៀនបាទថាស កុំច្រឡាសលើរៀមច្បង
ស្រដីនឹងអ្នកផង ពាក្យឱ្យគួរកុំឯងរឹ ។
អឺអើអញដាច់សាច់ ឆ្គងពាក្យពេចន៍គេស្រដី
ដើមដៀលឱ្យអប្រិយ ស្រដីថាកូនអត់ពូជ ។
ថាស់ទុំមិនប្រដៅ ជេរកូនចៅទើបវាខូច
ជេរកូនថាឥតពូជ មិនដឹងច្បាប់នឹងថាស់ទុំ ។
គេដៀលដល់ម៉ែឪ កេរ្តិ៍អាស្រូវស្អុយរហ៊ាម
គេស្តីដើមជៀវជុំ ដំនៀលនោះដល់មកថាស់ ។

(ដកស្រង់ពី "ច្បាប់ផ្សេងៗ" ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ទំព័រ ១-២ បោះពុម្ពឆ្នាំ ១៩៧០)

បទពាក្យ ៧

កម្ពុជាតូចពិតតែសម្បត្តិមាន មានគ្រប់ធនធានសម្បូរផល
ផលរ៉ែព្រឹក្សទឹក សុទ្ធតែផ្តល់ ផ្តល់សត្វរចល់ក្នុងព្រៃឈើ ។
ឈើធំភ្នំខ្ពស់ជ្រោះជាមេ មេគង្គទន្លេនាំល្បាប់លើ
លើសលប់វាលស្រែចម្ការធ្វើ ធ្វើផ្តល់ផលលើលើសអស់ដី ។
ដីក្នុងមានថ្មកំបោររ៉ែ រ៉ែត្បូងដែកដែរប្រេងកាតល្បី
ល្បីទន់ឡាបសេដាមេត្រី ត្រីសាបទឹកល្បីធម្មជាតិកេរ ។
កេរកោះសម្បត្តិលទ្ធកម្មស្វែង ស្វែងស្ងប់កោតក្រែងចិត្តបិតថេរ
ថេរបតិកភណ្ឌសល់ដាលដេរ ដេរដាសជាកេរខ្មែរប្រុសស្រី ។
ស្រីប្រុសឧស្សាហ៍ការកសាង សាងពាន់ប្រាប្រាង្គជាស្នាថ្មី
ថ្មីសាងវាវិធានីល្បី ល្បីកសិកម្មដីខ្មែរស្រឡាញ់ ។

(ដកស្រង់ពីកំណាព្យខ្មែរ ភាគ ២ ក្រសួងអប់រំ ឆ្នាំ ១៩៨៥ ទំព័រទី ៤-៥)

អត្ថបទកំណាព្យបទភុជង្គលីលានិងបទបន្ទោលកាក

ប្អូនធ្លាប់សិក្សារួចមកហើយអំពី ពាក្យចួន ផ្ចួន រណ្តំ និងការព្យមាត្រដែលមានក្នុងកំណាព្យបទផ្សេងៗដូចជា បទកាកគតិ បទភុជង្គលីលា បទព្រហ្មគីតិ ពំនោល បទពាក្យ ៧ និងបទបន្ទោលកាក។

ក្នុងមេរៀននេះ ប្អូននឹងហាត់តែងកំណាព្យបទបន្ទោលកាកនិងបទភុជង្គលីលា។

ចូរប្អូនមើលឧទាហរណ៍ខាងក្រោម ៖

បទភុជង្គលីលា

គឺព្រះមានបុណ្យកន្លង	ទេសនាចែងចង	ជាបទគាថា។
រីឯហៅមាតុភរិយា	មាតុភរិយាជា	ទាសភរិយាផង។
ទាំងបួនប្រសើរឥតហ្មង	គួរឱ្យចាំចង	ទុកក្នុងអង្គារ។
រីឯហៅមាតុភរិយា	ប្រពន្ធនោះជា	លោកទុកស្មើម្តាយ។
ចរិតបីប្រការក្នុងកាយ	មួយចង់ខ្ទល់ខ្ទាយ	ប្រយោជន៍ឱ្យប្តី។
បានថ្កើងរុងរឿងឮល្បី	មិនឱ្យអាប់ប្តី	ឱ្យបានសក្តិយស។

(ដកស្រង់ពីច្បាប់ស្រីរបស់ ម៉ឺន ម៉ែ ក្នុងឯកសារប្រជុំច្បាប់ទំព័រ ៤៦-៤៧ចោះពុម្ពឆ្នាំ ១៩៨៧)

- រង្វាស់កាព្យ

  ១វគ្គមាន ៣ឃ្លា។

  - ឃ្លាទី ១ មាន ៦ព្យាង្គ
  - ឃ្លាទី ២ មាន ៤ព្យាង្គ
  - ឃ្លាទី ៣ មាន ៤ព្យាង្គ។

- សញ្ញាចាប់ចុងចួន

  - ព្យាង្គទី ៦ ឃ្លាទី ១ វគ្គទី ១ ⟹ ព្យាង្គ ៤ ឃ្លា ២ វគ្គទី ១
  - ព្យាង្គទី ៤ ឃ្លាទី ៣ វគ្គទី ១ ⟹ ព្យាង្គទី ៦ ឃ្លាទី ១ វគ្គទី ២ ⟹ ព្យាង្គទី ៤ ឃ្លាទី ២ ក្នុងវគ្គទី ២ ឬវគ្គបន្ត។

- ចួនក្នុងវគ្គ

  - ព្យាង្គទី ៦ នៃឃ្លាទី ១ចួននឹងព្យាង្គទី ៤ នៃឃ្លាទី ២។

- ចួនឆ្លងវគ្គ

  - ព្យាង្គទី ៤ នៃឃ្លាទី ៣ ក្នុងវគ្គទី ១ចួននឹងព្យាង្គទី ៦ នៃឃ្លាទី ១ វគ្គទី ២ ចួននឹងព្យាង្គទី ៤ នៃឃ្លាទី ២ វគ្គទី ២។

បទបន្ទោលកាក

ថ្លែងដោយទំនង ដំណើរត្រីផងយាត្រា

ពើបនឹងជុចណា ត្រីស្រែកថារឿយចៀសចេញ ។

ជុចថាអះអើ បុណ្យអ្នកនេះតើម្តេចមិញ

ក៏មកប្រើអញ ចៀសចេញឱ្យអ្នកជាល្បែង ។

ត្រីថាបើថ្នោះ អញនឹងទម្លុះចៅឯង

ឱ្យឃល់ជាក់ស្តែង ត្បិតឯងមកនៅរាំងផ្លូវ ។

(នាគផ្តោះផ្តួងជុចនិងត្រី "ល្បើកជុចនិងត្រី" របស់លោក វិសេស ជួង

កំណាព្យខ្មែរភាគ ១ ក្រសួងអប់រំឆ្នាំ ១៩៨៤ ទំព័រ ៦០)

- **រង្វាស់កាព្យ**

  ក្នុង ១វគ្គមាន ៤ឃ្លា ។

  - ឃ្លាទី ១ មាន ៤ព្យាង្គ
  - ឃ្លាទី ២ មាន ៦ព្យាង្គ
  - ឃ្លាទី ៣ មាន ៤ព្យាង្គ
  - ឃ្លាទី ៤ មាន ៦ព្យាង្គ ។

- **សញ្ញាចាប់ចុងចួន**

  - ព្យាង្គទី ៤ ឃ្លាទី ១ ⟹ ព្យាង្គទី ៤ ឃ្លាទី ២គ្រប់វគ្គ
  - ព្យាង្គទី ៦ ឃ្លាទី ២ ⟹ ព្យាង្គទី ៤ ឃ្លាទី ៣ ⟹ ព្យាង្គទី ២ឬ ៤ នៃឃ្លាទី ៤
  - ព្យាង្គទី ៦ នៃឃ្លាទី ៤ វគ្គទី ១ ⟹ ព្យាង្គទី ៦ នៃឃ្លាទី ២ វគ្គទី ២ ⟹ ព្យាង្គទី ៤ នៃឃ្លាទី ៣ វគ្គទី ២ ⟹ ព្យាង្គទី ២ឬ ៤ នៃវគ្គ ២ឬវគ្គបន្ត ។

លំហាត់

ចូរប្អូនជ្រើសរើសប្រធានបទណាមួយក៏បានមកតាក់តែងជាបទភុជង្គលីលា ឬបទកាកគតិតាមការពេញចិត្ត ។

ប្រធានបទ

- សាមគ្គីនាំមកនូវជ័យជម្នះ
- ព្យាយាមគង់បានសម្រេច

សេចក្តីណែនាំ

មុននឹងចាប់ផ្តើមសរសេរ ចូរប្ជូនអនុវត្តតាមការណែនាំខាងក្រោម ៖

- ជ្រើសរើសប្រធានបទ
- កំណត់បទដែលត្រូវតែង (ជាបទបន្ទោលកាកឬបទភុជង្គលីលា)
- លើកគំនិតសំខាន់ៗដែលទាក់ទងនឹងប្រធានបទ
- កំណត់គំនិតសំខាន់របស់អត្ថបទ
- តាក់តែងតាមក្បួនកាព្យនៃបទនីមួយៗដោយគោរពតាមទម្រង់ឧទាហរណ៍ខាងលើ ៖
- រង្វាស់កាព្យ
  - ចំនួនឃ្លានៅក្នុងវគ្គ
  - ចំនួនព្យាង្គនៅក្នុងឃ្លានីមួយៗ
- ចំណាប់ចុងចួន : តាមបទភុជង្គលីលា ឬបទបន្ទោលកាក ដោយគោរពបានតាមក្បួនចាប់ចុងចួនត្រឹមត្រូវតាមសូរពួកអនិងពួកអ ពួកអ៊ីនិងពួកអ៊ី ចួនស្រៈនិងស្រៈ ឬប្រកបនឹងព្យញ្ជនៈ។
- ផ្ទួនឬរណ្តំ : ស្រៈនិងស្រៈ ព្យញ្ជនៈនិងព្យញ្ជនៈ ... ។
- សរសេរតាមលំដាប់លំដោយគំនិតឱ្យបានត្រឹមត្រូវ
- ចៀសវាងកំហុសអក្ខរាវិរុទ្ធ ឬការប្រើពាក្យមិនសមស្រប
- ប្រើប្រាស់ឈ្នះទោលនិងឈ្នះផ្សំបានត្រឹមត្រូវ
- ពិនិត្យនិងផ្ទៀងផ្ទាត់ឡើងវិញឱ្យបានត្រឹមត្រូវទាំងខ្លឹមសារចំណាប់ចុងចួននិងសញ្ញាសម្ព័ន្ធផ្សេងៗ ដូចជា ខណ្ឌសញ្ញាជាដើម
- សរសេរសម្រេចដោយផ្ទៃតផ្ទង់ ដើម្បីឡើងបង្ហាញ ។

មេរៀនទី

១០ ពលរដ្ឋល្អ

ពលរដ្ឋម្នាក់ៗជាកោសិការបស់ប្រទេសជាតិ។ ប្រទេសជាតិអាចស្ថិតស្ថេរគង់វង្ស និងមានការរីកចម្រើនលូតលាស់អាស្រ័យដោយប្រទេសនេះសម្បូរទៅដោយពលរដ្ឋល្អ។ ពលរដ្ឋល្អត្រូវមានចំណេះដឹង ជំនាញ ឥរិយាបថនិងសីលធម៌ល្អ។ តើអ្នកទាំងអស់គ្នា បានត្រៀមខ្លួនឱ្យក្លាយជាពលរដ្ឋល្អហើយឬនៅ ? តើពលរដ្ឋល្អត្រូវមានតួនាទីនិងភារកិច្ចដូចម្តេចខ្លះចំពោះជាតិមាតុភូមិ ?

មេរៀននេះបានបង្ហាញអំពីភារកិច្ចនិងតួនាទីរបស់ពលរដ្ឋទាំងប្រុសស្រីក្នុងការរួមចំណែកការពារ និងកសាងជាតិ។ ទន្ទឹមនឹងនេះ អ្នកនឹងបានសិក្សាផងដែរអំពី ប្រលោមលោកទំនើប សំណេរសំបុត្រ ការធ្វើសម្ភាសន៍ ល្បះក្រង។

ប្រលោមលោកទំនើប

យើងធ្លាប់សិក្សារួចមកហើយអំពីប្រភេទរឿងនិទាន កំណាព្យ ល្ខោន។ ឥឡូវអ្នកនឹងសិក្សាអំពីរឿងប្រលោមលោកទំនើប។ រឿងប្រលោមលោក គឺរឿងប្រលោមចិត្តមនុស្ស ដែលអ្នកតែងប្រឌិតប្រដូចឡើងតាមទំនងព្រឹត្តិការណ៍ក្នុងសង្គម រឿងប្រលោមលោក និយាយអំពីជីវិត ជំនឿ ទំនៀមទម្លាប់ ជីវភាពរស់នៅ ស្នេហា ប្រវត្តិសាស្ត្រ ដែលកើតមានជាក់ស្តែងក្នុងសង្គម។ ប្រលោមលោកទំនើប ជាប្រភេទអក្សរសិល្ប៍ដែលស្ថិតនៅក្នុងសម័យបច្ចុប្បន្ននេះ និងប្រភេទស្នាដៃដែលកើតក្រោយសង្គ្រាមលោកលើកទី ២។ តាមរយៈគោលគំនិតនៃស្នាដៃទាំងនេះ គេសង្កេតឃើញអក្សរសិល្ប៍ខ្លះមានទំនោរទៅរកនិន្នាការជាតិនិយម និងខ្លះទៀតធ្ងន់ទៅលើមនោគមន៍វិជ្ជា។ ស្នាដៃបែបនេះឆ្លុះបញ្ចាំងពីតថភាពនៅក្នុងសង្គមបានច្បាស់លាស់តាមសម័យកាលនីមួយៗនិងបណ្តុះនូវទស្សនៈវិទ្យាសាស្ត្រ បច្ចេកទេសជឿនលឿន ដល់អ្នកអានអ្នកសិក្សាក្នុងការជួយកសាងសង្គមជាតិឱ្យរីកចម្រើន។

ប្រលោមលោកទំនើបមានច្រើនប្រភេទដូចជាប្រលោមលោកបែបស្នេហា ប្រលោមលោកបែបមនោគមវិជ្ជានិងប្រលោមលោកបែបប្រវត្តិសាស្ត្រជាដើម។ ក្នុងរឿងនីមួយៗរមែងបង្កប់នូវចំណុចសំខាន់ៗដូចជា ៖

១ . អត្ថន័យ

អ្នកនិពន្ធច្រើនលើកមកបង្ហាញដូចជា បញ្ហាតួអង្គ បញ្ហាជំនឿ បញ្ហាស្នេហា បញ្ហាវណ្ណៈ ...នៅក្នុងសង្គមជាក់ស្តែង ដែលក្នុងនោះមានបញ្ហាចោទ និងដោះស្រាយដូចជា ៖

- វិធីចោទ គឺការចោទដោយផ្អែកទៅតាមសម័យកាលនីមួយៗ ដែលតែងតែមានរឿងរ៉ាវ ឬព្រឹត្តិការណ៍សំខាន់ៗហើយប្លែកៗគ្នា ដោយទ្រទ្រង់ចិត្តគំនិត មនោសញ្ចេតនា ទស្សនៈរបស់មនុស្សជាជរាប។
- វិធីដោះស្រាយ គឺដោះស្រាយដោយសមត្ថភាពផ្ទាល់ខ្លួនរបស់តួអង្គ ភាពចៃដន្យ កម្លាំងសាមគ្គីសមូហភាព គ្រួសារ សង្គម។

២ . អត្ថរូប

អ្នកនិពន្ធបានប្រើសិល្ប៍វិធីតែងនិពន្ធដោយមាន

ក. អារម្ភកថា

ខ. ផ្តើមរឿង

ការផ្តើមរឿងពុំសូវមានលក្ខណៈឯកភាពគ្នាទេ គឺអាស្រ័យទៅតាមសិល្បវិធីរបស់អ្នកនិពន្ធម្នាក់ៗ។ យើងសង្កេតឃើញថា អ្នកនិពន្ធបានប្រើវិធីផ្តើមរឿងដោយការបង្ហាញធម្មជាតិនៅត្រង់កន្លែងណាមួយ ការបង្ហាញឈ្មោះតួអង្គឬទំនាស់ការបង្ហាញសកម្មភាព។ល។ រួចភ្ជាប់ទៅនឹងដំណើររឿងតែម្តង។

ឧទាហរណ៍ : រឿងកុលាបម៉ៃលិន អ្នកនិពន្ធផ្តើមរឿងដោយពណ៌នារៀបរាប់ពីទីកន្លែងរបស់តួអង្គ។ រឿងសូជាត អ្នកនិពន្ធផ្តើមដោយបរិយាយពីប្រវត្តិរបស់តួអង្គតែម្តង។ រឿងផ្កាស្រពោន អ្នកនិពន្ធផ្តើមរឿងដោយពណ៌នាពីទេសភាព "រទេះភ្លើងបោលលឿនដូចព្យុះកាត់ព្រៃខ្លុង ..."។ រឿងទុំទាវ អ្នកនិពន្ធផ្តើមដោយពណ៌នាពីប្រវត្តិតួអង្គ "នេះនឹងថ្លាថ្លែងដើមឈ្មោះទុំ នៅខេត្តបាភ្នំដែនដីស្រែ កើតកបទំនៀមមានឪម៉ែ ប៉ុន្តែហេតុត្បិតឥតសម្តែង ..."។

រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ អ្នកនិពន្ធផ្តើមរឿងដោយបង្ហាញសកម្មភាព "រថអយស្ម័យយានបានដឹកនាំអ្នកដំណើរពីស្ថានីយបាត់ដំបង ហើយបោលយ៉ាងលឿនសំដៅទៅទីក្រុងភ្នំពេញដោយបញ្ចេញសន្ធឹកខ្ទុះខ្ទារស្ទើរញ័រប្រិចពី។ អ្នកជិះភាគច្រើនបាននាំគ្នាធ្វើដំណើរទៅកាន់ព្រះរាជធានីដើម្បីចូលរួមក្នុងពិធីសមាជជាតិលើកទី ៩។ ... ក្នុងចំណោមអ្នកដំណើរដែលកំពុងសប្បាយរីករាយទាំងនេះ ពិនិត្យឱ្យបានហ្មត់ចត់ទៅឃើញបុរសម្នាក់រាងធំដំបង សម្បុរសណ្តែកបាយ សក់រួញ ..."។

គ. តួរឿងឬដំណើររឿង

នៅក្នុងតួរឿងឬដំណើររឿង អ្នកនិពន្ធប្រើវិធីច្រើនយ៉ាង ដើម្បីធ្វើឱ្យសាច់រឿងមានសកម្មភាពប្រទាក់ក្រឡាគ្នា ហើយមានភាពរស់រវើក ធ្វើឱ្យអ្នកអាន អ្នកស្តាប់ អ្នកទស្សនាជក់ចិត្តជិតអារម្មណ៍។ វិធីទាំងនោះមាន ៖

- **វចនវិធី :** វិធីប្រើប្រាស់ពាក្យពេចន៍នៅក្នុងអត្ថបទ។ ពាក្យពេចន៍ត្រូវឱ្យស្របតាមស្ថានភាពសង្គមបរិយាកាស តួនាទី ឋានៈ មុខរបរ និងតាមប្រភេទនៃរឿងផងដែរដូចជា ពាក្យពេចន៍របស់កសិករ អាជីវករ មន្ត្រី រាជការ រាជសព្ទ សង្ឃសព្ទជាដើម។
- **រចនាវិធី :** វិធីប្រើប្រាស់ឃ្លាល្បះ ដើម្បីឱ្យស្នាដៃឬអត្ថបទរឿងមានសម្រស់ទាក់ទាញអារម្មណ៍ បង្កើតបាននូវបរិយាកាសអណ្តែតអណ្តូង រំភើបរីករាយ កើតទុក្ខ ព្រួយបារម្ភ ...។
- **សន្ទេហាវិធី :** វិធីដែលអ្នកនិពន្ធធ្វើឱ្យអ្នកអាន អ្នកទស្សនាងឿងឆ្ងល់ចង់តាមដានទស្សនា គឺអាស្រ័យលើអ្នកនិពន្ធមានទេពកោសល្យក្នុងការបញ្ចូលសន្ទេហាវិធីនេះឯងដូចជាក្នុងរឿងទុំទាវពេលព្រះរាជាជ្រើសរើសទាវទៅធ្វើជាស្នំ តើស្នេហាទុំនិងទាវនឹងទៅជាយ៉ាងណា ? ពេលម្តាយកុហកទាវយកទាវមករៀបការជាមួយម៉ឺនងួន តើស្នេហាទុំនិងទាវទៅជាយ៉ាងណា ?

- បដិវិធីឬវិធីផ្ទុយ : វិធីដែលអ្នកនិពន្ធប្រើសម្រាប់ធ្វើឱ្យតួអង្គមានទំនាស់វិបត្តិគ្នាខាងពាក្យសំដី កាយវិការ វាចាចិត្ត ។
- វណ្ណនាវិធី : វិធីដែលអ្នកនិពន្ធលើកយកតួអង្គ ព្រឹត្តិការណ៍ ធម្មជាតិ ទេសភាព សកម្មភាព មកពណ៌នារៀបរាប់ឱ្យឃើញច្បាស់ហាក់នៅនឹងភ្នែកស្រស់ៗ ។
- ឧបមានវិធី : វិធីដែលអ្នកនិពន្ធធ្វើការប្រៀបធៀបតួអង្គឬសកម្មភាពតួអង្គនៅក្នុងដំណើររឿង ដើម្បីរំលេចនូវជីវរូបារម្មណ៍ ឬមនោរម្មណ៍ ។

  ឧទាហរណ៍ : រឿងទុំទាវ

  ខ្លួនប្អូនសព្វថ្ងៃប្រៀបដូចផ្កា ខ្លួនអ្នកឧបមាដូចកន្លង់
  ហើរកឃើញផ្កាចូលត្រឹមត្រង់ រួចមិនបង្អង់ត្រាច់លីលា ។
  ទុំថាខ្លួនបងដូចរាជសីហ៍ ខ្លួននាងទាវស្រីដូចគុហា
  រាជសីហ៍បើបានលំនៅជា មិនឱ្យឃ្លាតឃ្លាគុហាឡើយ ។
- សំវាទវិធី : វិធីដែលអ្នកនិពន្ធធ្វើឱ្យតួអង្គពីរនាក់ឡើងសន្ទនាឆ្លើយឆ្លងគ្នាអំពីបញ្ហាអ្វីមួយ ។

  ឧទាហរណ៍ : រឿងទុំទាវ ក្នុងពេលគេដង្ហែនាងទាវទៅថ្វាយព្រះរាជា ទាវនិយាយទៅកាន់នាង នោថា ៖

  បងមិនអាណិតចិត្តប្អូនផង ទុក្ខធ្ងន់កន្លងពុំមានស្បើយ
  សមប្អូនក្សិណក្សួយទេដឹងអើយ ទុក្ខអើយពោរពេញជាថ្មី ។
  ទុក្ខមួយព្រួយព្រោះអង្គក្សត្រា យកជាសង្សារមួមបេតី
  ទុក្ខមួយឃ្លាតទុំនោមពិសី រស់ថ្ងៃសូវស្លាប់ទៅក៏ជា ។
- ឯកវាទវិធី : វិធីដែលគេធ្វើឱ្យតួអង្គមួយរងទុក្ខទោសមានការឈឺចាប់ក្នុងខ្លួន ឬមានវិប្បដិសារីអំពីរឿងអ្វីមួយដោយមានការនិយាយរំឭកអំពីហេតុភេទឬរឿងរបស់ខ្លួនតែម្នាក់ឯង ។

  ឧទាហរណ៍ : ក្នុងរឿងកុលាបប៉ែលិន ចៅចិត្របាននិយាយម្នាក់ឯងថា "ឱ! ខ្លួនអញអើយ កណ្តោចកណ្តែង ខ្លោចផ្សាតែម្នាក់ឯង ហើយងាកទៅពឹងបងប្អូនញាតិសាច់សាលោហិតជិតខាងឯណាក៏គ្មាន ..." ។
- វឌ្ឍមានវិធី : វិធីដែលអ្នកនិពន្ធប្រើដើម្បី ធ្វើឱ្យដំណើររឿងកាន់តែតឹងតែងឡើងៗតាំងពីកម្រិតទាបរហូតដល់ខ្ពស់ ។
- ឧបកថាវិធី : វិធីដែលអ្នកនិពន្ធចែកដំណើររឿងជាដំណាក់ៗ ។ មានន័យថា កំពុងតែនិយាយអំពីហេតុការណ៍ត្រង់នេះស្រាប់តែដំណើររឿងត្រូវផ្អាក ហើយចាប់រឿងផ្សេងមកនិយាយវិញម្តង ។

- **បុនរុត្តិវិធី** : វិធីតែងកាព្យ ដែលធ្វើឱ្យផ្ទួនពាក្យសម្តីដែលអ្នកនិពន្ធប្រើដើម្បីបញ្ជាក់សកម្មភាពរបស់តួអង្គឱ្យកាន់តែជាក់ស្តែងថែមទៀត ។

  ឧទាហរណ៍ : នៅក្នុងរឿងកាកី

និកៗថាអេះ	នាងនេះល្អម្ល៉េះ	នេះហៅល្អល្អន់
ត្រកាលឃើញម្តង	នេះហោងហៅបុណ្យ	គ្មានស្រីណាប៉ុន
	ល្អពន់ប្រមាណ ។	
អេះនេះហៅល្អ	ល្អច្នេះរកក្រ	ក្រែរកទៀតគ្មាន
អញធ្លាប់ឃើញសត្វ	និងរាប់ពុំបាន	ពុំដែលឃើញមាន
	ឱ្យល្អដូច្នេះ ។	

- **ហាសវិធី** : វិធីដែលអ្នកនិពន្ធប្រើក្នុងដំណើររឿង ធ្វើឱ្យអ្នកអាន អ្នកស្តាប់ផ្ទុះសំណើចដោយមិនដឹងខ្លួន ។
- **ប្រលោមវិធី** : វិធីដែលអ្នកនិពន្ធចេះលួងលោម បបោសអង្អែលធ្វើឱ្យអ្នកអាន អ្នកស្តាប់ រីករាយរំភើប អណ្តែតអណ្តូងតាមដំណើររឿង ។
- **ទារុណវិធី** : វិធីដែលអ្នកនិពន្ធធ្វើឱ្យដំណើររឿងមានភាពកម្សត់ព្រាត់ប្រាស់និងការធ្វើទុក្ខទោសតួអង្គ ។

ឃ. ការបញ្ចប់រឿង

នៅចុងបញ្ចប់នៃរឿងអ្នកនិពន្ធមានសិល្បវិធីដោយខ្លែកៗក្នុងការបញ្ចប់រឿងរបស់ខ្លួន ដោយពុំមានក្បួនឬលក្ខណៈឯកភាពគ្នាទូទៅឡើយ គឺអាស្រ័យទៅតាមគោលបំណងឬទស្សនៈរបស់អ្នកនិពន្ធ ។ អ្នកនិពន្ធខ្លះបញ្ចប់រឿងដោយឱ្យតួអង្គឯករបស់រឿងនៅរស់ ជួនកាលឱ្យតួអង្គឯកស្លាប់ ជួនកាលបញ្ចប់រឿងទាំងមូលដោយក្តីសង្ឃឹមគ្រប់គ្នា ជួនកាល បញ្ចប់រឿងទាំងមូលដោយក្តីអស់សង្ឃឹមឬបរាជ័យ ជួនកាលបញ្ចប់រឿងដោយបង្ហាញជោគជ័យរបស់តួអង្គ និងផ្តល់ភាពសប្បាយរីករាយដល់អ្នកអាន អ្នកស្តាប់ ។

ឧទាហរណ៍ : នៅក្នុងរឿង កុលាបប៉ៃលិនអ្នកនិពន្ធបានបញ្ចប់រឿងដោយឱ្យតួអង្គសំខាន់ទទួលបានជោគជ័យនិងភាពសុខដុមរមនា "លុះបានឫក្សវេលាល្អតាមឫក្សហោរាសាស្ត្រ ទើបហ្លួងរតនសម្បត្តិចាត់ចែងរឿងមង្គលការ អាពាហ៍ពិពាហ៍រវាងនាងក្រមុំឃុនឥន្ទ្រី បុត្រីលោកជាគូនឹងចៅចិត្រ ។ នៅឱកាសនោះ លោកអញ្ជើញអ្នកមុខអ្នកការទាំងអស់រាជការ ជំនួញ ... ។ លុះចំណេរកាលតមក គូស្វាមីភរិយាទាំងពីរនាក់ក៏បានរួមរស់ជាមួយគ្នាជាសុខក្សេមក្សាន្ត លុះត្រាតែកើតជាកូនពូនជាចៅតរងឫត្រកូលរៀងទៅហោង" ។

៣ . អត្ថរស

ស្នាដៃអក្សរសិល្ប៍ដែលល្អគឺអាស្រ័យលើគោលធំៗបីគឺ អត្ថន័យ អត្ថរូប និងអត្ថរស។ យើងអាចចែកអត្ថរសនៅក្នុងអត្ថបទអក្សរសិល្ប៍ជាបីគឺ បច្ចេករស វិសេសរស និងសព្វរស។

ក. បច្ចេករស

ជាតម្លៃដែលអ្នកនិពន្ធបានបង្កើតឡើងពិសេសសម្រាប់តាក់តែងនិពន្ធរឿងរ៉ាវផ្សេងៗក្នុងអក្សរសិល្ប៍។ គេអាចឱ្យឈ្មោះតម្លៃសិល្បៈកែច្នៃនូវអត្ថបទផ្សេងៗគ្នានៃអក្សរសិល្ប៍នោះថា បច្ចេករសបច្ចេកសិល្បារម្មណ៍រសដែលមាន ៖

- **កាព្យរស** : តម្លៃដែលកវីរចនាអត្ថបទជាពាក្យកាព្យឱ្យមានសម្ផស្ស ចួនរណ្តំណែងណងក្នុងការពណ៌នារៀបរាប់អ្វីមួយធ្វើឱ្យអ្នកអានអ្នកស្តាប់រំភើបតាមដំណើររឿងដែរ។
  ឧទាហរណ៍ : កំណាព្យរៀបរាប់ពីព្រះអាទិត្យអស្តង្គត រៀបរាប់ធម្មជាតិ ព្រៃព្រឹក្សាទេសភាពសត្វម្រឹគីម្រឹគា ដោយប្រើពាក្យពេជន៍ចួនរណ្តំពីរោះដល់ត្រចៀក រំភើបដល់ចិត្តទៀតផង។
- **ប្រលោមរស** : តម្លៃដែលអ្នកនិពន្ធបង្កើតជាដំណើររឿងក្តី ជាសកម្មភាពតួអង្គក្តីធ្វើឱ្យមានភាពអណ្តែតអណ្តូង ស្នេហាក្រោមពន្លឺព្រះចន្ទ កម្សត់លើផ្នូកខ្សាច់ លើកោះ។ល។
  ឧទាហរណ៍ : រឿងផ្កាស្រពោន និយាយពីដំណើរតាមរថភ្លើងរបស់ប៊ុនធឿនទៅស្រុកកំណើតទាំងកណ្តោចកណ្តែងក្នុងចំណោមមិត្តភក្តិទាំងឡាយដែលសប្បាយរីករាយ ព្រោះតែនឹកសង្សារផ្ទះសម្បែង និងឪពុកម្តាយ។ លក្ខណៈនេះធ្វើឱ្យអ្នកអានរំភើប កើតនូវការកម្សត់ សប្បាយព្រួយជាមួយតួអង្គក្នុងរឿងដែរ។
- **នាដករស** : តម្លៃដែលអ្នកនិពន្ធប្រើនៅក្នុងការសរសេររឿងល្ខោនដោយមានការរៀបរាប់ពីដំណើររឿងក្នុងអត្ថបទល្ខោនឱ្យមានលក្ខណៈឯកភាពទាំងក្នុងសកម្មភាព ទីកន្លែង និងពេលវេលា។

ខ. វិសេសរស

ជាតម្លៃដែលអ្នកនិពន្ធបានបង្កើតឡើងពិសេសៗនៅក្នុងការតាក់តែងនិពន្ធល្ខោន កំណាព្យ រឿងព្រេង រឿងល្បើក ឬអត្ថបទផ្សេងៗក្តី។ វិសេសរសមានច្រើនប្រភេទដូចជា ៖

- **សុន្ទរីរស(តម្លៃល្អ)** : តម្លៃល្អដែលធ្វើឱ្យអ្នកអាន អ្នកទស្សនាឱ្យតម្លៃទៅលើរឿងដែលខ្លួនពេញចិត្តទោះបីរឿងនោះអាក្រក់ក៏ដោយ។ ល្អម្យ៉ាងទៀត គឺល្អដោយសារអ្នកនិពន្ធបង្ហាញលក្ខណៈតួអង្គត្រឹមត្រូវតាមការពិត សេចក្តីពិត ឬរូបលក្ខណៈពិត។ ល្អម្យ៉ាងទៀត ដោយសារអ្នកនិពន្ធចេះពណ៌នារូបភាព លក្ខណៈសកម្មភាពរបស់តួអង្គ ដំណើររឿង ធម្មជាតិ ទេសភាពនៅក្នុងរឿង។

ឧទាហរណ៍ : រឿងកាកី អ្នកនិពន្ធបង្ហាញថា រូបសម្ផស្សស្រស់នាងកាកី ល្អទាំងគ្រប់ ល្អទាំងកាយពាក្យសម្តី ។

- **វិហាសរូបរស(តម្លៃអាក្រក់) :** តម្លៃដែលអ្នកនិពន្ធបង្ហាញទៅលើលក្ខណៈអាក្រក់របស់តួអង្គក្តី លក្ខណៈសកម្មភាពក្តីតាមរយៈការពណ៌នានេះធ្វើឱ្យមានភាពប្រត្យក្សអំពីរឿងរបស់តួអង្គដើម្បីបង្កើតនូវសោភណភាពនៃរឿង ។

  ឧទាហរណ៍ : រឿងរាមកេរ្តិ៍ វិហាសរូបរសត្រង់កន្លែងដែលអ្នកនិពន្ធបង្ហាញនូវរូបលក្ខណៈរបស់តួអង្គ កូវ័ន ជាថ្មើរព្រៃ មានរូបរាងអាក្រក់តែមានទឹកចិត្តល្អបរិសុទ្ធស្គាល់គុណទោស ។ រីឯការពណ៌នាពីតាជូជក នៅក្នុងរឿងព្រះវេស្សន្តរគឺអាក្រក់ទាំងរូប សម្បុរ ទាំងកាយនិងចិត្ត ។

- **វិសិដ្ឋរស :** តម្លៃដែលស្តែងឡើងដោយអ្នកនិពន្ធបង្ហាញនូវសកម្មភាពអស្ចារ្យរបស់តួអង្គក្នុងការធ្វើពលិកម្មអ្វីមួយដែលសកម្មភាពខ្លះមានការលះបង់ខ្ពស់រហូតដល់មនុស្សធម្មតាធ្វើពុំដូចទៀតផង ។

  ឧទាហរណ៍ : តួអង្គព្រះពោធិសត្វក្នុងរឿងព្រះវេស្សន្តរបានដាក់ទានតាំងពីទ្រព្យសម្បត្តិ រហូតដល់ប្រពន្ធកូនខ្លួនឯងថែមទៀតផង ។

- **រីររស :** តម្លៃដែលអ្នកនិពន្ធបង្ហាញនូវលក្ខណៈអាកប្បកិរិយា ចិត្តភ្លាហានមោះមុតរបស់តួអង្គក្នុងការប្រយុទ្ធ ដោយកាយវាចាចិត្តឬក្នុងអំពើណាមួយដើម្បីទប់ទល់តតាំងនឹងអំពើអ្វីមួយដែលមានលក្ខណៈមិនល្អ ។

  ឧទាហរណ៍ : ក្នុងរឿងកុលាបប៉ៃលិនថៅចិត្រមានសេចក្តីក្លាហានចេញមុខប្រយុទ្ធតតាំងជាមួយក្រុមចោរដែលស្នាក់ប្លន់ដំណើររបស់ក្រុមគ្រួសារលោកហ្លួងរតនសម្បត្តិ ។ រឿងរាមកេរ្តិ៍ ហនុមានតតាំងនឹងទ័ពយក្សក្នុងសង្គ្រាមដណ្តើមនាងសិតា ។

- **ទារុណរស :** តម្លៃដែលអ្នកនិពន្ធរៀបរៀងរឿងឡើងធ្វើឱ្យឃើញនូវសកម្មភាពប្រយុទ្ធ ការព្យាបាទសងសឹក ជិះជាន់ រំលោភធ្វើទុក្ខទោសទណ្ឌកម្មយ៉ាងយោរយៅអស្ចារ្យរហូតដល់បាត់បង់ជីវិតតួអង្គទន់ខ្សោយដែលគ្មានសមត្ថភាព ។

- **នាដ្យរស :** តម្លៃដែលចេញមកពីការកម្សត់នៅក្នុងរឿងវិបត្តិទំនាស់ ប្រឆាំងរវាងតួអង្គបដិបក្ខដ៏មានកម្លាំង សមត្ថភាព មធ្យោបាយ គ្រឿងការពារប៉ុនគ្នា ស្មើគ្នា ។

  ឧទាហរណ៍ : សង្គ្រាមរវាងព្រះរាម និងក្រុងរាពណ៍ ក្នុងរឿងរាមកេរ្តិ៍បានបន្សល់ទុកនូវការបែកបាក់ព្រាត់ប្រាសបងប្អូន សាច់ញាតិ ក្រុមគ្រួសាររបស់ជាតិយក្សក៏ដូចជាពួកស្វាសុទ្ធតែទទួលនូវសោកនាដកម្ម ។

- **ហាសរស** : តម្លៃដែលកើតឡើងមកពីលក្ខណៈសកម្មភាពឬចលនានៃរឿងក្តី នៃតួអង្គក្តីក្នុងការបង្កើតភាពកំប្លែងធ្វើឱ្យអ្នកអាន អ្នកស្តាប់សប្បាយរីករាយសើចអបអរសាទរជ្រះថ្លាក្នុងចិត្ត ។

  ឧទាហរណ៍ : រឿងធនញ្ជ័យត្រង់សកម្មភាពរបស់ធនញ្ជ័យពេលសេះដាក់ក្នុងថង់យាមជូនសេដ្ឋីហួប ធនញ្ជ័យជិះសេះចត្រង្គ ជិះដើរដោលនឹងថ្នោលបើកក្តោងតាមស្តេច ។ល ។

- **សោភ័ណរស** : តម្លៃដែលធ្វើឱ្យអក្សរសិល្ប៍មានលក្ខណៈល្អប្រសើរគឺ ល្អក្នុងផ្នែកអត្ថន័យប៉ិនចោទ ប៉ិនស្រាយ ។ ល្អក្នុងផ្នែកអត្ថរូប គឺអត្ថបទមានភាពទាក់ទាញអារម្មណ៍អ្នកអានឱ្យចូលចិត្តពីរោះស្តាប់ និយាយខ្លីងាយយល់ ។

- **ទស្សនីយរស** : តម្លៃដែលកើតឡើងតាមរយៈការរៀបរាប់ទេសភាព ធម្មជាតិ ព្រៃព្រឹក្សា មច្ឆាបក្សាបក្សីប្រកបដោយសូរស័ព្ទ សំឡេងពីរោះរណ្តំគ្នានៃស្រៈ និងព្យញ្ជនៈបង្កើតជាបរិយាកាសមួយ ។

  ឧទាហរណ៍ : ក្នុងរឿងទុំទាវ ការរៀបរាប់ទេសភាពធម្មជាតិតាមដងទន្លេមេគង្គពីក្រុងលង្វែកមកស្រុកត្បូងឃ្មុំ ក្នុងពេលដែលព្រះរាមាទ្រង់យាងមកជំនុំជម្រះក្តីអរជូន និងក្រុមបក្សពួក ។

គ. **សព្ទរស**

ជាតម្លៃខួរទៅនៃរឿងដែលកវីនិពន្ធតែងលើកយកមកប្រើក្នុងអត្ថបទ ឬស្នាដៃរបស់ខ្លួនមានដូចជា ៖

- **តថរស** : តម្លៃដែលអ្នកនិពន្ធយកតួអង្គជាក់ស្តែងមានមនុស្សគ្រប់វ័យនិងលើកយកបញ្ហាជីវភាពប្រចាំថ្ងៃរបស់មនុស្សមានដូចជា ទំនាស់វិបត្តិផ្សេងៗទាក់ទងនឹងការគ្រប់គ្រងសង្គមជំនឿ ប្រពៃណី សាសនា មកធ្វើការតាក់តែងនិពន្ធឱ្យឃើញជាក់ច្បាស់នឹងភ្នែក ងាយយល់ងាយស្តាប់ ។

  ឧទាហរណ៍ : រឿងទុំទាវ បានបង្ហាញយ៉ាងជាក់ច្បាស់អំពីតថភាពសង្គមខ្មែរសម័យលង្វែកដែលពេលនោះ ប្រជាជនខ្មែរប្រកាន់ខ្ជាប់នូវប្រពៃណីនំមិនធំជាងនាឡិក្នុងការទុកដាក់កូនចៅឱ្យមានគូស្រករ ។

- **អច្ឆរិយរស** : តម្លៃស្តែងចេញតាមរយៈការលើកឡើងរបស់អ្នកនិពន្ធក្នុងការយកតួអង្គអរូបីឬតួអង្គសត្វចេះនិយាយ តួអង្គទេវៈឬសកម្មភាពអស្ចារ្យ ចេះហោះហើរ ប្រែកាឡា បែងភាគ ។ លក្ខណៈអស្ចារ្យទាំងនេះជាតម្លៃអច្ឆរិយៈ ។

- កុសលរស : តម្លៃដែលស្ថិតនៅលើការអប់រំទូន្មានប្រៀនប្រដៅ(ពិសេសកុសលនៅក្នុងរឿងផ្ដែកមនោគតិនិយម) នៅក្នុងក្បួនច្បាប់ផ្សេងៗហៅថា ច្បាប់ឧបទេសដែលមាននៅក្នុងពាក្យសុភាសិត ពាក្យទំនីមទំនៀម ពាក្យទូន្មាន ពុទ្ធភាសិតនៅក្នុងរឿងព្រេង រឿងល្បើកដែលស្ដែងឡើងតាមរយៈអត្ថន័យរបស់អត្ថបទឬសកម្មភាពរបស់តួអង្គជាដើម ។

សំណួរ

១. ដូចម្ដេចហៅថា ប្រលោមលោកទំនើប ? តើរឿងប្រលោមលោកទំនើបបានចាប់ផ្ដើមពីពេលណា ?

២. តើរឿងប្រលោមលោកទំនើប មានធាតុសំខាន់ៗអ្វីខ្លះ ? ចូរបង្ហាញ ។

លំហាត់

១. ក្នុងចំណោមរឿងខាងក្រោម តើរឿងណាខ្លះជាប្រលោមលោកទំនើប ?

- រឿងផ្កាស្រពោន
- រឿងថៅកែចិត្តចោរ
- រឿងស្នាន់ទីទុយនិងអណ្ដើក
- រឿងកុលាបប៉ៃលិន
- រឿងទីក្រុងភ្នំពេញ
- រឿងប្រាសាទតាព្រហ្ម
- រឿងសូផាត
- រឿងស៊ីមបរឡាន
- រឿងចចក
- រឿងប្រាសាទភ្នំបាយ័ង់កោរ
- រឿងតេជោយ័ត
- រឿងសង្គ្រាមរវាងគីង្គក់និងតាព្រហ្ម ។

២. ចូរអ្នករករឿងប្រលោមលោកទំនើបខ្មែរនិងបរទេសឱ្យបានយ៉ាងតិចពីររឿង រួចបង្ហាញមូលហេតុដែលអ្នកចាត់ទុករឿងទាំងនោះជាប្រលោមលោកទំនើប ។

ភ្ជាក់រឭក



ក. សិក្សាពាក្យគន្លឹះ

- យ៉ាប់ (គុ) : ដែលនឿយហាត់ខ្លាំង ដែលធ្ងន់ហួសកម្លាំង ដែលដុនជាបត្រដាបត្រដួស ដែលលំបាកខ្លាំង ។
- វក់រី (កិ) : វិលចុះវិលឡើងដដែលៗដូចគេរី ។
- ធុរៈ (ន) : រវល់ ដំណើរជំពាក់ដោយកិច្ចនីមួយៗ ។
- ទើសទាស់ (កិ) : ទើសផងទាស់ផងគឺ ទើសដំណើរទាស់ទំនងដោយស្គាល់យោគយល់គ្នាជាដើម ។
- ស្និទ្ធស្នាល (គុ) : ដែលជាទីស្រឡាញ់ ជាទីពេញចិត្ត ជិតជិតនិងគ្នាឥតរង្កៀស ។
- រំលោភ (កិ) : បំពានដោយសេចក្តីលោភ បំពានបំពារទាំងអំណាច ប្រព្រឹត្តល្មើស ។
- ញោស (គុ) : ដែលចាស់គ្រាំគ្រាខ្ចែមទ្រមខ្លាំង ទុំខ្លាំង(ផ្លែឈើ) ។
- ឃុំ (កិ) : ខាំងរក្សាមិនឱ្យទៅណាតាមអំពើចិត្ត ។
- ឱកាស (ន) : វេលាទំនេរ ពេលស្រួល ការយល់ព្រមតាម ទីទំនេរ ចន្លោះ ។

ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទនេះ អ្នកត្រូវយកចិត្តទុកដាក់ដើម្បីឆ្លើយអំពីសំណួរកាលអាកាស អត្ថន័យ លក្ខណៈតួអង្គ សង្ខេបអត្ថបទ តម្លៃអប់រំ ។

គ. អត្ថបទ

ថ្ងៃរសៀលម៉ោងជាងបី ពូសនបើកឡានទៅដល់មន្ទីរធ្វើការឃើញស៊ីមកំពុងតែមើលសៀវភៅអង្គុយលើអាស៊ីបកញ្ចាស់គាត់ ។ ពូសនចតឡានស្រួលបួលរួចក៏ដើរសំដៅទៅស៊ីមសួរថា ៖

- ស៊ីមជក់រឿងណាស់ថ្ងៃនេះ មិនឮសូរឡានខ្ញុំទេឬ ? សុខសប្បាយជាទេ ស៊ីមឮសំឡេងក៏ងាកមើល បិទសៀវភៅក៏ឆ្លើយតប៖
- ចុះពូសុខសប្បាយជាទេ ? ទៅណាបាត់ជាងមួយអាទិត្យ ? ខ្ញុំស្មានតែមិនមែនពូបើកឡាននេះបានជាខ្ញុំមិនសូវគិត ។
- លោកពឹងពូឱ្យជូនបងប្អូនលោកទៅលេងកែប ... ។

ម៉េចសប្បាយទេទៅលេងកែប ។ ស៊ីមបានសួរ បានក្តាមត្រីសមុទ្រយកមកផ្ញើខ្ញុំខ្លះទេ ... ។

មិនបានទេស៊ីមអើយ ឯងមិនសូវមានលុយនោះ។ លើកនេះយ៉ាប់ណាស់ឡានខូចញឹកបូមសាំងវាមិនសូវស្រួលសោះ ។ ម្យ៉ាងទៀតប្រើវក់រីតែម្តងហើយ បន្តិចកែប បន្តិចទឹកឈូ។ ខ្ញុំនៅជាប់នឹងឡានគ្មានហ៊ានឱ្យអ្នកណាកាន់ជួសទេ ម្ល៉ោះហើយស៊ីមឯង គ្រាន់តែភ្លេចកន្ទែងមួយជូតខ្លួនក៏ប្រើឯងទៅយកដែរ ... ។

- ក្រែងបានរង្វាន់ខ្លះដែរ ... ស៊ីមបញ្ជាក់ ។
- ឱ្យដែរតែតិចណាស់ ។ គ្រាន់តែផឹកកម្តៅគ្រឿងក្នុងមិនចង់គ្រប់ផង ។

ពូត្រូវចាយលុយផ្ទាល់ខ្លួនអស់ហាសិបរៀលទៀត ។ ម្យ៉ាងទៀត អាទិត្យមុននេះនៅផ្ទះមានធុរៈ។ មីងឯងគេមិនស្រួលចេះតែចុកពោះ ។ ពូទៅកែបលើកនេះទាំងទើសទាល់ទេ កុំតែលោកកុំអីមិនទៅទេ ... ។ ចុះស៊ីមឯងវិញ លោកស៊ីមឯងមានថាអ្វីទៀតទេ ?

- លោកគ្មានថាអ្វីទេ ។ គ្រាន់តែលោកមិនស្និទ្ធស្នាលដូចពេលមុនទៀត ។
- ស៊ីមឯងសូមទោសលោកទៅ ។
- ខ្ញុំជម្រាបច្រើនលើកហើយថា ខ្ញុំមិនសូមទេ ព្រោះខ្ញុំគ្មានខុស ។
- ស៊ីមឯងនៅតែរឹងដដែល ។

- ខ្ញុំការពារសិទ្ធិសេរីភាពរបស់យើងគ្រប់គ្នា ។
- លោកមិនផ្លាស់ស៊ីមឯងទេឬមើលទៅ ។
- ត្រង់ផ្លាស់ខ្ញុំមិនដឹងសោះ ហើយខ្ញុំក៏មិនដែលនិយាយពីរឿងនេះផង ។

តែតាមខ្ញុំសង្កេតឃើញតាំងពីក្រោយថ្ងៃដែលខ្ញុំបើកឡានទៅមុនលោក លោកមិនបានរំលោភលើខ្ញុំទៀតទេ ។ ខ្ញុំឈប់ជូតឡានផ្ដាល់ខ្លួនលោកទៀតហើយ ។ ម្ដងមួយកាលទេ ដែលខ្ញុំជូនកូនលោកឬទទួលកូនលោកពីសាលារៀន ហើយថ្ងៃសម្រាកអាទិត្យ ខ្ញុំបាននៅផ្ទះជាមួយកូនប្រពន្ធខ្ញុំស្រួលជាងមុន ។ ឥឡូវខ្ញុំមានឱកាសថែទាំគ្រួសារខ្ញុំច្រើន ហើយមិនសូវហត់នឿយរវក់រឹដូចមុនទៀតទេ ។ លោកស្រីក៏ប្រែនិយាយមករកខ្ញុំពីងខ្ញុំដោយសម្ដីស្រួល លែងពាក្យធំៗ ដូចមុនទៀតហើយ ។

- ពូខំតែព្រួយជួយភ័យស្មានតែត្រឡប់ពីកែបមកវិញនេះខានឃើញមុខឯងហើយ ។ ឯងត្រឡប់ជាគ្រាន់បើទៅវិញ ។ មនុស្សឥឡូវប្រែច្រើនណាស់ ។ ជាន់ដើមរបៀបស៊ីមឯងនេះ មិនគ្រាន់តែផ្លាស់ ឬដេញចោលទេ ប្រហែលជាត្រូវឃុំខ្លះផងមើលទៅ ។ ពួសរសើរលោកស៊ីមឯងណាស់ដែលមានចិត្តល្អដូចនេះ ។ មិនងាយរកបានទេថៅហ្វាយរបៀបនេះ ... ។
- ចុះពូឯងចង់បានថៅហ្វាយនាយរបៀបនេះទេ ?
- ម៉េចមិនចង់ ។
- បើរបៀបនេះត្រូវខំផ្លាស់របៀបចាស់ចោល គឺត្រូវខំរៀនអានសៀវភៅ អានកាសែតដូចខ្ញុំអីចឹង ។ ហើយតែចង់ដល់យើងចេះដឹងដូចគ្នាទៅ យើងហ៊ានរកខុសត្រូវ ហើយមនុស្សផ្លាប់រំលោភជិះជាន់យើង ក៏ប្រែជាចិត្តល្អវិញ ... ។
- មែន ស៊ីមឯងនិយាយនេះពិតជាចំជាត្រូវ ។ តែមានអ្នកបរឡានតិចណាស់ដែលមានគំនិតដែលមើលឃើញដូចស៊ីមឯង ។ ស៊ីមឯងមានដឹងទេ ពួកអាសៀង ពួកអាយ៉ែម ពួកពីរនាក់នោះវាចង់ញោសជាងពូទៅទៀត ។ វាគិតតែលេងបៀគិតតែផឹក ។ បើវាជួបពូវាគិតតែបបួលពូចូលរៀមចិនដាក់មួយកែវសិន ហើយឯអាហោងវិញពិបាករកលេខដាក់ណាស់ ។ ក្រោមពួកឡានវាមានមួយដបជានិច្ច អានោះគ្មានគិតអ្វីក្រៅពីឱបដបទេ ពេលចាំលោក ។
- គ្មានទាន់ឃល់ ។ ហេតុដូចនេះ យើងត្រូវខំកែប្រែខ្លួនយើងសិន ។ ក្រោយដែលយើងភ្ញាក់រឭកកែប្រែដុសខាត់គំនិតយើងបានហើយ យើងត្រូវជួយអ្នកដទៃទៀត ។ ជាដំបូងនេះ ពួត្រូវខំរៀនមើលសៀវភៅ បើខ្វះខ្ញុំឱ្យខ្ចីខ្លះ ។ កុំទុកពេលចោលទទេ ជាងទំនេរវៀនសូត្រទៅ ។
- ចុះស៊ីមឯងមើលសៀវភៅអីថ្ងៃនេះ ក៏ជក់មិនមើលឡានពូ ... ។

- ខ្ញុំមើល "ទំនៀមទម្លាប់និងច្បាប់ខ្មែរ" ។ ពួត្រូវការមើល ខ្ញុំឱ្យព្រោះខ្ញុំមានយកសៀវភៅប្រវត្តិអាចារ្យ ហែម ចៀវ មកជាមួយដែរថ្ងៃនេះ ។

ថាហើយស៊ីមបានហុចសៀវភៅទៅពួសន ។ ពួសនយកសៀវភៅទៅមើល ។ ស៊ីមដើរឆ្ងាយពីពួសនទៅអង្គុយលើគល់ឈើ ។ ពួសនមើលជក់ស្តុងប្រហែលបានមួយសន្ទឹកលោកលាន់មាត់ថា "បណ្តាំអាចារ្យហែមចៀវចំជាត្រូវ" រួចគាត់និយាយទៅកាន់ស៊ីម "ថ្ងៃក្រោយឱ្យពូខ្ចីសៀវភៅមើលទៀត" ។

(ដកស្រង់ចេញពីរឿងស៊ីមអ្នកបរឡានក្នុងសៀវភៅកម្រងអត្ថបទអក្សរសិល្ប៍ថ្នាក់ទី ៧ ឆ្នាំ ១៩៨២ ទំព័រ ១១៤-១១៧)

សំណួរ

១. តើអត្ថបទនេះដកស្រង់ចេញពីរឿងអ្វី ? និពន្ធនៅឆ្នាំណា ? អ្នកនិពន្ធឈ្មោះអ្វី ?

២. ចូរបង្ហាញកាលអាកាសនៃអត្ថបទខាងលើ ?

៣. រឿងនេះជារឿងប្រភេទណា ? ព្រោះអ្វី ?

៤. ស៊ីមបានឆ្លើយសំណួរពួសនថា : ខ្ញុំមើល "ទំនៀមទម្លាប់និងច្បាប់ខ្មែរ" ។ តាមចម្លើយនេះតើស៊ីមជាពលរដ្ឋបែបណា ?

៥. ចំណងជើងអត្ថបទគឺ "ភ្ញាក់រឭក" ។ តើតួអង្គណាមួយដែលភ្ញាក់រឭក ? ហេតុអ្វី ?

៦. តើអ្នកនិពន្ធបានបញ្ចប់រឿងដោយវិធីណា ?

៧. តើអត្ថបទនេះមានតម្លៃអប់រំដូចម្តេចខ្លះ ?

ល្បះក្រង

អ្នកធ្លាប់បានរៀនល្បះទោលនិងល្បះផ្សំរួចមកហើយ ។ ឥឡូវនេះអ្នកនឹងបានសិក្សាពីប្រភេទល្បះមួយទៀតគឺល្បះក្រង ។ ខាងក្រោមនេះមានល្បះក្រងពីរប្រភេទ ចូរអ្នកសិក្សាល្បះក្រងនីមួយៗឱ្យបានល្អិតល្អន់ ។

- ល្បះក្រងប្រភេទទី ១

ឧទាហរណ៍ :

- គាត់កាន់សីល / តែ / គាត់នៅតែប្រព្រឹត្តអំពើបាប ។
  ល្បះរងទី ១ ឈ្នាប់ចង ល្បះរងទី ២
- ព្រះពុទ្ធតែងទេសនាប្រោសសត្វ / ឬ / ដោះប្រស្នាទេវតា ។
  ល្បះរងទី ១ ឈ្នាប់ចង ល្បះរងទី ២
- កូនល្អគោរពឪពុកម្តាយ / និង / ចិញ្ចឹមឪពុកម្តាយចាស់ជរា ។
  ល្បះរងទី ១ ឈ្នាប់ចង ល្បះរងទី ២

- ល្បះក្រងប្រភេទទី ២

ឧទាហរណ៍ :

- កុសលកើតមកពីអំពើបុណ្យ / អកុសលកើតមកពីអំពើបាប ។
  ល្បះរងទី ១ ល្បះរងទី ២
- ចិត្តកាចនាំទៅកាន់សេចក្តីស្អប់ខ្ពើម / ចិត្តល្អនាំទៅកាន់កល្យាណមិត្ត
  ល្បះរងទី ១ ល្បះរងទី ២
- ចិត្តខន្តីនាំទៅកាន់សន្តិសុខ ។
  ល្បះរងទី ៣

យើងសង្កេតឃើញថា ល្បះក្រងនៅក្នុងប្រភេទទី ១ កើតឡើងពីល្បះរងទាំងពីរភ្ជាប់គ្នាដោយសារឈ្នាប់ចង " តែ និង ឬ" ។ ល្បះរងប្រភេទទី ២ កើតឡើងពីល្បះរងទាំងពីរដាក់បន្តគ្នា ដោយមិនប្រើចំណងឈ្នាប់ឡើយ ។

> *ល្បះក្រង គឺជាល្បះដែលកើតឡើងពីល្បះរងចាប់ពីពីរឡើងទៅនៅបន្តគ្នាហើយឃ្លាទោលទាំងអស់ភ្ជាប់គ្នាដោយសារ "ឈ្នាប់ចង" ឬ "ការដាក់បន្តគ្នា" ។*

លំហាត់

១. ចូរអ្នកអានល្បះខាងក្រោមដោយប្រាប់ថា តើល្បះនីមួយៗកើតឡើងដូចម្តេច ?

- គាត់មើលសិល្បៈ ឬ ដើរកម្សាន្តតាមមាត់ទន្លេ ។
- វាខ្ជិលរៀនសូត្រ តែវាចង់បានការងារធ្វើ ។
- អំពើល្អទទួលបានផលល្អ អំពើអាក្រក់ទទួលបានផលអាក្រក់ ។
- គ្រូពន្យល់មេរៀន សិស្សខ្លះស្តាប់ សិស្សខ្លះជជែកគ្នា សិស្សខ្លះខំកត់ត្រា ។

២. ចូរអ្នកបង្កើតល្បះក្រងពីរដោយប្រើឈ្មាប់ចងនិងល្បះក្រងពីរទៀតដោយប្រើល្បះក្រងជាក់បន្តគ្នា ។

មហាចោរនៅទល់ដែន

ក. សិក្សាពាក្យគន្លឹះ

- សច្ចា (កិ) : ប្រកាសពាក្យសច្ចៈ សំបួងសង្រួង ប្រតិស្ឋ អធិស្ឋាន ។
- សង្វេគ (ន) : សេចក្តីស្លុតចិត្ត ដំណើរតក់ស្លុត ការនឹកខ្លាចអំពើអាក្រក់ ការរំពឹងឃើញសេចក្តីទុក្ខលំបាក ដំណើរអណោចអាធម្ម ។
- កិត្តិយស (ន) : យសស័ក្តិដែលល្បីទូទៅ កេរ្តិ៍ឈ្មោះដ៏រុងរឿង ។
- ប្រឡូក (កិ) : លូកប្រវាយប្រតប់គ្នាច្របូកច្របល់ ច្របូកច្របល់គ្នាមិនដឹងណាជាអ្នកណា ។
- បរិយាកាស (ន) : អាកាសធាតុដែលព័ទ្ធជុំវិញប្រឹថពី ហើយដែលតែងតែប្រែប្រួលជាប្រក្រតី ។
- សាន្តត្រាណ (គុ) : ដែលមានការគ្រប់គ្រង ឬមានពំនាក់ដែលនាំឱ្យកើតសុខស្រួលហើយ ។
- ភ័ន្តប្រែ (កិ) : កើតចលាចលភ្ញាក់ផ្អើលដោយធ្វើសង្គ្រាមនឹងគ្នាឯងដរាបដល់ប្រែកិច្ចរាជការផែនដី ប្រែផែនទី ឬខូចទឹកដីព្រោះភ័ន្តគំនិត ។

ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទនេះ អ្នកត្រូវអានដោយយកចិត្តទុកដាក់ដើម្បីឆ្លើយសំណួរទាក់ទងនឹងបរិយាកាសសង្គមខ្មែរ ប្រភេទអត្ថបទ ការតែងនិពន្ធ ការបង្ហាញតួអង្គ សង្ខេបអត្ថបទ តម្លៃអប់រំ ។

គ. អត្ថបទ

ក្រោយប្រយុទ្ធគ្នាស្លាប់រស់ជាមួយនាយកាមាជាប្អូនរួចមក មានន្តបានចាកចេញពីដើមពោធិ៍កណ្តាលស្រែស្ពោះទៅផ្ទះនាយអគ្គីនៅភូមិរហាត់ទឹកដើម្បីព្យាបាលរបួស និងគេចខ្លួនពីការតាមចាប់របស់ស្តេចត្រាញ់ជាឪពុកឈ្មោះកម្ពុតផង ហើយក៏ថ្ងៃដំបូងដែលគាត់ចាប់ផ្តើមគំនិតតស៊ូដើម្បីបុព្វហេតុជាតិមាតុភូមិដែលកំពុងស្ថិតក្រោមការត្រួតត្រារបស់សៀម ។ ...

មានន្តចាប់បាតដៃនាយគីច្របាច់យ៉ាងខ្លាំង ជាសញ្ញាយល់ព្រមប្តូរជីវិតជាមួយគ្នា ។ បុរសបន្តសេចក្តីទៅទៀត ដូចតទៅ

- ទុក្ខយើងជាទុក្ខខ្មែរទាំងអស់គ្នា ។ ខ្ញុំមានគ្រោះកាចមួយយ៉ាងធំ ។
- គឺអ្វី ?
- គឺលាងទុក្ខខ្មែរ ធ្វើជនជាតិយើងឱ្យរុងរឿងឡើងវិញ
- ធ្វើយ៉ាងណា ?
- តស៊ូ ! ដូចខ្ញុំតែងនិយាយប្រាប់បងមុនៗស្រាប់ហើយ ។
- បាទ ! ខ្ញុំក៏តស៊ូដែរ
- អើ ! ត្រូវតែយើងតស៊ូ វាយខ្លាំង វាយរបបត្រប់គ្រង វាយគំនិតខ្ញុំគេ ភ្ជាប់ស្រុកខ្មែរមកខ្មែរវិញ តាមគន្លងអ្នកស្នេហាជាតិ ។
- យល់ព្រមពេញទី !
- អគ្គីក្រោកឈរលើកដៃសច្ចា ។ មានន្តញញឹម ។
- តែការតស៊ូមិនមែនជាការងាយទេ ។ អ្នកតស៊ូដើម្បីជាតិ គឺជាអ្នកដែលមានចិត្តស្អាតល្អ ចេះស្រឡាញ់គេ អាណិតគេ រួចចង់ជួយគេមែនៗគឺជាអ្នកដែលរម្យទមមិនចេះខឹង មិនខ្លាចការ មានចិត្តអំណត់ក្នុងកិច្ចការ ។ អើបង ! អ្នកតស៊ូ គឺមនុស្សដែលហ៊ានលះបង់ប្រយោជន៍ផ្ទាល់ខ្លួន មានបុណ្យសក្តិ ទ្រព្យសម្បត្តិ ប្រពន្ធកូនជាដើម ។ អ្នកតស៊ូមានតែទុក្ខ ជួបតែសេចក្តីអត់ឃ្លាន គ្មានពេលសប្បាយឬពេលទំនេរទេ រួចមានពេលខ្លះជាប់គុក រងទុក្ខទោសរហូតដល់ស្លាប់បាត់បង់ជីវិតផង ។ ចេញទៅតស៊ូគឺប្រាសព្រាត់អស់ចំណងស្នេហាទាំងឡាយដែលចង

យើង ដើម្បីឈោងចាប់យកភពមួយថ្មី ដែលយើងអាចដាក់ឈ្មោះហៅបានថា "ភពឯកា" ឬ "ភពសង្វេគ" ។ នៅចុងក្រោយបំផុត ចេញទៅតស៊ូ គឺចេញទៅបួស តែបួសនោះមានន័យធ្ងន់ជាងបួសធម្មតាទៅទៀត គឺបួសដើម្បីព្រះពុទ្ធសាសនាផង បួសដើម្បីជាតិផង ដើម្បីសេចក្តីសុខ និងសេចក្តីចម្រើនរបស់មនុស្សទាំងអស់លើទ្វីបលោកផង ។

- ទឹកពុះហើយឬ ?
- នាយអគ្គីស្ទុះត្បែតចូលចង្ក្រាន កាន់យកកំសៀវមួយចេញមក ។ អ្នកលាងចានដែកមួយយ៉ាងស្អាត រួចចាក់ទឹកពុះនោះក្នុងចានដែក ។ អ្នកយកគមកធ្វើសំឡី រួចលុបលាងមុខរបួសយ៉ាងថ្នម ។ រុំរបួសនោះយ៉ាងស្រួល ។ បុរសធ្វើផងនិយាយផងថា :
- គឺជាកិត្តិយសមួយយ៉ាងធំណាស់ ដែលយើងតាំងខ្លួនយើងជាអ្នកតស៊ូនេះ ។ ខ្ញុំសប្បាយចិត្តខ្លាំងណាស់ ដោយយល់ច្បាស់ថា លោកគ្រូ និងខ្ញុំនេះ បានគិតត្រូវ ។ មិនអីទេ យើងតាំងខ្លួនយើងជាអ្នកតស៊ូបានពេញទី ពីព្រោះយើងមិនដែលធ្វើអ្វីអាក្រក់នឹងអ្នកណា យើងមិនដែលប្លន់អ្នកណា យើងមិនដែលសេពសុរា លេងបៀ លួចកូនគេ ។ យើងជាអ្នកបួសស្រេចទៅហើយ ។ ចុះមិត្តយើងឯទៀត ទៅតាមយើងទេ ?
- ទៅ ! ប្រាកដជាទៅជាច់ខាត !
- យើងទៅតាំងទីកន្លែងត្រង់ណា ?
- គង់ដឹងទេ តែឥឡូវនេះត្រូវដឹងថា យើងឈប់ចូលស្រុកហើយ ។
- ជយោ ! លោកគ្រូ ! ហ្ន៎ រួចហើយ ឥឡូវសូមលោកគ្រូសម្រាកចុះខ្ញុំយាមមាត់ទ្វារជូន
- មានន្ទសើចចាប់ដៃនាយគីជាប់នៅស្ងៀមមួយស្របក់ រួចនិយាយថា :
- យាមឯណា ខ្ញុំមិនទាន់បានសួរបងឯងផង ។
- នាយគីធ្វើមុខស្មើ
- ឱ ! បាទ !
- តើកាលពីយើងបែកគ្នានោះ បងឯងមានទុក្ខយ៉ាងណាខ្លះម៉េចមិនប្រាប់ខ្ញុំផង ?
- នាយអគ្គីឡើងស្រងូតស្រងាត់ឆ្លើយថា :
- បាទ ! ខ្ញុំបានប្រឡូកជាមួយខ្មាំងដែលរោមខ្ញុំដូចស្រមោច ។ គេចាប់ខ្ញុំបាន ។ ខ្ញុំនឹកថា អស់បានជួបមុខលោកគ្រូហើយ ។ គេយកខ្ញុំទៅសម្លាប់ ។ ខ្ញុំញញឹមពីមុខក្តីមរណភាពនេះ ។ បាទ ! ខ្ញុំញញឹមព្រោះខ្ញុំពេញចិត្តនឹងស្លាប់ ព្រោះខ្ញុំបានស្លាប់ដោយបានបម្រើបុព្វហេតុមួយដ៏ល្អ គឺមាតុប្រទេស និងជនជាតិយើងពិតៗ ។ គាប់ជួនពេលនោះ នៅវេលាយប់ ចង្រិតយំ

អំពិលអំពែកហើរ ខ្យល់បក់ ផ្កាយរះព្រោងព្រាត ស្រីម្នាក់ជាបុត្រីមេកងមានចិត្តអាណិតខ្ញុំ បានលួចចូលមកដោះលែងខ្ញុំ ។

- បរិយាកាសនៃកិច្ចសន្ទនាក៏ប្រែរីករាយវិញ ។ សំឡេង :
- អូ ! អូ ! អូ !
- បាទ ! នាងនោះល្អ ចិត្តក៏ល្អទៀត គេថាខ្ញុំរត់ទៅចុះ ។ ខ្ញុំឃើញមុខនាងស្រពិលៗ ។ ខ្ញុំក៏ប្រាប់នាងថា :
- "អូន ! កុំមើលងាយបងៗមិនមែនជាមនុស្សចិត្តអន់រត់ពីកណ្តាប់ដៃខ្មាំងទេ ។ អូនជាខ្មាំងនឹងបង ឥឡូវត្រូវការអូនហ៊ានយកកាំបិតមកបុកត្រង់ចុងដង្ហើមបងឱ្យស្លាប់ទៅ មិនគប្បីមកដោះលែងបងដោយលួចលាក់ទេ" ។ នាងឱបដៃខ្ញុំដែលជាប់ចំណងនិយាយខ្សឹបខ្សួលថា : ចាំ ! ប្អូនសូមទោសផង ប្អូនជាមិត្តនឹងបងដែលមកដោះលែងបងនេះ ។ ជាកិត្តិយសមួយរបស់ប្អូន ដោយបានជួយជីវិតអ្នកស្នេហាជាតិម្នាក់ ។ ប្អូនមិនមែនខ្មាំងរបស់បងទេ ប្អូននិយាយនឹងបងមិនបានវែងឆ្ងាយទេ តែប្អូនសូមបងជ្រាបថាសព្វថ្ងៃនេះប្អូនជាមនុស្សរបស់ខ្មាំង ។ ពួកនេះបង្ក ឱ្យស្រុកយើងបង្ហូរឈាមគ្នា កាប់សម្លាប់គ្នា ព្រាត់ប្រាសគ្នា បែកគូស្នេហា បែកប្រពន្ធកូន បែកគ្រួសារ ។ ឱបង ! បង ! ពាក្យថាសង្គ្រាមៗធ្វើឱ្យប្អូនជាស្រីក្រៀមក្រំជានិច្ច ក្រៀមគ្មានពេលល្ហែ ក្រៀមរាល់ពេលវេលា ។ យប់ថ្ងៃ ព្រឹករសៀល ល្ងាច ប្អូនរាប់ពេល រាប់ម៉ោង រាប់នាទី ធ្មេចភ្នែកសួរថា "តើកាលណា ទើបបានសុខ ? ប្អូនចង្អៀតចិត្តណាស់បង " ។ ខ្ញុំឆ្លើយតបថា
- ប្អូនមានចិត្តដូចបង បងដែលខំច្បាំងនេះ ក៏ដើម្បីសេចក្តីសុខសាន្តគ្រាណដែរ ។ ដើម្បីឱ្យបានសុខនេះ លុះត្រាតែស្រុកត្រូវបានជាស្រុកអ្នកជា ។ ស្រុកខ្ញុំគេ ចម្បាំងនៅតែមាន ។ ស្រុកមិនយុត្តិធម៌ សង្គ្រាមនៅតែឆេះ ។ ស្រុកមានគំនិតប្រកាន់ពួកក្រុម ការភ័ន្តប្រែនៅតែកើត ។ បងច្បាំងនេះ ពុំមែនធ្វើឱ្យប្អូនខ្លាច ប្អូនព្រួយ យំបារម្ភនោះទេ...
- ទេ ! ទេ ! ប្អូនដឹងច្បាស់ណាស់ "បងធ្វើត្រូវ ប្អូនស្អប់ចម្បាំងរុករានទេតើ គឺប្អូនស្អប់ខាងក្រុមពួកខ្ញុំសព្វថ្ងៃនេះ" ។
- បងមិនទៅណាទេ ។
- ទេ ! ទេ !សូមបងអាណិតប្អូន អញ្ជើញទៅចុះ ទុកជីវិតបងដើម្បីស្រុម្រើសន្តានចិត្តខ្ពស់មួយដែលជាសន្តានចិត្តខ្មែរាល់គ្នាឱ្យបានសម្រេចទៅចុះ ។
- ប្អូនជាខ្មែរ ឬខ្មាំង ?

- ចាំ៖ ! ប្អូនជាខ្មែរ ។

- បងទៅណាមិនរួចទេ បងចង់ស្លាប់សម្លឹងអូន ចង់ស្លាប់រស់ជាមួយអូន ។

- ទេ ! បងអាណិតខ្មែរទាំងពួងផង តិ្បតខ្មែរទាំងអស់ត្រូវការបង... ទៅៗអញ្ជើញទៅចុះ ។

នារីយំសោកស្ទើរបោកខ្លួននៅលើដី ដោយខ្ញុំពុំព្រមរួចខ្លួនសោះនោះ ។ សូមលោកគ្រូគិតមើលតើឱ្យខ្ញុំទៅណារួច បើទុកស្រីកម្សត់នេះជាកំណប់មាសទៅហើយ ។ ដល់ក្រោយមក ខ្ញុំក៏បបួលនាងទៅជាមួយខ្ញុំ ។ ឱ ! រាត្រីកម្សត់ ។

លោកគ្រូ ! ខ្ញុំសូមសម្រក់ទឹកភ្នែកមួយតំណក់ចុះនៅលើសេចក្តីស្នេហាដ៏ស្មោះត្រង់នេះ ។ បាទ ! នាងព្រមរត់ទៅជាមួយខ្ញុំ ពីព្រោះថ្ងៃជិតរះជីវិតខ្ញុំជិតស្លាប់ហើយ ។

យើងចេញដំណើរទៅ ។ មិនយូរប៉ុន្មាន កងទ័ពខ្មាំងដេញតាមជាប់ពីក្រោយ ។ ឱលោកគ្រូអើយ ! នាងនោះរត់មិនរួច ព្រោះនាងពុំធ្លាប់រត់ពេលនោះសោះ ។ ខ្មាំងក៏កាន់តែជិតមក ជិតមក ។ ខ្ញុំដកព្រួញបាញ់តវិញ ដោយប្តេជ្ញាថា ឱ្យស្លាប់ជាមួយគ្នាចុះ ។ តស៊ូបានប្រមាណមួយសន្ទុះធំ ខ្មាំងព័ទ្ធយើងជុំវិញខ្លួនអស់ ។ បាទ ! ពេលនោះព្រួញអាសិរពិសមួយយ៉ាងកំណាចស្ទុះមកត្រូវនាងចំកណ្តាលខ្នង ប្អូនជាគូជីវិតដួលដេកលើធរណី ។

(ដកស្រង់ និងកែសម្រួលពីរឿង មហាចោរទល់ដែនរបស់លោក សាងសាវាត ទំព័រ ១២១-១២៥)

សំណួរ

១. តើអត្ថបទនេះដកស្រង់ចេញពីរឿងណា ? និពន្ធនៅឆ្នាំណា ? ស្ថិតក្នុងបរិយាកាសសង្គមដូចម្តេច ?

២. តើតួអង្គណាដែលត្រូវនឹងចំណងជើងអត្ថបទ ? តួអង្គនោះជាមនុស្សដូចម្តេច ? ចូររកភស្តុតាងបញ្ជាក់ ។

៣. ហេតុអ្វីបានជានាយអគ្គីពេញចិត្តនឹងស្លាប់នៅចំពោះមុខសត្រូវ ?

៤. តាមរយៈសម្តីនាយអគ្គីថា កូនក្រមុំមេកងខាងខ្មាំងមកដោះលែងគាត់ ។ តើខ្មាំងនោះជាពួកអ្នកណា ។ តើនាងធ្វើបែបនេះត្រឹមត្រូវដែរឬទេ ? ព្រោះអ្វី ?

៥. រឿងនេះជារឿងប្រភេទណា ? ព្រោះអ្វី ?

៦. ក្នុងនាមជាពលរដ្ឋម្នាក់ ប្រសិនបើជួបអំពើរំលោភឈ្លានពានពីសំណាក់សត្រូវមកលើសង្គម តើអ្នកមានគំនិតដោះស្រាយបែបណា ?

ភារកិច្ចរបស់ពលរដ្ឋចំពោះមាតុភូមិ



ក. សិក្សាពាក្យគន្លឹះ

- កាលៈទេសៈ (ន) : កាលសម័យរបស់ស្រុកទេស កាលនិងប្រទេស។ សម័យបច្ចុប្បន្នគេច្រើនប្រើសំដៅន័យថា "ហេតុការណ៍ចម្លែក ប្រវត្តិហេតុ ព្រឹត្តិការណ៍ផ្សេងៗ ការវិបរិតប្រែប្រួល"។
- មាតុភូមិ (ន) : ប្រទេសកំណើត ស្រុកកំណើត។
- ជំនាញ (គុ) : ដែលជាញ ដែលវាសវៃ ប៉ិនប្រសប់ ស្ទាត់ ដែលចេះស្ទាត់ប្រាកដ។
- ពលរដ្ឋ (ន) : ពលរបស់រដ្ឋ ពលអាស្រ័យនៅក្នុងរដ្ឋ ប្រជាជនទាំងប្រុសស្រីដែលទុកជាកម្លាំងរបស់ប្រទេស។
- យុគសម័យ (ន) : អាយុ អាយុពិភពលោក កាលគ្រាដំណើរកំណត់កាលរបស់ពិភពលោក។
- បរមបុរាណ (គុ) : ដែលល្អប្រពៃកើតមានយូរមកហើយ ដែលឧដុង្គឧត្តមធ្លាប់មានពីព្រេងនាយ។
- ឆន្ទៈ (ន) : សេចក្តីប្រាថ្នា បំណង គំនិត ការយល់ព្រម។
- និស្សិត (ន) : អ្នកដែលនៅក្នុងនិស្ស័យគេ អ្នករៀននៅក្នុងការគ្រប់គ្រងនៃគ្រូ។
- បណ្ឌិត (ន) : ជនអ្នកប្រព្រឹត្តល្អ គឺអ្នកកាន់សុចរិត១០ប្រការឬដោយពិស្តារ កាន់សុចរិត ៤០ប្រការដោយខ្ជាប់ខ្ជួនហ្មត់ចត់ជានិច្ច អ្នកប្រាជ្ញខាងផ្លូវសុចរិតយុត្តិធម៌។

- កវី (ន) : អ្នកប្រាជ្ញដែលចេះតែងឆន្ទ កាព្យឃ្លោង ។
- សមត្ថភាព (ន) : ភាពនៃសេចក្តីអាចហ៊ាន សេចក្តីមោះមុត ។ល ។
- ប្រពៃណី (ន) : ទំនៀម ពូជពង្ស តំណវង្សត្រកូល ។
- អនក្ខរជន (ន) : អ្នកមិនចេះអក្សរ ។
- ទេសនា (ន) : ដំណើរសម្តែង ការសម្តែងធម៌ ។
- ចងអាឃាត (ន) : ការកួចភ្ជាប់គ្នានូវគំនុំគុំកួន ការចងចិត្តគុំបម្រុងនឹងធ្វើព្យាបាទ ។
- កេរមរតក (ន) : ដំណែលដែលបន្សល់ទុកពីបុគ្គលដែលស្លាប់ហើយ ជាសម្បាច់របស់ដូនតា ឬមាតាបិតាដែលបានស្លាប់ទៅហើយ ។
- រដ្ឋធម្មនុញ្ញ (ន) : ច្បាប់បញ្ញត្តិសម្រាប់ប្រទេសនីមួយៗច្បាប់ទុកជាគោលចារឹកក្នុងការគ្រប់គ្រងរដ្ឋនីមួយៗដែលសភាបានបញ្ញត្តតែងតាំងឡើង ។
- អាជីវករ (ន) : ជនអ្នកប្រកបរបរអាជីវកម្ម ។
- ពាណិជ្ជកម្ម (ន) : អ្នកជំនួញ ។
- សិប្បករ (ន) : អ្នកធ្វើជាងផ្សេងៗ ។
- សុចរិត (ន) : ការប្រព្រឹត្តល្អ ។
- តុល្យភាព (ន) : ភាពស្មើគ្នា ស្របគ្នា ដូចគ្នា ។
- គ្រូបាធ្យាយ (ន) : គ្រូបង្រៀនធម៌ បង្រៀនច្បាប់ ។
- ជនានុជន (ន) : ជនធំតូច គឺបណ្តាជនទាំងធំទាំងតូច ។

២. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទនេះ អ្នកត្រូវអានដោយយកចិត្តទុកដាក់ដើម្បីឆ្លើយសំណួរទាក់ទងនឹងប្រភេទអត្ថបទ ប្រធានបទ ទស្សនៈអ្នកនិពន្ធ សង្ខេបអត្ថបទ តម្លៃអប់រំ ។

ក. អត្ថបទ

នៅគ្រប់កាលៈទេសៈ ពលរដ្ឋត្រូវរួមសាមគ្គីធ្វើការតបស្នងមាតុភូមិដែលយើងរស់នៅ ។ ការងារដែលធ្វើ គឺតម្រូវតាមមុខជំនាញនីមួយៗ ។

សិស្ស និស្សិត បញ្ញវន្ត កវី អ្នកនិពន្ធ បណ្ឌិត សិល្បករ ត្រូវប្រើសមត្ថភាពដែលខ្លួនមាន ផ្សព្វផ្សាយដល់ជនរួមឈាមនូវភាពថ្កុំថ្កើងនៃទឹកដីតាំងពីយុគសម័យបរមបុរាណ បង្ហាញពីធម្មជាតិ ដីធ្លី ពីប្រពៃណីស្អាតផូរផង់របស់ខ្មែរយើង ដើម្បីឱ្យអ្នកទាំងនោះមានទឹកចិត្តស្រឡាញ់ទឹកដីខ្លួន ។ ទន្ទឹមនឹងនោះ ត្រូវរួសរាន់ផ្ទេរចំណេះដឹងទៅឱ្យអនក្ខរជន តាមរយៈចលនាអក្ខរកម្ម និងបំពេញវិជ្ជា ។

ព្រះសង្ឃ ព្រះអង្គត្រូវទេសនាអប់រំប្រមុំចិត្តពុទ្ធសាសនិក ឱ្យវៀរចាកអំពើអកុសល ឱ្យទៅជាមនុស្សមានចិត្តជ្រះថ្លា មេត្តា សន្តោស ប្រណី ស្គាល់គុណទោស ឱ្យបោះបង់ចោលគំនិតចងអាឃាត ព្យាបាទតែជាតិសាសន៍ឯង។ រួមជាមួយនេះដែរ ព្រះសង្ឃជាប្រទីបបំភ្លឺផ្លូវដល់ជនានុជន ឱ្យជ្រះថ្លារួមគ្នា កសាងស្ពានថ្នល់ សាលារៀន ការពារវត្ថុបុរាណ ដើម្បីទុកជាកេរមតិកដល់មនុស្សជំនាន់ក្រោយ។ ធ្វើបែបនេះបាន ទើបសមនឹងច្បាប់រដ្ឋធម្មនុញ្ញ ចែងថា "ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ"។

ចំណែកខាងអាជីវករ ពាណិជ្ជករ សិប្បករ គោងធ្វើជំនួញដោយសុចរិត មិនត្រូវគិតតែយកចំណេញហួសប្រមាណ ។ អ្នកមិនត្រូវផលិតទំនិញខ្វះអនាម័យ ខ្វះគុណភាព និងមិនត្រូវគេចវេះពីការបង់ពន្ធជូនរដ្ឋឡើយ។

កសិករគោងតែជាអ្នកលៃលក តែខៃយ៉ាងណាធ្វើស្រែចម្ការឱ្យបានទិន្នផលខ្ពស់ឡើង ដោយប្រើវិធីកែប្រែគុណភាពដីតាមក្បួនកសិកម្មទំនើប ដូចជាការដាក់ជីឱ្យសមស្រប ការជ្រើសរើសពូជឱ្យល្អប្រពៃ។ បើអ្នកបំពេញភារកិច្ចនេះបាន អ្នកនឹងមានឈ្មោះថា ចូលរួមស្តារប្រទេសឱ្យផុតពីភាពអន់ថយហើយ។

ដោយឡែកកម្មករតាមរោងចក្រ សហគ្រាស អ្នកត្រូវយកឱ្យអស់លទ្ធភាព ប្រជែងយកឈ្នះផលិតផលនាំចូល ដើម្បីធ្វើឱ្យមានតុល្យភាពនៅលើទីផ្សារ សម្រួលដល់បម្រើបម្រាស់របស់អតិថិជន។

ក្មួយកុមារា កុមារី អ្នកត្រូវនាំគ្នាទៅសាលារៀន ស្តាប់ការទូន្មានរបស់គ្រូបាធ្យាយ រៀនឱ្យពូកែ ដើម្បីសមជា "ទំពាំងស្នងឫស្សី"។

រួមមក ពលរដ្ឋទាំងអស់គឺសុទ្ធតែមានភារកិច្ចបម្រើមាតុភូមិបានគ្រប់ៗគ្នា។ ប៉ុន្តែ ដើម្បីឱ្យសម្រេចផលល្អ អ្នកត្រូវមានឆន្ទៈមុតស្រួច មានស្មារតីប្តូរផ្តាច់ ប្រកាន់យកយុត្តិធម៌ជាមូលដ្ឋាន។ វាសនាប្រទេសជាតិពឹងផ្អែកលើពលរដ្ឋគ្រប់រូប។

(ដកស្រង់និងកែសម្រួលពីសៀវភៅ "អក្សរសិល្ប៍" ថ្នាក់ទី ៧ ក្រសួងអប់រំ ឆ្នាំ ១៩៨៣)

សំណួរ

១. តើអត្ថបទនេះជាប្រភេទអត្ថបទបែបណា ?

២. តើអត្ថបទនេះមានអត្ថន័យយ៉ាងដូចម្តេច ? ចូរពន្យល់ ។

៣. តើការស្គាល់ភារកិច្ចរបស់ខ្លួនចំពោះមាតុភូមិជាឧត្តមភាពមួយដ៏ប្រសើរឬទេ ? ព្រោះអ្វី ?

៤. ចូររកគំនិតឬទស្សនៈរបស់អ្នកនិពន្ធ។

៥. ចូរអ្នករកល្បះ ជាទម្រង់ល្បះក្រងឱ្យបាន ២ ដែលប្រើឈ្មាប់ចងនិងល្បះបន្តក្នុងអត្ថបទខាងលើ។

៦. ចំពោះអ្នកវិញ តើអ្នកមានបំណងធ្វើអ្វីខ្លះដើម្បីឱ្យមានប្រយោជន៍ដល់ប្រទេសជាតិ ?

១ លោកប៉ាស្ទ័រ

ពេលអ្នកស្តាប់អត្ថបទណាមួយ អ្នកត្រូវចេះកត់ត្រាសេចក្តីលម្អិតសំខាន់ៗនៅក្នុងអត្ថបទនោះ។ ចូរអ្នកស្តាប់អត្ថបទនិយាយពីលោកប៉ាស្ទ័រ ហើយត្រៀមឆ្លើយសំណួរខាងក្រោម ៖

១. តើលោកប៉ាស្ទ័រជាជនជាតិអ្វី ? មានតួនាទីជាអ្វី ?

២. តើលោកប៉ាស្ទ័រធ្លាប់សួរខ្លួនឯងថាដូចម្តេចខ្លះដើម្បីមនុស្សជាតិ ?

៣. ចូរបង្ហាញថាលោកប៉ាស្ទ័រជាអ្នកប្រាជ្ញ។

៤. តើលទ្ធផលគ្រប់យ៉ាងដែលលោកប៉ាស្ទ័ររកឃើញបានដោយសារអ្វី ?

៥. ដើម្បីឱ្យមានប្រយោជន៍ចំពោះខ្លួនឯងនិងចំពោះប្រទេសជាតិ តើអ្នកត្រូវធ្វើអ្វីខ្លះ ?

ការសម្ភាសតួសម្តែងក្នុងរឿងមហាចោរនៅទល់ដែន

យើងធ្លាប់បានសិក្សារួចមកហើយអំពីការសម្ភាសជាមួយបុគ្គលសំខាន់ឬមនុស្សក្នុងសហគមន៍នៅក្នុងមេរៀនមុនៗ។ ឥឡូវនេះ យើងនឹងសិក្សាបន្តទៀតអំពីការសម្ភាសតួអង្គនៅក្នុងរឿងប្រលោមលោកទំនើប។ យើងកំណត់យកភាពយន្តរឿង មហាចោរនៅទល់ដែន ដោយជ្រើសរើសយកអ្នកសម្តែងជាតួអង្គមានន្តមកធ្វើការសម្ភាស។ កញ្ញា សុខរី ជាអ្នកសម្ភាស , ធានីជាតួអង្គមានន្ត។

សុខរី : ជម្រាបសួរលោកធានី! តើលោកសុខសប្បាយឬទេ ?

ធានី : បាទ! ជម្រាបសួរអ្នកនាង! ខ្ញុំសុខសប្បាយទេ។ សូមអរគុណ!

សុខរី : លោកប្រហែលជាមមាញឹកណាស់ហើយក្នុងការងារសម្តែងនេះ។

ធានី : បាទ! មែនហើយគឺមានការនឿយហត់ខ្លះៗដែរ តែខ្ញុំនៅតែមានឆន្ទៈព្យាយាមជានិច្ច។

សុខរី : សូមទោស! ថ្មីៗនេះខ្ញុំឮថា លោកបានចូលរួមសម្តែងភាពយន្តរឿងមហាចោរនៅទល់ដែន។ តើលោកបានសម្តែងជាតួអង្គណាដែរ!

ធានី : បាទ! ខ្ញុំបានសម្តែងជាតួអង្គមានន្ត គឺជាតួអង្គឯកតែម្តង។

សុខរី : អូ! ជាតួអង្គឯកផង! តើលោកអាចជម្រាបបងប្អូនយើងអំពីសកម្មភាពទាក់ទងនឹងការសម្តែងនោះបានឬទេ ?

ធានី : អូ! បាទ! ពិតជាបានមិនមានបញ្ហាអ្វីទេ បើសំណួរនោះមិនហួសពីសមត្ថភាពខ្ញុំ។

សុខរី : ចាៈអរគុណ! តើការសម្តែងជាតួអង្គមានន្តមានដំណើររឿងបែបណាខ្លះ ?

ធានី : រឿងមហាចោរនៅទល់ដែនជារឿងបែបប្រវត្តិសាស្ត្រមួយដែលទាក់ទងទៅនឹងសម័យដែលសៀមត្រួតត្រាប៉ែកខាងលិចនៃប្រទេសយើង។ មានន្តជាកូនប្រុសរបស់ស្តេចកម្ពុតដែលគ្រប់គ្រងខេត្តសិរីសោភ័ណ ហើយបានចេញទៅតស៊ូដើម្បីទាមទារទឹកដីនិងសេរីភាពប្រឆាំងនឹងការឈ្លានពានរបស់សៀមដែលក្នុងនោះខ្លះពុកខ្លួនក៏ជាអាយ៉ងសៀម។ មានន្តត្រូវបានគេដាក់ឈ្មោះថា មហាចោរនៅទល់ដែន ដែលជាអ្នកមានទោសព្រោះ ប្លន់ជាតិ នគរ។ ដៃជើងព្រះចៅសៀមបានតាមចាប់នាយមានន្ត និងបក្សពួកដើម្បីបំបាក់ស្មារតីកម្លាំងអ្នកតស៊ូ។ មានន្តពុំញញើតឡើយ ព្រោះគាត់ជាពលរដ្ឋម្នាក់មានឧត្តមគតិជាតិនិយម ហើយតស៊ូទាមទារសេរីភាពរហូតបានជោគជ័យ។

សុខរី : អរគុណលោកធានី ដែលបានលើកឡើងត្រួសៗអំពីដំណើរសកម្មភាពតួអង្គ មានន្តក្នុងរឿងមហាចោរនៅទល់ដែន ។ អឺ! សូមទោសលោក ក្នុងសកម្មភាព ដែលលោកសម្តែង តើមានសកម្មភាពណាមួយដែលលោកពេញចិត្តជាងគេ ?

ធានី : គ្រប់សកម្មភាពរបស់ខ្ញុំសុទ្ធតែត្រូវនឹងចំណូលចិត្តរបស់ខ្ញុំទាំងអស់ ក្នុងនោះសកម្ម ភាពដែលខ្ញុំពេញចិត្តជាងគេនៅត្រង់ តួអង្គមានចិត្តរឹងប៉ឹង មិនចាញ់ល្បិចលួង លោមរបស់នាងកែវរមណីជាបុត្រីចៅហ្វាយខេត្តសុរិន្ទ និងជាបងប្អូនជីដូនមួយ របស់គាត់ ទោះបីជានាងនោះស្អាតយ៉ាងណាក៏ដោយ។ ស្មារតីជាតិនិយមបានជិត ជាប់ក្នុងដួងចិត្តរបស់ពលរដ្ឋខ្មែរម្នាក់ ដែលគិតប្រយោជន៍ជាតិ មាតុភូមិ ជាង សុខទុក្ខរបស់ខ្លួន និងគ្រួសារ។ ក្រៅពីសកម្មភាពនេះ ខ្ញុំក៏ពេញចិត្តចំពោះការដឹង កំហុសរបស់លោកមានន្តដែលគាត់ខឹងនាងទៅដោយគ្មានការពិចារណា ព្រោះ តែចោទប្រកាន់នាងទៅនារីជាទីស្រឡាញ់ថាក្បត់ខ្លួនមានសហាយជាមួយកាមា ដែលជាបងប្អូនរបស់គាត់។ ខ្ញុំក៏មិនសូវសប្បាយចិត្តចំពោះសកម្មភាពមានន្តដែល សម្លាប់ខ្លួនក្រោយពេលអានសំបុត្រនាងទៅចប់។ តាមការយល់ឃើញផ្ទាល់របស់ ខ្ញុំដំណោះស្រាយបែបនេះ ហាក់ដូចជាដាក់ទណ្ឌកម្មទៅវិញ។

សុខរី : សូមទោស! តើអារម្មណ៍របស់លោកផ្ទាល់ចំពោះតួអង្គមានន្តយ៉ាងដូចម្តេចដែរ ?

ធានី : បាទ! ខ្ញុំពេញចិត្តនឹងសម្តែងជាតួអង្គមានន្ត ព្រោះជាតួអង្គដែលតំណាងឱ្យឧត្តម គតិស្នេហាជាតិខ្មែរនៅសម័យនោះ។ សកម្មភាពតួអង្គបានជំរុញទឹកចិត្ត កាយ វាចារបស់ខ្ញុំឱ្យមានឆន្ទៈមុតមាំ ទើបពេលសម្តែងពុំសូវមានការខុសឆ្គងឡើយ។

សុខរី : ក្នុងនាមមិត្តអ្នកស្តាប់ និងក្នុងនាមនាងខ្ញុំផ្ទាល់សូមអរគុណលោកធានីជាថ្មីម្តង ទៀត ដែលបានផ្តល់ព័ត៌មានពីរយ៉ាង គឺបានស្តាប់សាច់រឿងសង្ខេប និងបានដឹង ពីចរិតលក្ខណៈរបស់លោកធានីជាអ្នកសម្តែង ដែលមានគំនិតស្រឡាញ់ជាតិ ដែលបង្ហាញឡើងតាមរយៈការផ្តល់បទសម្ភាសខាងលើ។ សូមលោកធានីទទួល បានជោគជ័យក្នុងការងាររបស់លោកគ្រប់ពេលវេលា។

ធានី : បាទ! អរគុណក្រៃលែងចំពោះអ្នកនាងដែលបានលើកទឹកចិត្ត ខ្ញុំដែលជា សិល្បករ។ ខ្ញុំសូមប្រសិទ្ធពរជូនអ្នកនាងសូមទទួលបានជោគជ័យ សូមមាន សុខភាពល្អ។ ទន្ទឹមនេះ ខ្ញុំសូមអំពាវនាវចំពោះប្រជាពលរដ្ឋខ្មែរទាំងអស់មក ចូលរួមលើកកម្ពស់តម្លៃវប្បធម៌ជាតិនិងសិល្បៈខ្មែរឱ្យបានខ្ពង់ខ្ពស់នៅក្នុងតំបន់និង នៅលើឆាកអន្តរជាតិ។

សំណួរ

១. តើអ្នកដែលត្រូវគេសម្ភាសតំណាងឱ្យតួអង្គណា ?

២. តើសុខរីបានប្រើពាក្យសម្តីបែបណាខ្លះទាក់ទងនឹងការធ្វើសម្ភាសតួអង្គ ? ចូរលើកឃ្លានោះមកបញ្ជាក់ ។

៣. តើល្បះ ឬឃ្លាត្រង់ណាដែលបង្ហាញថា អ្នកត្រូវគេសម្ភាសជាមនុស្សមានការទទួលខុសត្រូវខ្ពស់ ?

៤. តើអ្នកយល់យ៉ាងណាចំពោះទស្សនៈរបស់អ្នកត្រូវគេសម្ភាសដែលបានបង្ហាញនៅកថាខណ្ឌចុងក្រោយ ?

លំហាត់

ចូរអ្នករៀបចំជាដៃគូដើម្បីសម្ភាសតួអង្គណាមួយ តាមគំរូខាងលើក្នុងរឿងផ្កាស្រពោន រឿងស៊ីមអ្នកបរឡាន រឿងកុលាបប៉ៃលិន និងរឿងធនញ្ជ័យ ។

សំបុត្របែបប្រឌិត

រឿងមហាចោរនៅទល់ដែន បាននិយាយអំពីស្នេហាមួយរវាងតួអង្គមានន្ទនិងនាងទេវី។ ខាងក្រោមនេះជាសេចក្តីសង្ខេបនៃដំណើររឿងគូស្នេហាទាំងពីរ :

មានន្ទបានរៀបការ(ពិធីសែនព្រេន)ជាមួយនឹងនាងទេវីយ៉ាងតក់ក្រហល់ ហើយមានមេឃុំជំទប់បានជឿងឮទៀតផង។ គ្រានោះ លោកវិសេសក្លាហានបានឱ្យពរកូនទាំងពីរក្នុងពិធីនោះចប់សព្វគ្រប់ លោកក៏ទទួលអនិច្ចកម្មតែម្តង។ ទន្ទឹមគ្នានេះដែរ ព្រះកម្តុតដែលជាចៅហ្វាយខេត្តសិរីសោភណ ហើយត្រូវជាឪពុកមានន្ទ បានចាត់ឱ្យគេយកលិខិតមួយក្នុងឋានៈជាមេទ័ពប្រចាំអាណាខេត្តមកកោះហៅមានន្ទឱ្យទៅជួបជាបន្ទាន់ បើរឹងទទឹងមានទោសអាជ្ញាសឹក។ មានន្ទបានចាកចេញពីទេវីកម្សត់ដែលនាងមានផ្ទៃពោះពីរខែហើយដោយគ្រាន់តែបានឮពាក្យមួយឃ្លាថា "បងមកកុំខានណា!"។ មានន្ទត្រូវគេបញ្ជូនឱ្យទៅសមរភូមិ ហើយក៏ផ្តាំកាមាដែលជាប្អូនប្រុសបង្កើតឱ្យជួយមើលថែរក្សានាងទេវីផង។ កាមាមានចិត្តស្រឡាញ់នាងទេវីដូចគ្នានឹងមានន្ទដែរ តែនាងមិនព្រមទទួលការស្រឡាញ់នេះទេ ព្រោះនាងមានមានន្ទជាប្តីហើយថែមទាំងមានកូនស្រីមួយទៀតផង។ មានន្ទបានត្រឡប់ពីសមរភូមិបានមករកនាងទេវីដល់ផ្ទះ តែនាងទេវីមិនបាននិយាយពីសេចក្តីនឹករឭកដែលកប់ក្នុងទ្រូងរាប់ខែមកប្រាប់ប្តីបានឡើយ ព្រោះកាមាបានគំរាមថានឹងសម្លាប់កូនស្រីនាងចោល។ មិនតែប៉ុណ្ណោះ កាមាបង្ខំឱ្យនាងអង្គុយថ្វាយបង្គំឆ្ពោះទៅមាត់ទ្វារហាក់ដូចជាកំពុងអង្វរមានន្ទឱ្យលើកលែងទោសឱ្យនាងផង ព្រោះនាងបានស្រឡាញ់កាមាហើយ ដែលការណ៍នេះស្របគ្នានឹងសម្តីកាមាដែលបានពោលបំផ្លើសថាខ្លួនគេជាសហាយរបស់នាងទៀត។ ចាប់ពីពេលនោះមកមានន្ទ ឈប់មករកនាងទេវីរហូត។

ពីរឆ្នាំក្រោយមកមានន្ទបានទទួលលិខិតនាងទេវីមួយច្បាប់ តាមរយៈលោកតាគីរីសុមេរុ។ លិខិតនោះមានសេចក្តីដូចតទៅ

ក្នុងព្រៃ ថ្ងៃទី១៥កើត ខែបុស្ស ត.ស. ១៨៦៧

លំទោនគោរពចំពោះបងមានន្ទជាទីគោរព

ក្នុងពេលដែលបងកំពុងមើលសំបុត្ររបស់ប្អូននេះ ព្រលឹងប្អូនកំពុងស្ថិតនៅក្នុងពពកនាឋានទេវលោក។

ក្នុងឋានថ្មីនេះ ប្អូនបានសុខសប្បាយក្រៃណានឹងរកអ៊ីមកផ្ទឹមពុំបានឡើយ។

ចោលកន្ទុយភ្នែកមកមើលឋានមនុស្សវិញ ប្អូនសើចព្រោះឃើញបងហែលឆ្លងវដ្តសង្សារដ៏លំបាកដូចប្អូនបានហែលឆ្លងរួចមកហើយ។

ថ្ងៃមួយ ដល់បងដល់ត្រើយសុខដូចប្អូន បងនឹងឈរមើលអ្នកជាន់ក្រោយ ប្រវេប្រវាហែលឆ្លងដូចយើងទៀតពុំខានរួចបងមុខជាសើចដូចខ្ញុំសើចនឹងបងក្នុងពេលនេះ ។

ឱ ! ប្អូនថាបងកំពុងហែលឆ្លងសមុទ្រទុក្ខដូចប្អូនបានហែលឆ្លងនោះខុសទេ ព្រោះថាទុក្ខប្អូនខុសពីទុក្ខបងស្រឡះ ។

ទុក្ខប្អូន គឺទុក្ខស្នេហាលើរូបបង ។

ក្នុងមួយជាតិនេះ ប្អូនបានទទួលស្នេហាពីបងវិញ តែត្រឹមថ្ងៃបងបែកពីប្អូនទៅច្បាំងប៉ុណ្ណោះទេ ។ និកឃើញទេ បងទៅច្បាំង ប្អូនចាំៗៗចាំបាត់ៗ ។ ប្អូនបីកូនចាំមើលផ្លូវបង ។ ទឹកភ្នែកហូរៗជាផ្លុកជាអូរ ជាទន្លេ ជាសមុទ្រ ។ សម្រេចថាបងមិនឃើញត្រឡប់មកសោះ ។

ថ្ងៃបងមកដល់ ប្អូនស្មានថា ប្អូនផុតទុក្ខដែលធ្លាប់រួមរឹតប្អូនហើយ តែឥតដូច្នោះទេ ។ បងមិនយល់ប្អូន បងខឹងនឹងប្អូន ដោយគេចោទប្អូននោះ ជ្រុលពេកហួសនិស្ស័យប្អូន ។

ប្អូនមិនបន្ទោសបងទេ មិនចេះពិចារណាឱ្យវែងឆ្ងាយនោះទេ ពីព្រោះឥឡូវនេះប្អូនយល់ច្បាស់ថា ធម្មតាមនុស្សតែងភាន់ច្រឡំជានិច្ច ។

ដល់ពេលក្រោយ ប្អូនពកូនតាមបងដើម្បីទៅពន្យល់ និយាយនឹងបងថា បើរឿងពិតដែលប្អូនស្រឡាញ់បងនោះ ពុំគាប់ចិត្តបងទេ ពេលនោះប្អូនប្តេជ្ញាចិត្តថា ប្អូនសូមផ្តាច់ជីវិត ។ តែរកបងមិនឃើញសោះ ។

ទុក្ខប្អូនក៏ចេះតែមានរាល់ថ្ងៃ រាល់ខែ រាល់ឆ្នាំទៀត ។

ថ្ងៃមួយ មនុស្សម្នាក់បានជួយប្អូននិងបទុមកូនយើងឱ្យរួចពីកណ្តាប់ដៃកាមា ។ មនុស្សដ៏សប្បុរសនេះ បាននាំប្អូនទៅរកបងឯឃុំថ្មីស្រុកភ្នៀត ដោយបានជួយលាក់បំពួនឥតឱ្យអ្នកណាដឹងឡើយ ។

ពេញមួយឆ្នាំគត់ ប្អូនលបមើលឃើញតែគេងទៀត ឯរូបបងមិនដែលឃើញ ។ ប្អូនក៏ចាប់ឈឺៗៗ ឱ ! ឈឺត្រាតែ... ដូចបងជ្រាប ។

នេះហើយពណ៌សមុទ្រដែលប្អូនហែល !

ចុះពណ៌សមុទ្រដែលបងកំពុងហែលវិញនោះយ៉ាងណា ?

ដំបូងបងហែលម្នាក់ឯង គ្មានគូ ! ចំណាប់មែន ! ជាពិសេសជីវិតបងជាជីវិតតស៊ូ តស៊ូនឹងធម្មជាតិ តស៊ូនឹងខ្មាំង តស៊ូនឹងកិច្ចការ ។ ប្រសើរពេកណាស់ជីវិតបងខុសពីជីវិតអ្នកឯទៀត ។ ទុក្ខរបស់បងគឺទុក្ខរបស់រាស្ត្រខ្មែរ ។ ក្តីវេទនារបស់បង គឺក្តីវេទនារបស់សង្គមខ្មែរ បងមានការធ្វើច្រើន ។ គឺកិច្ចការនេះហើយ ដែលបំភ្លេចបងមិនឱ្យនឹកនាដល់ប្អូនដែលស្រឡាញ់បង ហើយមិនឱ្យនឹកនាដល់ស្ត្រីឯទៀត ។

ដូចនេះ បងជ្រាបរឿងយើងហើយ ! ប្អូនសូមលាហើយណាបងសម្លាញ់ ។

នៅចុងក្រោយបំផុត ប្អូនសូមឱ្យបងមានជ័យជម្នះក្នុងដំណើរការរបស់បង ដើម្បីជាតិខ្មែរ ដើម្បីប្រទេសជាតិ ដើម្បីប្រទេសខ្មែរ និងដើម្បីប្រជាជនខ្មែរ ។

ដោយសេចក្តីរាប់អានដ៏ខ្ពង់ខ្ពស់ !

ទេវី

(ដកស្រង់ពីរឿងមហាចោរនៅទល់ដែន ទំព័រ ៣០០-៣០២)

សំណួរ

១. តាមរយៈខ្លឹមសារសំបុត្រនេះ តើនាងទេវីជាតួអង្គបែបណា ?

២. តើនាងទេវីមានទុក្ខដោយសារអ្វី ? ទុក្ខរបស់មានន្តគឺអ្វី ? ចូរពន្យល់ ?

៣. ចូរបង្ហាញអារម្មណ៍តួអង្គមានន្តពេលអាន និងក្រោយពេលអានលិខិតនេះ ។

៤. ចូរបង្ហាញពីទម្រង់សំបុត្រខាងលើនេះ (ក្បាលសំបុត្រ តួសំបុត្រ បញ្ចប់សំបុត្រ) ។

លំហាត់

ចូរអ្នកសរសេរសំបុត្រមួយច្បាប់ដោយជ្រើសរើសស្ថានភាពខាងក្រោមសម្រាប់ជាមូលដ្ឋានក្នុងការសរសេរសំបុត្រ ។ មានន័យថា អ្នកត្រូវដាក់ខ្លួនអ្នកនៅក្នុងស្ថានភាពណាមួយខាងក្រោម ដើម្បីសរសេរសំបុត្រនេះទៅអ្នកជាទីស្រឡាញ់របស់អ្នក ៖

- អ្នកជាយុទ្ធជនការពារទឹកដីនៃព្រះរាជាណាចក្រកម្ពុជា
- អ្នកជាក្រុមគ្រួសាររបស់យុទ្ធជនដែលកំពុងបំពេញការងារការពារទឹកដី
- អ្នកជាមន្ត្រីរាជការទៅបំពេញបេសកកម្មក្រៅប្រទេស
- អ្នកកំពុងបន្តការសិក្សានៅឯទីក្រុងភ្នំពេញឃ្លាតឆ្ងាយពីក្រុមគ្រួសារ មិត្តភក្តិ ។

នៅពេលអ្នកសរសេរសំបុត្រនេះអ្នកគប្បីអនុវត្តទៅតាមលំនាំសំបុត្រគំរូនិងទម្រង់សំបុត្រដែលអ្នករកឃើញខាងលើ ។

យើងបម្រើសេវាកម្ម :

- អភិវឌ្ឍសៀវភៅនិងសម្ភារឧបទេស
- បោះពុម្ព
- ចែកផ្សាយដល់សាលារៀន

WE SERVE :

- Book and teaching-aid development
- Printing
- Distribution to schools



មានលក់សៀវភៅសិក្សាគោលសម្រាប់សិស្សនិង
សម្រាប់គ្រូ សៀវភៅហ្វឹកហាត់ សៀវភៅអំណានបន្ថែម
សម្ភារឧបទេស ព្រមទាំងសម្ភារការិយាល័យគ្រប់មុខ !

Selling textbooks, teacher´s manuals,
workbooks, supplementary readers,
teaching-aids and stationary !

IBC INTERNATIONAL BOOK CENTER
$ 3.00

9 789995 001360